# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

## សារត្ថប្បកាសិនី

## ភាគ ៣៣

## ខន្ធវារវគ្គ បញ្ចមភាគ

ពុទ្ធសករាជ ២៥៥៦

## អធិប្បាយ

## ខន្ធសំយុត្ត

# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

# សារត្ថប្បកាសិនី

## ភាគ ៣៣

## ខន្ធវារវគ្គ បញ្ចមភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

## ខន្ធសំយុត្ត

រួមមាន ២បណ្ណាសកៈ អដ្ឋកថាកែ៨៦សូត្រ

# ខន្ធសំយុត្ត

## មូលបណ្ណាសកៈ មាន ៥ វគ្គ

| | | | |
|---|---|---|---|
| ១-នកុលបិតុវគ្គ | មាន | ១០ | អដ្ឋកថា |
| ២-អនិច្ចវគ្គ | មាន | ០១ | អដ្ឋកថា |
| ៣-ភារវគ្គ | មាន | ១០ | អដ្ឋកថា |
| ៤-នតុម្ហាកវគ្គ | មាន | ០៧ | អដ្ឋកថា |
| ៥-អត្តទិបវគ្គ | មាន | ១០ | អដ្ឋកថា |

## មជ្ឈិមបណ្ណាសកៈ មាន ៥ វគ្គ

| | | | |
|---|---|---|---|
| ១-ឧបាយវគ្គ | មាន | ១០ | អដ្ឋកថា |
| ២-អរហន្តវគ្គ | មាន | ១០ | អដ្ឋកថា |
| ៣-ខជ្ជនិយវគ្គ | មាន | ០៨ | អដ្ឋកថា |
| ៤-ថេរវគ្គ | មាន | ១០ | អដ្ឋកថា |
| ៥-បុប្ផវគ្គ | មាន | ១០ | អដ្ឋកថា |

រួមក្នុងខន្ធសំយុត្តនេះ មាន ១០ វគ្គ ព្រះអដ្ឋកថាបានកែសេចក្តី

ដែលលំបាកចំនួន ៨៦ សូត្រ

# ស្រៈនិងសៀ៉យ

## Signes et accents:



# ស្រះពេញតួ
# Voyelles:

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូប<br>Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម<br>Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ<br>Laotien | ອ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| សិង្ហល<br>Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា<br>Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រ៉ូម<br>Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម<br>Siamois | ก | ข | ค | ฆ | ง |
| លាវ<br>Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា<br>Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា<br>Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សិង្ហ<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សង្ក Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຍ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຊ | ຍ |
| សិង្ហល Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សង្ក Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី*

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

> ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាមឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិតមិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែលបណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

**៣ អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

**៤ អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាម អាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយ ច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានធនូៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមក ហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះ ខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយ ខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បី ខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




*ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។*

*( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )*

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រេពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទយ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវ័ក)

ជាដើម បានរបនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរបនាទុក ជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថា ទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុឋៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ ដើម្បីបានឱកាសរបនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករបនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្ដាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សន្តាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន | ឧបាសក នាក់ ម៉ៅ

ឧបាសក ទុំ ទួន | ឧបាសក ហុក សឹងហួត

ឧបាសក ជឹម ជំនិត | ឧបាសក កើត ទិត្យ

ឧបាសក សន ម៉ារឌី | ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម វ៉ៃយ៉ា | ឧបាសក សុក្រ ហ៊ត

ឧបាសក សោម រតនៈ | ឧបាសក សំ ឆាយ

ឧបាសក ម៉ៅ ផុន | ឧបាសក ជា ស៊ីបាន

ឧបាសិកា ថាប់ លឿម | ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា ប៊ុត សុម៉ាលី | ឧបាសិកា យស សម្បត្តិ

ឧបាសិកា ពូ ហ៊ាង | ឧបាសិកា ប៊ុត សេដាដួង

ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

## ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គទិន្នោ នូវ បូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុធម្មបញ្ញោ ឆ្នុំ សារឿន ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

សាមណេរ កោវិទោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

## ផ្នែកឧបាសក

ឧបាសក ក្អាត ហ៊ិន ឧបាសក ហាយ ចំរើន

ឧបាសក ហុក សឹងហួត ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក ឈួន សំណាង ឧបាសក ឃឿម សារ៉េន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

*ឈ្មោះធម៌* *ទំព័រ*

## មូលបណ្ណាសកៈ

### នកុលបិតុវគ្គ


| | | |
|---|---|---|
| អដ្ឋកថា នកុលបិតុសូត្រ | ទី ១ | ១ |
| អដ្ឋកថា ទេវទហសូត្រ | ទី ២ | ១៨ |
| អដ្ឋកថា ហាលិទ្ទិកាសូត្រ | ទី ៣ | ២៤ |
| អដ្ឋកថា ទុតិយហាលិទ្ទិកា | ទី ៤ | ៣០ |
| អដ្ឋកថា សមាធិសូត្រ | ទី ៥ | ៣១ |
| អដ្ឋកថា បដិសល្លានសូត្រ | ទី ៦ | ៣៣ |
| អដ្ឋកថា ឧបាទាន.....សូត្រ | ទី ៧ | ៣៤ |
| អដ្ឋកថា ឧបាទាន.....សូត្រ | ទី ៨ | ៣៦ |
| អដ្ឋកថា អតីតា.....សូត្រ | ទី ៩ | ៣៧ |
| អដ្ឋកថា អតីតា.....សូត្រ | ទី ១០-១១ | ៣៨ |


### អនិច្ចវគ្គ


| | | |
|---|---|---|
| អដ្ឋកថា អានន្ទសូត្រ | ទី ១០ | ៤០ |


### ភារវគ្គ


| | | |
|---|---|---|
| អដ្ឋកថា ភារសូត្រ | ទី ១ | ៤១ |
| អដ្ឋកថា បរិញ្ញាសូត្រ | ទី ២ | ៤៤ |
| អដ្ឋកថា បរិជានសូត្រ | ទី ៣ | ៤៥ |

| | | |
|---|---|---|
| អដ្ឋកថា ឆន្ទរាគសូត្រ | ទី ៨–៩ | ៤៦ |
| អដ្ឋកថា អឃមូលសូត្រ | ទី ១០ | ៤៧ |
| អដ្ឋកថា បភង្គុសូត្រ | ទី ១១ | ៤៨ |

## នតុម្ហាកវគ្គ

| | | |
|---|---|---|
| អដ្ឋកថា នតុម្ហាកសូត្រ | ទី ១ | ៤៩ |
| អដ្ឋកថា ទុតិយនតុម្ហាក | ទី ២ | ៥០ |
| អដ្ឋកថា អញ្ញត្រភិក្ខុសូត្រ | ទី ៣ | ៥១ |
| អដ្ឋកថា ទុតិយអញ្ញត្រភិក្ខុ | ទី ៤ | ៥២ |
| អដ្ឋកថា បឋមអានន្ទសូត្រ | ទី ៥ | ៥៣ |
| អដ្ឋកថា ទុតិយអានន្ទសូត្រ | ទី ៦ | ៥៦ |
| អដ្ឋកថា អនុធម្មសូត្រ | ទី ៧ | ៥៧ |

## អត្តទីបវគ្គ

| | | |
|---|---|---|
| អដ្ឋកថា អត្តទីបសូត្រ | ទី ១ | ៥៩ |
| អដ្ឋកថា បដិបទាសូត្រ | ទី ២ | ៦១ |
| អដ្ឋកថា អនិច្ចសូត្រ | ទី ៣ | ៦២ |
| អដ្ឋកថា ទុតិយអនិច្ចសូត្រ | ទី ៤ | ៦៣ |
| អដ្ឋកថា សមនុបស្សនាសូត្រ | ទី ៥ | ៦៤ |
| អដ្ឋកថា បញ្ចក្ខន្ធសូត្រ | ទី ៦ | ៦៧ |
| អដ្ឋកថា សោភណាសូត្រ | ទី ៧–៨ | ៦៩ |
| អដ្ឋកថា ឆន្ទិខយសូត្រ | ទី ៩–១០ | ៧០ |


## មជ្ឈិមបណ្ណាសកៈ

## ឧបាយវគ្គ


អដ្ឋកថា ឧបាយសូត្រ ទី ១ ៧២
អដ្ឋកថា ពីជសូត្រ ទី ២ ៧៤
អដ្ឋកថា ឧទានសូត្រ ទី ៣ ៧៦
អដ្ឋកថា ឧបាទានបរិវដ្តសូត្រ ទី ៤ ៨៤
អដ្ឋកថា សត្តដ្ឋានសូត្រ ទី ៥ ៨៦
អដ្ឋកថា សម្មាសម្ពុទ្ធសូត្រ ទី ៦ ៨៩

-22-

អដ្ឋកថា អនត្តលក្ខណសូត្រ ទី ៧ ៩១
អដ្ឋកថា មហាលិសូត្រ ទី ៨ ៩៣
អដ្ឋកថា អាទិត្តសូត្រ ទី ៩ ៩៤
អដ្ឋកថា និរុត្តិបថសូត្រ ទី ១០ ៩៥


## អរហន្តវគ្គ


អដ្ឋកថា ឧបាទិយសូត្រ ទី ១ ៩៩
អដ្ឋកថា មញ្ញមានសូត្រ ទី ២ ១០០
អដ្ឋកថា អភិនន្ទមានោសូត្រ ទី ៣ ១០១
អដ្ឋកថា អនិច្ចសូត្រ ទី ៤ ១០២
អដ្ឋកថា អនត្តនិយសូត្រ ទី ៧ ១០៣
អដ្ឋកថា រជនិយ....សូត្រ ទី ៨ ១០៤
អដ្ឋកថា រាធ-សុរាធសូត្រ ទី ៩-១០ ១០៥


## ខជ្ជនិយវគ្គ


អដ្ឋកថា អស្សាទ.....សូត្រ ទី ១-៣ ១០៦

| | | | |
|---|---|---|---|
| អដ្ឋកថា | បឋមអរហន្តសូត្រ | ទី ៤ | ១០៧ |
| អដ្ឋកថា | ទុតិយអរហន្តសូត្រ | ទី ៥ | ១១៣ |
| អដ្ឋកថា | សីហសូត្រ | ទី ៦ | ១១៤ |
| អដ្ឋកថា | ខជ្ជនិយសូត្រ | ទី ៧ | ១៣១ |
| អដ្ឋកថា | បិណ្ឌោលយសូត្រ | ទី ៨ | ១៥៥ |
| អដ្ឋកថា | ចាលិលេយ្យសូត្រ | ទី ៩ | ១៧១ |
| អដ្ឋកថា | បុណ្ណាមសូត្រ | ទី ១០ | ១៨០ |

## ឃាតិវគ្គ

| | | | |
|---|---|---|---|
| អដ្ឋកថា | អានន្ទសូត្រ | ទី ១ | ១៨៤ |
| អដ្ឋកថា | តិស្សសូត្រ | ទី ២ | ១៨៦ |
| អដ្ឋកថា | យមកសូត្រ | ទី ៣ | ១៨៩ |
| អដ្ឋកថា | អនុរាធសូត្រ | ទី ៤ | ១៩៧ |
| អដ្ឋកថា | វក្កលិសូត្រ | ទី ៥ | ២០០ |
| អដ្ឋកថា | អស្សជិសូត្រ | ទី ៦ | ២០៥ |
| អដ្ឋកថា | ខេមកសូត្រ | ទី ៧ | ២០៨ |
| អដ្ឋកថា | ឆន្នសូត្រ | ទី ៨ | ២១៣ |

## បុប្ផវគ្គ

| | | | |
|---|---|---|---|
| អដ្ឋកថា | នទីសូត្រ | ទី ១ | ២១៨ |
| អដ្ឋកថា | បុប្ផសូត្រ | ទី ២ | ២២០ |
| អដ្ឋកថា | ផេណបិណ្ឌសូត្រ | ទី ៣ | ២២២ |
| អដ្ឋកថា | គោមយបិណ្ឌសូត្រ | ទី ៤ | ២៣២ |
| អដ្ឋកថា | នខសិខាសូត្រ | ទី ៥ | ២៣៨ |

| | | | |
|---|---|---|---|
| អដ្ឋកថា | សាមុទ្ទកសូត្រ | ទី ៦ | ២៣៩ |
| អដ្ឋកថា | កទ្ទលសូត្រ | ទី ៧ | ២៤០ |
| អដ្ឋកថា | ទុតិយកទ្ទលសូត្រ | ទី ៨ | ២៤២ |
| អដ្ឋកថា | ឆាវាសូត្រ | ទី ៩ | ២៤៦ |
| អដ្ឋកថា | សញ្ញាសូត្រ | ទី ១០ | ២៥៥ |

# សារត្ថប្បកាសិនី

## អដ្ឋកថា ខន្ធវារវគ្គ

## ខន្ធសំយុត្ត មូលបណ្ណាសកៈ

## លេខ ៣៣

## នកុលវគ្គទី ១

### អ ដ្ឋ ក ថា

### នកុលបិតុសូត្រទី ១

*នកុលបិតុវគ្គសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[១] *បទថា **ភគ្គេសុ** បានដល់ ក្នុងជនបទមានឈ្មោះយ៉ាងនេះ ។ បទថា **សុង្សុមារគិរេ** បានដល់ ក្នុងនគរឈ្មោះសុង្សុមារគិរៈ បានឮមកថា ពេលសាងនគរនោះ ក្រពើស្រែក ដូច្នោះ មនុស្សទាំងឡាយទើបតាំងឈ្មោះនគរនោះថា សុង្សុមារគិរៈ ។ បទថា **ភេសកឡាវនេ** សេចក្តីថា ក្នុង*

ព្រៃដែលបានឈ្មោះយ៉ាងនេះ ព្រោះយក្ខិណីឈ្មោះភេសកឡាអាស្រ័យនៅព្រៃនោះឯង ហៅថា **មិគទាយៈ** ព្រោះជាទីឲ្យអភ័យដល់ពួកម្រឹគ ព្រះមានព្រះ-ព្រះភាគទ្រង់អាស្រ័យនគរនោះ ក្នុងជនបទនោះ ប្រថាប់នៅក្នុងព្រៃនោះ ។ បទថា **នកុលបិតា** បានដល់ ជាបិតារបស់ទារកឈ្មោះ នកុលៈ ។

បទថា **ជិណ្ណោ** បានដល់ ជាអ្នកគ្រាំគ្រាព្រោះជរា ។ បទថា **វុឌ្ឍោ** បានដល់ ជាអ្នកមានចម្រើនវ័យ ។ បទថា **មហល្លកោ** បានដល់ ជាមនុស្សចាស់រាប់តាំងពីកើត ។ បទថា **អទ្ធគតោ** បានដល់ កន្លងកាល ៣ ។ បទថា **វយោអនុប្បត្តោ** បានដល់ កន្លងកាលទាំង ៣ នោះ ចូលដល់បច្ឆិមវ័យតាមលំដាប់ ។ បទថា **អាតុរកាយោ** បានដល់ មានកាយឈឺចាប់ ។ សេចក្តីពិតសរីរៈនេះ សូម្បីមានវណ្ណៈដូចមាស ក៏ឈ្មោះថា រសាប់រសល់ទុំះឯង ព្រោះអត្ថថា ហូរចេញជានិច្ច ប៉ុន្តែពោលដោយពិសេស សរីរៈនោះ រមែងមានការរសាប់រសល់ ៣ យ៉ាង គឺ រសាប់រសល់ព្រោះជរា ១ រសាប់រសល់ព្រោះព្យាធិ ១ រសាប់រសល់ព្រោះមរណៈ ១ ។ ក្នុង ៣ យ៉ាងនោះ ព្រោះភាពជាមនុស្សចាស់ ទើបឈ្មោះថា រសាប់រសល់ព្រោះជរានោះក៏ពិត សូម្បីដូច្នោះក្នុងទីនេះ លោកក៏បំណងយកសរីរៈនោះ រសាប់រសល់ ព្រោះព្យាធិ ព្រោះមានរោគរឿយៗ ។ បទថា **អភិក្ខណាតង្កោ** បានដល់ មានរោគរឿយ ៗ គឺ

មានរោគជានិច្ច ។ បទថា **អនិច្ចទស្សាវី** សេចក្ដីថា ខ្ញុំព្រះអង្គមិនអាចមក ក្នុងខណៈដែលប្រាថ្នា បានគាល់ពេលខ្លះប៉ុណ្ណោះ មិនបានគាល់រហូតអស់ កាល ។ បទថា **មនោភាវនីយានំ** បានដល់ អ្នកឲ្យចម្រើនចិត្ត ក៏កាលខ្ញុំ ព្រះអង្គឃើញភិក្ខុពួកណា ចិត្តរមែងចម្រើនដោយអំណាចកុសល ភិក្ខុទាំង នោះ បានដល់ ព្រះមហាថេរៈ មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម ឈ្មោះថា ជាអ្នកឲ្យចម្រើនចិត្ត ។ បទថា **អនុសាសតុ** បានដល់ សូមមេត្តា ទូន្មានរឿយៗ ។ ពិតហើយ ពាក្យទូន្មានគ្រាដំបូង ឈ្មោះថា ឱវាទ , ពាក្យ ទូន្មាន.តៗ ទៅ ឈ្មោះថា អនុសាសនី ។ មយ៉ាងទៀត ទូន្មានក្នុងរឿងដែល មានហើយ ឈ្មោះថា ឱវាទ , ទូន្មានតាមបែបផែន គឺ តាមប្រពៃណីទុំះឯង ក្នុងរឿងដែលមិនទាន់មាន ឈ្មោះថា **អនុសាសនី** ។ មយ៉ាងទៀត ពាក្យថា ឱវាទក្ដី , ពាក្យថា អនុសាសនីក្ដី ដោយអត្ថជាតែមយ៉ាងដូចគ្នា ផ្សេងគ្នាត្រឹម តែព្យញ្ជនៈប៉ុណ្ណោះឯង ។

បទថា **អាតុរោ ហាយំ** កាត់បទជា **អាតុរោ ហិ អយំ** ។ សេចក្ដីថា កាយនេះ មានពណ៌ដូចមាស សូម្បីស្មើដោយឈើប្រយង្គ ក៏ឈ្មោះថា រសាប់ រសល់ ព្រោះអត្ថថា ហូរចេញជានិច្ច ។ បទថា **អណ្ឌភូតោ** សេចក្ដីថា ដូច ជាពងមាន់ ប្រើការមិនបាន ពងមាន់ក្ដី ពងក្ងោកក្ដី ដែលមនុស្សយកមកធ្វើ

ជាកូនវ្ង ចាប់បោះ ឬគ្រវែង មិនអាចនឹងលេងបាន រមែងបែកក្នុងខណៈនោះ នោះឯង យ៉ាងណា កាយសូម្បីនេះក៏ដូច្នោះ កាលមានបុគ្គលជាន់ជាយសំពត់ក្តី ជំពប់ជង្គត់ក្តី ក៏ដួលចុះ រមែងបែកដូចជាពងមាន់ ដូច្នោះ លោកទើបពោលថា **អណ្ឌភូតោ** ។ បទថា **បរិយោនទ្ធោ** បានដល់ ត្រឹមតែសម្បុរស្បែកដែលគ្របដណ្តប់ទុក ព្រោះពងមាន់គង់មានសំបកពាសព័ទ្ធទុក ដូច្នោះ សូម្បីរបោម មូសជាដើម ចូលទៅចោះខាំសម្បកពងមាន់នោះ ក៏មិនអាចឲ្យពងនោះហូរទឹកចេញមកបាន តែកាយនេះ ចោះ ឬខាំបានតាមប្រាថ្នា ត្រង់កាយនេះដែលគ្របដណ្តប់ដោយស្បែកដ៏ស្តើងយ៉ាងនេះ ។ បទថា **កិមញ្ញត្រ ពាល្យា** សេចក្តីថា មិនមានអ្វីក្រៅអំពីសេចក្តីល្ងង់ខ្លៅ នឹងប្រយោជន៍អ្វី កាយនេះដែលមានសភាពទន់ជ្រាយពិតៗ ។ បទថា **តស្មា** បានដល់ ព្រោះកាយនេះជាយ៉ាងនេះ ។

[២] បទថា **តេនុបសង្កមិ** សេចក្តីថា គហបតីឈ្មោះនកុលបិតាចូលទៅគាល់ព្រះមានព្រះភាគទ្រង់ជាសទ្ធម្មចក្រពត្តិ តមក បំណងនឹងធ្វើសេចក្តីគោរពព្រះធម្មសេនាបតី ទើបចូលទៅរកព្រះសារីបុត្រដល់ទីនៅ ដូចរាជបុរសចូលគាល់ស្តេចចក្រពត្តិ តមកទើបចូលទៅរកបរិនាយកកែវ (អគ្គមហាសេ-នាបតី) ។ បទថា **វិប្បសន្នានិ** បានដល់ ថ្លាផូរផង់ ។ បទថា **ឥន្ទ្រិយានិ** បាន

ដល់ ឥន្ទ្រិយ មានចិត្តជាទី ៦ ។ បទថា **បរិសុទ្ធោ** បានដល់ ប្រាសចាកទោស ។ ពាក្យថា **បរិយោទាតោ** ជាវេវចនៈរបស់ពាក្យថា **បរិសុទ្ធោ** នុ៎ះឯង ។ ពិតណាស់ ព្រះសារីបុត្រនេះ លោកហៅថា **បរិយោទាតោ** ព្រោះលោកប្រាសចាកឧបក្កិលេសនុ៎ះឯង មិនមែនព្រោះជាមនុស្សស ។ គហបតីពេលឃើញភាពផូរផង់របស់ព្រះសារីបុត្រប៉ុណ្ណោះ ក៏ដឹងថា លោកមានឥន្ទ្រិយថ្លាផូរផង់ ។ បានឮថា នេះជាបញ្ញាប៉ាន់ស្មានរបស់ព្រះថេរៈ ។

បទថា **កិញ្ហិ នោ សិយា** សេចក្តីថា ព្រោះហេតុអ្វីទើបលោកមិនបានបញ្ញានោះ អធិប្បាយថា បានហើយនោះឯង ។ ដោយបទនេះ លោកសម្តែងអ្វី ។ សម្តែងថា ជាអ្នកស្និតស្នាលជាមួយព្រះសាស្តា ។

បានឮថា គហបតីនេះ ចាប់ផ្តើមតាំងពីបានឃើញព្រះសាស្តា ក៏មានសេចក្តីស្រឡាញ់ដូចថា ខ្លួនជាបិតា ចំណែកឧបាសិការបស់លោកក៏មានសេចក្តីស្រឡាញ់ដូចខ្លួនជាមាតា ។ លោកទាំងពីរហៅព្រះមានព្រះភាគដែលសាស្តាថា បុត្ររបស់យើង ។ ពិតហើយ សេចក្តីស្រឡាញ់របស់លោកទាំងពីរនោះ មានមកហើយក្នុងកពដទៃៗ ។ បានឮថា ឧបាសិកានោះ បានជាមាតា ចំណែកគហបតីនោះ បានជាបិតារបស់ព្រះតថាគត ៥០០ ជាតិ ។ ឧបាសិកាជាយាយ និងជាម្តាយធំ-មីង ឧបាសកជាតា និងជាពូ រហូតដល់អស់ ៥០០ ជាតិទៀត ។

រួមសេចក្ដីថា ព្រះសាស្ដាទ្រង់ចម្រើនជំពាត់ក្នុងដៃរបស់លោកទាំងពីរនោះឯង អស់ ១.៥០០ អត្តភាព ។ ដោយហេតុនោះឯង លោកទាំងពីរនោះ ទើបអង្គុយនិយាយក្នុងសម្នាក់របស់ព្រះសាស្ដា ប្រើពាក្យដែលនរណាៗ មិនអាចនឹងពោលក្នុងទីជិតបុត្រ និងធីតាបាន ។ ដោយហេតុនេះឯង ព្រះមានព្រះភាគ ទើបទ្រង់តាំងលោកទាំងពីរនោះទុកក្នុងតំណែងឯតទគ្គៈដោយព្រះតម្រាស់ថា ភិក្ខុទាំងឡាយ បណ្ដាឧបាសកដែលស្និទ្ធស្នាលរបស់តថាគត នកុលបិតាគហបតីចាត់ជាកំពូលដ៏លើស បណ្ដាឧបាសិកា សាវិកាដែលស្និទ្ធស្នាលរបស់តថាគត នកុលមាតា គហបតានីជាកំពូលដ៏លើស ដូច្នោះ ព្រះអង្គកាលទ្រង់ប្រកាសភាពជាអ្នកស្និទ្ធស្នាលនេះ ទើបត្រាស់ ពាក្យមានជាដើមថា **កិញ្ចិ នោ សិយា** ដូច្នេះ ។

បទថា **អមតេន អភិសិត្តោ** សេចក្ដីថា ឈានក្ដី វិបស្សនាក្ដី មគ្គក្ដី ផលក្ដី អ្វីដទៃក្នុងទីនេះ មិនគប្បីឃើញថាជា **អមតាភិសេក** (គឺ ការស្រោចស្រប់ដោយទឹកអម្រឹត) តែព្រះធម៌ទេសនាដ៏ពីរោះប៉ុណ្ណោះ គប្បីជ្រាបថា **អមតាភិសេក** ។

[៣] បទថា **ទូរតោបិ** បានដល់ ខាងក្រៅដែនខ្លះ ខាងក្រៅជនបទខ្លះ ។

[៤] ពាក្យថា **អសុត្វា បុថុជ្ជនោ** នេះ មានអត្ថដូចពោលមកហើយ

នុ៎ះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អរិយានំ អទស្សាវី** ជាដើម ដូចតទៅនេះ ៖ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកទាំងឡាយពោលថា អរិយៈ ព្រោះឆ្ងាយអំពីកិលេស ព្រោះមិនប្រព្រឹត្តទៅក្នុងសេចក្ដីវិនាស ព្រោះប្រព្រឹត្តទៅក្នុងសេចក្ដីចម្រើន ព្រោះលោកព្រមទាំងទេវលោក គប្បីប្រព្រឹត្តទៅតាមម្យ៉ាងទៀត ព្រះពុទ្ធទាំងឡាយនោះឯង ជាព្រះអរិយៈក្នុងលោកនេះ ដូចដែលលោកពោលទុកថា ព្រះតថាគត លោកហៅថា អរិយៈក្នុងលោក ព្រមទាំងទេវលោក ។ល។ ដូច្នេះ ក៏គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សប្បុរិសានំ** ដូចតទៅនេះ ៖ ព្រះបច្ចេកពុទ្ធ និងព្រះសាវករបស់តថាគត គប្បីជ្រាបថាជាសប្បុរស ពិតណាស់ លោកទាំងនោះ លោកពោលថាសប្បុរស ព្រោះជាបុគ្គលស្អាត ព្រោះប្រកបដោយគុណដែលជាលោកុត្តរៈ មួយទៀត លោកទាំងអស់នោះ លោកពោលទុកដោយចំណែកទាំង ២ យ៉ាង ពិតណាស់ សូម្បីព្រះពុទ្ធទាំងឡាយជាព្រះអរិយៈផង ជាសប្បុរសផង សូម្បីព្រះបច្ចេកពុទ្ធ និងព្រះសម្មាសម្ពុទ្ធក៏ហៅយ៉ាងនោះដូចគ្នា ដូចព្រះមានព្រះភាគត្រាស់ថា

បុគ្គលណា ដែលជាកតញ្ញូកតវេទី ជាអ្នកប្រាជ្ញ
ជាកល្យាណមិត្ត និងជាអ្នកមានភក្ដីភាពមុតមាំ
ធ្វើកិច្ចរបស់អ្នកបានទទួលដោយគោរព បណ្ឌិត

ទាំងឡាយហៅបុគ្គលនោះថា ជាសប្បុរស ។

បទថា កល្យាណមិត្តោ ទឡ្ហភត្តិ ច ហោតិ សេចក្តីថា ក៏ពុទ្ធសាវក លោកពោលទុកដោយបទត្រឹមតែប៉ុណ្ណេះ ព្រះបច្ចេកពុទ្ធទាំងឡាយ លោកពោលអំពីគុណមានកតញ្ញុតាជាដើម ។

នរណា មានប្រក្រតីមិនឃើញព្រះអរិយៈទាំងនោះក្នុងពេលនេះ និងមិនធ្វើសេចក្តីល្អក្នុងការឃើញ អ្នកនោះគប្បីជ្រាបថា ជាអ្នកមិនឃើញព្រះ-អរិយៈ និងអ្នកដែលមិនឃើញព្រះអរិយៈនោះ មាន ២ ជំពូក គឺ អ្នកមិនឃើញដោយចក្ខុមួយពួក អ្នកមិនឃើញដោយញាណមួយពួក ក្នុង ២ ពួកនោះ អ្នកមិនឃើញដោយញាណ លោកបំណងយកក្នុងទីនេះ ។ សូម្បីអ្នកដែលឃើញព្រះអរិយៈដោយមំសចក្ខុ ឬដោយទិព្វចក្ខុ ក៏ឈ្មោះថា ជាការមិនឃើញនុ៎ះឯង ព្រោះកាន់យកត្រឹមតែពណ៌ (រូប) នៃចក្ខុនោះ មិនមែនកាន់យកដោយអារម្មណ៍នៃអរិយប្បញ្ញា ។ សូម្បីសត្វតិរច្ឆាន មានឆ្កែស្រុក និងឆ្កែព្រៃជាដើម រមែងឃើញព្រះអរិយៈដោយចក្ខុ និងសត្វទាំងនោះ នឹងឈ្មោះថា មិនឃើញព្រះអរិយៈនោះក៏ទេ

ក្នុងសេចក្តីនោះ មានរឿងនេះជាឧទាហរណ៍

បានឮមកថា ឧបដ្ឋាករបស់ព្រះថេរៈដែលជាខីណាស្រព អាស្រ័យនៅ

ក្នុងចិត្តលតាបពិត ជាអ្នកបួសចាស់ ថ្ងៃមួយលោកត្រាច់បិណ្ឌបាតជាមួយព្រះថេរៈ កាន់បាត្រ និងចីវររបស់ព្រះថេរៈដើរទៅខាងក្រោយ សួរព្រះថេរៈថា លោកម្ចាស់ ដែលឈ្មោះថា ព្រះអរិយៈទាំងឡាយដូចម្តេច ។ ព្រះថេរៈឆ្លើយថា បុគ្គលខ្លះក្នុងលោកនេះជាមនុស្សចាស់ កាន់បាត្រ និងចីវររបស់ព្រះអរិយៈទាំងឡាយ ធ្វើវត្តបដិបត្តិ សូម្បីត្រាច់ទៅជាមួយគ្នា ក៏មិនស្គាល់ព្រះអរិយៈ អ្នកមានអាយុ ព្រះអរិយៈទាំងឡាយដឹងបានលំបាកយ៉ាងនេះ ។ សូម្បីកាលលោកពោលយ៉ាងនោះ លោកក៏មិនដឹង ។ ព្រោះដូច្នោះ ការឃើញដោយចក្ខុ និងការឃើញដោយញាណ (បញ្ញា) ក៏ឈ្មោះថា ឃើញ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលវក្កលិ ប្រយោជន៍អ្វីដោយកាយស្អុយដែលអ្នកឃើញហើយនេះ ។ អ្នកណាឃើញធម៌ អ្នកនោះឈ្មោះថា ឃើញតថាគត ។ អ្នកណាឃើញតថាគត អ្នកនោះឈ្មោះថា ឃើញធម៌ ។ ព្រោះដូច្នោះ សូម្បីអ្នកដែលឃើញដោយចក្ខុ មិនឃើញអនិច្ចលក្ខណៈជាដើម ដែលព្រះអរិយៈទាំងឡាយឃើញដោយញាណ និងមិនសម្រេចធម៌ ដែលព្រះអរិយៈសម្រេចហើយ គប្បីជ្រាបថា មិនឃើញព្រះអរិយៈ ព្រោះមិនឃើញធម៌ដែលធ្វើនូវភាពជាព្រះអរិយៈ និងមិនឃើញព្រះអរិយៈ ។

បទថា **អរិយធម្មស្ស អកោវិទោ** បានដល់ អ្នកមិនឈ្លាសក្នុងអរិយ-

ធម៌ផ្សេងៗ មានសតិប្បដ្ឋានជាដើម ។ ក៏ក្នុងពាក្យថា **អរិយធម្មេ អវិនីតោ** មានវិនិច្ឆ័យដូចតទៅនេះ ៖

*ដែលឈ្មោះថា វិន័យ មាន ២ យ៉ាង ក្នុង ២ យ៉ាងនេះ*
*តែមួយយ៉ាងចែកជា ៥ យ៉ាង លោកហៅបុថុជ្ជននេះថា*
*មិនបានទទួលការណែនាំ ព្រោះមិនមានវិន័យនោះ ។*

ក៏វិន័យនេះមាន ២ យ៉ាង គឺ សំវរៈវិន័យ ១ បហានវិន័យ ១ និងក្នុងវិន័យ ២ យ៉ាងនេះ វិន័យតែមួយយ៉ាងចែកចេញជា ៥ យ៉ាង ។

សូម្បីសំវរៈវិន័យក៏មាន ៥ យ៉ាង គឺ សីលសំវរៈ សតិសំវរៈ ញាណ-សំវរៈ ខន្តិសំវរៈ វិរិយសំវរៈ ។

សូម្បីបហានវិន័យ ក៏មាន ៥ យ៉ាង គឺ តទង្គប្បហាន វិក្ខម្ភនប្បហាន សមុច្ឆេទប្បហាន បដិបស្សទ្ធិប្បហាន និស្សរណប្បហាន ។

ក្នុង ៥ យ៉ាងនោះ **សំវរៈ** ក្នុងប្រយោគថា **ឥមិនា បាតិមោក្ខសំវរេន ឧបេតោ ហោតិ សមុបេតោ** ភិក្ខុជាអ្នកចូលដល់ហើយ ចូលដល់ព្រមហើយ ដោយបាតិមោក្ខសំវរនេះ នេះឈ្មោះថា សីលសំវរៈ , **សំវរៈ** ក្នុងប្រយោគថា **រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ** ភិក្ខុរមែងរក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ នេះឈ្មោះថា សតិសំវរៈ , **សំវរៈ** ក្នុងគាថា

ថា ៖

យានិ សោតានិ លោកស្មឹ សតិ តេសំ និវារណំ
សោតានំ សំវរំ ព្រូមិ បញ្ញាយេតេ បិថិយ្យរេ ។

ក្រសែពួកណាក្នុងលោក សតិជាគ្រឿងការពារក្រសែទាំងនោះ តថាគតពោលថា សតិជាគ្រឿងការពារក្រសែទាំងឡាយ ក្រសែទាំងនោះ បណ្ឌិតបិទបានដោយបញ្ញា ។ នេះឈ្មោះថា ញាណ-សំវរៈ ។

សំវរៈក្នុងប្រយោគថា **ខមោ ហោតិ សីតស្ស ឧណ្ហស្ស** ភិក្ខុរមែងអត់ធន់ចំពោះត្រជាក់ចំពោះក្តៅ នេះឈ្មោះថា ខន្តិសំវរៈ , សំវរៈ ក្នុងប្រយោគថា **ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ** ភិក្ខុគ្របសង្កត់ចំពោះកាមវិតក្កដែលកើតឡើងបាន នេះឈ្មោះ វីរិយសំវរៈ ។ មួយទៀត សំវរៈទាំងអស់នេះ លោកហៅថា **សំវរៈ** ព្រោះជាគ្រឿងបិទកាយទុច្ចរិតជាដើម ដែលនឹងគប្បីបិទ តាមនាទីរបស់ខ្លួន និងលោកហៅថា វិន័យ ព្រោះជាគ្រឿងកម្ចាត់កាយទុច្ចរិតជាដើម ដែលនឹងគប្បីកម្ចាត់តាមនាទីរបស់ខ្លួន សំវរៈវិន័យ គប្បីជ្រាបថា បែកជា ៥ យ៉ាង ដោយប្រការដូច្នេះមុន ។

មួយទៀត ក្នុងវិបស្សនាញាណ មាននាមរូបបរិច្ឆេទញាណជាដើម

ការលះអនត្ថៈនោះៗ ដោយវិបស្សនាញាណនោះៗ ដូចការលះងងឹត ដោយពន្លឺប្រទីបនុ៎ះឯង ព្រោះជាបដិបក្ខគ្នា គឺ លះសក្កាយទិដ្ឋិដោយការកំណត់នាមរូប លះទិដ្ឋិដែលមិនមានហេតុ និងទិដ្ឋិដែលមានហេតុមិនស្មើគ្នា ដោយការកំណត់បច្ច័យ លះវិចិកិច្ឆាដោយកង្ខាវិតរណវិសុទ្ធិដែលជាចំណែកខាងចុងនៃការកំណត់បច្ច័យនោះឯង លះការប្រកាន់ថា យើង របស់យើង ដោយការពិចារណានាមរូបដែលជាកលាបៈ លះសញ្ញាក្នុងវត្ថុដែលមិនមែនផ្លូវថា ជាផ្លូវ ដោយមគ្គាមគ្គញាណទស្សនវិសុទ្ធិ លះឧច្ឆេទទិដ្ឋិដោយការឃើញការកើតនៃនាមរូប លះសស្សតទិដ្ឋិដោយការឃើញការរលត់របស់នាមរូប លះសញ្ញាក្នុងវត្ថុដែលមានភ័យថា មិនមានភ័យ ដោយការឃើញនាមរូបថា ជាភ័យ លះសញ្ញាក្នុងអស្សាទៈ (សេចក្ដីពេញចិត្ត) ដោយការឃើញអាទីនវៈ (ទោស) លះសញ្ញាក្នុងអភិរតិ (សេចក្ដីត្រេកអរ) ដោយនិព្វិទានុបស្សនា លះសេចក្ដីមិនចង់ចេញ ដោយមុញ្ចិតុកម្យតាញាណ លះភាពមិនប្រងើយ ដោយឧបេក្ខាញាណ លះធម្មឋិតិ ដោយអនុលោមញាណ លះភាវៈដែលជាបដិលោម ដោយព្រះនិព្វាន ។ លះការប្រកាន់និមិត្តក្នុងសង្ខារ ដោយគោត្រភូញាណ នេះឈ្មោះថា **តទង្គប្បហាន** ។

មួយទៀត ការលះធម៌ មាននីវរណៈជាដើមនោះៗ ដោយឧបចារ-

សមាធិ និងអប្បនាសមាធិនុ៎ះឯង ដូចការការពារសារាយលើផ្ទៃទឹក ដោយការការពារដោយឈើ ដោយហាមការ: គឺ ការប្រព្រឹត្តទៅ នេះឈ្មោះថា **វិក្ខម្ភនប្បហាន** ។ ការលះពួកកិលេសដែលជាបក្ខពួកសមុទ័យ ដែលពោលទុកដោយន័យជាដើមថា ដើម្បីលះទិដ្ឋិក្នុងសន្តានរបស់ខ្លួនដោយមគ្គនោះៗ ព្រោះធ្វើអរិយមគ្គ ៤ ឲ្យកើត ដោយមិនឲ្យកើតឡើងយ៉ាងដាច់ខាត នេះឈ្មោះថា **សមុច្ឆេទប្បហាន** ។ មួយទៀត ការរម្ងាប់កិលេសទាំងឡាយ ក្នុងខណៈនៃផលចិត្ត នេះឈ្មោះថា **បដិបស្សទ្ធិប្បហាន** ។

ព្រះនិព្វាន ដែលលះសង្ខតធម៌បានទាំងអស់ ព្រោះរលាស់សង្ខតធម៌ទាំងអស់បាន នេះឈ្មោះថា **និស្សរណប្បហាន** ។

ម្យ៉ាងទៀត បហានទាំងអស់នេះ ហេតុដែលលោកហៅថា **បហាន** ព្រោះអត្ថថា លះបង់ ហៅថា **វិន័យ** ព្រោះអត្ថថា កម្ចាត់ ដូច្នោះលោកទើបហៅថា **បហានវិន័យ** ។ ម្យ៉ាងទៀត បហាននេះ លោកហៅថា បហានវិន័យ ព្រោះមានការលះកិលេសនោះៗ និងព្រោះមានការកម្ចាត់កិលេសនោះៗ សូម្បីបហានវិន័យ ក៏គប្បីជ្រាបថា ចែកជា ៥ ដោយប្រការដូច្នេះ ។

វិន័យនេះដោយសង្ខេប មាន ២ យ៉ាង ដោយប្រភេទ មាន ១០ យ៉ាង រមែងមិនមានដល់បុថុជ្ជនអ្នកមិនបានសិក្សានោះ ព្រោះជាអ្នកទម្លាយសំវរ: និង

ព្រោះមិនលះវត្ថុដែលគួរលះ ដូច្នោះ បុថុជ្ជននេះ លោកទើបហៅថា អ្នកមិនបានទទួលណែនាំ ព្រោះមិនមានវិន័យនោះ ។ សូម្បីក្នុងពាក្យនេះថា **សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ** ក៏ន័យនេះ ។ សេចក្ដីពិត ពាក្យនេះ ពោលដោយអត្ថ មិនផ្សេងគ្នាឡើយ ។ ដូចដែលត្រាស់ថា បុគ្គលជាអរិយៈ ក៏គឺ សប្បុរស បុគ្គលជាសប្បុរស ក៏គឺ អរិយៈ ធម៌របស់អរិយៈ ក៏គឺ ធម៌របស់សប្បុរស ធម៌របស់សប្បុរស ក៏គឺ ធម៌របស់អរិយៈ វិន័យរបស់អរិយៈ ក៏គឺ វិន័យរបស់សប្បុរស វិន័យរបស់សប្បុរស ក៏គឺ វិន័យរបស់អរិយៈ ។ ពាក្យថា **អរិយេ** ក្ដី **សប្បុរិសេ** ក្ដី **អរិយធម្មេ** ក្ដី **សប្បុរិសធម្មេ** ក្ដី **អរិយវិនយេ** ក្ដី **សប្បុរិសវិនយេ** ក្ដី នេះៗ តែម្យ៉ាងដូចគ្នា មានអត្ថតែមួយ ស្មើគ្នា ប៉ុនគ្នា មានសភាពជាយ៉ាងនោះ ដទៃៗ ក៏ជាយ៉ាងនោះ ។

បទថា **រូបំ អត្តតោ សមនុបស្សតិ** សេចក្ដីថា ភិក្ខុរូបខ្លះក្នុងសាសនានេះ ពិចារណាឃើញរូបថាជាខ្លួន ថា រូបយ៉ាងណា យើងក៏យ៉ាងនោះ យើងយ៉ាងណា រូបក៏យ៉ាងនោះ ពិចារណាឃើញរូប និងអត្តាថា តែមួយ ។ ភិក្ខុរូបខ្លះក្នុងសាសនានេះ ពិចារណាឃើញរូបថាជាខ្លួន ។ល។ ពិចារណាឃើញរូប និងខ្លួន ថាតែម្យ៉ាងដូចគ្នា រួមសេចក្ដីថា រមែងឃើញរូបដោយទិដ្ឋិថា ខ្លួន

ដូចប្រទីបប្រេងដែលកំពុងឆេះ បុគ្គលរមែងឃើញអណ្ដាតភ្លើង និងពន្លឺ តែមួយ ថា អណ្ដាតភ្លើងយ៉ាងណា ពន្លឺក៏យ៉ាងនោះ ពន្លឺយ៉ាងណា អណ្ដាតភ្លើងក៏យ៉ាងនោះ ។ បទថា **រូបវន្តំ វា អត្តានំ** សេចក្ដីថា ប្រកាន់វត្ថុដែលមិនមានរូប (នាមខន្ធ) ថាជាខ្លួន រមែងពិចារណាឃើញវត្ថុដែលមិនមានរូបនោះថា មានរូប ដូចឃើញដើមឈើដែលមានស្រមោល ។ បទថា **អត្តនិ វា រូបំ** សេចក្ដីថា ប្រកាន់វត្ថុដែលមិនមានរូបនុ៎ះឯង ថាជាខ្លួន ពិចារណាឃើញរូបក្នុងខ្លួន ដូចក្លិនក្នុងផ្កាឈើ ។ បទថា **រូបស្មឹ វា អត្តានំ** សេចក្ដីថា ប្រកាន់វត្ថុដែលមិនមានរូបនុ៎ះឯង ថាជាខ្លួន ពិចារណាឃើញរូបក្នុងខ្លួន ដូចកែវមណីក្នុងដប ។ បទថា **បរិយុដ្ឋដ្ឋាយី** សេចក្ដីថា តាំងនៅដោយអាការដែលត្រូវកិលេសរួបរឹត គឺដោយអាការដែលត្រូវគ្របសង្កត់ ។ អធិប្បាយថា ទំពាររូប ដោយតណ្ហា និងទិដ្ឋិ យ៉ាងនេះថាយើង ថារបស់យើង ឈ្មោះថា រមែងប្រកាន់ ។ បទថា **តស្ស តំ រូបំ** បានដល់ រូបរបស់គេនោះ គឺ ដែលប្រកាន់យ៉ាងនោះ សូម្បីក្នុងខន្ធ មានវេទនាខន្ធជាដើម ក៏ន័យនេះឯង ។

បណ្ដាបទទាំងនោះ បទថា **រូបំ អត្តតោ សមនុបស្សតិ** សេចក្ដីថា លោកពោល រូបសុទ្ធៗ នុ៎ះឯង ថាខ្លួន ។ ម្យ៉ាងទៀត លោកពោលវត្ថុដែលមិនមានរូប ក្នុងឋានៈ ៧ ទាំងនេះថា ពិចារណាឃើញខ្លួនមានរូប ឬរូបក្នុងខ្លួន

ឬខ្លួនក្នុងរូប ១ , វេទនា ជាខ្លួន ១ ។ល។ សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន , ពោលខ្លួន ដែលលាយគ្នាជាមួយរូប និងអរូបក្នុងឋានៈ ១២ ក្នុងបណ្តាខន្ធ ៤ យ៉ាងនេះថា ពិចារណាឃើញខ្លួនមានវេទនា (គឺប្រកាន់រូប សញ្ញា សង្ខារ វិញ្ញាណថាជាខ្លួន ហើយខ្លួនមានវេទនា) ឬវេទនានៅក្នុងខ្លួន ឬខ្លួននៅក្នុងវេទនា ក្នុងបណ្តាខន្ធទាំងនោះ លោកពោលឧច្ឆេទទិដ្ឋិ ក្នុងឋានៈថា ពិចារណាឃើញរូបថាជាខ្លួន ពិចារណាឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ។ ក្នុងទិដ្ឋិដ៏សេស សស្សតទិដ្ឋិ រមែងជាយ៉ាងនេះ ។ សរុបសេចក្តីថា ក្នុងបញ្ចក្ខន្ធទាំងនេះ ភវទិដ្ឋិ ១៥ , វិភវទិដ្ឋិ ៥ រមែងយ៉ាងនេះ ទិដ្ឋិទាំងអស់នោះ គប្បីជ្រាបថា រមែងហាមមគ្គ មិនហាមសួគ៌ ដែលសោតាបត្តិមគ្គគប្បីសម្លាប់ ។

បទថា **ឯវំ ខោ គហបតិ អាតុរកាយោ ចេវ ហោតិ អាតុរចិត្តោ ច** សេចក្តីថា ដែលឈ្មោះថា កាយ សូម្បីរបស់ព្រះពុទ្ធទាំងឡាយ ក៏រមែងរសាប់-រសល់ដូចគ្នា ចំណែកចិត្តដែលប្រកបដោយតាមរាគៈ ទោសៈ និងមោហៈ ក៏ឈ្មោះថា រសាប់រសល់ ចិត្តនោះសម្តែងទុកក្នុងទីនេះហើយ ។

[៥] បទថា **ន ច អាតុរោ** សេចក្តីថា ក្នុងទីនេះលោកសម្តែងដល់ចិត្តដែលស្ងប់ មិនរសាប់រសល់ ព្រោះប្រាសចាកកិលេស ។ ដូច្នោះក្នុងព្រះសូត្រនេះ គប្បីជ្រាបថា លោកសម្តែងដល់លោកិយមហាជនថា មានកាយ

*រសោប់រសល់ និងមានចិត្តរសោប់រសល់ ព្រះវីណាស្រេព គប្បីជ្រាបថា មាន កាយរសោប់រសល់ មានចិត្តមិនរសោប់រសល់ , ព្រះសេក្ខៈ៧ ពួក មានកាយ រសោប់រសល់មានចិត្តរសោប់រសល់ក៏មិនមែន មានចិត្តមិនរសោប់រសល់ក៏មិន មែន តែកាលសេពគប់ រមែងសេពគប់ជាមួយអ្នកដែលមានចិត្តមិនរសោប់- រសល់ប៉ុណ្ណោះឯង ។*

ចប់អដ្ឋកថា នកុលបិតុសូត្រទី ១

# អ ដ្ឋ ក ថា

## ទេវទហសូត្រទី ២

ក្នុង *ទេវទហសូត្រទី ២* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៦] *សក្យៈទាំងឡាយ លោកហៅថា ទេវៈ ស្រះដែលជាមង្គលរបស់សក្យៈទាំងនោះ ឈ្មោះថា* ***ទេវទហ*** *ន័យមួយទៀត ស្រះនោះកើតឯង ព្រោះហេតុដូច្នោះ លោកទើបហៅថា ទេវទហៈ និគមមាននៅក្នុងទីមិនពីឆ្ងាយស្រះទេវទហៈនោះ ទើបពោលថា ទេវទហៈនោះឯង ដោយនប៉ុំសកលិង្គ ។* បទថា ***បច្ឆាភូមគាមិកា*** *បានដល់ អ្នកប្រាថ្នានឹងទៅកាន់បច្ឆាភូមជនបទដែលតាំងនៅក្នុងទិសដទៃទៀត បទថា* ***និវាសំ*** *បានដល់ នៅចាំវស្សារហូតដល់អស់ ៣ ខែ បទថា* ***អបលោកិតោ*** *ប្រែថា ប្រាប់លា បទថា* ***អបលោកេថ*** *ប្រែថា សូមអ្នកចូរប្រាប់លា សួរថា ព្រោះហេតុអ្វី ទើបឲ្យប្រាប់លាព្រះថេរៈ ? ឆ្លើយថា ព្រោះមានពុទ្ធបំណងនឹងធ្វើឲ្យភិក្ខុទាំងនោះមានភារៈ មុខនាទី ពិតណាស់ ភិក្ខុណា សូម្បីកាលនៅក្នុងវិហារតែមួយជាមួយគ្នា ក៏មិនទៅកាន់សំណាក់ កាលនឹងចេញទៅ ក៏ចេញទៅដោយមិនប្រាប់លា ភិក្ខុនេះឈ្មោះថា* ***និព្ភារោ*** *មិនមានភារៈ ភិក្ខុណាសូម្បីនៅក្នុងវិហារជាមួយគ្នា ក៏មកជួបគ្នាបាន កាលបើនឹង*

ចេញទៅ ចាំបាច់ត្រូវប្រាប់លា ភិក្ខុនេះឈ្មោះថា មានការៈ ភិក្ខុសូម្បីទាំងនេះ មិនមែនដូច្នោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះនឹងចម្រើនដោយគុណ មានសីលជាដើម សូម្បីដោយអាការយ៉ាងនេះ ទើបមានព្រះពុទ្ធបំណងទ្រង់នាំភិក្ខុទាំងនោះឲ្យមានការៈនាទី ទើបត្រាស់ឲ្យប្រាប់លា ។ បទថា **បណ្ឌិតោ** សេចក្តីថា អ្នកប្រកបដោយភាពជាបណ្ឌិត ៤ យ៉ាង មានការឆ្លាតក្នុងធាតុជាដើម ។ បទថា **អនុគ្គាហកោ** បានដល់ អ្នកអនុគ្រោះ ដោយការអនុគ្រោះ ២ យ៉ាង គឺ អនុគ្រោះដោយអាមិស និងអនុគ្រោះដោយធម៌ ៖

បានឮថា ព្រះថេរៈ មិនទៅបិណ្ឌបាតពីព្រឹកព្រលឹមដូចភិក្ខុពួកដទៃទេ កាលភិក្ខុទាំងពួងទៅហើយ ក៏ដើរត្រួតមើលទៅតាមលំដាប់ ទូទៅសង្ឃារាម បោសសម្អាតកន្លែងដែលមិនទាន់បានបោស ទាំងសម្រាមដែលនៅមិនទាន់បានចោល រក្សាទុកដាក់គ្រែ តាំង គ្រឿងឈើ និងគ្រឿងដី ដែលរក្សាទុកមិនល្អក្នុងសង្ឃារាម សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះបំណងថា កាលពួកអន្យតិរ្ថិយចូលទៅវិហារឃើញ នឹងធ្វើការតិះដៀល តពីនោះបានទៅកាន់គិលានដ្ឋាន លួងលោមចិត្តភិក្ខុឈឺ សួរថា លោកត្រូវការអ្វី ទើបរកភិក្ខុកម្លោះនិងសាមណេររបស់ភិក្ខុទាំងនោះ ទៅដើម្បីប្រយោជន៍តាមបំណង ហើយស្វែងរកភេសជ្ជៈដោយភិក្ខាចារវត្ត ឬក្នុងទីដែលអ្នកស្រឡាញ់រាប់អានគ្នា ថ្វាយដល់

ភិក្ខុទាំងនោះ ទើបបញ្ជូនភិក្ខុទាំងនោះទៅ ដោយពោលថា ឈ្មោះថា ការទំនុកបម្រុងភិក្ខុឈឺ ព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធសរសើរហើយ ទៅចុះ អ្នកដ៏សប្បុរស ពួកលោកកុំប្រមាទ ហើយខ្លួនឯងក៏ត្រាច់ទៅបិណ្ឌបាត ឬធ្វើភត្តកិច្ចក្នុងត្រកូលឧបដ្ឋាក ហើយទៅកាន់វិហារ ប្រការនេះ ព្រោះព្រះថេរៈនោះធ្លាប់ប្រព្រឹត្តមកជាប្រចាំហើយក្នុងទីនោះ ។

ក៏កាលព្រះមានព្រះភាគស្តេចចារិកទៅ ព្រះថេរៈគិតថា យើងជាព្រះអគ្គសាវក ទើបមិនដើរពាក់ស្បែកជើង ប៉ាំងឆត្រទៅខាងមុខ ។ ក៏ក្នុងបណ្តាភិក្ខុទាំងនោះ ភិក្ខុពួកណាដែលចាស់ ជាអ្នកជម្ងឺ ឬនៅក្មេងពេក ព្រះថេរៈក៏ឲ្យយកប្រេងលាបត្រង់កន្លែងឈឺចាប់របស់ភិក្ខុទាំងនោះ ហើយឲ្យភិក្ខុកម្លោះនិងសាមណេររបស់ខ្លួនកាន់បាត្រ និងចីវរ ក្នុងថ្ងៃនោះ ឬថ្ងៃស្អែក ក៏នាំភិក្ខុទាំងនោះទៅ ។ ក្នុងថ្ងៃមួយ ព្រះសាស្តាទ្រង់ឃើញលោក មិនបានសេនាសនៈអង្គុយនៅក្រោមឆ័ត្រ ព្រោះដល់វេលាវិកាល (ថ្ងៃក្តៅខ្លាំង) ថ្ងៃស្អែក ទើបឲ្យប្រជុំភិក្ខុសង្ឃសម្តែងរឿងដំរី ស្វា និងសត្វទទា ហើយទ្រង់បញ្ញត្តិសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីប្រើសេនាសនៈតាមលំដាប់ភិក្ខុដែលចាស់ ។ ជាដំបូងព្រះអង្គទ្រង់អនុគ្រោះដោយអាមិស ដោយប្រការដូច្នេះ ក៏ព្រះអង្គទ្រង់ឱវាទរយជនខ្លះ ពាន់ជនខ្លះ ដរាបភិក្ខុនោះតាំងនៅក្នុងសោតា-

បត្តិផល តពីនោះទើបទ្រង់លះភិក្ខុនោះ ហើយឪវាទភិក្ខុដទៃ ដោយន័យនេះ ភិក្ខុទាំងឡាយតាំងនៅក្នុងឪវាទរបស់ព្រះអង្គ ដែលទ្រង់ឪវាទហើយ ក៏សម្រេចព្រះអរហត្តភាពមិនអស់ ព្រះអង្គទ្រង់អនុគ្រោះដោយធម៌ ដោយប្រការដូច្នេះ ។

បទថា **បច្ចស្សោសុំ** សេចក្តីថា ភិក្ខុទាំងនោះគិតថា ភិក្ខុនេះមិនមែនជាឧបជ្ឈាយ៍ មិនមែនជាអាចារ្យ មិនមែនជាសម្លាញ់ ដូច្នោះ យើងនឹងធ្វើក្នុងសំណាក់របស់លោក ដូច្នេះ ក៏មិនបាននៅស្ងៀមព្រងើយ ទើបទទួលព្រះតម្រាស់ព្រះសាស្តាថា ព្រះករុណា ព្រះអង្គ ។

[៧] បទថា **ឯលគលាគុម្ពេ** បានដល់ រោងដែលប្រក់បាំងដោយគុម្ពវល្លិទឹក បានឮថា គុម្ពវល្លិទឹកនោះកើតក្នុងទីមានទឹកមិនដាច់ គ្រានោះ ភិក្ខុទាំងនោះ ធ្វើរោងមានសសរ ៤ ក្នុងទីនោះ ហើយលើកគុម្ពវល្លិទឹកនោះឡើងធ្វើជាគ្រឿងប្រក់រោងនោះ គុម្ពវល្លិទឹកនោះបានជាគ្រឿងការពាររោងនោះ ទីនោះភិក្ខុទាំងនោះ ទើបក.ឥដ្ឋទុកខាងក្រោមរោងនោះ រោយខ្សាច់ ក្រាលអាសនៈទុក ខ្យល់បក់ត្រសៀកៗ ក្នុងពេលថ្ងៃត្រង់មួយត្រជាក់ ព្រះថេរៈអង្គុយក្នុងទីនោះ ដែលលោកពោលទុកថា ត្រង់គុម្ពវល្លិទឹក ។ បទថា **នានាវេរជ្ជគតំ** សេចក្តីថា បានដល់ ប្រទេសផ្សេងៗ ក្រៅអំពីប្រទេសព្រះរាជាមួយព្រះអង្គ ។ បទថា **វិរជ្ជំ** បានដល់ ប្រទេសដទៃ ដូចជា អាវាសដទៃ ក្រៅអំពីអាវាសខ្លួន

ចេញ ឈ្មោះថា **វិទេស** (អាវាសផ្សេង) យ៉ាងណា ប្រទេសដទៃក្រៅអំពីប្រទេសដែលធ្លាប់នៅអាស្រ័យ ឈ្មោះ **វិរជ្ជៈ** (ប្រទេសផ្សេង) ក៏ដូច្នោះ ។ ប្រទេសផ្សេងនោះ លោក ហៅថា **វេរជ្ជៈ** ។ បទថា **ខត្តិយបណ្ឌិតា** បានដល់ព្រះរាជាដែលជាបណ្ឌិត មានព្រះបាទពិម្ពិសារ និងព្រះបាទកោសលជាដើម ។

បទថា **ព្រាហ្មណបណ្ឌិតា** បានដល់ ព្រាហ្មណ៍ដែលជាបណ្ឌិត មានចង្កីព្រាហ្មណ៍ និងវុក្ខព្រាហ្មណ៍ជាដើម ។ បទថា **គហបតិបណ្ឌិតា** បានដល់គហបតីដែលជាបណ្ឌិត មានចិត្តគហបតី និងសុទត្តគហបតីជាដើម ។ បទថា **សមណបណ្ឌិតា** បានដល់ អ្នកបួសដែលជាបណ្ឌិត មានសភិយបរិព្វាជក និងបិលោតិកបរិព្វាជកជាដើម ។ បទថា **វីមំសកា** បានដល់ បុគ្គលអ្នកស្វែងរកប្រយោជន៍ ។ បទថា **កឹវាទី** បានដល់ លោកពោលនូវការឃើញរបស់ខ្លួនថាយ៉ាងណា អធិប្បាយថា អ្នកមានលទ្ធិពោលយ៉ាងណា ។

បទថា **កិមក្ខាយី** បានដល់ ប្រាប់ឱវាទ និងអនុសាសន៍ដល់សាវកទាំងឡាយថា យ៉ាងណា ។ បទថា **ធម្មស្ស ចានុធម្មំ** បានដល់ ព្យាករណ៍តាមព្យាករណ៍ដែលព្រះមានព្រះភាគត្រាស់ហើយ ។ បទថា **សហធម្មិកោ** បានដល់ អ្នកប្រព្រឹត្តទៅជាមួយហេតុ ។ បទថា **វាទានុវាទោ** បានដល់ ពោលតាមវាទៈដែលព្រះមានព្រះភាគត្រាស់ ។ បាលីថា **វាទានុវាតោ** ដូច្នេះ ក៏មាន ។

អធិប្បាយថា ស្រេបតាម បណ្តោយតាម ប្រព្រឹត្តទៅតាម ។ សូម្បីដោយបទ នេះ ក៏លោកសម្តែងចំពោះវាទៈដែលបណ្តោយតាមវាទៈនុ៎ះឯង ។

[៨] ក្នុងបទថា **អវីតរាគស្ស** គប្បីជ្រាបអត្ថ ដោយតណ្ហានុ៎ះឯង ព្រោះដូច្នោះ តណ្ហានោះ លោកហៅថា **រាគៈ** ព្រោះតម្រេក, ថា **ឆន្ទៈ** ព្រោះ ពេញចិត្ត, ថា **បេមៈ** ព្រោះអត្ថថា ស្រឡាញ់, ថា **បិបាសារៈ** ព្រោះអត្ថថា ស្រេកឃ្លាន, ថា **បរិឡាហៈ** ក្តៅក្រហាយ ព្រោះអត្ថថា តាមដុត ។

[៩] សួរថា ព្រោះហេតុអ្វី លោកទើបផ្តើមពាក្យជាដើមថា **អកុសលេ ចាវុសោធម្មេ** ។ ឆ្លើយថា ដើម្បីសម្តែងទោសរបស់អ្នកមិនប្រាសចាករាគៈ និងអានិសង្សរបស់អ្នកប្រាសចាករាគៈក្នុងខន្ធ ៥ ។ បណ្តាបទទាំងនោះ បទថា **អវិឃាតោ** បានដល់ អ្នកអស់ទុក្ខហើយ ។ បទថា **អនុបាយាសោ** បានដល់ អ្នកអស់សេចក្តីចង្អៀតចង្អល់ ។ បទថា **អបរិឡាហោ** បានដល់ អ្នកមិនមាន សេចក្តីក្តៅក្រហាយ គប្បីជ្រាបសេចក្តីគ្រប់បទដូចពោលមកនេះ ។

ចប់អដ្ឋកថា ទេវទហសូត្រទី ២

# អ ដ្ឋ ក ថា

## ហាលិទ្ទិកានិសូត្រទី ៣

ក្នុង *ហាលិទ្ទិកាសូត្រទី ៣* មានវិនិច្ឆ័យដូចតទៅនេះ ៖

[១១] បទថា ***អវន្តីសុ*** បានដល់ ក្នុងដែនអវន្តី ពោលគឺ អវន្តីទក្ខិណាបថ ។ បទថា ***កុររឃរេ*** បានដល់ ក្នុងនគរមានឈ្មោះយ៉ាងនោះ ។ បទថា ***បបាតេ*** បានដល់ ក្នុងម្ខាងជ្រោះ បានឮថា កូនភ្នំនោះមានចំណែកម្ខាងដូចជាបាក់ធ្លាក់ទៅ ។ បាលីថា ***បវត្តេ*** ដូច្នេះក៏មាន អធិប្បាយថា ជាទីប្រកាសលទ្ធិរបស់ពួកតិរ្ថិយផ្សេងៗ ។ ដូច្នោះ ព្រះថេរៈទើបអាស្រ័យនគរនោះក្នុងវដ្ឋនោះ ហើយអាស្រ័យនៅលើភ្នំនោះ ។ បទថា ***ហាលិទ្ទិកានិ*** បានដល់គហបតីដែលមានឈ្មោះយ៉ាងនោះ ។ បទថា ***អដ្ឋកវគ្គិយេ មាគណ្ឌិយបញ្ហេ*** បានដល់ ក្នុងបញ្ហាដែលមានឈ្មោះថា មាគណ្ឌិយបញ្ហា ក្នុងវគ្គទី ៨ ។

[១២] ដោយបទថា ***រូបធាតុ*** លោកបំណងយករូបក្ខន្ធ ។ បទថា ***រូបធាតុរាគវិនិពន្ធំ*** សេចក្តីថា រួបរឹតហើយដោយតម្រេកក្នុងរូបធាតុ ។ បទថា ***វិញ្ញាណំ*** បានដល់ កម្មវិញ្ញាណ ។ បទថា ***ឱកសារី*** បានដល់ អ្នកអាស្រ័យផ្ទះជាប្រចាំ គឺ អ្នកអាស្រ័យអាល័យជាប្រចាំ ។ សួរថា ក៏ព្រោះហេតុអ្វី ក្នុង

ទីនេះ លោកទើបមិនពោលថា **វិញ្ញាណធាតុ ខោ គហបតិ** ។ ឆ្លើយថា ដើម្បី កម្ចាត់សេចក្ដីសង្ស័យ ។ ពិតហើយ ពោលអំពីអត្ថ បច្ច័យ លោកហៅថា **ឱក:** កម្មវិញ្ញាណដែលកើតមុន រមែងជាបច្ច័យទាំងដល់កម្មវិញ្ញាណ ទាំងដល់ វិបាកវិញ្ញាណដែលកើតខាងក្រោយ , ចំណែកវិបាកវិញ្ញាណ រមែងជាបច្ច័យ ទាំងដល់វិបាកវិញ្ញាណ ទាំងដល់កម្មវិញ្ញាណ ដូច្នោះ ដើម្បីកម្ចាត់សេចក្ដីសង្ស័យ ដែលគប្បីមានថា អ្វីហ្ន៎ដែលឈ្មោះថា វិញ្ញាណ ក្នុងទីនេះ ទើបទ្រង់មិនបាន កំណត់យកប្រការនោះ ធ្វើទេសនាមិនឲ្យប្រឡូកប្រឡល់គ្នា ម្យ៉ាងទៀត បើ ពោលដោយអំណាចអារម្មណ៍ ដើម្បីទឹងសម្ដែងវិញ្ញាណដ្ឋិតិ ដែលបច្ច័យតាក់ តែង ៤ យ៉ាង ដែលត្រាស់ទុកនោះ ទើបមិនរាប់វិញ្ញាណចូលក្នុងទីនេះ ។

[១៣] **ឧបាយ** ក្នុងពាក្យថា **ឧបាយុបាទានា** មាន ២ យ៉ាង គឺ តណ្ហាឧបាយ ១ ទិដ្ឋិឧបាយ ១ និងឧបាទាន ក្នុងពាក្យថា **ឧបាយុបាទានា** មាន ៤ យ៉ាង មានកាមុបាទានជាដើម ។ បទថា **ចេតសោ អធិដ្ឋានាភិនិ-វេសានុសយា** បានដល់ ជាទីតាំងអាស្រ័យ ជាទីប្រកាន់មាំ និងជាទីដេកនៃ អកុសលចិត្ត ។ បទថា **តថាគតស្ស** បានដល់ ព្រះសម្មាសម្ពុទ្ធ ពិតហើយ តណ្ហា និងឧបាទានទាំងនោះ ព្រះខីណាស្រពគ្រប់ជំពូកលះបង់បានហើយ ។ តែបើពោលឲ្យក្រៃលែង លោកពោលទុកយ៉ាងនេះថា ព្រះសាស្ដា ជាព្រះខី-

ណាស្រេពប្រាកដច្បាស់ហើយក្នុងលោក ។ សួរថា ព្រោះហេតុអ្វី លោកទើបចាត់វិញ្ញាណទុកក្នុងទីនេះថា **វិញ្ញាណធាតុយា** ដូច្នេះ ។ ឆ្លើយថា ដើម្បីសម្ដែងការលះកិលេស ។ ព្រោះថា កិលេសដែលលោកលះក្នុងខន្ធ ៤ ប៉ុណ្ណោះ មិនទាន់ជាការលះបាន ត្រូវលះបានក្នុងខន្ធទាំង ៥ ទើបជាការលះបាន ដូច្នោះ លោកទើបចាត់ទុក ដើម្បីសម្ដែងការលះកិលេស ។ បទថា **ឯវំ ខោ គហបតិ អនោកសារី ហោតិ** សេចក្ដីថា ឈ្មោះថា ជាអ្នកមិនមានផ្ទះយ៉ាងនេះ គឺ ដោយកម្មវិញ្ញាណដែលមិនមានផ្ទះ ។

[១៤] បទថា **រូបនិមិត្តនិកេតវិសារវិនិពន្ធា** ។ សេចក្ដីថា រូបនុ៎ះឯង ឈ្មោះថា និមិត្ត ព្រោះអត្ថថា ជាបច្ច័យនៃកិលេសទាំងឡាយ ឈ្មោះថា **និកេត** ព្រោះអត្ថថា ជាកន្លែងស្នាក់ ពោលគឺ ជាអារម្មណ៍ ដូច្នោះទើបឈ្មោះថា មានរូបជានិមិត្ត និងជាកន្លែងស្នាក់ ។ ការផ្សាយទៅ និងការជាប់ជំពាក់ ឈ្មោះថា **វិសារវិនិពន្ធ** ។ ដោយពីរបទថា **វិសារៈ** និង **វិនិពន្ធៈ** លោកពោលដល់កិលេសផ្សាយទៅ និងការជាប់ជំពាក់ដោយកិលេស ។ បទថា **រូប-និមិត្តនិកេតវិសារវិនិពន្ធា** ប្រែថា ព្រោះការផ្សាយទៅ និងការជាប់ជំពាក់ក្នុងរូប ដែលជានិមិត្ត និងជាកន្លែងស្នាក់ ដូច្នោះ ទើបមានអធិប្បាយថា ដោយការផ្សាយទៅនៃកិលេស និងដោយការជាប់ជំពាក់នៃកិលេសដែលកើតឡើង

ក្នុងរូប ដែលជានិមិត្ត និងជាទីស្នាក់ ។ បទថា **និកេតសារីតិ វុច្ចតិ** សេចក្ដីថា ទីដែលជាកន្លែងស្នាក់ លោកហៅថា **សារី** ដោយធ្វើឲ្យជាអារម្មណ៍ ។

[១៥] បទថា **បហីនា** សេចក្ដីថា ព្រះតថាគតទ្រង់លះបង់ការផ្សាយទៅ និងការជាប់ជំពាក់នៃកិលេសក្នុងរូបដែលជានិមិត្ត និងជាទីស្នាក់ ។ សួរថា ក៏ព្រោះហេតុអ្វី ក្នុងទីនេះ បញ្ចក្ខន្ធ លោកទើបហៅថា **ឱកៈ** , អារម្មណ៍ ៦ លោកទើបហៅថា **និកេតៈ** ។ ឆ្លើយថា ព្រោះឆន្ទរាគៈមានកម្លាំងខ្លាំង និងមានកម្លាំងខ្សោយ ។ ពិតណាស់ សូម្បីឆន្ទរាគៈមានកម្លាំងស្មើគ្នា អារម្មណ៍ទាំងនោះក៏មានសភាពផ្សេងគ្នា ដោយអត្ថថា ជាកន្លែងស្នាក់ គឺ ផ្ទះ ដែលជាកន្លែងស្នាក់ជាប្រចាំទុំះឯង លោកហៅថា **ឱកៈ** ។ ចំការជាដើម ជាទីស្នាក់របស់អ្នកដែលណាត់គ្នាធ្វើការថា ថ្ងៃនេះពួកយើងនឹងធ្វើក្នុងទីឯណោះ ឈ្មោះថា **និកេតៈ** ក្នុងពីរយ៉ាងនោះ ក្នុងខន្ធដែលប្រព្រឹត្តទៅខាងក្នុង ដូចឆន្ទរាគៈក្នុងផ្ទះ ដែលពេញដោយបុត្រ ភរិយា ទ្រព្យ និងធញ្ញាហារ រមែងមានកម្លាំងខ្លាំង ។ ក្នុងអារម្មណ៍ខាងក្រៅ ៦ ដូចឆន្ទរាគៈក្នុងចំការជាដើម មានកម្លាំងខ្សោយជាង ដូច្នោះ គប្បីជ្រាបថា ត្រាស់ទេសនាយ៉ាងនេះ ព្រោះឆន្ទរាគៈមានកម្លាំងខ្លាំង និងមានកម្លាំងខ្សោយ ។

[១៦] បទថា **សុខិតេសុ សុខិតោ** សេចក្ដីថា កាលពួកឧបដ្ឋាកបាន

ទទួលសេចក្ដីសុខ ព្រោះបានទ្រព្យ ធញ្ញាហារជាដើម ក៏មានសេចក្ដីសុខ ដោយសេចក្ដីសុខអាស្រ័យផ្ទះថា ឥឡូវនេះ យើងនឹងបានភោជនដែលគួរពេញចិត្ត ដូចជាសោយសម្បត្តិដែលពួកឧបដ្ឋាកទាំងនោះបានទទួល ហើយត្រាច់ទៅ ។ បទថា **ទុក្ខិតេសុ ទុក្ខិតោ** សេចក្ដីថា កាលពួកឧបដ្ឋាកទាំងនោះកើតសេចក្ដីទុក្ខដោយហេតុយ៉ាងណាមួយ ខ្លួនឯងមានសេចក្ដីទុក្ខផងដែរ ។ បទថា **កិច្ចករណីយេសុ** បានដល់ ក្នុងរឿងដែលគួរធ្វើ គឺ កិច្ច ។ បទថា **យោគំ អាបជ្ជតិ** សេចក្ដីថា ជួយខ្វល់ខ្វាយ គឺ ធ្វើកិច្ចទាំងនោះដោយខ្លួនឯង ។ បទថា **កាមេសុ** បានដល់ ក្នុងវត្ថុកាមទាំងឡាយ ។

[១៨] បទថា **ឯវំ ខោ គហបតិ កាមេហិ ន រិត្តោ ហោតិ** សេចក្ដីថា ជាអ្នកមិនទំនេរចាកកិលេសកាមទាំងឡាយ គឺ ជាអ្នកមិនសូន្យ ព្រោះនៅមានកាមខាងក្នុង យ៉ាងនេះ ។ ចំណែកផ្ទុយគ្នា គប្បីជ្រាបថា ទំនេរ គឺ សូន្យ ព្រោះមិនមានកាមទាំងនោះ ។

[២០] បទថា **បុរក្ខរានោ** បានដល់ ប្រាថ្នាក្នុងអនាគត ។ ក្នុងបទថា **ឯវំរូបោ សិយំ** ជាដើម បានដល់ ប្រាថ្នាថា យើងគប្បីជាអ្នកមានរូបយ៉ាងនេះ ក្នុងបណ្ដារូបដែលខ្ពស់ និងទាប ខ្មៅ និងសជាដើម , ប្រាថ្នាថា ក្នុងវេទនា មានសុខវេទនាជាដើម យើងគប្បីជាអ្នកឈ្មោះថា មានវេទនាយ៉ាង

នោះ , ក្នុងសញ្ញា មានសញ្ញាដែលកំណត់ ដោយនីលកសិណជាដើម យើងគប្បីជាអ្នកឈ្មោះថា មានសញ្ញាយ៉ាងនោះ , ក្នុងសង្ខារ មានបុញ្ញាភិសង្ខារជាដើមថា យើងគប្បីជាអ្នកឈ្មោះថា មានសង្ខារយ៉ាងនោះ , ក្នុងវិញ្ញាណមានចក្ខុវិញ្ញាណជាដើមថា យើងគប្បីជាអ្នកឈ្មោះថា មានវិញ្ញាណយ៉ាងនោះ ។

[២១] បទថា **អបុរក្ខរានោ** បានដល់ មិនប្រាថ្នាក្នុងអនាគត ។

[២២] បទថា **សហិតម្មេ អសហិតន្តេ** បានដល់ ពាក្យរបស់លោកមិនមានប្រយោជន៍ មិនរៀបរយ ពាក្យរបស់យើងមានប្រយោជន៍ រៀបរយផ្អែម ។ បទថា **អធិចិណ្ណន្តេ វិបរាវត្តំ** បានដល់ ពាក្យនិយាយរបស់លោកដែលសន្សំល្អមកយូរហើយទាំងអស់នោះ ពេលមកដល់សំដីរបស់យើង ក៏វិបរិតក្លាយ ។ បទថា **អារោបិតោ តេ វាទោ** បានដល់ ទោសរបស់លោកយើងលើកឡើងហើយ ។ បទថា **ចរ វាទប្បមោក្ខាយ** សេចក្តីថា លោកចូរចូលទៅរកអាចារ្យនោះៗ ស្វែងរកដើម្បីដោះស្រាយឲ្យរួចអំពីវាទៈនេះ ។ បទថា **និព្វេធេហិ វា សចេ បហោសិ** បានដល់ បើលោកគ្រាន់បើ លោកចូរពោលដោះស្រាយក្នុងទីនេះតែម្តងចុះ ។

ចប់អដ្ឋកថា ហាលិទ្ទិកានិសូត្រទី ៣

# អ ដ្ឋ ក ថា

## ទុតិយហាលិទ្ទិកានិសូត្រទី ៤

*ក្នុង ទុតិយហាលិទ្ទិកានិសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៥] ពាក្យថា* ***សក្កបញ្ហេ*** *នេះ លោកពោលទុកហើយ ទាំងក្នុងចូឡសក្កបញ្ហា និងទាំងក្នុងមហាសក្កបញ្ហា ។ បទថា* ***តណ្ហាសង្ខយវិមុត្តា*** *បានដល់ បង្អោនទៅក្នុងព្រះនិព្វានដែលជាទីអស់ទៅនៃតណ្ហា ដោយផលវិមុត្តិដែលមានព្រះនិព្វាននោះជាអារម្មណ៍ ។ បទថា* ***អច្ចន្តនិដ្ឋា*** *បានដល់ សម្រេច គឺ សម្រេចដោយល្អ សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នានេះឯង ។*

ចប់អដ្ឋកថា ទុតិយហាលិទ្ទិកានិសូត្រទី ៤

# អដ្ឋកថា

## សមាធិសូត្រទី ៥

[២៧] ក្នុង *សមាធិសូត្រទី ៥* មានវិនិច្ឆ័យដូចតទៅនេះ ៖

ព្រះមានព្រះភាគ ទ្រង់ឃើញភិក្ខុទាំងនោះវិនាសចាកភាពជាអ្នកមានចិត្តមានអារម្មណ៍តែមួយ ហើយទ្រង់ជ្រាបថា កាលភិក្ខុទាំងនេះមានចិត្ត មានអារម្មណ៍តែមួយ កម្មដ្ឋាននឹងចម្រើន ដូច្នេះហើយ ទើបបានត្រាស់ព្រះតម្រាស់នេះថា **សមាធិ** ជាដើម ។

[២៨] បទថា **អភិនន្ទតិ** បានដល់ រមែងប្រាថ្នា ។ បទថា **អភិវទតិ** សេចក្តីថា ភិក្ខុរមែងពោលដោយសេចក្តីត្រេកអរនោះថា អើ! អារម្មណ៍នេះគួរប្រាថ្នា គួររីករាយ គួរពេញចិត្ត ដូច្នេះ ។ មួយវិញទៀត កាលលោកត្រេកអរក្នុងអារម្មណ៍នោះ អាស្រ័យអារម្មណ៍នោះ ធ្វើឲ្យកើតសេចក្តីលោភឡើងដោយអាការយ៉ាងនេះ ឈ្មោះថា រមែងពោលសរសើរ ។ បទថា **អជ្ឈោសាយ តិដ្ឋតិ** បានដល់ ក្រសោបក្រសាវយក ។ បទថា **យា រូបេ នន្ទិ** បានដល់ សេចក្តីក្រើតក្រើន ពោលគឺ សេចក្តីប្រាថ្នាក្នុងរូបដ៏មានកម្លាំង ។ បទថា **តទុ-បាទានំ** គឺ ឈ្មោះថា ឧបាទាន ព្រោះអត្ថថា ប្រកាន់មាំក្នុងអារម្មណ៍នោះ ។

[២៩] *បទថា* ***នាភិនន្ទិ*** *បានដល់ មិនប្រាថ្នា ។ បទថា* ***នាភិវទតិ*** *សេចក្តីថា លោករមែងមិនពោលថា អារម្មណ៍គួរត្រេកអរ គួរសរសើរ ដោយអំណាចនៃសេចក្តីប្រាថ្នា គឺ ភិក្ខុអ្នកមានចិត្តប្រកបដោយវិបស្សនា សូម្បីកាលធ្វើការបន្ទឹវាចាថា មិនទៀង ជាទុក្ខ ក៏ឈ្មោះថា រមែងមិនពោលលើកសរសើរ នោះឯង ។*

ចប់អដ្ឋកថា សមាធិសូត្រទី៥

# អ ដ្ឋ ក ថា

## បដិសល្លានសូត្រទី ៦

[៣០] ក្នុង *បដិសល្លានសូត្រទី ៦* មានវិនិច្ឆ័យដូចតទៅនេះ ៖

ព្រះមានព្រះភាគទ្រង់ឃើញភិក្ខុទាំងនោះ វិនាសចាកកាយវិវេកហើយ ទ្រង់ជ្រាបថា កាលពួកភិក្ខុនោះបានកាយវិវេក កម្មដ្ឋាននឹងចម្រើន ទើបបានត្រាស់ព្រះតម្រាស់នេះថា *បដិសល្លានេ* ជាដើម ។

ចប់អដ្ឋកថា បដិសល្លានសូត្រទី ៦

# អ ដ្ឋ ក ថា

## ឧបាទានបរិតស្សនាសូត្រទី ៧

ក្នុង **ឧបាទានបរិតស្សនាសូត្រទី ៧** មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣១] បទថា **ឧបាទានប្បរិតស្សនំ** បានដល់ សេចក្តីតក់ស្លុតដែលកើតឡើង ព្រោះសេចក្តីប្រកាន់ ។ បទថា **អនុបាទានអបរិតស្សនំ** បានដល់ សេចក្តីមិនតក់ស្លុតដែលកើតឡើង ព្រោះសេចក្តីមិនប្រកាន់ ។

[៣២] បទថា **រូបវិបរិណាមានុវត្តិ** សេចក្តីថា កម្មវិញ្ញាណ រមែងជាធម្មជាតិវិលទៅតាមការបែកធ្លាយនៃរូប ដោយន័យជាដើមថា រូបរបស់យើងប្រែប្រួលហើយ ដូច្នេះ ឬថា រូបនេះធ្លាប់មានដល់យើងហើយ តែឥឡូវនេះរូបនេះ មិនមានដល់យើងទេ ដូច្នេះ ។ បទថា **វិបរិណាមានុបរិវត្តិជា** បានដល់ (សេចក្តីតក់ស្លុត) កើតអំពីចិត្ត ដែលមានសេចក្តីប្រែប្រួលជាអារម្មណ៍ ព្រោះវិលទៅតាមរូបដែលប្រែប្រួលនោះឯង ។ បទថា **បរិតស្សនាធម្មសមុប្បាទា** បានដល់ សេចក្តីតក់ស្លុត ព្រោះតណ្ហា និងការកើតឡើងព្រមនៃអកុសលធម៌ ។ បទថា **ចិត្តំ** បានដល់ កុសលចិត្ត ។ បទថា **បរិយាទាយតិដ្ឋន្តិ** បានដល់ គ្របសង្កត់ហើយតាំងនៅ ។ បទថា **ឧត្តាសវា** បានដល់ មាន

សេចក្ដីតក់ស្លុត ។ បទថា **វិឃាតវា** បានដល់ មានសេចក្ដីចង្អៀតចង្អល់ចិត្ត គឺ មានសេចក្ដីទុក្ខ ។ បទថា **អបេក្ខវា** បានដល់ មានសេចក្ដីអាល័យ ។ បទថា **ឧបាទាយ ច បរិតស្សតិ** បានដល់ ជាអ្នកឈ្មោះថា តក់ស្លុត ព្រោះប្រកាន់ ។

[៣៣] បទថា **ន រូបវិបរិណាមានុបរិវត្តិ** បានដល់ កម្មវិញ្ញាណទាំងឡាយមិនមានដល់ព្រះខីណាស្រព ព្រោះដូច្នោះ ការនិយាយថា ការវិលទៅតាមសេចក្ដីបែកធ្លាយនៃរូប រមែងមិនមាន ដូច្នេះទើបត្រឹមត្រូវ ។

ចប់អដ្ឋកថា ឧបាទានបរិតស្សនាសូត្រទី ៧

# អ ដ្ឋ ក ថា

## ឧបាទានបរិតស្សនាសូត្រទី ៨

[៣៤] ក្នុង ទុតិយឧបាទានបរិតស្សនាសូត្រទី ៨ ព្រះមានព្រះភាគទ្រង់សម្តែងព្រះធម៌ទេសនាដោយអំណាច តណ្ហា មានះ និងទិដ្ឋិ ។ ព្រះអដ្ឋកថាចារ្យ ត្រាស់ចំពោះវដ្ដៈ និងវិវដ្ដៈក្នុងសូត្រទាំង ៤ តាមលំដាប់ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ឧបាទានបរិតស្សនាសូត្រទី ៨

# អ ដ្ឋ ក ថា

## អតីតានាគតបច្ចុប្បន្នសូត្រទី ១

*ក្នុង កាលត្តយអនិច្ចសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៦] បទថា **កោ បន វាទោ បច្ចុប្បន្នស្ស** សេចក្តីថា ក្នុងបច្ចុប្បន្ន មិនចាំបាច់ពោលដល់ឡើយ ។ រូបនុ៎ះ ក៏គង់ជារបស់មិនទៀងនុ៎ះឯង ។ បាន ឮថា ភិក្ខុទាំងនោះកំណត់ថា រូបដែលជាអតីត អនាគតមិនទៀង ទើបលំបាក ក្នុងបច្ចុប្បន្ន ។ លំដាប់នោះ កាលភិក្ខុទាំងនោះពោលដល់រូបដែលជាអតីត និងអនាគតក្រៅពីរូបបច្ចុប្បន្ននេះថា រូបដែលជាបច្ចុប្បន្ន ជារបស់មិនទៀង ដូច្នេះ ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យរបស់ភិក្ខុទាំងនោះនឹងត្រាស់ដឹងបាន ទើបទ្រង់សម្តែងព្រះធម៌ទេសនានេះតាមអធ្យាស្រ័យរបស់បុគ្គល ។*

ចប់អដ្ឋកថា អតីតានាគតបច្ចុប្បន្នសូត្រទី ១

# អ ដ្ឋ ក ថា

## អតីតានាគតបច្ចុប្បន្នសូត្រទី ១-១១

[៣៧-៣៨] *សូត្រទី ១ និងសូត្រទី ១១ ព្រះមានព្រះភាគ ត្រាស់តាមអជ្ឈាស្រ័យរបស់បុគ្គលបែបនោះឲ្យកាន់តែពិសេសឡើង ដោយបទថា ទុក្ខំ អនត្តា ដូច្នេះ ។*

ចប់អដ្ឋកថា អតីតានាគតបច្ចុប្បន្នសូត្រទី ១-១១

## ចប់នកុលបិតុវគ្គទី ១

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថា នកុលបិតុសូត្រ
២-អដ្ឋកថា ទេវទហសូត្រ
៣-អដ្ឋកថា ហាលិទ្ទិកានិសូត្រទី ១
៤-អដ្ឋកថា ហាលិទ្ទិកានិសូត្រទី ២
៥-អដ្ឋកថា សមាធិសូត្រ
៦-អដ្ឋកថា បដិសល្លានសូត្រ
៧-អដ្ឋកថា បរិតស្សនាសូត្រទី ១
៨-អដ្ឋកថា បរិតស្សនាសូត្រទី ២
៩-អដ្ឋកថា អតីតានាគតប្បច្ចុប្បន្នសូត្រទី ១
១០-អដ្ឋកថា អតីតានាគតប្បច្ចុប្បន្នសូត្រទី ១-១១

# អនិច្ចវគ្គទី ២

## អ ដ្ឋ ក ថា

## អានន្ទសូត្រទី ១-៩

[៣៩-៤៧] *សូត្រទី ១ ដល់ទី ៩ មិនមានអដ្ឋកថា ។*

# អ ដ្ឋ ក ថា

## អានន្ទសូត្រទី ១០

[៤៨] ព្រះសូត្រចុងក្រោយក្នុង អនិច្ចវគ្គ ប្រព្រឹត្តទៅដោយអំណាចពាក្យសួរបទដ៏សេស ព្រះអង្គទ្រង់សម្តែងដោយអំណាចនៃអ្នកមានបញ្ញាត្រាស់ដឹង ដោយប្រការនោះៗ ។

ចប់អដ្ឋកថា អានន្ទសូត្រទី ១០

## ចប់អនិច្ចវគ្គទី ២

### រួមក្នុងវគ្គនេះមាន ១ អដ្ឋកថា

១-អដ្ឋកថា អានន្ទសូត្រទី ១០

# ភារវគ្គទី ៣

## អ ដ្ឋ ក ថា

### ភារសូត្រទី ១

ភារសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤៩] *បញ្ចុទានក្ខន្ធាតិស្ស វចនីយំ* កាត់ជា *បញ្ចុបាទានក្ខន្ធា ឥតិ អស្ស វចនីយំ* សេចក្តីថា ជាប្រការដែលគប្បីត្រាស់យ៉ាងនោះ ។ បទថា *អយំ វុច្ចតិ ភិក្ខវេ ភារោ* សេចក្តីថា ឧបាទានក្ខន្ធ ៥ លោកពោលថា ជាភារៈ ។ សួរថា ដោយអត្ថដូចម្តេច ? ឆ្លើយថា ដោយអត្ថថា ជាភារៈចាំបាច់ត្រូវរក្សា ។ ពិតហើយ ឧបាទានក្ខន្ធទាំង ៥ នោះ ចាំបាច់ត្រូវរក្សាដោយការឲ្យឈរ ឲ្យដើរ ឲ្យអង្គុយ ឲ្យដេក ឲ្យងូតទឹក តាក់តែងខ្លួន ឲ្យទំពារ ឲ្យស៊ីជាដើម ទើបឈ្មោះថា ជាភារៈ (របស់ធ្ងន់) ព្រោះដូច្នោះ លោកទើបហៅថា *ភារៈ* ព្រោះអត្ថថា ជាភារៈដែលចាំបាច់ត្រូវរក្សា ។

[៥០] បទថា *ឯវំ នាមោ* បានដល់ មានឈ្មោះជាដើមថា តិស្សៈ ថា

ទត្តៈ បទថា **ឯវំគោត្តោ** បានដល់ មានគោត្រជាដើមថា កច្ចាយនគោត្រ វច្ឆាយនគោត្រ ។ ដូច្នោះ ទ្រង់សម្តែងបុគ្គលដែលសម្រេចត្រឹមតែវោហារ ឲ្យឈ្មោះថា **ភារហារៈ** (អ្នកទទួលភារៈ) ។ ពិតណាស់ បុគ្គលលើកខន្ធភារៈឡើងក្នុងខណៈបដិសន្ធិនោះឯង ហើយឲ្យខន្ធនេះ ងូត បរិភោគ អង្គុយ ដេកលើគ្រែ និងតាំងដែលទន់ ហើយរក្សា ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ ដរាបដល់អស់ជីវិត ហើយលះបង់ចោលក្នុងចុតិខណៈ កាន់យកខន្ធដទៃក្នុងបដិសន្ធិខណៈទៀត ព្រោះដូច្នោះទើបឈ្មោះថា **អ្នកទទួលភារៈ** ។

[៥១] បទថា **បោនោព្ភវិកា** បានដល់ ដែលកើតក្នុងភពថ្មី ។ បទថា **នន្ទិរាគសហគតា** បានដល់ ដល់កាពតែមួយជាមួយនន្ទិរាគៈនុ៎ះឯង ។ ក្នុងទីនេះ លោកបំណងយកការកើតព្រមជាមួយនន្ទិរាគៈនោះ ។ បទថា **តត្រតត្រាភិនន្ទិនី** បានដល់ មានប្រក្រតីត្រេកអរក្នុងទីកើត ឬក្នុងអារម្មណ៍ មានរូបជាដើមនោះៗ ។ ក្នុងកាមតណ្ហាជាដើម សេចក្តីត្រេកអរដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ឈ្មោះថា **កាមតណ្ហា** សេចក្តីត្រេកអរក្នុងរូបភព និងអរូបភព សេចក្តីជាប់ជំពាក់ក្នុងឈាន សេចក្តីត្រេកអរដែលកើតព្រមដោយសស្សតទិដ្ឋិ នេះឈ្មោះថា **ភវតណ្ហា** សេចក្តីត្រេកអរដែលកើតព្រមជាមួយឧច្ឆេទទិដ្ឋិ ឈ្មោះថា **វិភវតណ្ហា** ។ បទថា **ភារាទានំ** បានដល់ ការចាប់យក

ភារៈ ។ ពិតហើយ បុគ្គលនេះ រមែងចាប់យកភារៈដោយតណ្ហា ។

[៥២] បទថា **អសេសវិរាគនិរោធោ** ជាដើម ជាវេវចនៈនឹងនិព្វាន នោះឯង ។ ពិតណាស់ តណ្ហាមកដល់ព្រះនិព្វាននោះហើយ រមែងប្រាសចាក សេចក្តីត្រេកអរ រមែងរលត់ រមែងលះបង់ រមែងរួចស្រឡះ រមែងរួចផុត ដោយមិនមានចំណែកសល់ ក៏ក្នុងព្រះនិព្វាននេះមិនមានអាល័យ គឺ កាម ឬ អាល័យ គឺ ទិដ្ឋិ ដូច្នោះ ព្រះនិព្វានទើបបានឈ្មោះទាំងនេះ ។

[៥៣] បទថា **សមូលំ តណ្ហំ** សេចក្តីថា អវិជ្ជា ឈ្មោះថា ជាមូល របស់តណ្ហា ។ បទថា **អព្ពុយ្ហ** បានដល់ ដកតណ្ហានោះ ព្រមទាំងឫសដោយ អរហត្តមគ្គ ។ បទថា **និច្ឆាតោ បរិនិព្វុតោ** សេចក្តីថា អ្នកចេញចាកតណ្ហា នឹងហៅថា អ្នកបរិនិព្វានហើយ ក៏គួរ ។

ចប់អដ្ឋកថា ភារសូត្រទី ១

# អ ដ្ឋ ក ថា

## បរិញ្ញាសូត្រទី ២

ក្នុង **បរិញ្ញាសូត្រទី ២** មានវិនិច្ឆ័យដូចតទៅនេះ ៖

[៥៤] បទថា **បរិញ្ញេយ្យេ** ប្រែថា គប្បីកំណត់ដឹង អធិប្បាយថា គប្បីឈានកន្លងដោយល្អ ។ បទថា **បរិញ្ញំ** បានដល់ កំណត់ដឹងកន្លងចំណែក អធិប្បាយថា ឈានកន្លងដោយល្អ ។

[៥៥] បទថា **រាគក្ខយោ** ជាដើម ជាឈ្មោះរបស់ព្រះនិព្វាន ។ ពិតណាស់ ព្រះនិព្វាននោះ ឈ្មោះថា កំណត់ដឹងកន្លងចំណែក ។

ចប់អដ្ឋកថា បរិញ្ញាសូត្រទី២

# អ ដ្ឋ ក ថា

## បរិជានសូត្រទី ៣

[៥៦] ក្នុង *បរិជានសូត្រទី ៣* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៥៧] *បទថា **អភិជានំ** បានដល់ ដឹងច្បាស់ ដោយបទនេះ លោកពោលសំដៅយក **ញាតបរិញ្ញា** បទទី ២ លោកពោលសំដៅយក **តិរណបរិញ្ញា** បទទី ៣ និងទី ៤ លោកពោលសំដៅយក **បហានបរិញ្ញា** រួមសេចក្តីមក ក្នុងសូត្រនេះ លោកពោលបរិញ្ញា ៣ យ៉ាងនេះឯង ។*

ចប់អដ្ឋកថា បរិជានសូត្រទី ៣

# អ ដ្ឋ ក ថា

## ឆន្ទរាគសូត្រទី ៤-៩

[៥៨-៦៧] *សូត្រទី ៤ ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយក្នុងធាតុសំយុត្តនុ៎ះឯង ។ តែក្នុងទីនេះ លោកពោលសច្ចៈ ៤ ទុកក្នុងសូត្រទី ៥ ទី ៦ និងទី ៧ ក្នុងធាតុសំយុត្តនោះ តាមលំដាប់ ។ ក្នុងសូត្រទី ៩ លោកពោលវដ្តៈ និងនិព្វាន ។*

ចប់អដ្ឋកថា ឆន្ទរាគសូត្រទី៤-៩

# អ ដ្ឋ ក ថា

## អឃមូលសូត្រទី ១០

*ក្នុង* ***អឃមូលសូត្រទី ១០*** *មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៦៨] *បទថា* ***អឃំ*** *បានដល់ ទុក្ខ ។ ក្នុងទីនេះ លោកពោលទុក្ខលក្ខណៈប៉ុណ្ណោះ ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា អឃមូលសូត្រទី ១០

# អ ដ្ឋ ក ថា

## បភង្គុសូត្រទី ១១

*ក្នុង បភង្គុសូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៧០] បទថា បភង្គុ បានដល់ មានការបែកធ្លាយជាសភាវៈ ។ ក្នុងទីនេះ ត្រាស់ដល់អនិច្ចលក្ខណៈប៉ុណ្ណោះ ដោយប្រការដូច្នេះឯង ។*

ចប់អដ្ឋកថា បភង្គុសូត្រទី ១១

## ចប់ភារវគ្គទី ៣

### រួមក្នុងវគ្គនេះមាន ១១ អដ្ឋកថា

១-អដ្ឋកថា ភារៈសូត្រ
២-អដ្ឋកថា បរិញ្ញាសូត្រ
៣-អដ្ឋកថា បរិជានសូត្រ
៤-អដ្ឋកថា ឆន្ទរាគសូត្រទី ៤-៩
១០-អដ្ឋកថា អឃសូត្រ
១១-អដ្ឋកថា បភង្គុសូត្រ

# ឧត្បាទកវគ្គទី ៤

## អ ដ្ឋ ក ថា

## ឧត្បាទកសូត្រទី ១

[៧១] *បឋមឧត្បាទកសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*បទថា បជហថ បានដល់ ចូរលះបង់ ដោយការលះបង់ឆន្ទរាគៈ ។*

[៧២] *ក្នុងវគ្គ មានស្នោជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖*

*ដើមត្នោត និងដូងជាដើម មានស្រាយខាងក្នុង មានខ្លឹមខាងក្រៅ ឈ្មោះថា ស្នោ ។ ដើមគគី ដើមសាលៈ និងដើមត្រយឹងជាដើម មានខ្លឹមខាងក្នុង មានស្រាយខាងក្រៅ ឈ្មោះថា ឈើ ។ មែកឈើដែលដុះចេញទៅដូចដៃដើមឈើ ឈ្មោះថា មែកឈើ ។ ស្លឹកត្នោត និងស្លឹកដូងជាដើម ឈ្មោះថា ស្លឹកឈើ ។*

ចប់អដ្ឋកថា បឋមឧត្បាទកសូត្រទី ១

# អ ដ្ឋ ក ថា

## ទុតិយនត្ថុម្ហាកសូត្រទី ២

[៧៣] *ទុតិយនត្ថុម្ហាកសូត្រទី ២ ទ្រង់វៀរឧបមាចេញ ហើយត្រាស់តាមអធ្យាស្រ័យរបស់បុគ្គលដែលគប្បីត្រាស់ដឹង ។*

ចប់អដ្ឋកថា ទុតិយនត្ថុម្ហាកសូត្រទី២

# អ ដ្ឋ ក ថា

## អញ្ញត្រភិក្ខុសូត្រទី ១

ក្នុង *អញ្ញត្រភិក្ខុសូត្រទី ១* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៧៤] បទថា *រូបញ្ចេ ភន្តេ អនុសេតិ* សេចក្តីថា ផ្តេកផ្តិតដល់រូបណាមួយ ។ បទថា **តេន សង្ខំ គច្ឆតិ** សេចក្តីថា ផ្តេកផ្តិតដល់រូបនោះ ដោយការផ្តេកផ្តិតណាព្រោះកាមរាគៈជាដើម ដោយការផ្តេកផ្តិតនោះឯង រមែងដល់ការរាប់ គឺ បញ្ញត្តិថា ស្រឡាញ់ ក្រោធ វង្វេង ។ បទថា **ន តេន សង្ខំ គច្ឆតិ** សេចក្តីថា ដោយការផ្តេកផ្តិតដែលមិនពិតនោះ រមែងមិនដល់ការរាប់ថា ស្រឡាញ់ ក្រោធ វង្វេង ។

ចប់អដ្ឋកថា អញ្ញត្រភិក្ខុសូត្រទី ១

# អ ដ្ឋ ក ថា

## ទុតិយអញ្ញត្រភិក្ខុសុត្រទី ២

*ក្នុង អញ្ញត្រភិក្ខុសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៧៧] បទថា **តំ អនុមិយ្យតិ** សេចក្ដីថា រូបដែលគេផ្ដេកផ្ដិតនោះ រមែងស្លាប់ទៅតាមការផ្ដេកផ្ដិតដែលកំពុងស្លាប់ទៅ ព្រោះថា កាលអារម្មណ៍បែកធ្លាយ ធម៌ដែលមានរូបនោះជាអារម្មណ៍ រមែងតាំងនៅមិនបាន ។ បទថា **យំ អនុមិយ្យតិ** សេចក្ដីថា រូបណាស្លាប់ទៅជាមួយការផ្ដេកផ្ដិតណា ។ បទថា **តេន សង្ខំ គច្ឆតិ** សេចក្ដីថា ដោយការផ្ដេកផ្ដិតនោះ បុគ្គលរមែងដល់ការរាប់ថា ស្រឡាញ់ ក្រោធ វង្វេង ។ម្យ៉ាងទៀត ពាក្យថា **យំ** ជាតតិយាវិភត្តិ សេចក្ដីថា បុគ្គលរមែងដល់ការរាប់ថា ស្រឡាញ់ ក្រោធ វង្វេង ដោយការផ្ដេកផ្ដិតដល់រូបដែលស្លាប់ទៅនោះ ។*

ចប់អដ្ឋកថា ទុតិយអញ្ញត្រភិក្ខុសូត្រទី២

# អ ដ្ឋ ក ថា

## បឋមអានន្ទសូត្រទី ៥

ក្នុង បឋមអានន្ទសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៧៩] បទថា ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ សេចក្ដីថា កាលរូបតាំងនៅ គឺ រស់នៅ ជរារមែងប្រាកដ ។ ក៏ពាក្យថា ឋិតិ ជាឈ្មោះនៃការអនុបាល ពោលគឺ ជីវិតិន្ទ្រិយ ។ ពាក្យថា អញ្ញថត្តំ ជាឈ្មោះរបស់ជរា ។ ដោយហេតុនោះបុរាណាចារ្យទាំងឡាយ ទើបពោលថា ៖

ឧប្បាទោ ជាតិ អក្ខាតោ　　ភង្គោ វុត្តោ វយោតិ ច

អញ្ញថត្តំ ជរា វុត្តា　　ឋិតិ ច អនុបាលនា ។

ការកើតឡើង ហៅថា ជាតិ

សេចក្ដីរលត់ ហៅថា វយៈ

សេចក្ដីប្រែប្រួល ហៅថា ជរា

ការរក្សា ហៅថា ឋិតិ ។

ខន្ធមួយៗ មានលក្ខណៈ ៣ យ៉ាង គឺ ឧប្បាទៈ ជរា និងភង្គៈ ដោយប្រការដូច្នេះ ដែលព្រះអង្គទ្រង់សំដៅយក ទើបត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ

សង្ខតលក្ខណៈនៃសង្ខតៈទាំងនេះមាន ៣ យ៉ាង ដូច្នេះ ។ ក្នុងពាក្យនោះ ដែលឈ្មោះថា សង្ខតៈ បានដល់ សង្ខារប្រភេទណាមួយដែលកើតពីបច្ច័យ ។ តែសង្ខារមិនមែនជាលក្ខណៈ និងលក្ខណៈក៏មិនមែនសង្ខារ តែថាវៀរសង្ខារចេញ នរណាៗ មិនអាចនឹងបញ្ញត្តិលក្ខណៈបាន សូម្បីវៀរលក្ខណៈចេញ នរណាៗ ក៏មិនអាចបញ្ញត្តសង្ខារបាន ។ តែសង្ខារ ក៏រមែងប្រាកដដោយលក្ខណៈ ដោយប្រការដូច្នេះ ។

ឧបមាដូចជា មេគោនុ៎ះឯង មិនមែនជាលក្ខណៈ ។ លក្ខណៈនុ៎ះឯង មិនមែនជាមេគោ ។ តែវៀរមេគោចេញ ក៏មិនអាចបញ្ញត្តិលក្ខណៈបាន សូម្បីវៀរលក្ខណៈចេញ ក៏មិនអាចបញ្ញត្តិមេគោបាន តែមេគោ រមែងប្រាកដដោយលក្ខណៈ យ៉ាងណា ការឧបមេយ្យនេះក៏គប្បីជ្រាបដូច្នោះ ។

បណ្តាខណៈទាំង ៣ នោះ ក្នុងឧប្បាទខណៈនៃសង្ខារទាំងឡាយ សង្ខារក្តី ឧប្បាទលក្ខណៈក្តី ខណៈនៃកាលសង្ខារនោះក្តី រមែងប្រាកដ ។ កាលពោលថា **ឧប្បាទោបិ** (រមែងកើតឡើង) សង្ខារក្តី ជរាលក្ខណៈក្តី ខណៈនៃកាលសង្ខារនោះ រមែងប្រាកដ ។ កាលពោលថា **ឧប្បាទោបិ** សង្ខារ (នាំទៅ) ក្តី ជរាខណៈក្តី ខណៈនៃកាលសង្ខារក្តី រមែងប្រាកដ ។ ក្នុងលក្ខណៈគឺ ការបែកធ្លាយ (ភង្គលក្ខណៈ) សង្ខារក្តី សង្ខារលក្ខណៈក្តី ខណៈនៃកាល

សង្ខារនោះក្តី រមែងប្រាកដ ។ តែអាចារ្យពួកមួយពោលថា ដែលឈ្មោះថា ជរាខណៈនៃអរូបធម៌ទាំងឡាយ នរណាៗ មិនអាចបញ្ញត្តិបាន ចំណែកព្រះសម្មាសម្ពុទ្ធកាលត្រាស់ថា ការកើតឡើងនៃវេទនា រមែងប្រាកដ ការរលត់នៃវេទនារមែងប្រាកដ កាលវេទនាតាំងនៅ សេចក្តីប្រែប្រួលរមែងប្រាកដ ដូច្នេះ ឈ្មោះថា ទ្រង់បញ្ញត្តិលក្ខណៈ ៣ នៃអរូបធម៌ក្តី អរូបធម៌រមែងមានលក្ខណៈទាំង ៣ នោះ ព្រោះអាស្រ័យខណៈបច្ចុប្បន្ន កាលពោលដូច្នេះហើយ ទើបសម្រេចសេចក្តីនោះតាមអាចរិយគាថា នេះថា ៖

អត្ថិតា សព្វធម្មានំ ឋិតិ នាម បវុច្ចតិ
តស្សេវ ភេទោ មរណំ សព្វទា សព្វបាណិនំ

សភាពនៃធម៌ទាំងពួងជាបច្ចុប្បន្ន លោកហៅថា
**ឋិតិខណៈ** ការបែកធ្លាយនៃរូបនោះឯងរបស់សព្វ
សត្វក្នុងគ្រប់កាល ហៅថា **មរណៈ** ដូច្នេះ ។

មួយទៀត លោកនឹងពោលថា ការតាំងនៅ ដោយអំណាចសន្តតិ (ការបន្ត) គប្បីជ្រាបថា **ឋិតិ** ។ ក៏ព្រោះហេតុដែលក្នុងព្រះសូត្រនេះ មិនមានសេចក្តីប្លែកគ្នា ដូច្នោះ តាមមតិរបស់អាចារ្យក៏មិនគប្បីជកព្រះសូត្រនេះ គប្បីធ្វើព្រះសូត្រនេះប៉ុណ្ណោះជាសម្គាល់ ។

ចប់អដ្ឋកថា បឋមអានន្ទសូត្រទី ៥

# អ ដ្ឋ ក ថា

## ទុតិយអានន្ទសូត្រទី ៦

[៨១] ក្នុង *ទុតិយអានន្ទសូត្រទី ៦ មានសេចក្ដីងាយទាំងនោះឯង ។*

ចប់អដ្ឋកថា ទុតិយអានន្ទសូត្រទី៦

# អ ដ្ឋ ក ថា

## អនុធម្មសូត្រទី ១

ក្នុង **អនុធម្មសូត្រទី ១** មានវិនិច្ឆ័យដូចតទៅនេះ ៖

[៨៣] បទថា **ធម្មានុធម្មប្បដិបន្នស្ស** សេចក្តីថា អ្នកបដិបត្តិបុព្វភាគ-បដិបទា ដែលជាធម៌សមគួរដល់លោកុត្តរធម៌ ៩ ។ បទថា **អយមនុធម្មោ** សេចក្តីថា ធម៌នេះ ជាអនុលោមធម៌ ។ បទថា **និព្វិទាពហុលោ** បានដល់ជាអ្នកច្រើនទៅដោយសេចក្តីនឿយណាយ ។ បទថា **បរិជានាតិ** បានដល់កំណត់ដឹងដោយបរិញ្ញា ៣ ។ បទថា **បរិមុច្ចតិ** បានដល់ រួចផុតដោយបហាន-ប្បរិញ្ញា ដែលកើតឡើងក្នុងខណៈនៃមគ្គ ។

ក្នុងព្រះសូត្រនេះ ទ្រង់ត្រាស់ចំពោះមគ្គប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ ក្នុងបរិញ្ញា ៣ ក្រៅអំពីនេះ ក៏ដូចគ្នា ។ តែក្នុងទីនេះ លោកមិនកំណត់យកអនុបស្សនា កំណត់យកក្នុងបរិញ្ញាទាំង ៣ នោះ ព្រោះដូច្នោះ សូម្បីក្នុងទីនេះ អនុបស្សនានោះ គប្បីកំណត់តាមដែលលោកកំណត់ទុកហើយក្នុងបរិញ្ញា ៣ នុ៎ះឯង ។ ពិតហើយ ក្នុងបរិញ្ញាទាំង ៣ នោះ វៀរអនុបស្សនាណាមួយចេញ នរណាៗ មិនអាចនឹងនឿយណាយ ឬកំណត់ដឹងបាន ។

ចប់អដ្ឋកថា អនុធម្មសូត្រទី ១

## ចប់នតុម្ហាកវគ្គទី ៤

### រួមក្នុងវគ្គនេះមាន ៦ អដ្ឋកថា

១-អដ្ឋកថា នតុម្ហាកសូត្រទី ១

២-អដ្ឋកថា ភិក្ខុសូត្រទី ១

៣-អដ្ឋកថា ភិក្ខុសូត្រទី ២

៤-អដ្ឋកថា អានន្ទសូត្រទី ១

៥-អដ្ឋកថា អានន្ទសូត្រទី ២

៦-អដ្ឋកថា អនុធម្មសូត្រទី ១

# អត្តទីបវគ្គទី ៥

## អ ដ្ឋ ក ថា

## អត្តទីបសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៨៧] បទថា **អត្តទីបា** សេចក្តីថា អ្នកទាំងឡាយចូរធ្វើខ្លួនឲ្យជាទីពឹង ជាទីពំនាក់ ជាទីពួន ជាគតិ ជាទីទៅក្នុងខាងមុខ ជាទីពឹង ហើយនៅអាស្រ័យចុះ ។ បទថា **អត្តសរណា** នេះ ជាវេវចនៈរបស់បទថា **អត្តទីបា** នោះឯង ។ បទថា **អនញ្ញសរណា** នេះ ជាពាក្យហាមពឹងដល់អ្នកដទៃ ព្រោះថា អ្នកដទៃជាទីពឹងមិនបាន ព្រោះបុគ្គលម្នាក់នឹងព្យាយាមធ្វើឲ្យបុគ្គលម្នាក់ទៀត បរិសុទ្ធិមិនបាន សមដូចដែលទ្រង់ត្រាស់ទុកថា ៖*

*ខ្លួនទុំះឯង ជាទីពឹងរបស់ខ្លួន*
*អ្នកដទៃណា នឹងជាទីពឹងបាន*

*ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **អនញ្ញសរណា** មិន*

មានវត្ថុដទៃជាសរណៈ (កុំយកវត្ថុដទៃជាទីពឹង ទីរឭកឡើយ) ។

សួរថា ក៏ក្នុងទីនេះ អ្វីឈ្មោះថា ខ្លួន ?

ឆ្លើយថា ធម៌ដែលជាលោកិយៈ និងលោកុត្តរៈ (ឈ្មោះថាខ្លួន) ។

ដោយហេតុនោះឯង ព្រះអង្គទើបត្រាស់ថា **ធម្មទីបា ធម្មសរណា អនញ្ញសរណា** មានធម៌ជាទីពឹង មានធម៌ជាទីរឭក មិនមានវត្ថុដទៃជាទីពឹង ជាទីរឭក ដូច្នេះ ។ បទថា **យោនិ** បានដល់ ហេតុ ដូចក្នុងប្រយោគមានជាដើមថា **យោនិ ហេសា ភូមិជផលស្ស អធិគមាយ** (នេះឯងជាហេតុឲ្យសម្រេចផលដែលកើតអំពីភូមិ) ។ បទថា **កឹបហោតិកា** បានដល់ មានអ្វីជាដែនកើត អធិប្បាយថា កើតអំពីអ្វី ។

[៨៨] បទថា **រូបស្ស ត្វេវ** នេះ ទ្រង់ប្រារព្ធដើម្បីសម្ដែងការលះបង់សេចក្ដីសោកជាដើម ទាំងនោះឯង។

បទថា **ន បរិតស្សតិ** បានដល់ មិនក្ដៅក្រហាយ គឺ មិនតក់ស្លុត ។ បទថា **តទង្គនិព្វុតោ** បានដល់ រលត់ដោយអង្គនោះៗ ព្រោះរំលត់កិលេសទាំងឡាយដោយអង្គ គឺ វិបស្សនានោះ ។

ក្នុងព្រះសូត្រនេះ ទ្រង់ត្រាស់ចំពោះវិបស្សនាប៉ុណ្ណោះ ។

ចប់អដ្ឋកថា អត្តទីបសូត្រទី ១

# អ ដ្ឋ ក ថា

## បដិបទាសូត្រទី ២

ក្នុង បដិបទាសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៨៩] ក្នុងបទថា *ទុក្ខសមុទយគាមិនី សមនុបស្សនា* (ការពិចារណាឃើញនូវដំណើរឲ្យកើតឡើងនៃទុក្ខ) នេះ មានអធិប្បាយដូច្នេះថា ព្រោះទិដ្ឋិ-សមនុបស្សនា ដែលព្រះអង្គទ្រង់ត្រាស់យ៉ាងនេះ គឺ ពិចារណាឃើញរូបជាខ្លួន ឈ្មោះថា បដិបទាជាគ្រឿងកើតឡើងនៃសក្កាយៈដែលជាទុក្ខ ដូច្នោះទើបឈ្មោះថា *ទុក្ខសមុទយគាមិនី សមនុបស្សនា* ។

[៩០] មគ្គញ្ញាណ ៤ ព្រមដោយវិបស្សនា ត្រាស់ថា *សមនុបស្សនា* ក្នុងពាក្យនេះថា *ទុក្ខនិរោធគាមិនី សមនុបស្សនា* ដូច្នេះ ។ ក្នុងសូត្រនេះ ទ្រង់ត្រាស់ដល់វដ្តៈ និងវិវដ្តៈទុក ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា បដិបទាសូត្រទី ២

# អ ដ្ឋ ក ថា

## អនិច្ចសូត្រទី ៣

ក្នុង បឋមអនិច្ចសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៩១] បទថា **សម្មប្បញ្ញាយ ទដ្ឋព្វំ** សេចក្តីថា គប្បីឃើញដោយបញ្ញាដែលសម្បយុត្តដោយមគ្គព្រមដោយវិបស្សនា ។ បទថា **វិរជ្ជតិ វិមុច្ចតិ** បានដល់ រមែងប្រាសចាកតម្រេកក្នុងខណៈនៃមគ្គ រមែងរួចផុតក្នុងខណៈនៃផល ។ បទថា **អនុបាទាយ អាសវេហិ** សេចក្តីថា ព្រោះមិនប្រកាន់ ទើបរួចផុតចាកអាសវៈទាំងឡាយ ដែលរលត់ ដោយ (អនុប្បាទនិរោធ) ការរលត់មិនកើតឡើងទៀត ។

[៩២] បទថា **រូបធាតុយា** ជាដើម ត្រាស់ទុកដើម្បីសម្តែងបច្ចវេក្ខណញ្ញាណ ។ អាចារ្យពួកខ្លះពោលថា ដើម្បីសម្តែងបច្ចវេក្ខណញ្ញាណព្រមដោយផល ដូច្នេះក៏មាន ។ បទថា **ឋិតំ** បានដល់ តាំងនៅដោយភាពជាកិច្ចដែលនឹងគប្បីធ្វើឲ្យក្រៃលែងឡើង ។ បទថា **ឋិតត្តា សន្តុសិតំ** បានដល់ ត្រេកអរដោយការៈនៃគុណ ដែលនឹងគប្បីសម្រេច ។ បទថា **បច្ចត្តំយេវ បរិនិព្វាយតិ** បានដល់ រមែងបរិនិព្វានដោយខ្លួនឯង ។

ចប់អដ្ឋកថា បឋមអនិច្ចសូត្រទី ៣

# អ ដ្ឋ ក ថា

## ទុតិយអនិច្ចសូត្រទី ៤

ក្នុង *ទុតិយអនិច្ចសូត្រទី ២* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៩៣] បទថា **បុព្វន្តានុទិដ្ឋិយោ** សេចក្តីថា ទិដ្ឋិ ១៨ ដែលប្រព្រឹត្តទៅក្នុងទីបំផុតខាងដើម (អតីត:) មិនមាន ។ បទថា **អបរន្តានុទិដ្ឋិយោ** សេចក្តីថា ទិដ្ឋិ ៤៤ ដែលប្រព្រឹត្តទៅក្នុងទីបំផុតខាងចុង (អនាគត) មិនមាន ។ បទថា **ថាមសោ បរាមាសោ** សេចក្តីថា កម្លាំងនៃទិដ្ឋិ និងការស្ទាបអង្អែលនៃទិដ្ឋិមិនមាន ។ ដោយលំដាប់ពាក្យត្រឹមប៉ុណ្ណេះ គឺ ទ្រង់សម្តែងបឋមមគ្គហើយ ។

ឥឡូវនេះ កាលទ្រង់សម្តែងមគ្គ ៣ និងផល ៣ ព្រមដោយវិបស្សនា ទើបផ្តើមពាក្យមានជាដើមថា *រូបស្មឹ* ដូច្នេះ ។ មយ៉ាងទៀត ដែលឈ្មោះថា ទិដ្ឋិទាំងឡាយ លះបង់បានដោយវិបស្សនាទុំះឯង តែពាក្យនេះទ្រង់ផ្តើមដើម្បីសម្តែងមគ្គ ៤ ព្រមដោយវិបស្សនាថ្នាក់ខ្ពស់ ។

ចប់អដ្ឋកថា អនិច្ចសូត្រទី ២

# អ ដ្ឋ ក ថា

## សមនុបស្សនាសូត្រទី ៥

ក្នុង សមនុបស្សនាសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៩៤] បទថា **បញ្ចុបាទានក្ខន្ធេ សមនុបស្សន្តិ ឯតេសំ វា អញ្ញតរំ** សេចក្តីថា សមណៈ ឬព្រាហ្មណ៍ ការតាមឃើញបញ្ចក្ខន្ធដោយអំណាចនៃសេចក្តីប្រកាន់ខន្ធដែលបរិបូណ៌ ការតាមឃើញបណ្តាខន្ធទាំងនោះ ខន្ធណាមួយដោយអំណាចនៃសេចក្តីប្រកាន់ខន្ធដែលមិនបរិបូណ៌ ។ បទថា **ឥតិ អយញ្ចេវ សមនុបស្សនា** សេចក្តីថា ក៏អនុបស្សនានេះ ឈ្មោះថា **ទិដ្ឋិសមនុបស្សនា** ដោយប្រការដូច្នេះ ។ បទថា **អស្មីតិ ចស្ស អធិគតំ ហោតិ** សេចក្តីថា ធម៌ជាគ្រឿងយឺតយូរ ៣ យ៉ាង គឺ តណ្ហា មានះ និងទិដ្ឋិ ថាយើងមានហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ ៣ យ៉ាងនោះ ដែលមានតួសមនុបស្សនា ។ បទថា **បញ្ចន្នំ ឥន្ទ្រិយានំ អវក្កន្តិ ហោតិ** សេចក្តីថា កាលកិលេសជាតនោះមានហើយ ឥន្ទ្រិយ ៥ ដែលជាបច្ច័យនៃកម្មកិលេស រមែងកើត ។

ពាក្យថា **អត្ថិ ភិក្ខវេ មនោ** នេះ ទ្រង់ត្រាស់សំដៅយកចិត្តដែលមានធម្មជាអារម្មណ៍ ។ បទថា **ធម្មា** បានដល់ អារម្មណ៍ ។ បទថា **អវិជ្ជា-**

ធាតុ បានដល់ អវិជ្ជាក្នុងខណៈនៃជវនចិត្ត ។ បទថា **អវិជ្ជាសម្ផស្សជេន** បានដល់ កើតអំពីផស្សៈដែលសម្បយុត្តដោយអវិជ្ជា ។ ម្យ៉ាងទៀត បទថា **មនោ** បានដល់ ចិត្តដែលមានវិបាកជាអារម្មណ៍ក្នុងខណៈនៃភវង្គចិត្ត មនោ-ធាតុដែលជាកិរិយា ក្នុងខណៈនៃអាវជ្ជនចិត្ត និងធម៌ជាដើម ដែលមានប្រការដូចពោលហើយ ។ បទថា **អស្មីតិបិស្ស ហោតិ** សេចក្ដីថា គេបានប្រកាន់យ៉ាងនេះថា យើងមានហើយ ដោយអំណាចតណ្ហា មានះ ទិដ្ឋិ ។ ក្រៅអំពីនេះ ពាក្យថា **អយមហមស្មី** ព្រះអង្គទ្រង់កាន់យកធម៌ដែលជាអារម្មណ៍ មានរូបជាដើមណាមួយ ត្រាស់ដោយអំណាចអត្តទិដ្ឋិ (ប្រកាន់ថាជាខ្លួន) ថាជាយើង ។ ពាក្យថា **ភវិស្សំ** ត្រាស់ដោយអំណាចសស្សតទិដ្ឋិ (ប្រកាន់ថា វត្ថុគ្រប់យ៉ាងទៀង) , ពាក្យថា **ន ភវិស្សំ** ត្រាស់ដោយអំណាចឧច្ឆេទទិដ្ឋិ (ប្រកាន់ថា វត្ថុគ្រប់យ៉ាងដាច់សូន្យ) ។ ពាក្យទាំងអស់មាន **រូបី ភវិស្សំ** ជាដើម សំដៅយកសស្សតទិដ្ឋិប៉ុណ្ណោះ ។ បទថា **អថេត្ថ** សេចក្ដីថា បើដូច្នោះ គឺ កាលឥន្ទ្រិយទាំងនោះតាំងនៅដោយប្រការដូច្នេះឯង ។ បទថា **អវិជ្ជា បហីយតិ** សេចក្ដីថា យើងលះបង់អវិជ្ជាដែលជាតួមិនដឹងក្នុងសច្ចៈ ៤ ។ បទថា **វិជ្ជា ឧប្បជ្ជតិ** សេចក្ដីថា វិជ្ជាក្នុងអរហត្តមគ្គរមែងកើតឡើង ។

ក្នុងទីនេះ គប្បីជ្រាបវិនិច្ឆ័យយ៉ាងនេះ បទថា **អស្មិ** បានដល់ តណ្ហា

មានះ និងទិដ្ឋិ ។ អធិប្បាយថា វាងកម្ម និងឥន្ទ្រិយ ៥ ជាសន្ធិមួយ , វាង ឥន្ទ្រិយ ៥ រាប់ចិត្តដែលមានវិបាកជាអារម្មណ៍ដែលជាចំណែកឥន្ទ្រិយ ៥ ជាមួយ ចិត្តដែលមានកម្មជាអារម្មណ៍ ជាសន្ធិមួយ ។ ធម៌ជាគ្រឿងយឹតយូរ ៣ យ៉ាង ចាត់ជាអតីតអទ្ធា , ឥន្ទ្រិយជាដើម ចាត់ជាបច្ចុប្បន្នអទ្ធា , ក្នុងអទ្ធា ២ យ៉ាង នោះ ទ្រង់សម្តែងបច្ច័យនៃអនាគតអទ្ធា ផ្តើមពីចិត្តដែលមានកម្មជាអារម្មណ៍ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា សមនុបស្សនាសូត្រទី៥

# អ ដ្ឋ ក ថា

## បញ្ចក្ខន្ធសូត្រទី ៦

[៩៥] ក្នុង *បញ្ចក្ខន្ធសូត្រទី ៦* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៩៦] *រូបក្ខន្ធជាកាមាវចរ ខន្ធ ៤ ប្រព្រឹត្តទៅក្នុងភូមិ ៤ (កាមាវចរភូមិ រូបាវចរភូមិ អរូបាវចរភូមិ លោកុត្តរភូមិ) ។ បទថា* ***សាសវំ*** *បានដល់ជាបច្ច័យនៃអាសវៈដោយភាពជាអារម្មណ៍ ។ បទថា* ***ឧបាទានិយំ*** *បានដល់ជាបច្ច័យដល់ឧបាទាន ដោយភាពជាអារម្មណ៍យ៉ាងនោះដែរ ។ ក៏ក្នុងសេចក្តីនេះ មានអត្ថនៃពាក្យដូចតទៅនេះ ៖*

*រូប ឈ្មោះ* ***សាសវៈ*** *ព្រោះប្រព្រឹត្តទៅជាមួយនឹងអាសវៈទាំងឡាយដែលធ្វើជាអារម្មណ៍ឲ្យប្រព្រឹត្តទៅ ឈ្មោះថា* ***ជាបច្ច័យដល់ឧបាទាន*** *ព្រោះគប្បីប្រកាន់មាំ ។ ក្នុងទីនេះ* ***រូបក្ខន្ធ*** *លោកពោលថា ជាកាមាវចរៈ គឺ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស លោកពោលដោយអំណាចការប្រព្រឹត្តទៅនៃវិបស្សនា ។ ក្នុងទីនេះគប្បីជ្រាបវិនិច្ឆ័យយ៉ាងនេះ រូប ចាត់ចូលក្នុងខន្ធដោយអត្ថថា ជាគំនរ ,* ***វេទនា*** *ជាដើម ទាំងដែលមានអាសវៈ ទាំងដែលមិនមានអាសវៈ ចាត់ចូលក្នុងឧបាទានក្ខន្ធ ដោយអត្ថថា ជាគំនរធម៌ ដែលមាន*

*អាសវៈទាំងអស់ ចាត់ចូលក្នុងខន្ធដោយអត្ថថា ជាគំនរ ។ តែក្នុងទីនេះ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ចាត់ចូលក្នុងឧបាទានក្ខន្ធ ដោយអត្ថថា ជាគំនរធម៌ ដែលសាសវៈ ។*

ចប់អដ្ឋកថា បញ្ចក្ខន្ធសូត្រទី ៦

# អ ដ្ឋ ក ថា

## សោណសូត្រទី ៧-៨

*ក្នុង សោណសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៩៧] *បទថា សេយ្យោហមស្មិ សេចក្តីថា យើងជាអ្នកប្រសើរបំផុត ។*

*បទថា កិមញ្ញត្រ យថាភូតស្ស អទស្សនា សេចក្តីថា នឹងមានអ្វីយ៉ាងដទៃ ក្រៅអំពីការមិនឃើញធម៌តាមសេចក្តីពិត ។ អធិប្បាយថា ការមិនដឹង ការមិនឃើញទុំះឯងនឹងគប្បីមាន ។ ឥឡូវនេះព្រះមានព្រះភាគជាម្ចាស់កាលនឹងផ្តើមសម្តែងប្រភេទនៃវជិរៈ គឺ បរិវដ្ដៈ ៣ ដល់ព្រះសោណៈនោះ ទើបត្រាស់មានពាក្យជាដើមថា ម្នាលសោណៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច? សោណសូត្រទី ៨ មានអត្ថងាយយល់ទាំងអស់ ។*

ចប់អដ្ឋកថា សោណសូត្រទី ៧-៨

# អ ដ្ឋ ក ថា

## នន្ទិខយសូត្រទី ៩-១០

ក្នុងសូត្រទី ៩-១០ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១០៣] ពាក្យថា នន្ទិក្ខយា រាគក្ខយោ , រាគក្ខយា នន្ទិក្ខយោ ព្រោះសេចក្តីត្រេកត្រអាលអស់ទៅ រាគៈក៏អស់ទៅ ។ ព្រោះរាគៈអស់ទៅ សេចក្តីត្រេកត្រអាលក៏អស់ទៅនេះ សេចក្តីថា ទ្រង់ត្រាស់ទុកដើម្បីធ្វើមិនឲ្យផ្សេងអំពីអត្ថនៃពាក្យទាំងនេះថា នន្ទិ ឬថា រាគោ ។ ម្យ៉ាងទៀត បុគ្គលកាលនឿយណាយដោយនិព្វិទានុបស្សនា ឈ្មោះថា រមែងលះបង់នន្ទិ , កាលប្រាសចាកតម្រេកដោយវិរាគានុបស្សនា ឈ្មោះថា រមែងលះបង់រាគៈ ។

ដោយលំដាប់ពាក្យត្រឹមតែប៉ុណ្ណេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ឲ្យវិបស្សនាចប់ស្រេចហើយ ទ្រង់សម្តែងមគ្គចិត្តក្នុងទីនេះថា ព្រោះអស់រាគៈទើបអស់នន្ទិ ដូច្នេះ ហើយសម្តែងផលចិត្តថា ព្រោះអស់នន្ទិ និងរាគៈ ចិត្តក៏រួចផុតហើយ ។

ចប់អដ្ឋកថា នន្ទិខយសូត្រទី ៩-១០

# ចប់អត្តទីបវគ្គទី ៥

## រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថា អត្តទីបសូត្រ
២-អដ្ឋកថា បដិបទាសូត្រ
៣-អដ្ឋកថា អនិច្ចសូត្រទី ៣
៤-អដ្ឋកថា អនិច្ចសូត្រទី ៤
៥-អដ្ឋកថា សមនុបស្សនាសូត្រ
៦-អដ្ឋកថា បញ្ចក្ខន្ធសូត្រ
៧-អដ្ឋកថា សោណសូត្រទី ៧-៨
៨-អដ្ឋកថា ឧប្បាទយសូត្រទី ៩-១០

## រួមវគ្គដែលមានក្នុងមូលបណ្ណាសកៈ

១-នកុលបិតុវគ្គ
២-អនិច្ចវគ្គ
៣-ភារវគ្គ
៤-នតុម្ហាកវគ្គ
៥-អត្តទីបវគ្គ

# មជ្ឈិមបណ្ណាសក

# ឧបាយវគ្គ

## អ ដ្ឋ ក ថា

### ឧបាយសូត្រទី ១

*ក្នុង **ឧបាយសូត្រទី ១** នៃឧបាយវគ្គមានវិនិច្ឆ័យដូចតទៅនេះ ៖*

[១០៥] *បទថា **ឧបាយោ** បានដល់ ចូលដល់ខន្ធ ៥ គឺ ប្រកាន់មាំដោយអំណាចតណ្ហា មានះ និងទិដ្ឋិ ។ បទថា **វិញ្ញាណំ** បានដល់ កម្មវិញ្ញាណ (វិញ្ញាណដែលកើតពីកម្ម) ។ បទថា **អាបជ្ជេយ្យ** បានដល់ គប្បីដល់នូវសេចក្ដីចម្រើនជាដើម ដោយភាពជាធម្មជាតិអាចឲ្យកម្មស្ទុះទៅហើយរាំងបដិសន្ធិចិត្តបាន ។ ហេតុក្នុងការមិនកាន់យកបទថា **វិញ្ញាណូបាយំ** លោកបានពោលទុកហើយនុ៎ះឯង ។ បទថា **វោច្ឆិជ្ជតារម្មណំ** សេចក្ដីថា អារម្មណ៍រមែងដាច់ចេញ ព្រោះមិនអាចរាំងបដិសន្ធិបាន ។ បទថា **បតិដ្ឋា** វិញ្ញា-*

*ណស្ស សេចក្តីថា កម្មវិញ្ញាណ រមែងមិនមានទីពឹង ។ បទថា* ***តទប្បតិដ្ឋិតំ*** *កាត់បទជា* ***តំ អប្បតិដ្ឋិតំ*** *។ បទថា* ***អនភិសង្ខច្ច វិមុត្តំ*** *សេចក្តីថា មិនតាក់តែងបដិសន្ធិ ព្រោះរួចផុតហើយ ។*

ចប់អដ្ឋកថា ឧទាយសូត្រទី ១

# អ ដ្ឋ ក ថា

## ពីជសូត្រទី ២

ក្នុង **ពីជសូត្រទី ២** មានវិនិច្ឆ័យដូចតទៅនេះ ៖

[១០៦] បទថា **ពីជជាតានិ** បានដល់ ពូជទាំងឡាយ ។ បទថា **មូលពីជំ** បានដល់ ពូជកើតពីមើម មើមលំពាន់ មើមប្រស់ ល្មៀត ខ្ញី ជាដើម ។ បទថា **ខន្ធពីជំ** បានដល់ ពូជកើតពីដើម មានដើមពោធិ ដើមជ្រៃជាដើម ។ បទថា **ផលុពីជំ** បានដល់ ពូជកើតពីថ្នាំង មានអំពៅ ឫស្សី ដើមបបុសជាដើម ។ បទថា **អគ្គពីជំ** បានដល់ ពូជកើតពីត្រួយ មានត្រកួន ជីរលីងលាក់ជាដើម ។ បទថា **ពីជពីជំ** បានដល់ ពូជកើតពីគ្រាប់ គឺ បុព្វ-ណ្ណជាត មានស្រូវសាលី និងស្រូវខ្សាយជាដើម និងអបរណ្ណជាត មានសណ្តែក-បាយ និងសណ្តែកកជមាសជាដើម ។ បទថា **អក្ខណ្ឌានិ** បានដល់ មិនបាក់តាំងពីវេលាដែលពូជបាក់ហើយ (ខូច) រមែងមិនសម្រេចប្រយោជន៍ដល់ពូជ ។ បទថា **អបូតិកានិ** បានដល់ មិនស្អុយ ព្រោះសើមដោយទឹក ។ ពិតណាស់ពូជដែលស្អុយ រមែងមិនសម្រេចប្រយោជន៍ដល់ពូជ ។ បទថា **អវាតាតប-ប្បតានិ** សេចក្តីថា មិនត្រូវខ្យល់ និងកំដៅថ្ងៃ គឺ ធ្វើពូជឲ្យខូច ។ ពិតណាស់

ពូជដែលខ្សោះមិនមានខ្លឹមជា រមែងមិនសម្រេចប្រយោជន៍ដល់ពូជ ។ បទថា **សារាទានិ** បានដល់ ពូជដែលមានប្រយោជន៍ គឺ ដែលមានខ្លឹម ពិតណាស់ ពូជដែលមិនមានខ្លឹម រមែងមិនសម្រេចប្រយោជន៍ដល់ពូជ ។ បទថា **សុខស-យិតានិ** បានដល់ រក្សាទុកដោយល្អរហូតបួនខែ ដោយទំនងដែលគេដាក់ទុកក្នុងជង្រុកទុំះឯង ។ បទថា **បឋវី** បានដល់ ផែនដីដែលជាទីតាំងនៅខាងក្រោម បទថា **អាបោ** បានដល់ ទឹកដែលកំណត់អំពីខាងលើ ។

[១០៧] បទថា **ចតស្សោ វិញ្ញាណដ្ឋិតិយោ** សេចក្ដីថា ខន្ធ ៤ មានរូបក្ខន្ធជាដើម ដែលជាអារម្មណ៍នៃកម្មវិញ្ញាណ ពិតហើយ ខន្ធទាំងនោះ ដូចគ្នានឹងបឋវីធាតុ ព្រោះជាធម្មជាតិតាំងនៅបាន ដោយអំណាចជាអារម្មណ៍ , នន្ទិ និងរាគៈ ដូចគ្នានឹងអាបោធាតុ ព្រោះអត្ថថា ជាជ័រ ។ បទថា **វិញ្ញាណំ សាហារំ** បានដល់ កម្មវិញ្ញាណព្រមទាំងបច្ច័យ , ពិតណាស់ កម្មវិញ្ញាណនោះ ដុះឡើងលើផែនដី គឺ អារម្មណ៍ ដូចពូជដុះឡើងលើផែនដី ដូច្នោះ ។

ចប់អដ្ឋកថា ពីជសូត្រទី ២

# អ ដ្ឋ ក ថា

## ឧទានសូត្រទី ៣

ក្នុង **ឧទានសូត្រទី ៣** មានវិនិច្ឆ័យដូចតទៅនេះ ៖

[១០៨] បទថា **ឧទានំ ឧទានេសិ** សេចក្តីថា ទ្រង់បន្លឺនូវឧទានដែលមានសោមនស្សដ៏មានកម្លាំងជាសមុដ្ឋាន ។ សួរថា ក៏សោមនស្សនោះកើតដល់ព្រះមានព្រះភាគព្រោះអាស្រ័យអ្វី ? ឆ្លើយថា ព្រោះអាស្រ័យការៈដែលសាសនាជាហេតុនាំសត្វចេញចាកទុក្ខ ។ យ៉ាងណា ? បានឮថា ព្រះអង្គទ្រង់មានព្រះតម្រិះថា ឧបនិស្ស័យមាន ៣ យ៉ាង គឺ **ទានូបនិស្ស័យ សីលូបនិស្ស័យ ភាវនូបនិស្ស័យ** ក្នុងឧបនិស្ស័យ ៣ យ៉ាងនោះ ទានូបនិស្ស័យនិងសីលូបនិស្ស័យ មានកម្លាំងខ្សោយ , ភាវនូបនិស្ស័យ មានកម្លាំងខ្លាំង ។ ពិតណាស់ ទានូបនិស្ស័យ និងសីលូបនិស្ស័យ រមែងញ៉ាំងសត្វឲ្យសម្រេចមគ្គ ៣ និងផល ៣ , ភាវនូបនិស្ស័យ ឲ្យសម្រេចព្រះអរហត្ត ភិក្ខុតាំងនៅក្នុងឧបនិស្ស័យដែលមានកម្លាំងខ្សោយ ប្រឹងប្រែង ព្យាយាមកាត់គ្រឿងចង គឺឱរម្ភាគិយសញ្ញោជនៈ ៥ បានហើយ រមែងធ្វើមគ្គ ៣ និងផល ៣ ឲ្យកើតដោយប្រការដូច្នេះ កាលព្រះអង្គទ្រង់រំពឹងថា គួរអស្ចារ្យ ព្រះសាសនាជា

និយ្យានិកៈ (នាំសត្វចេញចាកទុក្ខ) សោមនស្សនេះ រមែងកើតឡើង ។

ក្នុង ២ យ៉ាងនោះ ភិក្ខុតាំងនៅក្នុងឧបនិស្ស័យដែលមានកម្លាំងខ្សោយ ប្រឹងប្រែង ព្យាយាម រមែងសម្រេចមគ្គ ៣ ផល ៣ ដូច្នោះ កាលនឹងបង្ហាញសេចក្តីនេះ គប្បីជ្រាបរឿងព្រះមិលកត្ថេរ ដូចតទៅនេះ ៖

បានឮមកថា ក្នុងវេលានៅជាគ្រហស្ថ ព្រះថេរៈនោះចិញ្ចឹមជីវិតដោយការធ្វើបាណាតិបាត ធ្វើអន្ទាក់ទុកមួយរយ ដាក់ត្រង់រន្ធមួយរយកន្លែង ក្នុងព្រៃ ។ ក្រោយមកថ្ងៃមួយ គេទំពារស៊ីសាច់ដែលអាំងទុកលើរងើកភ្លើង ហើយដើរទៅក្នុងទីជិតអន្ទាក់ ត្រូវសេចក្តីស្រេកគ្របសង្កត់ ទើបទៅកាន់វិហាររបស់ព្រះថេរៈដែលគង់ក្នុងព្រៃមួយរូប បើកថ្នាំងទឹកផឹក ដែលតាំងនៅក្នុងទីមិនឆ្ងាយពីព្រះថេរៈ ដែលកំពុងចង្ក្រម ។ មិនបានឃើញទឹកសូម្បីត្រឹមតែសើមដៃ ។ គេក៏ក្រោធ ពោលថា ភិក្ខុ ភិក្ខុ ពួកលោកឆាន់ភោជនដែលគហបតីឲ្យហើយ ក៏ដេកលក់ទៅ មិនចាត់ចែងទឹកទុកសូម្បីត្រឹមតែប្រមាមដៃមួយ ក្នុងថ្នាំងទឹក នោះជាវត្ថុមិនត្រឹមត្រូវ ។ ព្រះថេរៈពោលថា អាត្មាបានតាំងថ្នាំងទឹកផឹកទុកពេញហើយ នេះតើមានហេតុអ្វីហ្ន៎ ដូច្នេះហើយ ទើបទៅត្រួតមើលឃើញថ្នាំងទឹកនៅពេញ ទើបជ្រមុជស័ង្ខសម្រាប់ដាក់ទឹកផឹកដរាបពេញ ឲ្យទៅគេ ។ គេផឹកទឹកដែលពេញស័ង្ខលើកទីពីរ គិតថា ដែលឈ្មោះថា ថ្នាំងពេញ

ដោយទឹកយ៉ាងនេះ អាស្រ័យអំពើរបស់យើងទើបកើតមាន ដូចជាក្បឿងក្តៅ ទៅក្នុងអនាគត អត្តភាពរបស់យើងនឹងជាយ៉ាងណាហ្ន៎ ក៏មានចិត្តតក់ស្លុត ទម្លាក់ផ្កាចោល ហើយពោលថា សូមលោកម្ចាស់មេត្តាបំបួសខ្ញុំផងចុះ ។ ព្រះថេរៈប្រាប់តចបញ្ចកកម្មដ្ឋានហើយ ទើបឲ្យគេបព្វជ្ជា ។

កាលលោកធ្វើសមណធម៌ ទីកន្លែងដែលសម្លាប់ម្រឹគ និងជ្រូកជាច្រើន និងទីកន្លែងដាក់អន្ទាក់ និងមាត់រន្ធ រមែងប្រាកដ កាលលោកកំពុងរលឹកដល់ទីកន្លែងនោះ ក៏កើតសេចក្តីក្តៅក្រហាយក្នុងរាងកាយ លោកមិនអាចប្រព្រឹត្តទៅតាមលំនាំព្រះកម្មដ្ឋាន ដូចជាគោកោងដូច្នោះ ។ លោកគិតថា ដោយភាវៈជាភិក្ខុ យើងនឹងធ្វើដូចម្តេច ត្រូវសេចក្តីមិនត្រេកអរបៀតបៀន ក៏ទៅរកព្រះថេរៈ ថ្វាយបង្គំហើយពោលថា លោកម្ចាស់ខ្ញុំមិនអាចធ្វើសមណធម៌បាន ។ លំដាប់នោះ ព្រះថេរៈពោលនឹងគេថា លោកចូរធ្វើការដោយដៃ ។ លោកទទួលថា ករុណាលោកម្ចាស់ ហើយកាត់ឈើស្រស់ មានដើមល្វាជាដើម ធ្វើជាគំនរធំ ហើយសួរថា ឥឡូវនេះខ្ញុំនឹងធ្វើដូចម្តេច ។ ចូរដុតវា ។ លោកបង្កាត់ភ្លើងក្នុងទិសទាំង ៤ ក៏មិនអាចនឹងដុតបាន ទើបពោលថា ខ្ញុំមិនអាច លោកម្ចាស់ ។ ព្រះថេរៈពោលថា បើដូច្នោះ ចូរចេញទៅ ហើយញែកផែនដី យកភ្លើងប្រមាណប៉ុនអំពិលអំពែកពីអវិចីនរក ដាក់ចូលក្នុងគំនរនោះ ។ ព្រះថេរៈដុត

គំនរឈើធំយ៉ាងនោះ ឲ្យឆេះដោយឆាប់រហ័ស ដូចដុតស្លឹកឈើស្ងួត លំដាប់នោះ ព្រះថេរៈសម្តែងអវិចីនរក ហើយពោលថា បើលោកសឹក លោកនឹងឆេះក្នុងអវិចីនរកនេះ ដូច្នេះ ហើយឲ្យលោកកើតសេចក្តីសង្វេគ ។ ចាប់ផ្តើមតាំងពីលោកបានឃើញអណ្តាតភ្លើង លោកក៏ញ័ររន្ធត់ សួរថា លោកម្ចាស់ព្រះពុទ្ធសាសនាជាហេតុនាំចេញចាកទុក្ខឬ ។ ពិតហើយ អាវុសោ ។ លោកម្ចាស់ បើព្រះពុទ្ធសាសនាជាហេតុនាំចេញចាកទុក្ខ មិលកភិក្ខុនឹងធ្វើខ្លួនឲ្យផុតទុក្ខ លោកម្ចាស់កុំចាំបាច់ព្រួយឡើយ ។ ចាប់តាំងពីនោះមក លោកព្យាយាមធ្វើសមណធម៌ បំពេញវត្តបដិបត្តិ កាលត្រូវសេចក្តីលក់បៀតបៀន យកចំបើងជ្រលក់ទឹកដាក់លើសីសៈ អង្គុយដាក់ជើងទាំងពីរចុះក្នុងផើងទឹក ។ ថ្ងៃមួយលោកត្រងទឹកផឹក ដាក់ថ្នាំងទឹកទុកលើជើង បានឈររង់ចាំដរាបទឹកក្នុងថ្នាំងអស់ ។ គ្រានោះឯង ព្រះថេរៈបានប្រាប់ឧទ្ទេស ដល់សាមណេរដូច្នេះថា

ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ
សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ

យស រមែងចម្រើនក្រៃលែង ដល់បុគ្គលដែលមានសេចក្តី
ព្យាយាម មានសតិ មានការងារស្អាត ពិចារណាមុនទើប
ធ្វើ សង្រួម ជាអ្នករស់នៅដោយធម៌ និងជាអ្នកមិនប្រមាទ ។

លោកបង្អោនគាថាសូម្បីប្រកបដោយបទ ៤ បទ ចូលមកក្នុងខ្លួន ដែលឈ្មោះថា អ្នកមានសេចក្ដីព្យាយាម នឹងត្រូវដូចជាយើង សូម្បីអ្នកមានសតិក៏ដូចជាយើង ។ល។ ទាំងអ្នកមិនប្រមាទ ក៏គប្បីដូចជាយើងដូចគ្នា រួមសេចក្ដីថា លោកបង្អោនគាថានោះចូលមកក្នុងខ្លួនយ៉ាងនោះហើយ តាំងនៅក្នុងវារៈជំហានដើងនោះឯង កាត់សញ្ញោជនៈខាងក្រោម ៥ ហើយតាំងនៅក្នុងអនាគាមិផល ត្រេកអររីករាយ ពោលគាថានេះថា ៖

*យើងទូលដុំចំបើងសើមចន្ទ្រម ក៏សម្រេចផលទី ៣*
*(អនាគាមិផល) ម្នាលលោកអ្នកនិរទុក្ខ ជាលាភរបស់*
*យើងហ្ន៎ ។*

លោកតាំងនៅក្នុងឧបនិស្ស័យមានកម្លាំងខ្សោយ ព្យាយាមយ៉ាងនេះ ហើយកាត់សញ្ញោជនៈខាងក្រោម ៥ យ៉ាង និងធ្វើមគ្គ ៣ ផល ៣ ឲ្យកើតបាន ដោយប្រការដូច្នេះ ។

ដោយហេតុនោះ ព្រះមានព្រះភាគត្រាស់ថា **នោ ចស្សំ នោ ច មេ សិយា , ន ភវិស្ស ន មេ ភវិស្សតិ ឯវំ វិមុច្ចមានោ ភិក្ខុ ភិន្ទេយ្យ ឱរម្ភាគិយានិ សំយោជនានិ** កាលភិក្ខុចុះចិត្តស៊ប់យ៉ាងនេះថា បើអាត្មាអញមិនមានទេ (បរិក្ខារ) របស់អាត្មាអញក៏មិនមាន (បើការកសាងកម្មទុកទៅក្នុងអនាគត)

នឹងមិនមានទេ (បដិសន្ធិ) របស់អាត្មាអញ (ក្នុងអនាគត) ក៏នឹងមិនមាន ដូច្នេះ ទើបគួរកាត់សញ្ញោជនៈដែលជាចំណែកខាងក្រោមបាន ។

បណ្ដាបទទាំងនោះ បទថា **នោ ចស្សំ នោ ច មេ សិយា** សេចក្ដីថា បើយើងមិនគប្បីមាន សូម្បីបរិក្ខាររបស់យើងក៏មិនគប្បីមាន ឬថា បើការតាក់តែងកម្មក្នុងអតីតរបស់យើងនឹងមិនមានហើយ ឥឡូវនេះ ខន្ធ ៥ របស់យើងនេះក៏មិនគប្បីមាន ។ បទថា **នាភវិស្ស ន មេ ភវិស្សតិ** សេចក្ដីថា ក៏ឥឡូវនេះ យើងនឹងព្យាយាមដោយការតាក់តែងកម្ម ដែលឲ្យខន្ធកើតដល់យើងក្នុងអនាគតនឹងមិនមាន កាលការតាក់តែងកម្មមិនមាន ឈ្មោះថា បដិសន្ធិក្នុងអនាគតក៏នឹងមិនមានដល់យើង ។ បទថា **ឯវំ វិមុច្ចមានោ** សេចក្ដីថា ភិក្ខុកាលបង្អោនចិត្តទៅយ៉ាងនេះ តាំងនៅក្នុងឧបនិស្ស័យមានកម្លាំងខ្សោយ គប្បីកាត់ឱរម្ភាគិយសញ្ញោជនៈ ៥ បាន ។

[១០៩] បទថា **ឯវំ វុត្តេ** សេចក្ដីថា កាលព្រះមានព្រះភាគជាម្ចាស់ទ្រង់រំពឹងដល់ព្រះសាសនាជាហេតុនាំចេញចាកទុក្ខ ទើបត្រាស់ព្រះឧទាននេះ ។

[១១០] បទថា **រូបំបិ ភវិស្សតិ** សេចក្ដីថា រូបនឹងបែកធ្លាយ ។ បទថា **រូបស្ស វិភវា** បានដល់ ព្រោះឃើញការមិនមាននៃរូប ។ ពិតណាស់ មគ្គ ៤ ដែលសម្បយុត្តដោយវិបស្សនា ឈ្មោះថា ឃើញការមិនមាននៃរូបជាដើម

ដែលលោកសំដៅយក ពោលទុកដូច្នោះ ។

[១១១] បទថា **ឯវំ វិមុច្ចមានោ ភន្តេ ភិក្ខុ ឆិន្ទេយ្យ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុកាលបង្អោនចិត្តទៅយ៉ាងនេះ គប្បីកាត់ឱរម្ភាគិយសញ្ញោជនៈ ៥ បាន ហេតុអ្វីទើបមិនកាត់ ។

ឥឡូវនេះ កាលនឹងទូលសួរដល់មគ្គផលខ្ពស់ៗ តទៅ ភិក្ខុនោះទើបក្រាបទូលពាក្យជាដើមថា **កថំ បន ភន្តេ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អនន្តរា** បានដល់ កាលជាលំដាប់មាន ២ យ៉ាង គឺ កាលជាលំដាប់ជិត ១ កាលជាលំដាប់ឆ្ងាយ ១ ។ វិបស្សនា ឈ្មោះថា កាលជាលំដាប់ជិតដល់មគ្គ ឆ្ងាយដល់ផល ភិក្ខុសំដៅយកកាលជាលំដាប់នោះ ទើបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន កាលភិក្ខុដឹងដូចម្តេច ឃើញដូចម្តេច អរហត្តផល ដែលរាប់ថាការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានក្នុងលំដាប់នៃវិបស្សនា ។ បទថា **អតសិតាយេ** បានដល់ ក្នុងឋានៈដែលមិនគួរភ័យ គឺ មិនគួរខ្លាច ។ បទថា **តាសំ អាបជ្ជតិ** ប្រែថា រមែងដល់សេចក្តីភ័យខ្លាច ។ បទថា **តាសោ ហេសោ** សេចក្តីថា ព្រោះវិបស្សនាទន់ខ្សោយ ដែលប្រព្រឹត្តទៅយ៉ាងនេះថា **នោ ចស្សំ នោ ច មេ សិយា** (បើយើងមិនគប្បីមាន ខន្ធបញ្ចកៈរបស់យើងក៏មិនមាន) នេះ មិនអាចនឹងរួបរឹតដោយសេចក្តីស្រឡាញ់ក្នុងខ្លួនបាន ដូច្នោះ បុថុជ្ជនអ្នកមិន

បានស្តាប់ ទើបឈ្មោះថា មានសេចក្តីតក់ស្លុត ព្រោះគេគិតថា ឥឡូវនេះយើងនឹងដាច់សូន្យ យើងនឹងមិនមានអ្វីៗ ទើបឃើញខ្លួនដូចជាធ្លាក់ទៅក្នុងជ្រោះ ដូចព្រាហ្មណ៍ម្នាក់ ។

បានឮមកថា ព្រះចូឡនាគត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក សូធ្យាយព្រះធម៌ទាក់ទងដោយត្រៃលក្ខណ៍ នៅក្រោមលោហៈប្រាសាទ ។ គ្រានោះ ព្រាហ្មណ៍ម្នាក់កំពុងឈរស្តាប់ធម៌ក្នុងទីកន្លែងមួយ សង្ខារបានប្រាកដជារបស់ទទេ ។ ខ្លួនគេហាក់ដូចជាធ្លាក់ទៅក្នុងជ្រោះ ក៏ម្នីម្នាគេចចេញពីទីនោះ តាមផ្លូវទ្វារដែលបើកទុក ចូលផ្ទះហើយឲ្យកូនដេកលើទ្រូង ពោលថា បា! កាលយើងនឹកដល់លទ្ធិរបស់ខ្លួន ជាការវិនាសហើយ ។ បទថា **ន ហេសោ ភិក្ខុ តាសោ** សេចក្តីថា វិបស្សនាដែលមានកម្លាំងនោះ គឺ ប្រព្រឹត្តទៅយ៉ាងនោះ រមែងមិនឈ្មោះថា មានសេចក្តីតក់ស្លុតសម្រាប់ព្រះអរិយសាវកអ្នកបានស្តាប់ សេចក្តីពិត ព្រះអរិយសាវកមិនបានគិតយ៉ាងនេះថា យើងនឹងដាច់សូន្យ ឬនឹងវិនាស តែព្រះអរិយសាវកមានសេចក្តីគិតយ៉ាងនេះថា សង្ខារទាំងឡាយប៉ុណ្ណោះរមែងកើតឡើង សង្ខារទាំងឡាយប៉ុណ្ណោះរមែងរលត់ទៅ ។

ចប់អដ្ឋកថា ឧទានសូត្រទី ៣

# អ ដ្ឋ ក ថា

## ឧបាទានបរិវដ្តសូត្រទី ៤

ក្នុង ឧបាទានបរិវដ្តសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១១២] បទថា **ចតុបរិវដ្តំ** បានដល់ បរិវដ្តៈ ៤ យ៉ាង ក្នុងខន្ធមួយៗ ។ បទថា **រូបំ អព្ភញ្ញាសឹ** សេចក្ដីថា បានដឹងច្បាស់ថា រូបជាទុក្ខសច្ច ។ គប្បីជ្រាបដោយអំណាចសច្ចៈ ៤ ក្នុងបទទាំងពួង ដោយប្រការដូច្នេះ ។ កពឡិង្ការាហារដែលប្រព្រឹត្តទៅជាមួយឆន្ទរាគៈ ឈ្មោះថា អាហារ ក្នុងពាក្យថា **អាហារសមុទយា** នេះ ។

[១១៣] បទថា **បដិបន្នា** បានដល់ ជាអ្នកបដិបត្តិចាប់តាំងពីសីលរហូតដល់អរហត្តមគ្គ ។ បទថា **គាធន្តិ** ប្រែថា តាំងនៅ ។ ព្រះមានព្រះភាគជាម្ចាស់ត្រាស់សេក្ខភូមិដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ឥឡូវនេះ កាលនឹងត្រាស់អសេក្ខភូមិ ទើបត្រាស់ពាក្យមានជាដើមថា **យេ ច ខោ កេចិ ភិក្ខវេ** ដូច្នេះ ។ បទថា **សុវិមុត្តា** បានដល់ រួចផុតដោយល្អដោយអរហត្តមគ្គ ។ បទថា **កេវលិនោ** បានដល់ អ្នកមានកិច្ចសម្រេច គឺ សម្រេចកិច្ចគ្រប់យ៉ាង ។ បទថា **វដ្តំ តេសំ នត្ថិ បញ្ញាបនាយ** សេចក្ដីថា សមណព្រាហ្មណ៍ទាំងនោះ

រមែងប្រាកដដោយវដ្ដៈដ៏សេសណា វដ្ដៈដែលប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ រមែងមិនមាន ។ មួយ៉ាងទៀត បទថា វដ្ដំ បានដល់ ហេតុ សេចក្ដីថា ហេតុដើម្បីសេចក្ដីប្រាកដ រមែងមិនមាន ។ ដោយព្រះតម្រាស់ត្រឹមប៉ុណ្ណេះ ជាការដែលទ្រង់សម្ដែងវារៈនៃអសេក្ខភូមិហើយ ។

ចប់អដ្ឋកថា ឧទានបរិវដ្ដសូត្រទី ៤

# អ ដ្ឋ ក ថា

## សត្តដ្ឋានសូត្រទី ៥

ក្នុង សត្តដ្ឋានសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១១៨] បទថា សត្តដ្ឋានកុសលោ បានដល់ អ្នកឈ្លាសក្នុងហេតុ ៧ ប្រការ ។

បទថា វុសិតវា បានដល់ អ្នកមានព្រហ្មចរិយធម៌នៅរួចហើយ ។ បទថា ឧត្តមបុរិសោ បានដល់ បុរសដ៏ប្រសើរ ។ ពាក្យដ៏សេសគប្បីជ្រាបតាមន័យដែលពោលហើយក្នុងឧបាទានបរិវដ្តសូត្រនោះឯង ។ តែព្រះសូត្រនេះគប្បីជ្រាបថា ប្រកបដោយសេចក្ដីកើតក្រៃលែងច្រើន និងជាទីតាំងនៃសេចក្ដីជាប់ជំពាក់ចិត្ត ដូចព្រះរាជាឈ្នះសង្គ្រាមហើយ ស្ដាបនាពួកទាហានឈ្នះសង្គ្រាមទុកក្នុងតំណែងខ្ពស់ ហើយព្រះរាជទានសក្ការៈដល់ទាហានទាំងនោះ ព្រោះហេតុអ្វី? ព្រោះពួកជនដ៏សេស ឃើញសក្ការៈរបស់ទាហានទាំងនោះ នឹងសម្គាល់ថាជាអ្នកខ្លាំងក្លាខ្លះ យ៉ាងណា ព្រះមានព្រះភាគ ទ្រង់បំពេញព្រះបារមីអស់កាលរកប្រមាណមិនបាន ទ្រង់ឈ្នះកិលេសមារត្រង់មហាពោធិមណ្ឌល ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ប្រថាប់អង្គុយក្នុងព្រះជេតវនមហាវិហារ នាក្រុង

សាវត្ថី កាលទឹងសម្តែងព្រះសូត្រនេះ ទើបលើកព្រះខីណាស្រពឡើងសរសើរ ព្រោះហេតុអ្វី? ព្រោះសេក្ខបុគ្គលដ៏សេស ទឹងសម្គាល់ព្រះអរហត្តផលថា គួរសម្រេចដោយប្រការដូច្នេះ ។ ព្រះសូត្រនេះ គប្បីជ្រាបថា ប្រកបដោយសេចក្តីភ្ញើតភ្ញើនច្រើន ព្រោះព្រះអង្គទ្រង់លើកសរសើរព្រះខីណាស្រពសរសើរ គប្បីជ្រាបថា ជាទីតាំងនៃសេចក្តីពេញចិត្ត ព្រោះព្រះសេក្ខៈទាំងឡាយក៏ប្រាថ្នាចង់បាន ។

[១២៣] ក៏ក្នុងពាក្យនេះថា ***ឯវំ ខោ ភិក្ខវេ ភិក្ខុ សត្តដ្ឋានកុសលោ ហោតិ*** (ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្លាសក្នុងហេតុ ៧ ប្រការ យ៉ាងនេះឯង) នេះ ព្រះមានព្រះភាគទ្រង់ឲ្យទេសនាចប់ស្រេច ដោយការពិចារណាមគ្គចិត្ត និងផលចិត្ត ដោយព្រះតម្រាស់ត្រឹមតែប៉ុណ្ណេះ ។

[១២៤] ព្រះអង្គបានត្រាស់ព្រះតម្រាស់នេះថា ***កថញ្ច ភិក្ខវេ ភិក្ខុ តិវិធូបបរិក្ខី ហោតិ*** (ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកពិចារណានូវលក្ខណៈ ៣ ប្រការ តើដូចម្តេចខ្លះ) ទៀត ក៏ដើម្បីទ្រង់សម្តែងហេតុជាគ្រឿងនៅរឿយៗរបស់ព្រះខីណាស្រពយ៉ាងនេះថា ព្រះខីណាស្រពរមែងនៅដោយហេតុជាគ្រឿងនៅរឿយៗ ក្នុងអារម្មណ៍ណា អារម្មណ៍នោះមិនមែនជាសត្វ ឬបុគ្គល ត្រឹមតែជាធាតុជាដើមប៉ុណ្ណោះ និងសម្តែងដល់អាគមនីយបដិបទាថា ក្នុងធម៌ទាំងនេះ

ធម៌នេះមក ព្រោះធ្វើកម្ម ។ បណ្តាបទទាំងនោះ បទថា **ធាតុសោ ឧបបរិក្ខតិ** សេចក្តីថា ឃើញ គឺ ពិចារណាដោយសេចក្តីជាធាតុ ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏ន័យនេះឯង ។

ចប់អដ្ឋកថា សត្តដ្ឋានសូត្រទី ៥

# អ ដ្ឋ ក ថា

## សម្មាសម្ពុទ្ធសូត្រទី ៦

[១២៥] ក្នុង *សម្មាសម្ពុទ្ធសូត្រទី ៦* មានវិនិច្ឆ័យដូចតទៅនេះ ៖

[១២៦] *បទថា* **កោ អធិប្បាយសោ** *សេចក្តីថា អ្វីជាសេចក្តីប្រាថ្នាដែលក្រៃលែងជាងគ្នា ។ បទថា* **អនុប្បន្នស្ស** *សេចក្តីថា ពិតហើយ ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថាកស្សបៈ ទ្រង់ឲ្យមគ្គចិត្តនេះកើតឡើង ក្នុងរវាងនេះសាស្តាដទៃមិនអាចឲ្យកើតឡើងបាន ព្រះមានព្រះភាគ ឈ្មោះថា ធ្វើមគ្គដែលនៅមិនកើតឲ្យកើតឡើង ដោយប្រការដូច្នេះ ។ ពិតហើយ ក្នុង* **នគរោបមសូត្រ** *បុរាណមគ្គកើតក្នុងទីដែលមិនមានការប្រើ ក្នុងទីនេះឈ្មោះថា មគ្គដែលមិនទាន់កើតឡើង ព្រោះអត្ថថា មិនទាន់ប្រព្រឹត្តទៅ ។ បទថា* **អសញ្ជាតស្ស** *ជាវេវចនៈរបស់បទថា* **អនុប្បន្នស្ស** *នុ៎ះឯង ។ បទថា* **អនក្ខាតស្ស** *បានដល់មិនបានត្រាស់ទុក ។ ឈ្មោះថា* **មគ្គញ្ញូ** *ព្រោះដឹងមគ្គ ។ ឈ្មោះថា* **មគ្គវិទូ** *ព្រោះធ្វើមគ្គឲ្យជាក់ច្បាស់ គឺ ឲ្យប្រាកដ ។ ឈ្មោះថា* **មគ្គាមគ្គកោវិទ** *ព្រោះឆ្លាតក្នុងមគ្គ និងធម្មជាតិមិនមែនមគ្គ ។ បទថា* **មគ្គានុគា** *ប្រែថា ទៅតាមមគ្គ ។ បទថា* **បច្ឆា សមន្នាគតា** *សេចក្តីថា តថាគតដល់មុន សាវកដល់*

ក្រោយ ។

ចប់អដ្ឋកថា សម្មាសម្ពុទ្ធសូត្រទី៦

# អ ដ្ឋ ក ថា

## អនត្តលក្ខណសូត្រទី ៧

ក្នុង *អនត្តលក្ខណសូត្រទី ៧* មានវិនិច្ឆ័យដូចតទៅនេះ ៖

[១២៧] បទថា **បញ្ចវគ្គិយេ** បានដល់ អ្នកបួស ៥ រូប មានព្រះអញ្ញាកោណ្ឌញ្ញត្ថេរជាដើម ដែលជាឧបដ្ឋាកពីដើម ។ បទថា **អាមន្តេសិ** សេចក្ដីថា ថ្ងៃ ៥ កោច តាំងពីថ្ងៃដែលទ្រង់ប្រកាសធម្មចក្កក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ព្រះមានព្រះភាគត្រាស់ហៅភិក្ខុបញ្ចវគ្គិយ ដែលតាំងនៅក្នុងសោតាបត្តិផលតាមលំដាប់ ហើយត្រាស់ថា ឥឡូវនេះ តថាគតនឹងសម្ដែងធម៌ដើម្បីការអស់ទៅនៃអាសវៈដល់អ្នកទាំងឡាយ ។ បទថា **ឯតទវោច** សេចក្ដីថា បានត្រាស់ពាក្យនេះ គឺ **អនត្តលក្ខណសូត្រ** ដែលប្រព្រឹត្តទៅដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **អនត្តា** សេចក្ដីថា ឈ្មោះថា អនត្តា ដោយហេតុ ៤ យ៉ាង ដែលពោលហើយក្នុងកាលមុន ។ ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ផ្ដើមពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនឹងសម្គាល់សេចក្ដីនោះដូចម្ដេច ។ គប្បីជ្រាបថា ព្រោះដោយឋានៈត្រឹមតែប៉ុណ្ណេះ ព្រះមានព្រះភាគ ត្រាស់អនត្តលក្ខណៈប៉ុណ្ណោះ មិនបានត្រាស់

អនិច្ចលក្ខណៈ និងទុក្ខលក្ខណៈ ឥឡូវនេះ ទ្រង់សម្តែងលក្ខណៈទាំងនោះដើម្បីសម្តែងរួមលក្ខណៈទាំង ៣ ទើបទ្រង់ផ្តើមពាក្យនេះ ។

[១២៩] គប្បីជ្រាបដូច្នេះ ។ បទថា **តស្មា** សេចក្តីថា ព្រោះខន្ធ ៥ ទាំងនេះ មិនទៀង ជាទុក្ខ ជាអនត្តា ។ ពាក្យអធិប្បាយយ៉ាងពិស្តារក្នុងពាក្យថា *យំ កិញ្ចិ រូបំ* (រូបណាមួយ) ជាដើម ពោលទុកហើយក្នុងខន្ធនិទ្ទេស ពោលផ្នែកបញ្ញាការនាក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង គប្បីជ្រាបតាមទំនងដែលពោលហើយនុ៎ះឯង ។ ក៏ក្នុងព្រះសូត្រនេះ ទ្រង់ត្រាស់អនត្តលក្ខណៈប៉ុណ្ណោះឯង ។

ចប់អដ្ឋកថា អនត្តលក្ខណសូត្រទី ៧

# អ ដ្ឋ ក ថា

## មហាលិសូត្រទី ៨

*ក្នុងមហាលិសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[១៣១] *ពាក្យថា ឯកន្តទុក្ខំ ជាដើម មានន័យដូចពោលហើយក្នុងធាតុសំយុត្តនុ៎ះឯង ។*

ចប់អដ្ឋកថា មហាលិសូត្រទី ៨

# អ ដ្ឋ ក ថា

## អាទិត្តសូត្រទី ៩

*ក្នុង **អាទិត្តសូត្រទី ៩** មានវិនិច្ឆ័យដូចតទៅនេះ ៖*

[១៣៣] *បទថា **អាទិត្តំ** សេចក្តីថា ក្តៅខ្លាំង គឺ ឆេះសន្ធោសន្ធៅ ដោយភ្លើង ១១ កង ក្នុងព្រះសូត្រទាំងពីរនេះ ត្រាស់ទុក្ខលក្ខណៈប៉ុណ្ណោះ ។*

ចប់អដ្ឋកថា អាទិត្តសូត្រទី៩

# អ ដ្ឋ ក ថា

## និរុត្តិបថសូត្រទី ១០

ក្នុង និរុត្តិបថសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៣៤] ភាសាទាំងឯង ឈ្មោះថា **និរុត្តិបថ** ម្យ៉ាងទៀត **ភាសា** នោះៗ ផង , ឈ្មោះថា **បថៈ** ព្រោះជាផ្លូវនៃខ្លឹមសារដែលគប្បីដឹងច្បាស់ដោយអំណាចភាសាផង ហេតុនោះទើបឈ្មោះថា **និរុត្តិបថៈ** ។ សូម្បីក្នុងពីរបទដ៏សេសក៏ន័យនេះឯង ។ មួយទៀត បទទាំងបីនេះ គប្បីជ្រាបថា ជាវេវចនៈនៃគ្នានិងគ្នានោះឯង ។

បទថា **អសង្កិណ្ណា** សេចក្ដីថា មិនត្រូវលះបង់ គឺ មិនត្រូវពោលថានឹងមានប្រយោជន៍អ្វីដោយផ្លូវទាំងនេះ ហើយលះបង់ចេញ ។ បទថា **អសង្កិណ្ណបុព្វា** សេចក្ដីថា មិនធ្លាប់លះបង់សូម្បីក្នុងអតីត ។ បទថា **ន សង្កិយន្តិ** សេចក្ដីថា សូម្បីឥឡូវនេះ ក៏មិនត្រូវលះបង់ថា ប្រយោជន៍អ្វីដោយផ្លូវទាំងនេះ ។ បទថា **ន សង្កិយិស្សន្តិ** សេចក្ដីថា សូម្បីក្នុងអនាគតក៏នឹងមិនត្រូវទំលាក់ចោល ។ បទថា **អប្បដិកុដ្ឋា** បានដល់ មិនហាម ។ បទថា **អតីតំ** បានដល់ ឈានកន្លងសភាវៈរបស់ខ្លួន ឬកន្លងចិត្តទាំងឯង ។ បទថា **និរុទ្ធំ**

សេចក្តីថា មិនកន្ទុំចំណែកជទៃ រលត់ គឺ ចូលទៅស្ងប់ក្នុងទីនោះឯង ។ បទថា **វិបរិណតំ** បានដល់ ដល់សេចក្តីប្រែប្រួល គឺ វិនាសទៅ ។

[១៣៥] បទថា **អជាតំ** ប្រែថា មិនកើតឡើង ។ បទថា **អប្បាតុកូតំ** បានដល់ មិនតាំងនៅដោយប្រក្រតី ។

[១៣៧] បទថា **ឧក្កលា** បានដល់ អ្នកនៅក្នុងឧក្កលជនបទ ។ បទថា **វស្សភញ្ញា** បានដល់ វស្សគោត្រ និងភញ្ញគោត្រ ។ បានឮមកថា ជនទាំងពីរពួកនោះ ប្រកាន់ទិដ្ឋិជាមូល ។ ក្នុងបទថា **អហេតុកវាទា** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

ឈ្មោះថា **អហេតុកវាទា** ព្រោះប្រកាន់ថា ហេតុមិនមាន បច្ច័យមិនមាន ។ ឈ្មោះថា **អកិរិយវាទា** ព្រោះប្រកាន់ថា កាលបុគ្គលធ្វើបាប ឈ្មោះថា មិនជាការធ្វើជាដើម ។ ឈ្មោះថា **នត្ថិកវាទា** ព្រោះប្រកាន់ថា ទានដែលឲ្យហើយ មិនមានផលជាដើម ។ ក្នុងសេចក្តីនោះ មានជន ២ ពួក មានទិដ្ឋិ ៣ យ៉ាង តែមិនមែនមួយពួកៗ មានទិដ្ឋិមួយកន្ទុំនោះទេ ក្នុងសេចក្តីនេះ មួយពួកៗ គប្បីជ្រាបថា ធ្វើទិដ្ឋិទាំងបីឲ្យកើត ដូចភិក្ខុមួយរូបធ្វើឈានទាំង ៤ ឲ្យកើតឡើងតាមលំដាប់ ។ កាលបុគ្គលរំពឹង ត្រេកអរ ភ្លើតភ្លើនរឿយៗ ថា ហេតុមិនមាន បច្ច័យមិនមាន (ការឃើញរបស់គេ រមែងដូចជាត្រេកអរក្នុងឈាន) ដូចមគ្គ-

ទស្សនៈ គេឈានចុះកាន់សេចក្តីកំណត់ថា ជាមិច្ឆាទិដ្ឋិ គេត្រូវហៅថា ជាអ្នកមានធម៌ចំណែកខ្មៅដោយពិត ។ ក្នុងឋានៈសូម្បីទាំងនេះ គឺ កាលបុគ្គលធ្វើបាប មិនឈ្មោះថា ជាការធ្វើ , ទានដែលឲ្យហើយ រមែងមិនមានផល , មិច្ឆាទិដ្ឋិកបុគ្គល រមែងឈានចុះកាន់សេចក្តីកំណត់ដែលជាជាមិច្ឆាទិដ្ឋិ ដូចឈានចុះក្នុងអហេតុកទិដ្ឋិ ដូច្នោះ ។

ក្នុងពាក្យថា **ន គរហិតព្វំ ន បដិក្កោសិតព្វំ អមញ្ញឹសុ** នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

កាលបុគ្គលពោលថា វត្ថុដែលឈ្មោះថា អតីតក៏គង់ជាអតីត វត្ថុដែលជាអតីតនេះ ជាអនាគតក៏បាន ជាបច្ចុប្បន្នក៏បាន ឈ្មោះថា រមែងតិះដៀល ។ លុះឃើញទោសក្នុងទិដ្ឋិនោះហើយ កាលទឹងពោលថា ប្រយោជន៍អ្វីដោយវត្ថុដែលយើងតិះដៀលនេះ ឈ្មោះថា រមែងជំទាស់ ។ ក៏ពួកអ្នកប្រកាន់ទិដ្ឋិ ដែលត្រូវហៅថា ជាអ្នកមានធម៌ចំណែកខ្មៅដោយពិត សូម្បីទាំងនោះ សម្គាល់និរុត្តិបថទាំងនេះថា មិនគួរតិះដៀល មិនគួរហាមឃាត់ តែពោលវត្ថុដែលជាអតីតថា គង់ជាអតីត , វត្ថុដែលជាអនាគតថា គង់ជាអនាគត , វត្ថុដែលជាបច្ចុប្បន្នថា គង់ជាបច្ចុប្បន្នទុំះឯង ។ បទថា **និន្ទាព្យារោសឧបារម្ភភយា** (ព្រោះខ្លាចការនិន្ទា ការលើកទោស និងការប្រណាំងប្រជែង) សេចក្តីថា ព្រោះខ្លាច

ដល់ការនិន្ទា ព្រោះខ្លាចដល់ការចាក់ដោត ព្រោះខ្លាចដល់ការដាក់ទោស និងព្រោះខ្លាចដល់ការតិះដៀល អំពីសម្នាក់របស់វិញ្ញូជនទាំងឡាយ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់បញ្ញត្តិខន្ធ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា និរុត្តិបថសូត្រទី ១០

## ចប់ខ្ទុបាយវគ្គទី ១
## ក្នុងមជ្ឈិមបណ្ណាសកៈ
## រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា


| | |
|---|---|
| ១-អដ្ឋកថា ឧបាយសូត្រ | ២-អដ្ឋកថា ពីជសូត្រ |
| ៣-អដ្ឋកថា ឧទានសូត្រ | ៤-អដ្ឋកថា បរិវដ្ដសូត្រ |
| ៥-អដ្ឋកថា សត្តដ្ឋានសូត្រ | ៦-អដ្ឋកថា ពុទ្ធសូត្រ |
| ៧-អដ្ឋកថា បញ្ចវគ្គិយសូត្រ | ៨-អដ្ឋកថា មហាលិសូត្រ |
| ៩-អដ្ឋកថា អាទិត្តសូត្រ | ១០-អដ្ឋកថា និរុត្តិបថសូត្រ |

# អរហន្តវគ្គទី ២

## អ ដ្ឋ ក ថា

## ឧបាទិយសូត្រទី ១

ក្នុង ឧបាទិយសូត្រទី ១ អរហន្តវគ្គ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៣៨] បទថា ឧបាទិយមានោ (កាលប្រកាន់មាំ) បានដល់ ប្រកាន់មាំដោយអំណាចតណ្ហា មានះ និងទិដ្ឋិ ។ បទថា ពន្ធោ មារស្ស (ត្រូវមារចងទុក) បានដល់ ឈ្មោះថា ត្រូវអន្ទាក់មារចងទុក ។ បទថា មុត្តោ បាបិមតោ បានដល់ ដែលឈ្មោះថា រួចផុតហើយពីអន្ទាក់នៃមារមានចិត្តបាប ។

ចប់អដ្ឋកថា ឧបាទិយសូត្រទី ១

# អ ដ្ឋ ក ថា

## មញ្ញមានសូត្រទី ២

[១៤០] *ក្នុង មញ្ញមានសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*បទថា* ***មញ្ញមានោ*** *(កាលសំគាល់) បានដល់ សម្គាល់ដោយតណ្ហា មានះ និងទិដ្ឋិ ។*

ចប់អដ្ឋកថា មញ្ញមានសូត្រទី២

# អ ដ្ឋ ក ថា

## អភិនន្ទមានសូត្រទី ៣

[១៨១] ក្នុង *អភិនន្ទមានសូត្រទី ៣* មានវិនិច្ឆ័យដូចតទៅនេះ ៖

*បទថា* **អភិនន្ទមានោ** *(កាលត្រេកអរ) បានដល់ ត្រេកអរដោយតណ្ហា មានះ និងទិដ្ឋិទាំងឡាយ។*

ចប់អដ្ឋកថា អភិនន្ទមានសូត្រទី ៣

# អ ដ្ឋ ក ថា

## អនិច្ចសូត្រទី ៤

[១៤២] *ក្នុង អនិច្ចសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*បទថា ឆន្ទោ បានដល់ សេចក្តីពេញចិត្តដោយអំណាចតណ្ហា ។*

ចប់អដ្ឋកថា អនិច្ចសូត្រទី៤

[១៤៣-១៤៤] *អដ្ឋកថាទុក្ខសូត្រទី ៥ , អនត្តសូត្រទី ៦*

*សូម្បីក្នុង ទុក្ខសូត្រទី ៥ និងអនត្តសូត្រទី ៦ ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា ទុក្ខសូត្រទី៥ , អនត្តសូត្រទី៦

# អ ដ្ឋ ក ថា

## អនត្តនិយសូត្រទី ៧

[១៨៥] ក្នុង *អនត្តនិយសូត្រទី ៧* មានវិនិច្ឆ័យដូចតទៅនេះ ៖

*បទថា **អនត្តនិយំ** (មិនមែនជារបស់ខ្លួន) បានដល់ មិនមែនរបស់ខ្លួន អធិប្បាយថា សូន្យចាកសភាវៈជាបរិក្ខាររបស់ខ្លួន ។*

ចប់អដ្ឋកថា អនត្តនិយសូត្រទី ៧

# អ ដ្ឋ ក ថា

## រជនិយសណ្ឋិតសូត្រទី ៨

[១៤៦] ក្នុង *រជនិយសណ្ឋិតសូត្រទី ៨* មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា *រជនីយសណ្ឋិតំ* បានដល់ តាំងនៅដោយអាការដែលជាទីតាំងនៃសេចក្ដីត្រេកអរ អធិប្បាយថា តាំងនៅដោយភាពជាបច្ច័យនៃរាគៈ ។

ចប់អដ្ឋកថា រជនិយសណ្ឋិតសូត្រទី៨

# អ ដ្ឋ ក ថា

## រាធសូត្រទី ៩ និងសុរាធសូត្រទី ១០

[១៤៧-១៤៨] *រាធសូត្រទី ៩ និងសុរាធសូត្រទី ១០ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងរាហុលសំយុត្តឯង ។*

## ចប់អរហន្តវគ្គទី ២

### រួមក្នុងវគ្គនេះមាន ០៦ អដ្ឋកថា

| | |
|---|---|
| ១-អដ្ឋកថា ឧបាទិយសូត្រ | ២-អដ្ឋកថា មញ្ញមានសូត្រ |
| ៣-អដ្ឋកថា អភិនន្ទមានសូត្រ | ៤-អដ្ឋកថា អនិច្ចសូត្រ |
| ៥- ទុក្ខសូត្រ (មិនមាន អដ្ឋកថា) | ៦- អនត្តសូត្រ (មិនមាន អដ្ឋកថា) |
| ៧-អដ្ឋកថា អនត្តនិយសូត្រ | ៨-អដ្ឋកថា រជនិយសណ្ឋិតសូត្រ |
| ៩- រាធសូត្រ (មិនមាន អដ្ឋកថា) | ១០-សុរាធសូត្រ (មិនមាន អដ្ឋកថា) |

# ខជ្ជនិយវគ្គទី ៣

## អ ដ្ឋ ក ថា

### អស្សាទ-សមុទយសូត្រទី ១-៣

[១៤៩-១៥១] ក្នុងសូត្រទាំង ៣ ដំបូង ព្រះមានព្រះភាគជាម្ចាស់ត្រាស់អរិយសច្ចៈ ៤ ទាំងអស់ ។

ចប់អដ្ឋកថា អស្សាទសូត្រជាដើមទី១-៣

# អ ដ្ឋ ក ថា

## បឋមអរហន្តសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បឋមអរហន្តសូត្រទី ១** ដូចតទៅនេះ ៖*

[១៥២] *បទថា **យាវតា ភិក្ខវេ សត្តាវាសា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា សត្តាវាស មានប្រមាណប៉ុនណា ។ បទថា **យាវតា ភវគ្គំ** សេចក្តីថា ឈ្មោះថា ភវគ្គព្រហ្ម (ព្រហ្មស្ថិតនៅក្នុងភពខ្ពស់បំផុត) មានប្រមាណប៉ុនណា ។*

*បទថា **ឯតេ អគ្គា ឯតេ សេដ្ឋា** សេចក្តីថា ព្រះអរហន្តទាំងឡាយនោះរាប់ថា ជាកំពូល និងប្រសើរទីបំផុត ។ បទថា **យទិទំ អរហន្តោ** គឺ (ប្រែថា ឈ្មោះថាព្រះអរហន្តពួកណានោះឯង) សូម្បីព្រះសូត្រនេះ ក៏គប្បីជ្រាបថា ញុំាងនូវសេចក្តីត្រេកអរបន្ថែម និងរំភើបចិត្ត ដោយន័យមុននោះឯង ។*

[១៥៣] *បទថា **អថាបរំ ឯតទវោច** សេចក្តីថា ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នោះ គឺ ព្រះតម្រាស់មានជាដើមថា **សុខិនោ វត អរហន្តោ** (ព្រះអរហន្តទាំងឡាយមានសេចក្តីសុខពិតហ្ន៎) ដោយគាថាទាំងឡាយ ដែលកំណត់សម្តែងអត្ថន័យនោះ និងដែលកំណត់សម្តែងអត្ថន័យពិសេស ។*

## គុណសម្បត្តិពិសេសរបស់ព្រះអរហន្ត

បណ្តាបទទាំងនោះ បទថា **សុខិនោ** គឺ (ព្រះអរហន្តទាំងឡាយ) នៅជាសុខដោយសេចក្តីសុខដែលកើតអំពីការចូលឈាន ដោយសេចក្តីសុខ ដែលកើតអំពីការសម្រេចមគ្គ និងដោយសេចក្តីសុខដែលកើតអំពីសម្រេចផល ។

បទថា **តណ្ហា តេសំ ន វិជ្ជតិ** សេចក្តីថា ព្រះអរហន្តទាំងនោះ មិនមានតណ្ហាដែលជាហេតុឲ្យកើតទុក្ខ (ដែលនឹងត្រូវបានទទួល) ក្នុងអបាយ ។ ព្រះអរហន្តទាំងនោះ ឈ្មោះថា មានសុខពិតនោះឯង ព្រោះមិនមានទុក្ខដែលមានតណ្ហាជាមូលយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **អស្មិមានោ សមុច្ឆិន្នោ** សេចក្តីថា ព្រះអរហន្តកាត់អស្មិមានះ (សេចក្តីប្រកាន់ថា ជាយើងនោះ) ៩ យ៉ាង ដាច់ហើយ ដោយអរហត្តមគ្គ ។

បទថា **មោហជាលំ បទាលិតំ** សេចក្តីថា សំណាញ់ គឺ អវិជ្ជា (ព្រះអរហន្ត) ទម្លាយហើយដោយញាណ ។

បទថា **អនេញ្ជំ** បានដល់ ព្រះអរហន្តជាគ្រឿងលះបង់តណ្ហា ពោលគឺឯជា ។

បទថា **អនុបលិត្តា** បានដល់ (ព្រះអរហន្ត) មិនត្រូវលាបលេន ដោយគ្រឿងលាបលេន គឺ តណ្ហា និងទិដ្ឋិ ។ បទថា **ព្រហ្មភូតា** ប្រែថា ប្រសើរជា

ទីបំផុត ។ បទថា **បរិញ្ញាយ** បានដល់ កំណត់ដឹងហើយដោយបរិញ្ញា ៣ ។ ក្នុងបទថា **សត្តសទ្ធម្មគោចរា** មានវិគ្រោះថា សទ្ធម្ម ៧ ប្រការទាំងនេះ គឺ សទ្ធា ១ ហិរិ ១ ឱត្តប្បៈ ១ ពហុសច្ចៈ ១ ភាពជាអ្នកប្រារព្ធសេចក្តីព្យាយាម ១ ភាពជាអ្នកមានសតិតាំងមាំ ១ បញ្ញា ១ ជាអារម្មណ៍របស់ព្រះអរហន្ត ទាំងនោះ ហេតុនោះ ព្រះអរហន្តទាំងនោះទើបឈ្មោះថា មានសទ្ធម្ម ៧ ជា អារម្មណ៍ ។

បទថា **សត្តរតនសម្បន្នា** (ជាអ្នកបរិបូណ៌ដោយរតនៈ ៧ ប្រការ) បានដល់ ប្រកបដោយរតនៈ គឺ ពោជ្ឈង្គៈ ៧ ប្រការ ។

បទថា **អនុវិចរន្តិ** (រមែងត្រាច់ទៅ) សេចក្តីថា សូម្បីពួកលោកិយ មហាជន ក៏ត្រាច់ទៅដូចគ្នា ។

ក៏ក្នុងសូត្រនេះ ទ្រង់ត្រាស់បំណាងដល់អាចារៈ ដែលប្រាសចាកការ រង្កៀសសង្ស័យរបស់ព្រះខីណាស្រពទាំងឡាយ ដោយហេតុនោះឯង ព្រះ- មានព្រះភាគទើបត្រាស់ថា **បហីនភយភេរវា** (អ្នកលះសេចក្តីភ័យ និងសេចក្តី ខ្លាចបានហើយ) ។

ក្នុងបទថា **បហីនភយភេរវា** នោះ អធិប្បាយថា សេចក្តីខ្លាចជា ធម្មតាឈ្មោះថា **ភ័យ** សេចក្តីខ្លាចដែលខ្លាំងក្លា ឈ្មោះថា **ភេរវៈ** ។

បទថា **ទសហង្គេហិ សម្បន្នា** (អ្នកបរិបូណ៌ដោយអង្គ ១០) បានដល់ ប្រកបដោយអង្គដែលជាអសេក្ខៈ ។

បទថា **មហានាគា** (ជាមហានាគ) បានដល់ ជាមហានាគដោយហេតុ ៤ ប្រការ ។

បទថា **សមាហិតា** (មានចិត្តតាំងមាំ) បានដល់ (មានចិត្តតាំងមាំ) ដោយឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា **តណ្ហា តេសំ ន វិជ្ជតិ** (លោកទាំងនោះមិនមានតណ្ហា) សេចក្ដីថា ព្រះអរហន្តទាំងនោះមិនមានសូម្បី តណ្ហាដែលធ្វើ (សត្វលោក) ឲ្យជាទាសៈ ដែលព្រះរដ្ឋបាលត្ថេរពោលទុក យ៉ាងនេះថា "សូមថ្វាយព្រះពរមហាបពិត្រ ព្រះមានព្រះភាគជាម្ចាស់ព្រះអង្គ នោះ ត្រាស់ទុកហើយថា សត្វលោកខ្វះកន្ទះ (ជានិច្ច) មិនចេះឆ្អែត ជាទាសៈ នៃតណ្ហា" ដូច្នេះឯង ។

ព្រះមានព្រះភាគសម្ដែងការៈ ដែលព្រះខីណាស្រពទាំងឡាយ ជាអ្នក គ្មានបំណុល ដោយបទថា **តណ្ហា តេសំ ន វិជ្ជតិ** នេះ ។

បទថា **អសេក្ខញាណំ** បានដល់ ញាណក្នុងអរហត្តផល ។

បទថា **អន្តិមោយំ សមុស្សយោ** ប្រែថា នេះជាទីបំផុតនៃអត្តភាព ។

បទថា **យោ សារោ ព្រហ្មចរិយស្ស** (គុណដែលជាខ្លឹមនៃព្រហ្មចរិយៈ)

សេចក្តីថា ផល ឈ្មោះថា ជាសារៈនៃព្រហ្មចរិយៈ គឺ មគ្គ ។

បទថា **តស្មិំ អបរប្បច្ចយា** (មិនអាស្រ័យអ្នកដទៃ) សេចក្តីថា តាំងនៅក្នុងអរិយផលនោះ ចាក់ធ្លុះដោយប្រចក្ស (ដោយខ្លួនឯង) តែថា សម្បត្តិនេះ មិនមែនសម្បត្តិរបស់អ្នកដទៃ ។

បទថា **វិធាសុ ន វិកម្បន្តិ** គឺ មិនញាប់ញ័រក្នុងចំណែកនៃមានះ ៣ ។

បទថា **ទន្តភូមិំ** បានដល់ អរហត្តផល ។

បទថា **វិជិតាវិនោ** បានដល់ ឈ្នះកិលេសទាំងឡាយ មានរាគៈជាដើមហើយស្ថិតនៅ ។

ក្នុងបទថា **ឧទ្ធំ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

(ក្នុងរាងកាយ) ចុងសក់ ព្រះមានព្រះភាគត្រាស់ហៅថា ខាងលើ **(ឧទ្ធំ)** បាតជើង ត្រាស់ហៅថា ខាងក្រោម **(អធោ)** , កណ្តាលខ្លួន ត្រាស់ហៅថា ខាងទទឹង **(តិរិយំ)** , (ក្នុងអារម្មណ៍) អារម្មណ៍ដែលជាអតីត ត្រាស់ហៅថា ខាងលើ , អារម្មណ៍ដែលជាអនាគត ត្រាស់ហៅថា ខាងក្រោម , អារម្មណ៍ដែលជាបច្ចុប្បន្ន ត្រាស់ហៅថា ខាងទទឹង ។

ម្យ៉ាងទៀត (ក្នុងលោក) ទេវលោក ត្រាស់ហៅថា ខាងលើ , អបាយ ត្រាស់ហៅថា ខាងក្រោម , មនុស្សលោក ត្រាស់ហៅថា ខាងទទឹង ។

បទថា នត្ថិ តេសំ ន វិជ្ជតិ សេចក្តីថា ព្រះអរហន្តទាំងនោះ មិនមានតណ្ហាក្នុងឋានៈទាំងនោះ ឬកាលពោលដោយសង្ខេប (ក៏គឺ) មិនមានតណ្ហាក្នុងខន្ធទាំងឡាយ ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។

ក្នុងសូត្រនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងដល់ព្រះអរហន្តទាំងឡាយមិនមានតណ្ហាដែលជាមូលនៃវដ្តៈ ។ បទថា ពុទ្ធា បានដល់ អ្នកត្រាស់ដឹងសច្ចៈ ៤ ។

ក្នុងព្រះគាថានេះ មានការប្រមូលសីហនាទដូចតទៅនេះ ៖

ព្រះខីណាស្រពទាំងឡាយ ស្ថិតនៅខាងលើកព (អ្នកឆ្លងកពបានហើយ) រមែងបន្លឺសីហនាទ ពោលគឺ បន្លឺដោយមិនភ័យខ្លាចថា យើងទាំងឡាយនៅជាសុខដោយវិមុត្តិសុខ តណ្ហាដែលជាហេតុនៃទុក្ខ យើងទាំងឡាយលះបង់បានហើយ ខន្ធ ៥ យើងទាំងឡាយកំណត់ដឹងហើយ តណ្ហាដែលធ្វើសត្វលោកឲ្យជាទាសៈ និងតណ្ហាដែលជាមូលនៃវដ្តៈ យើងទាំងឡាយលះបង់បានហើយ យើងទាំងឡាយជាអ្នកដែលមិនមានអ្នកណាក្រៃលែងជាង (និង) មិនដូចនរណាឈ្មោះថា ពុទ្ធ (ពុទ្ធសាវក) ព្រោះត្រាស់ដឹងសច្ចៈ ៤ ។

ចប់អដ្ឋកថា បឋមអរហន្តសូត្រទី ៨

# អ ដ្ឋ ក ថា

## ទុតិយអរហន្តសូត្រទី ៥

[១៥៤] *សូត្រទី ៥ កាលព្រះមានព្រះភាគត្រាស់ព្រះទេសនាឲ្យជាដូចកម្រងកែវសុទ្ធៗ មិនមានគាថា ក៏ត្រាស់តាមអធ្យាស្រ័យរបស់អ្នកស្តាប់ដែលនឹងត្រាស់ដឹង ។*

ចប់អដ្ឋកថា ទុតិយអរហន្តសូត្រទី ៥

# អ ដ្ឋ ក ថា

## សីហសូត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុង **សីហសូត្រទី ៦** ដូចតទៅនេះ ៖

[១៥៥] បទថា **សីហោ** បានដល់ រាជសីហ៍ ៤ ពួក គឺ តិណរាជសីហ៍ ១ ពួក , កាឡរាជសីហ៍ ១ ពួក , បណ្ឌុរាជសីហ៍ ១ ពួក , កេសររាជសីហ៍ ១ ពួក ។

បណ្តារាជសីហ៍ ៤ ពួកនោះ **តិណរាជសីហ៍** (មានរូបរាង) ដូចជាមេគោ ពណ៌ស្រដៀងសត្វព្រាប និងស៊ីស្មៅជាអាហារ ។

**កាឡរាជសីហ៍** (មានរូបរាង) ដូចជាមេគោខ្មៅ ស៊ីស្មៅជាអាហារដូចគ្នា ។ **បណ្ឌុរាជសីហ៍** (មានរូបរាង) ដូចជាមេគោ ពណ៌ស្រដៀងស្លឹកឈើលឿង ស៊ីសាច់ជាអាហារ ។ **កេសររាជសីហ៍** ប្រកបដោយ (លក្ខណៈគឺ) ផ្ទៃមុខ ចុងកន្ទុយ និងចុងជើងទាំង ៤ ដូចជាមានអ្នកណាយកទឹកល័ខមកតាក់តែងបន្ថែម តាំងពីសីសៈរបស់រាជសីហ៍នោះចុះទៅ មានជួរប្រាកដ ៣ ជួរ ដែលដូចជាមានអ្នកណាមកចុចទុក ដោយពណ៌ទឹកល័ខ ពណ៌ក្រហមស្រស់ និងពណ៌ហិង្គុ (ជួរទាំង ៣ នោះ) កន្ទង់ខ្នងទៅ បំផុតត្រង់ខាងក្នុងជើង

ទន់ ជាវង់ទក្ខិណាវដ្ត ។

ឯត្រង់ដើម.ករបស់កេសររាជសីហ៍នោះ មានរោមឡើងជាកួន ដូចវង់រុំទុកដោយសំពត់កម្ពលតម្លៃទាំងសែន (ចំណែក) កន្លែងដ៏សេស (ខាងក្នុងរាងកាយ) មានពណ៌សបរិសុទ្ធិដូចម្សៅស្រូវសាលី និងកម្ទេចផង់លម្អិតនៃស័ង្ខ ។

បណ្តារាជសីហ៍ទាំង ៤ នេះ កេសររាជសីហ៍នេះ ព្រះមានព្រះភាគទ្រង់បំណាងយកហើយក្នុងសូត្រនេះ ។

បទថា **មិគរាជា** បានដល់ រាជានៃពួកម្រឹគ ។

បទថា **អាសយា** ប្រែថា ចាកទីនៅ អធិប្បាយថា កេសររាជសីហ៍រមែងចេញទៅអំពីល្អាងមាស ឬអំពីល្អាងប្រាក់ ល្អាងកែវមណី ល្អាងកែវផលឹក និងល្អាងមនោសិលា ។

ក៏កេសររាជសីហ៍នេះ កាលនឹងចេញទៅ (ចាកទីនៅ) រមែងចេញទៅដោយហេតុ ៤ ប្រការ គឺ ត្រូវសេចក្តីងងឹតបៀតបៀន ចេញទៅដើម្បីត្រូវការពន្លឺ ១ , បន្ទោបង់ឧច្ចារបស្សាវៈ ចេញទៅដើម្បីត្រូវការបន្ទោបង់ឧច្ចារបស្សាវៈ , ត្រូវសេចក្តីស្រេកឃ្លានបៀតបៀន ចេញទៅដើម្បីត្រូវការរកចំណី និងត្រូវទឹកសម្ភព (អសុចិ) បៀតបៀន (កើតតម្រេក) ចេញទៅ

ទៅដើម្បីត្រូវការសេពអសទ្ធម្ម ១ ។ តែក្នុងសូត្រនេះ ព្រះមានព្រះភាគទ្រង់បំណងយកកេសរាជសីហ៍ចេញទៅដើម្បីត្រូវការរកចំណី ។

បទថា **វិជម្ភតិ** (មិគពត់កាយ) សេចក្តីថា កេសរាជសីហ៍ដាក់ជើងក្រោយទាំងពីរទុកស្មើគ្នាលើផែនមាស ផែនប្រាក់ ផែនកែវមណី ផែនកែវផលិក និងមនោសិលា យ៉ាងណាមួយ ហើយទម្រេតជើងមុខចេញ ទាញចំណែកក្រោយនៃរាងកាយចូលហើយ ឯចំណែកមុខចេញទៅកោងខ្នង ងើយកបញ្ចេញសំឡេងដូចផ្គរលាន់ រលាស់ធូលីដែលជាប់នៅតាមរាងកាយ ចេញទៅ ឈ្មោះថា មិគពត់ខ្លួន ។

ក៏ឯកេសរាជសីហ៍ រត់ត្រឡប់ទៅត្រឡប់មកនៅលើផែនដី មិគពត់ខ្លួន (នោះឯង) ដូចកូនគោជំទង់ ដូច្នោះ ក៏កាលវារត់ រាងកាយនឹងប្រាកដនៅក្នុងទីងងឹតដូចកំណាត់ឧស (ត្រូវគេវែង) វិលវល់ ដូច្នោះ ។

ក្នុងបទថា **អនុវិលោកេតិ** (ក្រឡេកមើល) មានអធិប្បាយថា ៖

សួរថា ព្រោះហេតុអ្វី កេសរាជសីហ៍ទើបរមិលមើលឆ្វេងស្តាំ ។

ឆ្លើយថា ព្រោះមានសេចក្តីអាណិតក្នុងសត្វដទៃ ។ បានឮមកថា កាលកេសរាជសីហ៍នោះបន្លឺសីហនាទ សត្វទាំងឡាយដូចជា ដំរី ប្រើស និងក្របីដែលកំពុងត្រាច់ (រកស៊ី) ជិតកន្លែងដែលមិនរាបស្មើទាំងឡាយ មានកណ្តាប់

មាត់ជ្រោះជាដើម ក៏នឹង (តក់ស្លុត) ភ្ញាក់ផ្អាក់ចុះទៅក្នុងជ្រោះក៏មាន កេសរ-រាជសីហ៍រមិលមើលឆ្វេងស្តាំ ក៏ព្រោះអាណិតចំពោះសត្វទាំងនោះ ។

សួរថា ក៏កេសររាជសីហ៍នោះ ធ្វើកិច្ចដូចនាយព្រានស៊ីសាច់សត្វដទៃជាប្រចាំ នឹងមានសេចក្តីអាណិតផងឬ ?

ឆ្លើយថា មែនហើយ នៅមាន ។ សេចក្តីពិត កេសររាជសីហ៍នោះមិនចាប់សត្វតូចៗ ជាអាហាររបស់ខ្លួន ព្រោះគិតថា រឿងអ្វីនឹងត្រូវឲ្យសត្វចំនួនច្រើនត្រូវស្លាប់ យ៉ាងនេះឈ្មោះថា ធ្វើសេចក្តីអាណិត ។ សមដូចព្រះតម្រាស់ដែលត្រាស់ទុកដូច្នេះថា (ព្រោះវាគិតថា) សូមកុំធ្វើឲ្យសត្វតូចៗ ដែលនៅតាមស្ថានទីរដិបរដុប (មិនរាបស្មើ) ត្រូវបានទទួលសេចក្តីតក់ស្លុតឡើយ ។

បទថា **សីហនាទំ នទតិ** (បន្លឺសីហនាទ) សេចក្តីថា លំដាប់ដំបូងកេសររាជសីហ៍នឹងបន្លឺ (សីហនាទ) ដែលមិនបន្តរឲ្យកើតសេចក្តីគួរខ្លាច ២ ដង ក៏ឯកាលវាឈរបន្លឺ (សីហនាទ) លើផែនដី មិតពត់ខ្លួនយ៉ាងនោះ សំឡេង (បន្លឺ) ក៏នឹងគ្រហឹម ជាសំឡេងតែមួយទៅជុំវិញទិស រហូតផ្ទៃដី ៣ យោជន៍ ពួកសត្វជើង ២ និងជើង ៤ ដែលនៅខាងក្នុងផ្ទៃដី ៣ យោជន៍ បានឮសំឡេងបន្លឺយ៉ាងខ្ទរខ្ទា គ្រហឹមរបស់កេសររាជសីហ៍នោះហើយ ក៏មិនអាចនឹងឈរក្នុងទីដើមបាន ។

បទថា **គោចរាយ បក្កមតិ** (ចេញទៅដើម្បីរកស៊ី) សេចក្ដីថា ទៅរកចំណី ។ កេសររាជសីហ៍ទៅរកចំណី ដោយវិធីដូចម្ដេច ? អធិប្បាយថា កេសររាជសីហ៍នោះ ឈរលើផែនដីដែលខ្លួនដែលមិតពត់ខ្លួន កាលបោះពួយទៅផ្លូវខាងស្ដាំ ខាងឆ្វេង ឬខាងក្រោយ ក៏នឹង (បោះពួយ) ទៅដល់ផ្ទៃដីបានប្រមាណមួយឧសភៈ កាលលោតឡើងទៅខាងលើ ក៏នឹងលោតឡើងទៅបាន ៤ ឧសភៈខ្លះ ៨ ឧសភៈខ្លះ កាលនឹងលោតលេងត្រង់ៗ លើផ្ទៃដីដែលរាបស្មើ ក៏នឹងលោតលេងទៅបានសូម្បីផ្ទៃដីប្រមាណ ១៦ ឧសភៈខ្លះ ប្រមាណ ២០ ឧសភៈខ្លះ កាលនឹងលោតលេងអំពីត្រើយទន្លេ ឬអំពីភ្នំ ក៏នឹងលោតលេងបានរហូតដល់អស់ផ្ទៃដីប្រមាណ ៦០ ឧសភៈខ្លះ ប្រមាណ ៨០ ឧសភៈខ្លះ ។ (កាលរត់ទៅ) ក្នុងរវាងផ្លូវឃើញដើមឈើ ឬភ្នំ ចូលហើយ កាលនឹងចៀសចេញអំពីដើមឈើ ឬភ្នំនោះ ក៏នឹងចៀសចេញទៅផ្លូវខាងឆ្វេង ខាងស្ដាំ ឬខាងលើ បានប្រមាណមួយឧសភៈ ។ តែកាលបន្លឺសីហនាទលើកទី ៣ ព្រមនឹងការបន្លឺនោះឯង ក៏នឹងប្រាកដក្នុងទី ៣ យោជន៍ គ្រាទៅបាន ៣ យោជន៍ហើយ ក៏នឹងត្រឡប់មកឈប់ឈរស្ដាប់សំឡេងដែលជះត្រឡប់របស់ខ្លួនឯង ។ កេសររាជសីហ៍ ជៀសចេញទៅ (ចាកទីនៅ) ដោយភាពរហ័សយ៉ាងនេះ ។

បទថា **យេភុយ្យេន** បានដល់ **បាយេន** (ប្រែថា ដោយច្រើន) ។ បទ

ថា **ភយំ សំវេគំ សន្តាសំ** ទាំងអស់ ជាឈ្មោះនៃសេចក្ដីភ័យតក់ស្លុតនៃចិត្ត ទ្រុំងឯង ។ ព្រោះថា សត្វចំនួនច្រើនបានស្ដាប់សំឡេងរាជសីហ៍ហើយ រមែង (តក់ស្លុត) ខ្លាច ។ ដែលមិនខ្លាច មានចំនួនតិច ។

សួរថា ក៏សត្វចំនួនតិចទាំងនោះ គឺ ពួកណាខ្លះ ?

ឆ្លើយថា សត្វទាំងនោះប គឺ រាជសីហ៍ផងគ្នា ១ ដំរីអាជានេយ្យ ១ សេះអាជានេយ្យ ១ គោឧសុភអាជានេយ្យ ១ បុរសអាជានេយ្យ ១ ព្រះខីណាស្រព ១ ។ សួរថា ក៏ព្រោះហេតុអ្វី សត្វទាំងនោះទើបមិនខ្លាច ?

ឆ្លើយថា រាជសីហ៍ផងគ្នាដែលមិនខ្លាច ក៏ព្រោះគិតថា យើងស្មើគ្នា ដោយជាតិ គោត្រ ត្រកូល និងសេចក្ដីក្លាហាន ។ ដំរីអាជានេយ្យជាដើម ដែលមិនខ្លាច ក៏ព្រោះខ្លួនឯងមានសក្កាយទិដ្ឋិខ្លាំងក្លា ។ (ចំណែក) ព្រះខីណាស្រព មិនខ្លាច ព្រោះលោកលះសក្កាយទិដ្ឋិបានហើយ ។

បទថា **ពិលាសយា** (អាស្រ័យនៅក្នុងរន្ធ) បានដល់ សត្វដែលនៅក្នុងរន្ធ គឺ រស់នៅក្នុងរន្ធជាប្រចាំ មានពស់ សត្វស្កា និងសត្វទន្សងជាដើម ។ បទថា **ទកាសយា** (អាស្រ័យក្នុងទឹក) បានដល់ សត្វដែលនៅក្នុងទឹក មាន ត្រី និងអណ្ដើកជាដើម ។ បទថា **វនាសយា** (អាស្រ័យនៅក្នុងព្រៃ) បានដល់ សត្វដែលនៅក្នុងព្រៃ (សត្វព្រៃ) មានដំរី សេះ ប្រើស និងម្រឹគជាដើម ។

បទថា **បវិសន្តិ** (នឹងចូលទៅ) សេចក្តីថា ចូលទៅបណ្តើរ សម្លឹងមើលផ្លូវដោយគិតថា រាជសីហ៍នឹងមកចាប់យកក្នុងកាលឥឡូវនេះ ។ បទថា **ទឡ្ហេហិ** ប្រែថា រឹងមាំ ។ បទថា **វរត្តេហិ** ប្រែថា ខ្សែស្បែក ។ ក្នុងបទថា **មហិទ្ធិកោ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

គប្បីជ្រាបថា កេសររាជសីហ៍មានឫទ្ធិច្រើន ដោយការឈរលើផែនដីដែលខ្ទនមិតពត់កាយ ហើយលោតទៅខាងស្តាំជាដើម បានប្រមាណមួយឧសភៈ លោតត្រង់ទៅខាងមុខ បានប្រមាណ ២០ ឧសភៈជាដើម ។ គប្បីជ្រាបថា កេសររាជសីហ៍មានសក្តិធំ ដោយការជាម្ចាស់នៃម្រឹគដ៏សេសទាំងឡាយ ។

គប្បីជ្រាបថា កេសររាជសីហ៍មានអានុភាពច្រើន ព្រោះពួកសត្វដ៏សេសបានស្តាប់សំឡេងក្នុងទីប្រមាណ ៣ យោជន៍ដោយជុំវិញហើយ នឹងនាំគ្នាគេចចេញទៅ ។

[១៥៦] បទថា **ឯវមេវ ខោ** មានអធិប្បាយថា ព្រះមានព្រះភាគត្រាស់ចំពោះព្រះអង្គថា ដូចយ៉ាងនោះៗ ក្នុងសូត្រនោះៗ (គឺ) ៖

លំដាប់ដំបូង ក្នុងសូត្រនេះថា “ម្នាលភិក្ខុទាំងឡាយ ពាក្យថា សីហៈ នេះឯង ជាឈ្មោះរបស់តថាគតអរហន្តសម្មាសម្ពុទ្ធ” ព្រះមានព្រះភាគត្រាស់ដល់ព្រះអង្គថា ដូចជារាជសីហ៍ ។

ក្នុងសូត្រនេះថា “ម្នាលសុនក្ខត្តៈ ពាក្យថា គ្រូពេទ្យអ្នកវះកាត់នេះឯង ជាឈ្មោះរបស់តថាគត” ព្រះមានព្រះភាគ ត្រាស់ចំពោះព្រះអង្គថា ដូចជាគ្រូពេទ្យ ។

ក្នុងសូត្រនេះថា “ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍នេះឯងជាឈ្មោះរបស់តថាគត” ព្រះមានព្រះភាគត្រាស់ដល់ព្រះអង្គថា ដូចជាព្រាហ្មណ៍ ។

ក្នុងសូត្រនេះថា “ម្នាលតិស្សៈ ពាក្យថា បុរសអ្នកឆ្លាតក្នុងផ្លូវនេះឯងជាឈ្មោះរបស់តថាគត” ព្រះមានព្រះភាគត្រាស់ដល់ព្រះអង្គថា ដូចជាមគ្គុទេសក៍ ។

ក្នុងសូត្រនេះថា “ម្នាលសេលៈ តថាគតជាព្រះរាជា” ព្រះមានព្រះភាគត្រាស់ដល់ព្រះអង្គថា ដូចជាព្រះរាជា ។

តែក្នុងសូត្រនេះ ព្រះមានព្រះភាគកាលនឹងត្រាស់ដល់ព្រះអង្គថា ដូចជារាជសីហ៍នោះឯង ទើបបានត្រាស់ទុកយ៉ាងនេះ ។

ក្នុងព្រះតម្រាស់នោះមាន (ប្រការប្រៀបធៀប) ដូចគ្នាដូចតទៅនេះ ៖

វេលាដែលព្រះតថាគតទ្រង់ធ្វើអភិនិហារ (ប្រាថ្នាពុទ្ធភូមិ) ទៀបបាទមូលរបស់ព្រះទីបង្ករសម្ពុទ្ធ ហើយទ្រង់បំពេញបារមីមកអស់វេលារាប់មិនបានក្នុងភពចុងក្រោយ ទ្រង់ធ្វើម៉ឺនលោកធាតុឲ្យញាប់ញ័រដោយការបដិសន្ធិ និង

ដោយការប្រសូតិចាកព្រះគភ៌របស់ព្រះមាតា (តមក) ទ្រង់ចម្រើនវ័យ បាន សោយសម្បត្តិដូចជាទិព្វ ប្រថាប់នៅក្នុងប្រាសាទ ៣ ខ្នង គប្បីឃើញថា ដូចគ្នានឹងវេលាដែលរាជសីហ៍នៅក្នុងល្អាង មានល្អាងមាសជាដើម ដូច្នោះ ។

វេលាដែលព្រះតថាគតទ្រង់ប្រថាប់លើខ្នងសេះកណ្ឋកៈ មាននាយឆន្នៈជាសម្លាញ់ ស្តេចចេញតាមទ្វារព្រះ (នគរ) ដែលទេវតាបើកថ្វាយ (មិនពេញព្រះទ័យ) ក្នុងរាជសម្បត្តិទាំង ៣ ទ្រង់ស្លៀកដណ្តប់សំពត់កាសាវៈដែលព្រហ្មបង្អោនទូលថ្វាយហើយ (អធិដ្ឋានព្រះទ័យ) បួសត្រង់មាត់ច្រាំងស្ទឹងអនោមានទី កាលមានព្រះជន្មាយុបាន ២៩ ព្រះវស្សា (តពីនោះ) ក្នុងថ្ងៃទី ៧ ស្តេចទៅកាន់ក្រុងរាជគ្រឹះ ស្តេចត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះនោះហើយ (មកប្រថាប់) សោយព្រះក្រយាហារត្រង់ញកភ្នំឈ្មោះ បណ្ឌវៈ ដរាបដល់ (វេលា) ដែលទ្រង់ប្រទានបដិញ្ញាចំពោះព្រះរាជា (ពិម្ពិសារ) ថា កាលបានត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណហើយ ស្តេចនឹងមកកាន់ដែនមគធមុន គប្បីឃើញថា ដូចជាវេលាដែលរាជសីហ៍ចេញចាកល្អាងជាទីនៅ មានល្អាងមាសជាដើម ដូច្នោះ ។

តាំងពីព្រះតថាគតទ្រង់ប្រទានបដិញ្ញា (ចំពោះព្រះរាជា) ហើយ ចូលទៅរកអាឡារតាបសកាលាមគោត្រ រហូតដល់វេលាសោយមធុបាយាស ដែលនាងសុជាតាថ្វាយដោយ (ពូតជា) ពំនូត ៤៩ ដុំ គប្បីជ្រាបថា ដូចវេលាដែល

រាជសីហ៍មិតពត់កាយ ដូច្នោះ ។

កាលព្រះតថាគត ទ្រង់ទទួលស្លៅ ៨ ក្តាប់ ដែលសោត្ថិយព្រាហ្មណ៍ (ថ្វាយ) ក្នុងវេលាល្ងាច ដែលទេវតាក្នុងម៉ឺនចក្រវាឡសរសើរ (ព្រះកិត្តិគុណ) (និង) បូជាដោយគ្រឿងបូជា មានគ្រឿងក្រអូបជាដើម ទ្រង់បានធ្វើប្រទក្សិណ (ស្តេចយាងខាងស្តាំ) ពោធិព្រឹក្ស ៣ ជុំវិញ ហើយទ្រង់ឈានឡើងកាន់ពោធិ-បល្ល័ង្ក ទ្រង់ក្រាលស្លៅជាកម្រាល (ទ្រនាប់អង្គុយ) លើទីខ្ពស់ ១៤ ហត្ថ ហើយប្រថាប់អង្គុយអធិដ្ឋានចតុរង្គប្បធាន (សេចក្តីព្យាយាមមានអង្គ ៤) ក្នុងខណៈនោះឯង ទ្រង់កម្ចាត់មារ និងពលសេនាមារបានហើយ ទ្រង់ជម្រះវិជ្ជា ៣ ឲ្យបរិសុទ្ធិក្នុងយាមទាំង ៣ ទ្រង់ពិចារណាទាំងអនុលោម និងបដិលោមដោយការពិចារណាញាណគូ[១] , (យមកញ្ញាណ) គឺ បហានញ្ញាណ និងសមុទយ-ញ្ញាណ នៃបដិច្ចសមុប្បាទ កាលទ្រង់ចាក់ធ្លុះព្រះសព្វញ្ញុតញ្ញាណហើយ ធ្វើម៉ឺនលោកធាតុឲ្យញាប់ញ័រ ដោយអានុភាពនៃព្រះសព្វញ្ញុតញ្ញាណនោះ គប្បីជ្រាបថា ដូចដែលរាជសីហ៍រលាស់រោមរបាំងក ដូច្នោះ ។

---

១-(បាឋៈថា បដិច្ចសមុប្បាទបហានសមុទយយមកញ្ញាណបដិវេធន បវេត្តនស្ស ច្បាប់កូមាជា បដិច្ចសមុប្បាទមហាសមុទ្ទំ យមកញ្ញាណមន្ថនេន មន្ថេន្តស្ស ប្រែថា ទ្រង់ញាំញីមហាសមុទ្រ គឺ បដិច្ចសមុប្បាទ ទាំងអនុលោម និងបដិលោម ញាំញីដោយញាណទាំងគូ ។

ការដែលព្រះតថាគត ទ្រង់ចាក់ដុះព្រះសព្វញ្ញុតញ្ញាណហើយ ប្រថាប់នៅត្រង់គល់ពោធិអស់ ៧ សប្តាហ៍ សោយព្រះក្រយាហារ គឺ មធុបាយាស ៤៩ ដុំ ក្នុងមួយថ្ងៃអស់ហើយ (តពីនោះស្តេចប្រថាប់) ទៀបគល់ឈើអជបាលនិគ្រោធ ទ្រង់ទទួលពាក្យអារាធនារបស់ស្តេចមហាព្រហ្ម ដែលទូលសូមឲ្យទ្រង់សម្តែងធម៌ ហើយប្រថាប់នៅក្បែរគល់អជបាលនិគ្រោធនោះ (ឯង) ក្នុងថ្ងៃទី ១១ (បន្ទាប់ពីថ្ងៃដែលប្រថាប់នៅក្បែរគល់អជបាលនិគ្រោធ) ទ្រង់ត្រិះរិះថា ថ្ងៃស្អែកនេះ ជាថ្ងៃអាសាឡ្ហបុណ្ណមីហើយ វេលាជិតភ្លឺទ្រង់រំពឹងថា តថាគតគួរសម្តែងធម៌ដល់អ្នកណាមុន (លុះ) ទ្រង់ជ្រាបថា អាឡារតាបស និងឧទ្ទកតាបសមរណភាពហើយ ទើបបានពិចារណាមើលបញ្ចវគ្គិយ ដើម្បីត្រូវការនឹង (ស្តេចទៅ) សម្តែងធម៌ប្រោស គប្បីឃើញថា ដូចវេលាដែលរាជសីហ៍ត្រួតមើលទិសទាំង ៤ ដូច្នោះ ។

វេលាដែលព្រះ តថាគតទ្រង់ប្រដាប់បាត្រ និងចីវររបស់ព្រះអង្គ ស្តេចចេញចាកពីដើមអជបាលនិគ្រោធ ខាងក្រោយសោយព្រះក្រយាហារហើយ ដោយទ្រង់ត្រិះរិះថា នឹងបង្វិលចក្ក គឺ ធម៌ ប្រោសដល់បញ្ចវគ្គិយ ដូច្នេះ ហើយស្តេចពុទ្ធដំណើរអស់រយៈផ្លូវ ១៨ យោជន៍ គប្បីឃើញថា ដូចវេលាដែលរាជសីហ៍ធ្វើដំណើរទៅរកចំណី អស់រយៈផ្លូវ ៣ យោជន៍ ដូច្នោះ ។

វេលាដែលព្រះតថាគត ស្ដេចពុទ្ធដំណើរទៅអស់រយៈផ្លូវ ១៨ យោជន៍ ហើយប្រថាប់គង់ពត់ភ្នែនយ៉ាងល្អ បញ្ចុះបញ្ចូលព្រះបញ្ចវគ្គិយ ដែលពួកទេវតា (មក) ប្រជុំគ្នាអំពីម៉ឺនចក្រវាឡ ទ្រង់បន្លឺលចក្កធម៌ ដោយន័យជាដើមថា "ម្នាល ភិក្ខុទាំងឡាយ អន្តធម៌ទាំងឡាយពីរប្រការនេះ ដែលបព្វជិតមិនគួរសេព" គប្បី ជ្រាបថា ដូចវេលាដែលរាជសីហ៍បន្លឺសីហនាទ ដូច្នោះ ។

ក៏កាលព្រះតថាគតទ្រង់សម្ដែងធម្មចក្រនេះហើយ ព្រះសូរសេងសម្ដែង ធម៌របស់រាជសីហ៍ គឺ ព្រះតថាគត ដូចបានឮទៅទូទាំងម៉ឺនលោកធាតុ ចំណែក ខាងក្រោម ដូចទៅដល់អវិចី ខាងលើដូចទៅដល់ភវគ្គព្រហ្ម ។

វេលាដែលព្រះតថាគតត្រាស់ទូន្មានធម៌ សម្ដែងលក្ខណៈ ៣ បែកសច្ចៈ ៤ ព្រមទាំងអាការ ១៦ រហូតដល់ពាន់ន័យ ពួកទេវតាដែលមានអាយុវែង កើតសេចក្ដីតក់ស្លុតដោយញាណ គប្បីជ្រាបថា ដូចវេលាដែលសត្វតូចៗ ត្រូវ តក់ស្លុត ព្រោះសំឡេងរាជសីហ៍ ដូច្នោះ ។

បទថា **យទា** គឺ **យស្មឹ កាលេ** (ក្នុងកាលណា) ។

បទថា **តថាគតោ** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ដោយហេតុ ៨ ប្រការ គឺ ៖

(១) ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្ដេចមកហើយយ៉ាងនោះ ។

(២) ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្ដេចទៅ ហើយយ៉ាងនោះ ។

(៣) ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្ដេចមកកាន់លក្ខណៈដែលពិតប្រាកដ ។

(៤) ទ្រង់ព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងធម៌ដែលពិត តាមសេចក្ដីពិត ។

(៥) ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់មានប្រក្រតីឃើញពិត ។

(៦) ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់មានប្រក្រតីត្រាស់ពិត ។

(៧) ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់មានប្រក្រតីធ្វើពិត ។

(៨) ទ្រង់ព្រះនាមថា **តថាគត** ព្រោះគ្របសង្កត់ ។

សេចក្ដីពិស្ដាររបស់ព្រះនាមទាំងនោះ បានពោលទុកហើយក្នុងអដ្ឋកថាព្រហ្មជាលសូត្រ ទាំងក្នុងអដ្ឋកថាមូលបរិយាយសូត្រ ។

បទថា **លោកេ** បានដល់ ក្នុងសត្វលោក ។ បទថា **ឧប្បជ្ជតិ** សេចក្ដីថា ព្រះតថាគត ឈ្មោះថា ស្ដេចកំពុងឧប្បត្តិឡើង ផ្ដើមពីការតាំងសេចក្ដីប្រាថ្នា (ពុទ្ធភូមិ) ដរាបដល់ (ប្រថាប់អង្គុយទៀប) ពោធិបល្ល័ង្ក ឬ (សម្រេច) អរហត្តមគ្គញ្ញាណ តែកាលសម្រេចអរហត្តផលហើយ ឈ្មោះថា ស្ដេចឧប្បត្តិឡើងហើយ ។ បទទាំងឡាយ មានបទថា **អរហំ សម្មាសម្ពុទ្ធោ** ជាដើម ខ្ញុំ

(ព្រះពុទ្ធឃោសាចារ្យ) បានអធិប្បាយទុកហើយយ៉ាងពិស្តារក្នុងពុទ្ធានុស្សតិ-និទ្ទេស ក្នុងបករណ៍ពិសេសឈ្មោះថា វិសុទ្ធិមគ្គ ។

បទថា **ឥតិ រូបំ** សេចក្តីថា នេះគឺ រូប រូបមានប៉ុណ្ណេះ មិនមានរូបដទៃក្រៅអំពីនេះ ។

ដោយព្រះតម្រាស់ត្រឹមតែប៉ុណ្ណេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ (ឧបាទាយរូប) ទាំងអស់ ទាំងដោយសភាវៈ ទាំងដោយសេចក្តីពិត ទាំងដោយទីបំផុត ទាំងដោយការកំណត់ ទាំងដោយការប្រែប្រួល ។

បទថា **ឥតិ រូបស្ស សមុទយោ** សេចក្តីថា នេះឈ្មោះថា ការកើតឡើងនៃរូប ។

ក៏ដោយព្រះតម្រាស់ត្រឹមតែប៉ុណ្ណេះ ព្រះមានព្រះភាគ ទ្រង់សម្តែងដល់ពាក្យទាំងអស់ មានជាដើមថា ព្រោះអាហារកើត រូបទើបកើត ។ បទថា **ឥតិ រូបស្ស អត្ថង្គមោ** សេចក្តីថា នេះឈ្មោះថា សេចក្តីរលត់នៃរូប ។ សូម្បីដោយព្រះតម្រាស់នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងដល់ពាក្យទាំងអស់ មានជាដើមថា ព្រោះអាហាររលត់ រូបទើបរលត់ ។ សូម្បីក្នុងបទថា **ឥតិ វេទនា** ជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **វណ្ណវន្តោ** ប្រែថា មាន (សម្បុរ) ពណ៌

(ផូរផង់) ដោយពណ៌សម្បុររបស់រាងកាយ ។ បទថា **ធម្មទេសនំ សុត្វា** សេចក្តីថា ស្តាប់ព្រះធម៌ទេសនារបស់ព្រះតថាគត ដែលប្រដាប់ដោយលក្ខណៈ ៥០ ក្នុងខន្ធទាំង ៥ នេះ ។

បទថា **យេភុយ្យេន** បានដល់ ក្នុងលោកនេះ វៀរទេវតាដែលជាព្រះអរិយសាវក ។

អធិប្បាយថា ទេវតាដែលជាព្រះអរិយសាវកទាំងនោះ មិនកើតសូម្បីសេចក្តីភ័យខ្លាច គឺ សេចក្តីតក់ស្លុត ព្រោះលោកជាព្រះខីណាស្រព ទាំងមិនកើតសេចក្តីសង្វេគដោយញាណ ព្រោះបុគ្គលដែលសង្វេគ បានសម្រេចផលដែលនឹងគប្បីសម្រេចបានដោយសេចក្តីព្យាយាមហើយ ដោយឧបាយនៃប្រាជ្ញា តែទេវតាក្រៅពីនេះ ធ្វើទុកក្នុងចិត្តដល់ភាវៈដែលមិនទៀង តាមដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ក៏សេចក្តីតក់ស្លុតនោះមាន" ទើបកើត[១] សូម្បីសេចក្តីភ័យខ្លាច គឺ សេចក្តីតក់ស្លុត ទាំងកើតសេចក្តីខ្លាច ព្រោះញាណ ក្នុងវេលាដែលវិបស្សនាចាស់ក្លា ។

ពាក្យថា **ភោ** នោះ ត្រឹមតែជាវោហារ ការហៅតាមធម្មតាប៉ុណ្ណោះ ។

---

១ (ច្បាប់ភូមា ជា **ឧប្បជ្ជតិ** មិនមាន **ន** បដិសេធ ប្រែតាមច្បាប់ភូមា) ។

បទថា **សក្កាយបរិយាបន្នា** ប្រែថា ជាប់ដោយបញ្ចក្ខន្ធ ។ កាលព្រះសម្មាសម្ពុទ្ធ ទ្រង់ចង្អុលទោសនៃវដ្ដៈ ហើយទ្រង់សម្ដែងព្រះធម៌ទេសនា ប្រកបដោយត្រៃលក្ខណ៍ដល់ទេវតាទាំងនោះហើយ ញាណភ័យ ទើបឈានចុះដោយប្រការដូច្នេះ ។

**[១៥៧]** បទថា **អភិញ្ញាយ** ប្រែថា ដឹងហើយ ។

បទថា **ធម្មចក្កំ** សំដៅយក បដិវេធញ្ញាណខ្លះ ទេសនាញាណខ្លះ ។ ព្រះញាណ ដែលជាហេតុឲ្យព្រះមានព្រះភាគអ្នកប្រថាប់អង្គុយទៀបពោធិបល្ល័ង្ក បានចាក់ធ្លុះ (អរិយ) សច្ចៈ ៤ ព្រមទាំងអាការ ១៦ បានគ្រប់ ១.០០០ ន័យ ឈ្មោះថា បដិវេធញ្ញាណ ។ ព្រះញាណ ដែលជាហេតុឲ្យព្រះមានព្រះភាគទ្រង់ប្រកាសធម្មចក្ក ដែលមានបរិវដ្ដ ៣ (និង) មានអាការ ១២ ឈ្មោះថា ទេសនាញាណ ។

ព្រះញាណទាំងពីរនោះ ជាញាណដែលកើត (ខាង) ក្នុងព្រះទ័យរបស់ព្រះទសពលប៉ុណ្ណោះ បណ្ដាព្រះញាណទាំងពីរនោះ **ទេសនាញាណ** គប្បី (កំណត់) កាន់យកក្នុងទីនេះ ។

ក៏ឯទេសនាញាណនេះ គប្បីជ្រាបថា ដរាបណាដែលសោតាបត្តិផល មិនទាន់កើតដល់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ព្រមទាំងព្រហ្ម ១៨ កោដិ ដរាបនោះ

មិនទាន់ឈ្មោះថា ព្រះមានព្រះភាគទ្រង់ប្រកាស កាលសោតាបត្តិផលកើតហើយ (ទុំះឯង) ទើបឈ្មោះថា ទ្រង់ប្រកាសហើយ ។

បទថា **អប្បដិបុគ្គលោ** ប្រែថា ប្រាសចាកបុគ្គលដែលនឹងប្រាកដស្មើ ។

បទថា **យសស្សិនោ** (មានយស) បានដល់ ដល់ព្រមដោយបរិវារ ។

បទថា **តាទិនោ** បានដល់ ដូចគ្នាតែមួយ មានលាភ និងអត់លាភ ជាដើម ។

ចប់អដ្ឋកថា សីហសូត្រទី៦

# អ ដ្ឋ ក ថា

## ខជ្ជនិយសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ខជ្ជនិយសូត្រទី ៧** ដូចតទៅនេះ ៖*

*[១៥៨] បទថា **បុព្វេនិវាសំ** សេចក្តីថា បុព្វេនិវាសានុស្សតិញ្ញាណនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សំដៅយកការរលឹកដល់ ដោយអំណាចអភិញ្ញាក៏ទេ តែត្រាស់សំដៅយកសមណព្រាហ្មណ៍អ្នករលឹកដល់ខន្ធដែលធ្លាប់អាស្រ័យនៅក្នុងភពមុនដោយអំណាចវិបស្សនា ។*

*ដោយហេតុនោះឯង ព្រះអង្គទើបត្រាស់ថា សមណៈ ឬព្រាហ្មណ៍ រមែងរលឹកដល់ខន្ធដែលជាទីតាំងនៃឧបាទាន ៥ ទាំងអស់នោះ ឬខន្ធណាមួយ ក្នុងបណ្តាខន្ធដែលជាទីតាំងនៃឧបាទានទាំង ៥ នោះ ។*

*អធិប្បាយថា ខន្ធក្តី ឧបាទានក្ខន្ធក្តី វត្ថុដែលទាក់ទងដោយខន្ធក្តី បញ្ញត្តិក្តី ចាត់ជាអារម្មណ៍នៃការរលឹកដល់ ដោយអំណាចអភិញ្ញាទាំងនោះ ។*

*បទថា **រូបញ្ញេវ អនុស្សរតិ** សេចក្តីថា ភិក្ខុដែលរលឹកដល់យ៉ាងនេះ មិនមែនរលឹកដល់សត្វ ឬបុគ្គលដទៃណាៗ ទេ ប៉ុន្តែថា លោកបានរលឹកដល់ចំពោះរូបក្ខន្ធដែលរលត់ទៅហើយក្នុងអតីត ។*

សូម្បីក្នុងខន្ធដទៃ មានវេទនាជាដើម ក៏មានន័យនេះដូចគ្នា ។

ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងលក្ខណៈនៃសុញ្ញតា ព្រះមានព្រះភាគទើបត្រាស់ថា **កិញ្ច ភិក្ខវេ រូបំ វទេថ** (ភិក្ខុទាំងឡាយ ព្រោះអ្វីទើបហៅថារូប ដូច្នេះជាដើម ។

អធិប្បាយថា ប្រៀបដូចកាលហ្វូងគោ (មួយ) កំពុងដើររកស៊ី បុរស (ម្នាក់) កំពុងតាមរកគោ (របស់ខ្លួន) ដែលបាត់ទៅ ពេលឃើញគោដែលប្រើមានពណ៌ស ពណ៌ក្រហម ឬពណ៌ខ្មៅ គេក៏មិនអាចសម្រេចចិត្តបាន ដោយហេតុត្រឹមតែឃើញប៉ុណ្ណេះថា នេះគឺ ហ្វូងគោរបស់យើង ព្រោះហេតុអ្វី ? ព្រោះគោដទៃៗ ដែលមានលក្ខណៈដូច្នោះក៏មាន តែលុះបានឃើញស្នាមលំពែងនិងស្នាមស្នជាដើម ត្រង់រាងកាយ (របស់គោ) ហើយ ទើបគេសម្រេចចិត្តថា នេះគឺហ្វូងគោរបស់យើង យ៉ាងណា (រឿងសុញ្ញតា) ក៏ដូច្នោះដែរ ព្រះមាន-ព្រះភាគសូម្បីបានត្រាស់សុញ្ញតាទុកហើយ (តែ) ដរាបណានៅមិនទាន់បានត្រាស់ដល់លក្ខណៈរបស់សុញ្ញតាទុកផង ដរាបនោះ សុញ្ញតានោះ ក៏មិនទាន់ជាការត្រាស់ទុកស្រេចនោះទេ កាលបានត្រាស់ដល់លក្ខណៈរបស់សុញ្ញតាទុកផង (នោះឯង) ទើបរាប់ថា បានត្រាស់សុញ្ញតាទុកស្រេចបាច់ហើយ ។

ព្រោះថា **សុញ្ញតា** ប្រៀបដូចគោ **លក្ខណៈរបស់សុញ្ញតា** ប្រៀបដូច

លក្ខណៈរបស់គោ កាលមិនទាន់បានសង្កេតលក្ខណៈរបស់គោ គោក៏មិនទាន់រាប់ថា បានត្រូវសង្កេតដោយល្អ យ៉ាងណា (លក្ខណៈរបស់សុញ្ញតា) ក៏ដូច្នោះដែរ កាលព្រះមានព្រះភាគមិនទាន់បានត្រាស់ដល់លក្ខណៈរបស់សុញ្ញតាទុកផង សុញ្ញតាក៏មិនរាប់ថាបានត្រាស់ទុកស្រេចបាច់ហើយ តែកាលបានត្រាស់ដល់លក្ខណៈរបស់សុញ្ញតានោះទុក ដោយសុញ្ញតានោះ ទើបជាការត្រាស់ទុកស្រេចបាច់ហើយ ដើម្បីទ្រង់នឹងសម្តែងលក្ខណៈនៃសុញ្ញតាដូចពោលមកនេះ ព្រះមានព្រះភាគទើបត្រាស់ពាក្យថា **កិញ្ច ភិក្ខវេ រូបំ វទេថ** ដូច្នេះជាដើម ។

[១៥៩] បណ្តាបទទាំងនោះ បទថា **កិញ្ច** ជាពាក្យសួរដល់ហេតុ ។ អធិប្បាយថា ដោយហេតុណា អ្នកទាំងឡាយទើបហៅថារូប គឺ ដោយហេតុណា រូបនោះ ទើបឈ្មោះថា រូប ។

បទថា **ឥតិ** ក្នុងពាក្យថា **រុប្បតីតិ ខោ** នេះ ជាបទសម្តែងដល់ហេតុ អធិប្បាយថា ក៏ព្រោះហេតុដែលរូបនោះបែកធ្លាយ ដូច្នោះ ទើបហៅថា រូប ។

បទថា **រុប្បតិ** សេចក្តីថា កម្រើក គឺ ត្រូវប៉ះខ្ទប់ ប៉ះទង្គិច អធិប្បាយថា ត្រូវបៀតបៀន គឺ បែកធ្លាយ ។

ក្នុងពាក្យថា **សីតេនបិ រុប្បតិ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ៖

មុនដំបូង សេចក្តីវិនាសព្រោះត្រជាក់ប្រាកដ (ច្បាស់) ក្នុងលោកន្តរិ-

យនរក ។

អធិប្បាយថា ក្នុងចន្លោះចក្រវាឡ ៣ មានលោកន្តរិយនរកនៅចន្លោះចក្រវាឡមួយៗ (មួយកន្លែងៗ មានទំហំធំ) ប្រមាណ ៨.០០០ យោជន៍ (និង) ខាងក្រោមក៏មិនមានផែនដី ខាងលើក៏មិនមានពន្លឺព្រះច័ន្ទ ពន្លឺព្រះអាទិត្យ (មិនមាន) ពន្លឺប្រទីប (មិនមាន) ពន្លឺកែវមណី ងងឹតឈ្លប់រហូតអស់កាល បណ្តាសត្វដែលកើតក្នុងលោកន្តរិយនរកនោះ មានអត្តភាពប្រមាណ ៣ គាវុត សត្វទាំងនេះប្រើក្រចកដ៏វែង និងក្រាស់ តោងព្យួរក្បាលទៅក្រោម ជើងទៅលើ ដូចសត្វប្រចៀវ កាលណាសត្វនោះសសៀរទៅប៉ះគ្នា កាលនោះ ក៏សម្គាល់ថា យើងបានអាហារហើយ នឹងស្ទុះលោតចូលទៅក្នុងទីនោះ ក៏បានធ្លាក់ចុះទៅក្នុងផ្ទារទឹករក្សាលោក ត្រូវខ្យល់បក់ដាច់ជាកំណាត់ៗ ដូចផ្លែស្រគំ កាលធ្លាក់ចុះទៅក្នុងទឹកនោះ ក៏នឹងពុះខ្ជោលឡើងនៅក្នុងទឹកក្រុត ដូចដុំម្សៅធ្លាក់ចុះក្នុងខ្ទះញដ៏ក្តៅ ដូច្នោះ ។

សេចក្តី វិនាស ព្រោះត្រូវសេចក្តីត្រជាក់ ប្រាកដ (ច្បាស់) ក្នុងលោក-ន្តរិយនរក ដោយប្រការដូចពណ៌នាមកដូច្នេះ ។

សូម្បីក្នុងបណ្តាប្រទេសដែលត្រជាក់ ព្រោះទឹកកកធ្លាក់ មានមហិសរដ្ឋជាដើម សេចក្តីវិនាស (បែប) នោះ ក៏ប្រាកដ (ច្បាស់) និងដូចគ្នា ពិតណាស់

សត្វទាំងឡាយក្នុងប្រទេសទាំងនោះ ដល់ការអស់ជីវិត ព្រោះមានសរីរៈបែកធ្លាយ ព្រោះសេចក្តីត្រជាក់ ។

សេចក្តីវិនាស ព្រោះត្រូវសេចក្តីក្តៅប្រាកដ (ច្បាស់) ក្នុងអវិចីមហានរក ។ សេចក្តីវិនាស ព្រោះសេចក្តីស្រេកឃ្លាន ប្រាកដ (ច្បាស់) ក្នុងបេតវិស័យ និងក្នុងវេលាកើតទុរ្ភិក្ស ។ សេចក្តីវិនាស ព្រោះសេចក្តីស្រេក ប្រាកដ (ច្បាស់) ក្នុងអបាយភូមិ មានកាឡកញ្ជិកាអបាយភូមិ ជាដើម ។

## កាឡកញ្ជិកអសុរ

បានឮមកថា កាឡកញ្ជិកអសុរមួយ មិនអាចអត់ធន់នឹងសេចក្តីស្រេកបាន ទើបចុះមកកាន់ទន្លេគង្គា ដែលជ្រៅ និងមានទទឹងប្រមាណ ១ យោជន៍ (ប្រាកដថា) ក្នុងទីដែលអសុរនោះទៅដល់ ទឹកក៏រីងស្ងួតអស់ (មានតែ) ផ្សែងផ្សាយឡើង វេលានោះអសុរបានដើរទៅមកនៅលើទឹកនោះ ប្រៀបដូចជាដើរលើថ្មដារដែលក្តៅគគុក ។ កាលអសុរនោះ បានឮសំឡេងទឹកហើយ ក៏រត់ទៅ រត់មកយ៉ាងនោះឯង វេលាក៏ភ្លឺ (ល្មម) ។ វេលានោះ ភិក្ខុដែលសមាទានការត្រាច់បិណ្ឌបាតជាវត្តប្រមាណ ៣០ រូប កំពុងដើរទៅបិណ្ឌបាតពីព្រឹកព្រលឹម ឃើញប្រេតនោះ ទើបសួរថា "ញោម ញោមជាអ្នកណា?"

ប. ខ្ញុំជាប្រេត លោកម្ចាស់

ភិ. ប្រេតកំពុងរកអ្វីហ្នឹង?

ប. រកទឹកផឹក លោកម្ចាស់

ភិ. ទន្លេគង្គានេះ (មានទឹក) ពេញប្រៀប ប្រេតមើលមិនឃើញឬ?

ប. ទឹកទន្លេ មិនសម្រេច (ប្រយោជន៍) ឡើយ លោកម្ចាស់

ភិ. បើដូច្នោះ ចូរប្រេតដេកចុះលើផែនដីនៃទន្លេគង្គាចុះ ពួកអាត្មានឹងដងទឹកចាក់ទៅក្នុងមាត់របស់ប្រេត ។

ប្រេតនោះ បានដេកផ្ងារចុះលើច្នេរខ្សាច់ ។ ភិក្ខុបាននាំបាត្រទាំង ៣០ (ផ្លាស់គ្នា) ដងទឹកចាក់ទៅក្នុងមាត់របស់ប្រេតនោះ ។ កាលភិក្ខុទាំងនោះធ្វើយ៉ាងនោះ វេលា (បិណ្ឌបាត) ក៏ជិតចូលមក ។ គ្រានោះ ភិក្ខុទាំងឡាយទើបនិយាយថា ដល់វេលាបិណ្ឌបាតរបស់ពួកអាត្មាហើយប្រេត ប្រេតល្មមបានសេចក្តីសប្បាយចិត្តហើយមែនទេ? ប្រេត ឆ្លើយប្រាប់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើថាទឹកប្រមាណកន្លះទូកដៃ អំពីទឹកដែលលោកម្ចាស់ប្រមាណ ៣០ រូប យកបាត្រទាំង ៣០ ដួសចាក់ឲ្យប្រេតបានហូរចូលទៅក្នុង.ក ដូចចូលទៅក្នុង.ករបស់អ្នកដទៃសោត សូមឲ្យប្រេតចូរកុំរួចផុតពីអត្តភាពជាប្រេតឡើយ ។ សេចក្តីវិនាស ព្រោះសេចក្តីស្រេកប្រាកដ (ច្បាស់) ក្នុងបេតវិស័យដោយប្រការដូចពណ៌នាមកដូច្នេះ ។

សេចក្តីវិនាសព្រោះរបោមជាដើម ប្រាកដ (ច្បាស់) ក្នុងប្រទេសទាំងឡាយដែលច្រើនដោយរបោម និងសត្វល្អិតជាដើម ។

ក៏ក្នុងបទទាំងនេះ គប្បីជ្រាបអធិប្បាយដូចតទៅនេះ ៖

បទថា **ឌំសា** បានដល់ របោម ។

បទថា **មកសា** បានដល់ មូសទុំះឯង ។

សូម្បីខ្យល់ទាំងឡាយក៏គប្បីជ្រាប មានខ្យល់ក្នុងពោះ និងខ្យល់ត្រង់ខ្នងជាដើម ។ ព្រោះថា រោគខ្យល់កើតឡើងក្នុងរាងកាយហើយ រមែងទម្លាយដៃជើង និងខ្នងជាដើម រមែងធ្វើឲ្យជាបុគ្គលខ្វាក់ភ្នែក ឲ្យជាមនុស្សគម ធ្វើឲ្យជាមនុស្សពិការ អស់កម្លាំង ។

បទថា **អាតបោ** ប្រែថា កំដៅថ្ងៃ ។ សេចក្តីវិនាសព្រោះកំដៅថ្ងៃនោះ ប្រាកដ (ច្បាស់) ក្នុងផ្លូវកន្តារទាំងឡាយ មានផ្លូវកន្តារសមុទ្រខ្សាច់ជាដើម ។

មានរឿងដំណាលថា ស្រីម្នាក់នឿយហត់អស់កម្លាំងអំពីការធ្វើដំណើរដោយក្រុមរទេះក្នុងផ្លូវដាច់ស្រយ៉ាលនាសមុទ្រខ្សាច់រហូតអស់មួយយប់ លុះដល់វេលាថ្ងៃ កាលព្រះអាទិត្យរះឡើង ខ្សាច់ក៏ក្តៅឡើង នាងមិនអាចនឹងដាក់ជើងចុះទៅបាន ទើបយកកញ្ជើ (ដែលទូលមក) ចុះអំពីសីសៈហើយជាន់ កាលកញ្ជើក្តៅឡើងៗ ដោយលំដាប់ នាងក៏មិនអាច (ជាន់) ឈរបានទើបដាក់សំពត់

ចុះលើកញ្ជើនោះហើយជាន់ សូម្បីសំពត់នោះក៏ក្តៅទៀត នាងទើបចាប់កូនតូចដែល.ពមកឲ្យដេកផ្កាប់មុខចុះ ហើយ (ឈរ) ជាន់កូនតូចដែលស្រែកយំ (នាង) ត្រូវសេចក្តីក្តៅដុតពេលដ៏ខ្លាំង (មិនយូរ) ក៏ស្លាប់ក្នុងទីនោះឯងព្រមទាំងកូនតូច (របស់នាង) នោះ ។

បទថា **សរីសបា** បានដល់ សត្វដែលមានខ្លួនវែងគ្រប់ប្រភេទ ដែលលូនទៅ សេក្តីវិនាសព្រោះសម្ផស្សរបស់សត្វមានខ្លួនវែងទាំងនោះ គប្បីជ្រាបដោយអំណាចនៃហេតុ ត្រូវអាសេរ្ពិសខាំជាដើម ។

លក្ខណៈ ២

ធម៌ទាំងឡាយ មានលក្ខណៈ ២ យ៉ាង គឺ **សាមញ្ញលក្ខណៈ** (លក្ខណៈទូទៅ) ១ , **បច្ចត្តលក្ខណៈ** (លក្ខណៈចំពោះខ្លួន) ១ ។ បណ្តាលក្ខណៈទាំងពីរនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងបច្ចត្តលក្ខណៈរបស់រូបក្ខន្ធទុក ជាលំដាប់ដំបូង ដោយប្រការដូចពណ៌នាមកដូច្នេះ ។ ក៏បច្ចត្តលក្ខណៈនេះ មានដល់រូបក្ខន្ធទាំងនោះ មិនមានដល់ខន្ធទាំងឡាយ (ក្រៅពីនេះ) មានវេទនាខន្ធជាដើមទេ ព្រោះដូច្នោះ ទើបហៅថា បច្ចត្តលក្ខណៈ ។

ចំណែក **អនិច្ចលក្ខណៈ ទុក្ខលក្ខណៈ** និង**អនត្តលក្ខណៈ** រមែងមានដល់ខន្ធទាំងឡាយ មានវេទនាជាដើមផង ព្រោះដូច្នោះ លក្ខណៈទាំង ៣ នោះ

ទើបហៅថា **សាមញ្ញលក្ខណៈ** ។

## វេទនា

ពាក្យជាដើមថា **កិញ្ច ភិក្ខវេ វេទនំ វទេថ** (ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយហៅវេទនា ដូចម្តេច) ដូចនឹងពាក្យដែលពោលមកមុន ទើបគួរជ្រាបតាមន័យដែលពោលហើយនោះឯង ចំណែកក្នុងពាក្យដែលមិនដូចគ្នានឹងពាក្យដែលពោលមកមុន ពាក្យនោះមានការ ពង្រីកសេចក្តីឲ្យជាក់ច្បាស់ដូចតទៅនេះ ៖

បទថា **សុខំបិ វេទយិតិ** សេចក្តីថា រមែងសោយ គឺ សោយអារម្មណ៍ដែលជាសុខ សូម្បីក្នុងពីរបទតមកក៏មានន័យ (សេចក្តីដូចគ្នា) នេះ ។

សួរថា ក៏អារម្មណ៍នេះ ឈ្មោះថា ជាសុខ ជាទុក្ខ មិនសុខមិនទុក្ខ បានយ៉ាងណា ?

ឆ្លើយថា បាន ព្រោះជាបច្ច័យនៃសុខជាដើម សេចក្តីនេះមានមកហើយក្នុងមហាលិសូត្រនេះថា ម្នាលមហាលិ ក៏ព្រោះហេតុដែលរូប ជាហេតុនាំមកនូវសេចក្តីសុខ ជាហេតុឲ្យឈានចុះកាន់សេចក្តីសុខ ។

ក្នុងបទថា **វេទយតិ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

វេទនានោះឯងសោយសុខ មិនមែនសត្វ ឬបុគ្គលណា ព្រោះថា វេទនា

មានការសោយអារម្មណ៍ជាលក្ខណៈ ព្រោះដូច្នោះ វេទនាសោយបានក៏ព្រោះអាស្រ័យវត្ថុជាមួយអារម្មណ៍ រួមសេចក្តីថា ក្នុងទីនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្តែងចំណែកបច្ចត្តលក្ខណៈប៉ុណ្ណោះ សូម្បីរបស់វេទនា ដោយប្រការដូចពណ៌នាមកដូច្នេះ ។

## សញ្ញា

បទថា **នីលំបិ សញ្ជានាតិ** សេចក្តីថា ចាំបាន ដោយធ្វើបរិកម្មក្នុងផ្កាឈើពណ៌ខៀវ ឬក្នុងសំពត់ ចូលដល់ឧបចារៈ ឬអប្បនា ក៏ឈ្មោះថា សញ្ញាគួរទាំងបរិកម្មសញ្ញា ទាំងឧបចារៈសញ្ញា ទាំងអប្បនាសញ្ញា សូម្បីសញ្ញាដែលកើតឡើងថា ពណ៌ខៀវ ពណ៌ខៀវ ក៏គួរនោះឯង ។ សូម្បីក្នុងវត្ថុទាំងឡាយមានពណ៌លឿងជាដើម ក៏មានន័យនេះដូចគ្នា សូម្បីក្នុងទីនេះ ព្រះមានព្រះភាគទ្រង់សម្តែងចំពោះបច្ចត្តលក្ខណៈរបស់សញ្ញា ដែលមានការចាំបានជាលក្ខណៈ ។

## សង្ខារ

បទថា **រូបំ រូបត្តាយ សង្ខតំ អភិសង្ខរោន្តិ** (តាក់តែងសង្ខតធម៌ គឺរូប ដោយសភាពជារូប) សេចក្តីថា ចុងភៅចម្អិនយាគូ ក៏ដើម្បីឲ្យជាយាគូ តាក់តែងទឹកដោះ ក៏ដើម្បីឲ្យជាទឹកដោះនោះឯង យ៉ាងណា សង្ខារទាំងឡាយក៏ដូច្នោះ តាក់តែង គឺ ប្រមូលមក បានដល់ រួបរួមទុក អធិប្បាយថា រមែងឲ្យ

សម្រេចនូវរូបនោះឯង ដែលបានឈ្មោះថា **សង្ខត:** ព្រោះបច្ច័យទាំងឡាយមកប្រជុំគ្នាតាក់តែង ដើម្បីឲ្យកើតរូប គឺ ដើម្បីឲ្យកើតរូបនោះ ដោយប្រការដែលវត្ថុដែលត្រូវតាក់តែង និងឈ្មោះថា ជារូបបាន ។ សូម្បីក្នុងវេទនាទាំងឡាយ ក៏មានន័យដូចគ្នានេះឯង ។ ក៏ក្នុងពេលដែលពោលដោយសង្ខារនេះ មានសេចក្ដីសង្ខេបដូច្នេះ ៖

សង្ខារទាំងឡាយ រមែងតាក់តែង គឺ ញ៉ាំងរូបដែលកើតព្រមជាមួយខ្លួន ឬធម៌ទាំងឡាយមានវេទនាជាដើម ដែលសម្បយុត្តគ្នាឲ្យកើត សូម្បីក្នុងទីនេះ ព្រះមានព្រះភាគជាម្ចាស់ ក៏ទ្រង់សំដែងចែកចំពោះបច្ចត្តលក្ខណៈរបស់សង្ខារ ដែលមានការតាំងចិត្តជាលក្ខណៈ ដោយប្រការដូច្នេះ ។

## វិញ្ញាណ

បទថា **អម្ពិលម្បិ វិជានាតិ** សេចក្ដីថា រមែងដឹងរសជូររបស់ផ្លែស្វាយ ផ្លែម្កាក់ និងផ្លែក្រូចឆ្មាជាដើម ថាជារសជូរ ។

ក្នុងបទទាំងពួងក៏ន័យនេះ ។ម្យ៉ាងទៀត ក្នុងបទទាំងនេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **តិត្តកំ** បានដល់ រសល្វីងផ្សេងៗ មានរសល្វីងរបស់ស្ដៅ និងអំបែងថ្ងៃជាដើម ។

បទថា **កដកំ** បានដល់ រសហិរផ្សេងៗ មានរសហិររបស់ជីរប្លី និង ម្ទេសជាដើម ។

បទថា **មធុរំ** បានដល់ រសផ្អែមផ្សេងៗ មានរសផ្អែមរបស់ទឹកដោះថ្លា និងទឹកអំពៅជាដើម ។

បទថា **ខារិកំ** បានដល់ រសខារផ្សេងៗ មានរសខាររបស់ត្រប់ ត្នោត, លំពេក , ទំពាំង , ដូង , ថ្មៃ និងផ្តៅជាដើម ។

បទថា **អខារិកំ** បានដល់ ផ្លែឈើប្រភេទណាមួយ (និង) ស្លឹកឈើដែល មានរសលាយគ្នា មានស្លឹកស្វាជាដើម ។

បទថា **លោណិកំ** បានដល់ រសប្រៃផ្សេងៗ មានរសប្រៃរបស់យាគូ ដាក់អំបិល ត្រីប្រឡាក់ និងបាយដាក់អំបិលជាដើម ។

បទថា **អលោណិកំ** បានដល់ រសសាបផ្សេងៗ មានរសយាគូមិនដាក់ អំបិល ត្រីមិនប្រឡាក់អំបិល ភត្តមិនដាក់អំបិលជាដើម ។

បទថា **តស្មា វិញ្ញាណន្តិ វុច្ចតិ** សេចក្តីថា ព្រោះហេតុដែលវិញ្ញាណ ដឹងច្បាស់នូវរស ចែកជាប្រភេទមានរសជូរជាដើមនេះ ដោយការចែកផ្សេងៗ គ្នា គឺ មានរសជូរជាដើម ។ ដូច្នោះទើបហៅថា វិញ្ញាណ ។

សូម្បីក្នុងទីនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងចែកចំពោះបចត្តលក្ខណៈ

របស់វិញ្ញាណ ដែលមានការដឹងច្បាស់ (អារម្មណ៍) ជាលក្ខណៈ ដោយប្រការដូចពណ៌នាមកដូច្នេះឯង ។

## សញ្ញា វិញ្ញាណ បញ្ញា

ក៏ព្រោះហេតុ សញ្ញាប្រាកដ ដោយកំណត់ដល់អាការ និងសណ្ឋានរបស់អារម្មណ៍ ដូច្នោះ សញ្ញានោះ ទើបទ្រង់ចែកទុកក្នុងចក្ខុទ្វារ ។ (តែ) ព្រោះហេតុវិញ្ញាណប្រាកដ ដោយកំណត់ប្រភេទ គឺ ប្រចក្សចំពោះអារម្មណ៍ វៀរ (ការកំណត់) អាការ និងសណ្ឋាន ដូច្នោះ វិញ្ញាណនោះ ទើបទ្រង់ចែកទុកក្នុងជិវ្ហាទ្វារ ។

ម្យ៉ាងទៀត ដើម្បីកំណត់ដល់សភាវៈសញ្ញា និងវិញ្ញាណទាំងនេះ ដោយមិនវង្វេង ទើបគួរជ្រាបដល់សេចក្តីប្លែកគ្នាក្នុងបទទាំងនេះថា **សញ្ជានាតិ** (សញ្ញា) **វិជានាតិ** (វិញ្ញាណ) **បជានាតិ** (បញ្ញា) ។

ក្នុងបទទាំង ៣ នោះ ត្រឹមតែឧបសគ្គ (សំ, វិ, ប) ប៉ុណ្ណោះ ដែលប្លែកគ្នា ចំណែកបទថា **ជានាតិ** មិនប្លែកគ្នាឡើយ ។ ម្យ៉ាងទៀត ព្រោះបទថា **ជានាតិ** នោះ មានអត្ថថា **ដឹង** ទើបគួរជ្រាបសេចក្តីប្លែកគ្នាដូចតទៅនេះ ៖

អធិប្បាយថា **សញ្ញា** ត្រឹមតែការចាំបាននូវអារម្មណ៍ មានពណ៌ខៀវជាដើមប៉ុណ្ណោះ (តែ) មិនអាចឲ្យដល់ការចាក់ធ្លុះ (សាមញ្ញ) លក្ខណៈ គឺ

មិនទៀង ជាទុក្ខ ជាអនត្តាបាន ។ វិញ្ញាណ រមែងដឹងអារម្មណ៍ មានពណ៌ខៀវជាដើម និងឲ្យដល់ការចាក់ធ្លុះ (សាមញ្ញ) លក្ខណៈ មានការមិនទៀងជាដើម តែមិនអាចឲ្យឈានទៅដល់មគ្គបាន ។

បញ្ញា រមែងដឹងច្បាស់អារម្មណ៍ មានពណ៌ខៀវជាដើមផង រមែងឲ្យដល់ការចាក់ធ្លុះ (សាមញ្ញ) លក្ខណៈ មានមិនទៀងជាដើមផង ទាំងឲ្យឈានទៅដល់សេចក្តីប្រាកដនៃមគ្គផង ។

## ប្រៀបធៀប

ប្រៀបដូច កាលមនុស្សនាំកហាបណៈមកធ្វើជាគំនរ ទុកលើផែនក្តារបស់ហេរញ្ញិក កាលមនុស្ស ៣ នាក់ គឺ កុមារតូច អ្នកស្រុកជម្ពូតា (និង) ហេរញ្ញិកអ្នកស្ទាត់ជំនាញ ឈរសម្លឹងមើល កុមារតូច ដឹងត្រឹមតែថា កហាបណៈទាំងឡាយស្អាតល្អ វិចិត្រ (មានលក្ខណៈ) បួនជ្រុង និងមូល ជាដើម (តែ) មិនដឹងថា នេះជារតនសម្បត្តិ ដែលប្រើជាគ្រឿងឧបភោគបរិភោគនៃមនុស្សទាំងឡាយ ។

អ្នកស្រុកជម្ពូតា ដឹងថា កហាបណៈទាំងឡាយស្អាតល្អជាដើម ជារតនសម្បត្តិ ជាគ្រឿងឧបភោគ និងបរិភោគរបស់មនុស្សទាំងឡាយ តែមិនដឹងថា នេះជាវត្ថុក្លែងក្លាយ នេះជាវត្ថុពិត នេះសាច់មិនល្អ នេះសាច់ល្អ ។

ហេរញ្ញិកអ្នកស្ទាត់ជំនាញ រមែងដឹងថា កហាបណៈទាំងឡាយស្អាតល្អជាដើម រមែងដឹងថា កហាបណៈទាំងឡាយហៅថា រតនៈ ទាំងរមែងដឹងថា ជារបស់ក្មេងក្លាយជាដើមផង ។

ក៏កាលដឹង ពេលបានឃើញរូបខ្លះ បានឮសំឡេងខ្លះ បានហិតក្លិនខ្លះ បានភ្លក់រសខ្លះ ប្រើដៃថ្លឹងមើលដល់សភាពធ្ងន់ស្រាលខ្លះ ក៏ជ្រាបបាន (ក្តាម) ថា ធ្វើនៅស្រុកឯណោះខ្លះ ជ្រាបថា ធ្វើនៅនិគមឯណោះ ក្រុងឯណោះ មួយភ្នំឯណោះ (និង) មាត់ច្រាំងទន្លេឯណោះខ្លះ ជ្រាបថា អាចារ្យឯណោះធ្វើ យ៉ាងណា (សញ្ញា វិញ្ញាណ និងបញ្ញា) ក៏ដូច្នោះដែរ (គឺ) សញ្ញារមែងចាំបានត្រឹមតែអារម្មណ៍ថា ជាពណ៌ខៀវជាដើមប៉ុណ្ណោះ ប្រៀបដូចកុមារតូច បានឃើញកហាបណៈដូច្នោះ ។

**វិញ្ញាណ** រមែងដឹងអារម្មណ៍ថា ជាពណ៌ខៀវជាដើម ទាំងឲ្យដល់ការចាក់ធ្លុះលក្ខណៈថា មិនទៀងជាដើម ប្រៀបដូចអ្នកស្រុក ឃើញកហាបណៈដូច្នោះ ។

(ចំណែក) **បញ្ញា** រមែងដឹងអារម្មណ៍ថា ជាពណ៌ខៀវជាដើមផង ឲ្យដល់ការចាក់ធ្លុះលក្ខណៈថា មិនទៀងជាដើមផង ទាំងអាចឲ្យឈានទៅដល់សេចក្តីប្រាកដនៃមគ្គ ដោយប្រៀបដូចហេរញ្ញិកអ្នកជំនាញ ឃើញកហាបណៈ

ដូច្នោះ ។

ក៏សេចក្ដីផ្សេងគ្នា (ដូចពោលមក) នោះ នៃសញ្ញា វិញ្ញាណ និងបញ្ញា ចាក់ធ្លុះ (យល់) បានលំបាក ព្រោះហេតុនោះ ព្រះនាគសេនទើបថ្វាយព្រះពរ (ស្ដេចមិលិន្ទ) ថា សូមថ្វាយព្រះពរមហាបពិត្រ ព្រះមានព្រះភាគទ្រង់ធ្វើវត្ថុ ដែលធ្វើបានលំបាក ។

ស្ដេចមិលិន្ទត្រាស់សួរថា បពិត្រព្រះនាគសេនដ៏ចម្រើន អ្វីគឺវត្ថុដែលធ្វើបានលំបាក ដែលព្រះមានព្រះភាគទ្រង់ធ្វើទុកហើយ ?

ព្រះស្ដេចនាគសេនថ្វាយព្រះពរថា សូមថ្វាយព្រះពរមហាបពិត្រ វត្ថុធ្វើបានលំបាក ដែលព្រះមានព្រះភាគទ្រង់ធ្វើទុក គឺ ត្រាស់ប្រាប់ដល់ការកំណត់អរូបធម៌ទាំងឡាយ គឺ ចិត្ត និងចេតសិក ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយជាមួយគ្នាថា នេះគឺ ផស្សៈ នេះគឺ វេទនា នេះគឺ សញ្ញា នេះគឺ ចេតនា នេះគឺ ចិត្ត ។

ប្រៀបដូច ប្រេង ៥ ប្រភេទ នេះគឺ ប្រេងល្ង ប្រេងស្ពៃ ប្រេងស្រគំ ប្រេងល្ហុងខ្វៃ ប្រេងធ្វើអំពីខ្លាញ់រាវ ដែលដាក់រួមគ្នាទុកក្នុងថាសតែមួយ កាលនឹងដួសប្រេងតែមួយប្រភេទ ចេញពីថាសតែមួយនោះ ម្ដងមួយៗ (ហើយប្រាប់) ថា នេះប្រេងល្ង នេះប្រេងស្ពៃ រាប់ថាធ្វើបានលំបាក (ពិតហើយ) ការកំណត់

អរូបធម៌ គឺ ចិត្ត និងចេតសិក ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយ (ដូចដែលព្រះមានព្រះភាគត្រាស់ទុក) នេះ ធ្វើបានលំបាកជាងនោះ ។ តែព្រោះព្រះអង្គទ្រង់ចាក់ធ្លុះដោយសព្វញ្ញុតញ្ញាណមកល្អហើយ ព្រះមានព្រះភាគ ទ្រង់ជាធម្មិស្សរ ធម្មរាជ ទើបទ្រង់ (អាច) ធ្វើការកំណត់អរូបធម៌ទាំងនេះ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយបាន ។

សូម្បីដោយការដងទឹកត្រង់ទន្លេធំ ៥ ខ្សែ ហូរចូលកាន់សមុទ្រហើយ ចែកចេញ (ប្រាប់) យ៉ាងនេះថា នេះជាទឹកអំពីទន្លេគង្គា នេះជាទឹកអំពីទន្លេយមុនា ក៏គប្បីជ្រាបអត្ថន័យ (ដូចពោលមក) នេះ ។

## លក្ខណៈរបស់ទុក្ខ

[១៦០] ព្រះមានព្រះភាគ លុះត្រាស់ដល់លក្ខណៈរបស់អនត្តាដោយមាតិកា ២ ប្រការ គឺ ប្រការទីមួយ ត្រាស់ដល់សុញ្ញតា ប្រការទីពីរ ត្រាស់ដល់លក្ខណៈរបស់សុញ្ញតា យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងដល់លក្ខណៈរបស់ទុក្ខ ទើបត្រាស់ពាក្យថា **តត្រ ភិក្ខវេ** ដូច្នេះជា ដើម ។

បណ្ដាបទទាំងនោះ បទថា **ខជ្ជាមិ** សេចក្ដីថា រូប មិនបានទំពាស៊ីសាច់ដូចសុនខទំពាស៊ីទេ តែគប្បីជ្រាបថា ប្រៀបដូចបុគ្គលស្លៀកសំពត់សាច់គ្រោតគ្រាត និយាយថា សំពត់ខាំ (សាច់) យើង ដូច្នេះក៏ដោយ សំដៅយក

ការចាក់ដោត ដែលកើតអំពីការស្នៀកសំពត់សាច់គ្រោតគ្រាតនោះ យ៉ាងណា សូម្បីរូបនេះ ក៏ដូច្នោះ (គឺ) ឲ្យកើតការបៀតបៀនឡើង ទើបឈ្មោះថា ស៊ី ។

បទថា **បដិប្បន្នោ ហោតិ** សេចក្ដីថា ភាពជាអ្នកបដិបត្តិចាប់ផ្ដើមតាំងពី (រក្សា) សីល (ឲ្យបរិសុទ្ធិ) ដរាបដល់ (សម្រេច) អរហត្តមគ្គ ។

ក៏ក្នុងបទនេះ គប្បីជ្រាបអធិប្បាយ (បន្ថែម) ថា ព្រះយោគាវចរណា មានញាណជាកម្លាំង ចាស់ក្លាដោយពុទ្ធញាណដ៏ប្រសើរ បំពេញសេចក្ដីព្យាយាម ដែលជាទីតាំងនៃការបំពេញព្យាយាម ត្រូវជន្លត់ឈើបុក ឬបន្ទាមុត ត្រូវអាវុធប្រហារ ឬត្រូវសត្វកាចទាំងឡាយ មានខ្លាធំជាដើមចាប់ស៊ី ក៏ធ្វើវេទនានោះ ឲ្យជាអព្វោហារិក (មិនឲ្យវេទនាប្រាកដ) ពិចារណាមូលកម្មដ្ឋាន រមែងតោងយកព្រះអរហត្តទុកបាននោះឯង ព្រះយោគាវចរនេះហៅថា ឈ្មោះថា ភាពជាអ្នកបដិបត្តិដើម្បីនឿយនាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់វេទនា ដូចព្រះមិគិមល្លត្ថេរ , ដូចព្រះមហាតិស្សត្ថេរ បុត្ររបស់កុដុម្ពី , ដូចភិក្ខុមួយរូប ក្នុងចំនួនភិក្ខុប្រមាណ ៣០ រូប (ចាំវស្សានៅក្នុងព្រៃវត្តនី) ដែល (ត្រូវខ្លាធំខាំ) ដេក (ពិចារណាកម្មដ្ឋាន) ក្នុងមាត់ខ្លាធំ និងប្រៀបដូចព្រះថេរៈមួយរូប ដែលត្រូវបន្ទាមុត ដូច្នោះ ។

## ព្រះថេរៈត្រូវបន្ទាមុត ពិចារណាកម្មដ្ឋាន

បានឮមកថា កាលភិក្ខុ ១២ រូប គោះរគាំងហើយ បំពេញសេចក្តីព្យាយាមនៅក្នុងព្រៃ ភិក្ខុមួយរូប ពេលព្រះអាទិត្យអស្តង្គតប៉ុណ្ណោះ ក៏គោះរគាំងចុះកាន់ទីចង្ក្រម (លោក) ចង្ក្រមបណ្តើរ ព្យាយាមបណ្តើរ (ក្លាត់) ទៅជាន់បន្ទាត្រង់ទីស្មៅគ្របទុក ។ បន្លាមុតជ្ជុះខ្នងជើង វេទនាប្រព្រឹត្តទៅ ដូចជាត្រូវក្បៀងមុត ដូច្នោះ ។ ព្រះថេរៈគិតថា យើងនឹងដកបន្លានេះចេញ ឬនឹងបណ្តោយឲ្យបន្លាមុតជាប់នៅដូច្នេះ ។ លោកមានសេចក្តីគិតដូច្នេះថា ឈ្មោះថាការទៅកាន់ទុគ្គតិ មាននរកជាដើម (ការធ្លាក់នរក) ព្រោះត្រូវបន្លានេះមុត មិនមាន (យើងនឹងបណ្តោយឲ្យ) បន្លាមុតដូចដើម ។ លោកធ្វើវេទនានោះឲ្យជាអព្វោហារិក (មិនឲ្យវេទនាប្រាកដ) ហើយដើរចង្ក្រមរហូតអស់មួយយប់ កាលជិតភ្លឺ បានបញ្ជូនសញ្ញាឲ្យដល់ភិក្ខុមួយរូបទៀត ភិក្ខុរូបនោះទើបមក (រកលោក) ហើយសួរថា

-មានការអ្វី លោកម្ចាស់?

-ខ្ញុំត្រូវបន្លាមុត អ្នកមានអាយុ

-កាលណា លោកម្ចាស់?

-តាំងពីព្រលប់ម្ល៉េះ អ្នកមានអាយុ

-ហេតុដូចម្តេច លោកទើបមិនហៅពួកខ្ញុំ ពួកខ្ញុំ នឹងបានមកដកបន្លា

ចេញ ហើយយកប្រេងក្តៅៗ បន្តក់ (របួស) ឲ្យ?

-ពេលបន្ទាមុត ខ្ញុំព្យាយាមដកហើយអ្នកមានអាយុ

-លោកដកចេញហើយឬនៅ លោកម្ចាស់?

-អ្នកមានអាយុ ខ្ញុំដកចេញបានត្រឹមតែចំណែកខ្លះ

រឿងដ៏សេស បានអធិប្បាយទុកយ៉ាងពិស្តារហើយ ក្នុងនិទ្ទេសនៃសតិ-ប្បដ្ឋានសូត្រ ក្នុងអដ្ឋកថាទីឃនិកាយ និងមជ្ឈិមនិកាយនុ៎ះឯង ។

## លក្ខណៈ របស់អនិច្ចំ

[១៦១] សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបផ្តើមថា **តំ កឹ មញ្ញថ ភិក្ខវេ** (ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់សេចក្តីនោះដូចជាម្តេច?)

ឆ្លើយថា កាលមុននេះ ព្រះមានព្រះភាគត្រាស់ចំពោះលក្ខណៈរបស់ទុក្ខ មិនបានត្រាស់លក្ខណៈរបស់អនិច្ចំទេ ព្រះមានព្រះភាគទ្រង់ផ្តើមពាក្យថា **តំ កឹ មញ្ញថ ភិក្ខវេ** នេះទុក ក៏ដើម្បីសម្តែងដល់លក្ខណៈរបស់អនិច្ចំនោះម្យ៉ាងទៀត ដើម្បីនឹងទ្រង់ប្រមូលលក្ខណៈទាំង ៣ (អនិច្ចំ ទុក្ខំ អនត្តា) មកសម្តែងទុក (ព្រមគ្នា) ទើបទ្រង់ផ្តើមពាក្យនេះទុក ។

[១៦២] បទថា **អបចិនាតិ នោ អាចិនាតិ** (ប្រាសចាកការសន្សំ មិនសន្សំ) សេចក្តីថា ធ្វើវដ្តៈឲ្យវិនាស មិនសន្សំវដ្តៈទុក ។ បទថា **បជហាតិ**

**ន ឧបាទិយតិ** (លះបង់ មិនប្រកាន់) សេចក្តីថា រមែងលះបង់វដ្តៈនោះឯង គឺ មិនប្រកាន់ទុក ។ បទថា **វិសិនេតិ ន ឧស្សិនេតិ** សេចក្តីថា រមែងបាចសាច (វដ្តៈ) មិនប្រមូលទុក ។ បទថា **វិធូបេតិ ន សន្ធូបេតិ** សេចក្តីថា រមែងធ្វើវដ្តៈឲ្យរលត់ មិនបង្កាត់ឲ្យឆេះ ។

[១៦៣] សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ផ្តើមពាក្យនេះទុកថា **ឯវំ បស្សំ ភិក្ខវេ** (ម្នាលភិក្ខុទាំងឡាយ អរិយសាវកឃើញហើយយ៉ាងនេះ) ?

ឆ្លើយថា ព្រះមានព្រះភាគទ្រង់ផ្តើមទុក ព្រោះទ្រង់ប្រាថ្នាថា តថាគតនឹងសម្តែងមហាខីណាស្រពដែលធ្វើវដ្តៈឲ្យវិនាស ហើយតាំងនៅ ។

ព្រះមានព្រះភាគត្រាស់វិបស្សនាទុកដោយឋានៈ (ហេតុ) ត្រឹមតែប៉ុណ្ណោះឯង ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងមគ្គ ៤ ព្រមទាំងវិបស្សនា ទើបទ្រង់ផ្តើមពាក្យនេះ (**ឯវំ បស្សំ ភិក្ខវេ**) ទុក ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់មគ្គទី ១ (សោតាបត្តិមគ្គ) ដោយឋានៈ (ហេតុ) ត្រឹមតែប៉ុណ្ណោះ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងមគ្គ ៣ ទៀត (សកិទាគាមិមគ្គ , អនាគាមិមគ្គ និងអរហត្តមគ្គ) ព្រមទាំងវិបស្សនា ទើបទ្រង់ផ្តើមពាក្យនេះ (**ឯវំ បស្សំ ភិក្ខវេ**) ទុក ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់មគ្គទី ៣ ដោយឋានៈត្រឹមតែប៉ុណ្ណោះ ឥឡូវនេះ ទ្រង់ផ្ដើមពាក្យនេះ (**ឯវំ បស្សំ ភិក្ខវេ**) ទុក ដើម្បីនឹងទ្រង់សម្ដែងអរហត្តមគ្គព្រមទាំងវិបស្សនាទុំះឯង ។

[១៦៤] បទថា **សបជាបតិកា** បានដល់ ព្រមទាំងស្ដេចទេវរាជ ដែលជាបជាបតី ។

បទថា **អារកា វ នមស្សន្តិ** ប្រែថា (ទេវតាទាំងឡាយ) នមស្ការពីចម្ងាយនោះឯង គឺ នមស្ការភិក្ខុដែលនៅសូម្បីក្នុងទីឆ្ងាយទុំះឯង ដូចនមស្ការព្រះនិតត្ថេរៈ ដូច្នោះ ។

## ព្រះនិតត្ថេរៈ

មានរឿងដំណាលថា ព្រះថេរៈចេញបួសអំពីត្រកូលអ្នកចាក់ផ្កាឈើចោល បានសម្រេចព្រះអរហត្តផល ក្នុងវេលាកោរសក់ហើយទុំះឯង គិតថា យើងទើបតែបួសថ្ងៃនេះឯង កិច្ចបព្វជិតរបស់យើងក៏ដល់ទីបំផុត (សម្រេច) ថ្ងៃនេះដូចគ្នា យើងនឹងបំពេញមហាអរិយវង្សប្បដិបទារបស់បណ្ឌិត ដែលមានការចម្រើនសេចក្ដីសន្ដោសក្នុងបច្ច័យ ៤ ជាទីត្រេកអរ ។

លោកចូលទៅក្នុងក្រុងសាវត្ថី ត្រូវការ (ស្វែងរក) សំពត់បង្សុកូល ហើយស្វែងរកកំណាត់សំពត់ ។ ខណៈនោះ ស្ដេចមហាព្រហ្មមួយអង្គ ចេញ

ចាកសមាបត្តិ បានត្រួតមើលដែនដីមនុស្ស ក៏ឃើញព្រះថេរៈ គិតថា ព្រះថេរៈទើបតែបួសក្នុងថ្ងៃនេះឯង ហើយក៏បានសម្រេចព្រះអរហត្តផលក្នុងវេលាកោរសក់អស់ក្នុងថ្ងៃនេះ (ឥឡូវនេះ) កំពុងស្វែងរកកំណាត់សំពត់ដើម្បីបំពេញមហាអរិយវង្សប្បដិបទា ដូច្នេះ ហើយបានឈរផ្គងអញ្ជលីនមស្ការ ។

បន្ទាប់មក ស្តេចមហាព្រហ្មមួយអង្គទៀត ឃើញស្តេចមហាព្រហ្មអង្គដំបូងឈរផ្គងអញ្ជលីនមស្ការយ៉ាងនោះ ទើបសួរថា

-លោកនមស្ការនរណា?

មហាព្រហ្មទី ១ -នមស្ការព្រះនិតត្ថេរៈ

មហាព្រហ្មទី ២ -ព្រោះហេតុអ្វី ?

មហាព្រហ្មទី ១ -ព្រះនិតត្ថេរៈទើបតែបួសក្នុងថ្ងៃនេះឯង ហើយបានសម្រេចព្រះអរហត្តផលក្នុងវេលាកោរសក់អស់នោះឯង (ឥឡូវនេះ) កំពុងស្វែងរកកំណាត់សំពត់ ដើម្បីបំពេញមហាអរិយវង្សប្បដិបទា ។

ស្តេចមហាព្រហ្មនោះ ក៏បាននមស្ការព្រះថេរៈនោះ (ដូចគ្នា) ខណៈនោះ ស្តេចមហាព្រហ្មដទៃៗ (ក៏មកបន្តបន្ទាប់គ្នា) រួមជាស្តេចមហាព្រហ្ម ៧០០ បានឈរនមស្ការ (ព្រះនិតត្ថេរៈ) ។

ដោយហេតុនោះ ព្រះបុរាណាចារ្យ ទើបពោលបទជាគាថាព័ន្ធទុកថា ៖

*ទេវតាទាំងនោះ ចំនួនច្រើនដល់ ៧០០*

*ចេញចាកព្រហ្មវិមាន មានចិត្តជ្រះថ្លា*

*នមស្ការព្រះនិតត្ថេរះហើយ ព្រះថេរៈ*

*ជាព្រះខីណាស្រព កាន់យកសំពត់*

*បង្សុកូល ។*

*។ល។*

*ជាព្រះខីណាស្រព ធ្វើសំពត់បង្សុកូល*

*ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់សម្តែងឲ្យដល់ទីបំផុត គឺ ព្រះអរហត្ត ដោយទ្រង់ពង្រីកទេសនាចេញទៅ រួមដោយកពទាំង ៣ ដោយប្រការដូច្នេះ វេលាចប់ទេសនា ភិក្ខុ ៥០០ រូប បានសម្រេចជាព្រះអរហន្ត ។*

ចប់អដ្ឋកថា ខជ្ជនិយសូត្រទី៧

# អដ្ឋកថា

## បិណ្ឌោលយសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង បិណ្ឌោលយសូត្រទី ៨ ដូចតទៅនេះ ៖*

*[១៦៥] បទថា កិស្មិញ្ចិទេវ បករណេ បានដល់ ព្រោះហេតុយ៉ាងណាមួយទុំះឯង ។*

*បទថា បណាមេត្វា ប្រែថា ដេញចេញទៅ ។*

*សួរថា ព្រះមានព្រះភាគទ្រង់បណ្តេញភិក្ខុទាំងនេះទៅ ព្រោះហេតុអ្វី?*

*ឆ្លើយថា ពិតហើយថា ក្នុងវស្សាមួយ ព្រះមានព្រះភាគប្រថាប់ចាំវស្សានៅក្នុងក្រុងសាវត្ថី ចេញវស្សាបវារណាហើយហែហមដោយភិក្ខុសង្ឃដ៏ច្រើន ស្តេចចេញចាកក្រុងសាវត្ថីត្រាច់ចារិកទៅក្នុងជនបទ ស្តេចដល់កបិលភស្តុ ហើយស្តេចចូលទៅកាន់និគ្រោធារាម ។ សក្យរាជទាំងឡាយបានស្តាប់ (ដំណឹង) ថា ព្រះសាស្តាស្តេចមកដល់ហើយ ខាងក្រោយសោយព្រះក្រយាហារស្រេច ទ្រង់ត្រាស់ឲ្យរាជបុរសទាំងឡាយរែកទឹកដោះថ្លា ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម និងទឹកបាន:ដែលជាកប្បិយ:ច្រើនរយអម្រែក ស្តេចទៅកាន់វិហារ ប្រគេនថ្វាយព្រះសង្ឃ ថ្វាយបង្គំព្រះសាស្តាហើយ ប្រថាប់អង្គុយ*

ធ្វើបដិសណ្ឋារៈ (ចំពោះព្រះសាស្តា) ក្នុងទីដ៏សមគួរមួយ ។ (ចំណែក) ព្រះសាស្តា ប្រថាប់គង់ត្រាស់ធម្មកថាដ៏ពីរោះថ្វាយសក្យរាជទាំងនោះ ។ ខណៈនោះភិក្ខុពួកខ្លះកំពុងជូតសំអាតសេនាសនៈ ពួកខ្លះកំពុងចាត់តាំងគ្រែ និងតាំងជាដើម (ចំណែក) សាមណេរទាំងឡាយកំពុងជម្រះស្មៅ ។

ក្នុងស្ថានទីដែលចែកវត្ថុ ភិក្ខុដែលមកដល់ហើយក៏មាន ភិក្ខុដែលមិនទាន់មកដល់ក៏មាន ភិក្ខុដែលមកដល់ហើយនឹងទទួលលាភជំនួសភិក្ខុដែលមិនទាន់មកដល់ ក៏និយាយសំឡេងខ្លាំងៗ ឡើងថា ចូរឲ្យដល់ពួកខ្ញុំ ចូរឲ្យដល់អាចារ្យរបស់ពួកខ្ញុំ ចូរឲ្យដល់ឧបជ្ឈាយ៍របស់ពួកខ្ញុំ ។ ព្រះសាស្តាទ្រង់ស្តាប់ហើយ បានត្រាស់សួរព្រះអានន្ទត្ថេរថា អានន្ទ ក៏សំឡេងខ្លាំងៗ នោះ ជានរណាដូចជាអ្នកប្រមង់ដណ្តើមត្រីគ្នា ។ ព្រះថេរៈក្រាបទូល (ឲ្យទ្រង់ជ្រាប) សេចក្តីនោះ ព្រះសាស្តាទ្រង់ស្តាប់ហើយ ត្រាស់ថា អានន្ទ ភិក្ខុទាំងឡាយបញ្ចេញសំឡេងខ្លាំងៗ ព្រោះអាមិសជាហេតុ មិនមែនឬ? ។ ព្រះថេរៈក្រាបទូលថា ពិតមែន ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា អានន្ទ មិនសមគួរឡើយ មិនសមរម្យឡើយ ព្រោះតថាគតបំពេញបារមីមក ៤ អសង្ខេយ្យ កម្រៃមួយសែនកប្បព្រោះចីវរជាដើមជាហេតុក៏មិនមែន ទាំងភិក្ខុទាំងនេះ ចេញចាកផ្ទះបួសជាអនាគារិកៈ ព្រោះចីវរជាដើម ជាហេតុក៏មិនមែន ។ ពួកគេបួសព្រោះដើម្បីភាព

ជាព្រះអរហន្តជាហេតុ (តែ) ត្រឡប់មកធ្វើវត្ថុដែលមិនមានប្រយោជន៍ ឲ្យដូចនឹងវត្ថុដែលមានប្រយោជន៍ , ធ្វើវត្ថុដែលមិនមានសារៈ ឲ្យដូចជាវត្ថុមានសារៈ ទៅចុះអានន្ទ ចូរ (ទៅ) បណ្តេញភិក្ខុទាំងនោះ (ឲ្យចេញទៅ) ។

បទថា **បុព្វណ្ហសមយំ** គឺ ក្នុងវេលាព្រឹកក្នុងថ្ងៃស្អែក ។ បទថា **វេលុវលដ្ឋិកាយ មូលេ** គឺ ត្រង់គល់ដើមផ្ចៅជំទង់ ។ បទថា **បពាឡ្ហោ** ប្រែថា (ភិក្ខុសង្ឃដែលតថាគត) បណ្តេញហើយ ។ បាឋៈថា **បពាឡ្ហោ** ក៏មានន័យ (ស្មើនឹង) **បពាហិតោ** (បណ្តេញហើយ) ។ ទាំងពីរបទ រមែងសម្តែងដល់ភាវៈដែលត្រូវនាំចេញហើយនុ៎ះឯង ។

បទថា **សិយា អញ្ញថត្តំ** សេចក្តីថា គប្បីមានសេចក្តីជ្រះថ្លាជាយ៉ាងដទៃ ឬគប្បីមានភាវៈជាយ៉ាងដទៃ ។

សួរថា គប្បីមានយ៉ាងណា?

ឆ្លើយថា ក៏កាលភិក្ខុដកសេចក្តីជ្រះថ្លា (ក្នុងព្រះមានព្រះភាគ) ដោយគិតថា ព្រះសម្មាសម្ពុទ្ធទ្រង់បណ្តេញពួកយើង ព្រោះហេតុបន្តិចបន្តួច ឈ្មោះថាមានសេចក្តីជ្រះថ្លាយ៉ាងដទៃ ។ កាលពួកភិក្ខុចៀសចេញទៅ ចូលតិរ្ថិយព្រមទាំងភេទនុ៎ះឯង ឈ្មោះថា មានភេទជាយ៉ាងដទៃ ។

ចំណែកកុលបុត្រដែលបួសហើយទាំងឡាយ មានចិត្តតាំងមាំថា ពួក

យើងនឹងអាចកំណត់ (ជ្រាប) ព្រះអធ្យាស្រ័យរបស់ព្រះសាស្តាឲ្យបាន ហើយមិនអាចជ្រាបបាន ទើបគិតថា យើងនឹងបួសតទៅទៀតធ្វើអ្វី ហើយប្រាប់លាសិក្ខា វិលត្រឡប់មកជាហីនភេទ គប្បីជ្រាបថា សេចក្តីផ្លាស់ប្តូរក្នុងពាក្យថា **សិយា វិបរិណាមោ** នេះ ។

បទថា **វច្ឆស្ស** បានដល់ កូនគោដែលនៅបៅដោះ ។

បទថា **អញ្ញថត្តំ** បានដល់ ភាពជាយ៉ាងដទៃ គឺ សេចក្តីសោកសៅ ។

អធិប្បាយថា កូនគោដែលនៅបៅដោះ កាលមិនបាន (ផឹក) ទឹកដោះ ព្រោះរកមេមិនឃើញ រមែងសោកសៅញាប់ញ័រ ។

បទថា **វិបរិណាមោ** បានដល់ សេចក្តីស្លាប់ ។ អធិប្បាយថា កូនគោនោះ កាលមិនបានទឹកដោះ ក៏នឹងស្គមស្គាំង ព្រោះការស្រេកឃ្លាន ក៏នឹងដួលចុះដាច់ខ្យល់ស្លាប់ ។

បទថា **ពីជានំ តរុណានំ** បានដល់ ពូជដែលដុះហើយ ត្រូវបានទឹកជួយ ។

បទថា **អញ្ញថត្តំ** បានដល់ ភាពជាយ៉ាងដទៃ គឺ ការក្រៀមស្វិតនុ៎ះឯង អធិប្បាយថា ពូជទាំងនោះកាលមិនបានទឹក ក៏នឹងក្រៀមស្វិត ។

បទថា **វិបរិណាមោ** បានដល់ សេចក្តីវិនាស ។ អធិប្បាយថា ពូជ

ទាំងនោះមិនមានទឹកក៏នឹងស្វិត វិនាសអស់ទៅ នៅសល់តែចំបើងប៉ុណ្ណោះ ។

បទថា **អនុគ្គហិតោ** សេចក្តីថា បានទទួលអនុគ្រោះហើយដោយការអនុគ្រោះដោយអាមិស និងការអនុគ្រោះដោយធម៌ ។

បទថា **អនុគ្គណ្ហាយ** សេចក្តីថា តថាគតគប្បីអនុគ្រោះដោយការអនុគ្រោះដោយអាមិស និងការអនុគ្រោះដោយធម៌ទាំងពីរយ៉ាងនោះ ។ ព្រោះថា សាមណេរ និងភិក្ខុកម្លោះដែលបួសថ្មី កាលមានការខ្វះខាតដោយបច្ច័យមានចីវរជាដើម ឬមានជម្ងឺ ព្រះសាស្តា ឬឧបជ្ឈាយ៍ អាចារ្យមិនទាន់បានអនុគ្រោះដោយការអនុគ្រោះដោយអាមិសក៏នឹងលំបាក មិនអាចធ្វើការស្វាធ្យាយ ឬមនសិការ (ដល់ធម៌បាន) (ភិក្ខុទាំងនោះ) ដែលព្រះសាស្តា ឬឧបជ្ឈាយ៍ អាចារ្យមិនទាន់បានអនុគ្រោះដោយការអនុគ្រោះដោយធម៌ ក៏នឹងសាបសូន្យចាកឧទ្ទេស និងចាកឱវាទានុសាសនី មិនអាចនឹងវៀរចាកអកុសល មកចម្រើនកុសលបាន ។ តែ (ភិក្ខុទាំងនោះ) បានទទួលអនុគ្រោះ ដោយការអនុគ្រោះទាំងពីរនេះហើយ ក៏មិនលំបាកកាយ ប្រព្រឹត្តក្នុងការស្វាធ្យាយ និងមនសិការ (ដល់ធម៌) បដិបត្តិតាមដែលព្រះសាស្តា ឬឧបជ្ឈាយាចារ្យទូន្មានហើយ បន្ទាប់មក សូម្បីមិនបានទទួលការអនុគ្រោះនោះ (តែ) ក៏នៅបានកម្លាំង ព្រោះការអនុគ្រោះគ្រាដំបូងនោះឯង (ទើបធ្វើឲ្យ) តាំងមាំនៅក្នុងសាសនាបាន ព្រោះ

ដូច្នោះ ព្រះមានព្រះភាគទើបទ្រង់មានបរិវិតក្កៈយ៉ាងនេះឡើង ។

## ព្រហ្មមកគាល់ព្រះពុទ្ធ

[១៦៦] បទថា **ភគវតោ បុរតោ បាតុរហោសិ** សេចក្តីថា ស្តេចមហាព្រហ្ម បានជ្រាបព្រះតម្រិះរបស់ព្រះសាស្តាហើយ បាន (មក) ប្រាកដចំពោះព្រះភ័ក្ត្រ (ព្រះមានព្រះភាគ) ដោយគិតថា ព្រះមានព្រះភាគទ្រង់បណ្តេញភិក្ខុទាំងនេះឲ្យចេញទៅ ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ប្រាថ្នានឹងធ្វើការអនុគ្រោះភិក្ខុទាំងនោះ ទើបទ្រង់គិតដល់ហេតុយ៉ាងនេះ សូម្បីយើងក៏នឹងធ្វើឲ្យ (ព្រះមានព្រះភាគ) កើតព្រះឧស្សាហ៍នោះ (តទៅ) ។ អ្នកចម្អិនដ៏ឆ្លាត (ជ្រាបថា) បណ្តាអាហារមានរសជូរជាដើម រសណាត្រូវព្រះទ័យព្រះរាជា ក៏នឹងផ្សំរសនោះឲ្យឆ្ងាញ់ដោយគ្រឿងផ្សំ ហើយថ្ងៃស្អែកក៏បង្អោននាំចូលទៅថ្វាយព្រះរាជា (ទៀត) យ៉ាងណា ស្តេចមហាព្រហ្មនោះក៏ដូច្នោះដែរ ព្រោះខ្លួនឯងជាអ្នកឆ្លាត ទើបបានទូលឧបមា ដែលព្រះមានព្រះភាគទ្រង់នាំមកហើយនុ៎ះឯង ដោយពាក្យមានជាដើមថា **ឯវមេតំ ភគវា** ហើយពោលពាក្យនេះថា **សន្តេត្ថ ភិក្ខូ** ដើម្បីទូលសូមឲ្យព្រះមានព្រះភាគធ្វើការអនុគ្រោះភិក្ខុសង្ឃ ។

បណ្តាបទទាំងនោះ បទថា **អភិនន្ទតុ** សេចក្តីថា (សូមព្រះមានព្រះភាគ) ទ្រង់ត្រេកអរឲ្យភិក្ខុសង្ឃដែលមកយ៉ាងនេះថា សូមភិក្ខុសង្ឃចូរមកកាន់សម្នាក់

តថាគតចុះ ។

បទថា **អភិវទតុ** (សូមព្រះមានព្រះភាគ) ចូរទូន្មាន ប្រទានឱវាទា-នុសាសនីដល់ភិក្ខុសង្ឃដែលមកដល់ហើយចុះ ។

## ព្រះសម្ពុទ្ធទ្រង់សម្តែងឫទ្ធិ

[១៦៧] បទថា **បដិសល្លានា** បានដល់ ចាកសភាពជាបុគ្គលតែមួយ ។

បទថា **តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខាសិ** បានដល់ (ព្រះមានព្រះភាគ) ទ្រង់សម្តែងឫទ្ធិ ។ បទថា **ឯកទ្វីហិកាយ** បានដល់ (ភិក្ខុ) មកម្តងមួយរូបខ្លះ មកម្តង ២ រូបខ្លះ ។ បទថា **សារជ្ជមានរូបា** បានដល់ ខ្លាច ព្រោះមានសេចក្តីកោតក្រែងជាប្រមាណ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបទ្រង់សម្តែងឫទ្ធិឲ្យភិក្ខុទាំងនោះចូលទៅគាល់ដោយវិធីនោះ ?

ឆ្លើយថា ព្រោះទ្រង់ប្រាថ្នាប្រយោជន៍ ។ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបថា បើភិក្ខុទាំងនោះគប្បីមក (គាល់) ជាក្រុមៗ សោត ពួកភិក្ខុក៏នឹងនាំគ្នានិយាយចំអកឡកឡឺយថា ព្រះមានព្រះភាគទ្រង់បណ្តេញភិក្ខុហើយ ស្តេចចូលកាន់ព្រៃ (តែ) ក៏មិនអាចនឹងប្រថាប់នៅក្នុងព្រៃនោះឲ្យគ្រប់ថ្ងៃបាន ទើបស្តេចត្រឡប់មករកភិក្ខុដូចដើមវិញ ។ គ្រានោះ ពួកភិក្ខុមិនគប្បីធ្វើសេចក្តីគោរព

ក្នុងព្រះពុទ្ធ (និង) នឹងមិនអាចទទួលព្រះធម៌ទេសនាបាន ។ តែកាលភិក្ខុទាំងនោះមានសេចក្ដីភ័យខ្លាច ស្ងប់ស្ងៀម មកគាល់ម្ដងមួយរូប ពីររូប ពួកភិក្ខុក៏មានសេចក្ដីគោរពក្នុងព្រះអង្គ ពួកភិក្ខុក៏អាចទទួលព្រះធម៌ទេសនាបាន ដូច្នេះ ទើបទ្រង់សម្ដែងបែបនោះ ព្រោះទ្រង់ប្រាថ្នាប្រយោជន៍ដល់ភិក្ខុទាំងនោះ ។

បទថា **និសីទឹសុ** សេចក្ដីថា ព្រោះកាលភិក្ខុទាំងនោះខ្លាច មក (គាល់ព្រះពុទ្ធ) ភិក្ខុមួយរូបៗ ក៏នឹងគិតថា ព្រះសាស្ដាទ្រង់សម្លឹងមើលយើងប៉ុណ្ណោះ ទ្រង់មានព្រះបំណងដាក់ទោសយើងដោយពិត ដូច្នេះ ហើយសន្សឹមៗ មកថ្វាយបង្គំអង្គុយចុះ គ្រានោះ ភិក្ខុដទៃៗ ក៏នឹង (មានទំនងតែមួយដូចគ្នា) ភិក្ខុ ៥០០ រូប នាំគ្នាមកអង្គុយដោយអាការយ៉ាងនេះឯង ។

ចំណែកព្រះសាស្ដា ទតឃើញភិក្ខុសង្ឃអង្គុយយ៉ាងនោះ មិនកម្រើកកាយ ប្រៀបដូចក្រសែទឹកក្នុងមហាសមុទ្រ (ហូរទៅស្ងប់ស្ងៀម) ក្នុងសមុទ្រសីទន្តរ និងដូច (អណ្ដាត) ប្រទីបស្ងប់ស្ងៀមហើយក្នុងទីស្ងាត់ខ្យល់ ដូច្នោះ ទើបទ្រង់មានព្រះតម្រិះថា ធម៌ទេសនាបែបណា ទើបនឹងសមគួរដល់ភិក្ខុទាំងនេះ ។

លំដាប់នោះ ព្រះអង្គទ្រង់មានព្រះតម្រិះដូច្នេះថា ភិក្ខុទាំងនេះតថាគតបណ្ដេញ ព្រោះអាហារជាហេតុ ធម៌ទេសនារឿងបាយ ដែលធ្វើជាដុំប៉ុណ្ណោះ

ជាសប្បាយដល់ភិក្ខុទាំងនោះ តថាគតសម្តែងធម៌ទេសនាហើយ នឹងសម្តែងទេសនាមានបរិវដ្ដៈ ៣ ក្នុងវេលាចប់ធម៌ទេសនា ភិក្ខុទាំងអស់ ក៏នឹងសម្រេចអរហត្តផល ។ គ្រានោះ កាលនឹងទ្រង់សម្តែងធម៌ទេសនានោះ ដល់ភិក្ខុទាំងនោះ ទើបត្រាស់ពាក្យថា **អន្តមិទំ ភិក្ខវេ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អន្តំ** បានដល់ ខាងក្រោម គឺ ថោកទាប ។

បទថា **យទិទំ បិណ្ឌោល្យំ** សេចក្ដីថា ការរស់នៅរបស់បុគ្គលអ្នកចិញ្ចឹមជីវិតដោយការស្វែងរកដុំបាយនោះណា ។

**អត្ថន័យរបស់ពាក្យថា បិណ្ឌោល្យៈ**

ក៏ក្នុងបទថា **បិណ្ឌោល្យំ** នេះមានអត្ថចំពោះបទ ដូច្នេះ ៖

ភិក្ខុឈ្មោះថា **បិណ្ឌោលៈ** ព្រោះសំដៅសេចក្ដីថា ត្រាច់ស្វែងរកដុំបាយ ការធ្វើការងាររបស់ភិក្ខុដែលស្វែងរកដុំបាយ ឈ្មោះថា **បិណ្ឌោល្យៈ** អធិប្បាយថា ការរស់នៅដែលឲ្យសម្រេចដោយការស្វែងរកដុំបាយ ។

បទថា **អភិសាបោ** ប្រែថា ការជេរ អធិប្បាយថា មនុស្សទាំងឡាយក្រោធហើយ រមែងជេរថា លោកដណ្ដប់ចីវរហើយ មិនដឹងខ្លួន កាន់អំបែងក្បឿងដើរស្វែងរកដុំបាយ ។ ឬថា រមែងជេរសូម្បីយ៉ាងនេះថា លោកមិនមានអ្វីធ្វើឬ ? លោកមានកម្លាំងគ្រប់គ្រាន់ដោយវីរិយៈបែបនេះ នៅលះបង់ហិរិ-

ឱត្តប្បៈ កាន់បាត្រដើរស្វែងរកដុំបាយ មិនខុសអ្វីពីមនុស្សកំព្រា ។ បទថា **តញ្ច ខោ ឯតំ** សេចក្តីថា ការដើរស្វែងរកដុំបាយទាំងដែលត្រូវពាក្យជេរប្រទិច នោះ ។

បទថា **កុលបុត្តា ឧបេន្តិ អត្ថវសិកា អត្ថវសំ បដិច្ច** សេចក្តីថា កុលបុត្រដោយជាតិ និងកុលបុត្រដោយអាចារៈក្នុងសាសនារបស់តថាគត ជាអ្នកនៅក្នុងអំណាចនៃផល នៅក្នុងអំណាចនៃហេតុ គឺ អាស្រ័យអំណាចនៃផល អំណាចនៃហេតុ ទើបប្រកប (ការត្រាច់ស្វែងរកដុំបាយ) ។

## អធិប្បាយស័ព្ទ រាជាភិនីតៈជាដើម

ក្នុងបទថា **រាជាភិនីតា** ជាដើម គប្បីជ្រាបអធិប្បាយដូចតទៅនេះ ៖

កុលបុត្រពួកណា ទំពារស៊ីរបស់ព្រះរាជាហើយ ត្រូវឃុំឃាំងក្នុងគុកហ្លួង (តមក) គេចចេញបាន ទើប (ទៅ) បួស កុលបុត្រទាំងនោះ ឈ្មោះថា **រាជាភិនីតៈ** ។

ក៏កុលបុត្រទាំងនោះឈ្មោះថា រាជាភិនីតៈ ព្រោះត្រូវនាំទៅកាន់ទីឃុំ-ឃាំងរបស់ព្រះរាជា ។

ចំណែកកុលបុត្រពួកណា ត្រូវចោរចាប់បានក្នុងព្រៃ កាលពួកខ្លះត្រូវ

ចោរនាំទៅ ពួកខ្លះក៏និយាយថា នាយ យើងទាំងឡាយដែលពួកលោកលែង ហើយ ក៏នឹងមិនទៅគ្រប់គ្រងផ្ទះទេ (តែ) នឹងបួស ក្នុងការបួសនោះ យើងនឹង ឲ្យចំណែកបុណ្យដល់ពួកលោកអំពីបុណ្យ មានការបូជាព្រះពុទ្ធជាដើម ដែល ពួកយើងនឹងធ្វើ កុលបុត្រទាំងនោះដែលចោរទាំងនោះលែងហើយ ទើប (ទៅ) បួស កុលបុត្រទាំងនោះឈ្មោះថា **ចោរាភិនីតៈ** ។

ក៏កុលបុត្រទាំងនោះឈ្មោះថា ចោរាភិនីតៈ ព្រោះបានសេចក្ដីថា ត្រូវ ពួកចោរនាំទៅដើម្បីសម្លាប់ ។

ចំណែកកុលបុត្រពួកណាជំពាក់បំណុល ហើយមិនអាចសងវិញបាន ទើបគេចចេញទៅបួស កុលបុត្រទាំងនោះឈ្មោះថា **ឥណដ្ដៈ** (ជំពាក់បំណុល) បានសេចក្ដីថា ត្រូវបំណុលបៀតបៀន បាលីជា **ឥណដ្ឋា** ក៏មាន មានសេចក្ដី ថា តាំងនៅក្នុងបំណុល (ជំពាក់បំណុល) ។ កុលបុត្រពួកណា ត្រូវរាជភ័យ ចោរភ័យ ឆាតកភ័យ និងរោគភ័យ យ៉ាងណាមួយ គ្របសង្កត់ ប្រទូសរ៉ាយ ហើយបួស កុលបុត្រទាំងនោះឈ្មោះថា **ភយដ្ដៈ** (ភ័យ) អធិប្បាយថា ត្រូវ ភ័យបៀតបៀន បាលីជា **ភយដ្ឋា** ក៏មាន បានសេចក្ដីថា តាំងនៅក្នុងភ័យ ។

បទថា **អាជីវិកាបកតា** បានដល់ កុលបុត្រដែលត្រូវការចិញ្ចឹមជីវិត ប្រទូសរ៉ាយ គឺ គ្របសង្កត់ អធិប្បាយថា មិនអាចចិញ្ចឹមបុត្រ និងភរិយាបាន ។

បទថា **ឱតិណ្ណា** បានដល់ ចូលទៅនៅខាងក្នុង ។ កុលបុត្រនោះ កើតការគិតឡើង ដោយន័យជាដើមថា នឹងធ្វើទីបំផុតទុក្ខឲ្យបានទើបបួស តមកមិនអាចធ្វើការបួសនោះឲ្យ (បានផល) យ៉ាងនោះបាន ដើម្បីទ្រង់បង្អុលដល់កុលបុត្រនោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យនេះថា **សោ ច ហោតិ អភិជ្ឈាលុ** ។

បណ្តាបទទាំងនោះ បទថា **អភិជ្ឈាលុ** បានដល់ ជាអ្នកមានប្រក្រតីសម្លឹងរំពៃ (ចង់បាន) វត្ថុរបស់អ្នកដទៃ (មកជារបស់ខ្លួន) ។ បទថា **តិព្វសារាគោ** បានដល់ មានរាគៈច្រើន ។

បទថា **ព្យាបន្នចិត្តោ** បានដល់ មានចិត្តវិបត្តិ ព្រោះជាចិត្តខូច ។

បទថា **បទុដ្ឋមនសង្កប្បោ** បានដល់ មានចិត្តប្រទុស្តរ៉ាយ ដូចគោកាច ។

បទថា **មុដ្ឋស្សតិ** បានដល់ គ្មានសតិ គឺ រលឹកមិនបានថា វត្ថុដែលខ្លួនធ្វើហើយក្នុងទីនេះ រមែងបាត់ទៅក្នុងទីនេះ ដូចថាសដាក់ (ដុំ) បាយ ទុកហើយ (ក៏ភ្លេច) ដូច្នោះ ។

បទថា **អសម្បជានោ** បានដល់ មិនមានបញ្ញា គឺ វៀរចាកការកំណត់ខន្ធជាដើម ។

បទថា **អសមាហិតោ** បានដល់ មិនតាំងមាំ ព្រោះមិនមានឧបចារសមាធិ និងអប្បនាសមាធិ ដូចទូកដែលចងទុកហើយ ព្រោះត្រូវក្រសែទឹកហូរ

ត្របាញ់បោកបក់ ដូច្នោះ ។

បទថា **វិព្ភន្តចិត្តោ** បានដល់ មានចិត្តវិលទៅ (វេវីវង់) ដូចសត្វ លោមព័ទ្ធកណ្តាលផ្លូវ ដូច្នោះ ។

បទថា **បាកតិន្ទ្រិយោ** បានដល់ មិនសង្រួមឥន្ទ្រិយ ដូចគ្រហស្ថសម្លឹង មើលកូនកម្លោះ កូនក្រមុំ ឈ្មោះថា ជាអ្នកមិនសង្រួមឥន្ទ្រិយ ដូច្នោះ ។

បទថា **ឆវាលាតំ** បានដល់ អង្កត់ឧសក្នុងទីដែលដុតសាកសព ។

បទថា **ឧភតោ បទិត្តំ មជ្ឈេ គូថគតំ** បានដល់ អង្កត់ឧសដុតសាក-សពប្រវែងប្រមាណ ៨ ធ្នាប់ ត្រូវភ្លើងឆេះក្នុងទីទាំងពីរ (ចុងសងខាង) (ចំណែក) ត្រង់កណ្តាលប្រលាក់លាមក ។

បទថា **នេវ គាមេ** សេចក្តីថា ប្រសិនបើអង្កត់ឧសដុតសាកសពនោះ នឹងអាចនាំទៅប្រើជាប្រយោជន៍ មាននឹម ដងនង្គ័ល វនុកទ្វារផ្ទះ ក្តោរថ និងជុំជាដើមបានសោត ក៏គប្បីប្រើដើម្បីប្រយោជន៍ជាគ្រឿងផ្ទះក្នុងស្រុកបាន បើនឹងអាចនាំទៅប្រើដើម្បីប្រយោជន៍ជាគ្រឿងក្រាល និងគ្រែតូចជាដើម ក្នុង ខ្ទមស្រែបានសោត ក៏គប្បីប្រើដើម្បីប្រយោជន៍ជាគ្រឿងប្រើក្នុងព្រៃបាន តែ ព្រោះហេតុដែលមិនអាចនាំទៅប្រើដើម្បីប្រយោជន៍បានទាំងពីរផ្លូវ ដូច្នោះ ព្រះ-មានព្រះភាគទើបត្រាស់ទុកយ៉ាងនេះ ។

បទថា **គិហិភោគា ច បរិហីនោ** សេចក្តីថា កាលពួកគ្រហស្ថអ្នកនៅក្នុង (ស្រុក) បែងចែកទេយ្យធម៌ (ថ្វាយ) ភោគៈចំណែកណាជាចំណែកដែលលោកនឹងគប្បីបាន ក៏សាបសូន្យហើយចាកភោគៈចំណែកនោះឯង ។

បទថា **សាមញ្ញត្ថញ្ច** សេចក្តីថា នឹង (មិនធ្វើ) ប្រយោជន៍ គឺ គុណរបស់សមណៈ ដែលកុលបុត្រតាំងនៅក្នុងឱវាទរបស់ឧបជ្ឈាយ៍ និងអាចារ្យ ហើយគប្បីសម្រេចបានដោយអំណាចបរិយត្តិ និងបដិវេធ (ឲ្យបរិបូណ៌) ។

ក៏ឧបមា (ពោលដោយអង្កត់ឧសដុតសាកសព) នេះ ព្រះសាស្តាទ្រង់នាំមក មិនមែនដោយអំណាចរបស់ភិក្ខុដែលទ្រុស្តសីល តែទ្រង់នាំមកដោយអំណាចបុគ្គលដែលមានសីលបរិសុទ្ធិ (តែ) ខ្ជិលច្រអូស ត្រូវទោសទាំងឡាយមានអភិជ្ឈាជាដើម គ្របសង្កត់ហើយ ។

## អកុសលវិតក្កៈធ្វើឲ្យបុគ្គលដូចជាអង្កត់ឧសដុតសាកសព

[១៦៨] ពាក្យថា **តយោ មេ ភិក្ខវេ** ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ផ្តើមទុក ទ្រង់ផ្តើមទុកដើម្បីសម្តែងថា សភាពរបស់បុគ្គលនេះ ដែលប្រៀបដូចអង្កត់ឧសដុតសាកសព មាតាបិតាមិនបានធ្វើឲ្យ ឧបជ្ឈាយាចារ្យមិនបានធ្វើឲ្យ តែអកុសលវិតក្កៈដ៏លាមកទាំងនេះ (ផ្សេងៗ) ធ្វើឲ្យ ។

បទថា **អនិមិត្តំ វា សមាធឹ** បានដល់ សមាធិក្នុងវិបស្សនា អធិប្បាយ

ថា សមាធិក្នុងវិបស្សនានោះ ព្រះមានព្រះភាគត្រាស់ហៅថា អនិមិត្តៈ (មិនមាននិមិត្ត) ព្រោះដកនិមិត្តទាំងឡាយ មាននិមិត្តថាទៀងជាដើមបាន ។

ម្យ៉ាងទៀត ក្នុងព្រះបាលីពេលនេះ គប្បីជ្រាបសេចក្តីថា សតិប្បដ្ឋាន ៤ លោយគ្នា , (ចំណែក) អនិមិត្តសមាធិ (សមាធិដែលមិនមាននិមិត្ត) ជាបុព្វភាគ (ចំណែកខាងដើម) , ម្យ៉ាងទៀត អនិមិត្តសមាធិ លោយគ្នា , (ចំណែក) សតិប្បដ្ឋានជាបុព្វភាគ ។

## អនិមិត្តសមាធិដកទិដ្ឋិ ២ យ៉ាង

[១៦៩] ពាក្យនេះថា **ទ្វេមា ភិក្ខវេ ទិដ្ឋិយោ** ព្រះមានព្រះភាគត្រាស់ទុក ដើម្បីសម្តែងថា អនិមិត្តសមាធិភាវនា រមែងប្រព្រឹត្តទៅដើម្បីលះមហាវិតក្កៈទាំង ៣ នេះ តែម្យ៉ាងប៉ុណ្ណោះក៏មិនមែន តែនៅដកសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិបានទៀតផង ។

បទថា **ន វជ្ជវា អស្សំ** បានដល់ យើងគប្បីជាអ្នកមិនមានទោស ។ បទដ៏សេសក្នុងព្រះបាលីនេះងាយទាំងអស់នោះឯង ។

ព្រះមានព្រះភាគ ទ្រង់ញុំាងទេសនាក្នុងសូត្រសូម្បីនេះ ឲ្យវិលជុំវិញភព ៣ ហើយ (រហូតដល់កំពូល) ដោយអរហត្តផល ដោយប្រការដូចពណ៌នាមកដូច្នេះ ។ វេលាចប់ទេសនា ភិក្ខុ ៥០០ រូប បានសម្រេចអរហត្តផល ព្រម

ដោយបដិសម្ភិទាទាំងឡាយ ។

ចប់អដ្ឋកថា បិណ្ឌោលយសូត្រទី ៨

# អ ដ្ឋ ក ថា

## ចាលិលេយ្យសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុង បាលិលេយ្យសូត្រទី ៩ ដូចតទៅនេះ ៖

[១៧០] ភិក្ខុដែលក្រុងកោសម្ពីឈ្លោះគ្នាបទថា **ចារិកំ បក្កាមិ** សេចក្ដីថា ក្នុងគ្រាដែលភិក្ខុនៅក្រុងកោសម្ពីឈ្លោះគ្នា ថ្ងៃមួយ ព្រះសាស្ដាទើបទ្រង់នាំរឿងរបស់ព្រះបាទ **ទីឃីតិកោសល** មក ហើយត្រាស់ទូន្មានដោយព្រះគាថាទាំងឡាយមានជាដើមថា ៖

មិនថាក្នុងកាលណាៗ ក្នុងលោកនេះ ពៀរទាំង
ឡាយ មិនរម្ងាប់ដោយការចងពៀរឡើយ ។

ថ្ងៃនោះ កាលភិក្ខុទាំងនោះកំពុងឈ្លោះគ្នា រាត្រីក៏ភ្លឺហើយ សូម្បីថ្ងៃទីពីរ ព្រះមានព្រះភាគក៏ត្រាស់រឿងនោះដដែលទៀត ។ សូម្បីថ្ងៃនោះ កាលភិក្ខុទាំងនោះនៅតែឈ្លោះគ្នាដូចដើម រាត្រីក៏ភ្លឺហើយ ដល់ថ្ងៃទី ៣ ព្រះមាន-ព្រះភាគក៏នៅត្រាស់រឿងនោះដដែលទៀតនោះឯង ។

### ព្រះសម្ពុទ្ធស្ដេចចារិកទៅមួយអង្គឯង

គ្រានោះ ភិក្ខុមួយរូប ទើបបានក្រាបទូលចំពោះព្រះអង្គយ៉ាងនេះថា

បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគចូរខ្វល់ខ្វាយតិចចុះ ប្រកបការប្រថាប់នៅជាសុខក្នុងបច្ចុប្បន្នចុះ ខ្ញុំព្រះអង្គទាំងឡាយនឹងប្រាកដ ព្រោះសេចក្តីបែកបាក់ ឈ្លោះវិវាទគ្នាគ្រានេះឯង ព្រះសាស្តាទ្រង់ព្រះតម្រិះថា មោឃ-បុរសទាំងនេះ មានចិត្តត្រូវទោសៈគ្របសង្កត់ហើយ តថាគតមិនអាចនឹងផ្សះ-ផ្សាមោឃបុរសទាំងនេះឲ្យព្រមគ្នាបានឡើយ ដូច្នេះហើយទ្រង់ត្រិះរិះ (ទៀត) ថា ប្រយោជន៍អ្វីរបស់តថាគតនឹងមោឃបុរសទាំងនេះ តថាគតនឹងនៅដោយការត្រាច់ចារិកទៅមួយអង្គឯង ។

[១៧១] ព្រះសាស្តាទ្រង់ត្រិះរិះយ៉ាងនេះហើយ ព្រឹកឡើង លុះទ្រង់ជម្រះព្រះវរកាយរៀបរយហើយ ទើបបានស្តេច (ចេញ) ត្រាច់បិណ្ឌបាតក្នុងក្រុងកោសម្ពី មិនបានត្រាស់ហៅអ្នកណាៗ (ឲ្យតាមស្តេចទៅជាមួយ) មួយព្រះអង្គឯងប៉ុណ្ណោះ ស្តេចចៀសចារិកទៅមិនមានភិក្ខុជាគម្រប់ពីរ ។ ព្រះថេរៈពោលពាក្យ នេះថា **យស្មឹ អាវុសោ សមយេ** ក៏ព្រោះលោកបានជ្រាបការចារិកទៅរបស់ព្រះមានព្រះភាគទាំងអស់ថា ថ្ងៃនេះព្រះមានព្រះភាគស្តេចនឹងចៀសទៅជាមួយភិក្ខុតែមួយរូប ថ្ងៃនេះស្តេចនឹងចៀសទៅជាមួយភិក្ខុពីររូប ថ្ងៃនេះស្តេចនឹងចៀសទៅជាមួយភិក្ខុ ១០០ រូប ថ្ងៃនេះស្តេចនឹងចៀសទៅជាមួយភិក្ខុ ១,០០០ រូប និងថ្ងៃនេះ ស្តេចទៅត្រឹមតែមួយព្រះអង្គឯង គឺ ការចារិកទៅរបស់

ព្រះមានព្រះភាគទាំងអស់ ប្រាកដ គឺ ជាក់ច្បាស់ដល់ព្រះថេរៈនោះ ។

## ស្តេចចារិកកាន់ព្រៃបាលិលេយ្យកៈ

[១៧២] បទថា **អនុបុព្វេន** សេចក្តីថា ព្រះមានព្រះភាគ ស្តេចត្រាច់បិណ្ឌបាតទៅតាមលំដាប់ស្រុកនិគមបណ្តើរ បំណងនឹងប្រោសភិក្ខុអ្នកនៅដោយការត្រាច់ចារិកទៅតែម្នាក់ឯង ទើបបានស្តេចទៅកាន់ **ពាលកលោណការ-គ្រាម** ។ ក្នុងពាលកលោណការគ្រាមនោះ ព្រះមានព្រះភាគត្រាស់អានិសង្សក្នុងការនៅដោយការត្រាច់ (ចារិក) ទៅម្នាក់ឯង ដល់ព្រះភគុត្ថេរ រហូតដល់អស់វេលាខាងសោយព្រះក្រយាហារស្រេច (ក្នុងវេលាពេលថ្ងៃ) និងរហូតដល់អស់ទាំង ៣ យាម ក្នុងវេលាពេលយប់ ស្អែកឡើង ទ្រង់មានព្រះថេរៈជាបច្ឆាសមណៈ ស្តេចត្រាច់បិណ្ឌបាតហើយ ទ្រង់ឲ្យព្រះថេរៈនោះត្រឡប់ក្នុងទីនោះឯង ទ្រង់ត្រិះរិះថា តថាគតនឹងប្រោសកុលបុត្រ ៣ នាក់ (ភិក្ខុ ៣ រូប) អ្នកនៅជាមួយគ្នាដោយសេចក្តីស្មគ្រស្មោះ ទើបស្តេចពុទ្ធដំណើរទៅកាន់ព្រៃបាចីនវង្សៈ ។ ព្រះអង្គបានត្រាស់អានិសង្សក្នុងការនៅជាមួយគ្នា ដោយសេចក្តីស្មគ្រស្មោះដល់ភិក្ខុទាំង ៣ រូបនោះ អស់មួយយប់ (ព្រឹកឡើងស្តេចចេញបិណ្ឌបាត) ទ្រង់ឲ្យភិក្ខុទាំង ៣ រូបនោះ ត្រឡប់ក្នុងទីនោះឯង ហើយស្តេចពុទ្ធដំណើរសំដៅទៅកាន់ក្រុងបាលិលេយ្យកៈតែមួយព្រះអង្គឯង ស្តេចយាង

ដល់ក្រុងបាលិលេយ្យកៈតាមលំដាប់ ដោយហេតុនោះ ព្រះសង្គីតិកាចារ្យទើបពោលថា ព្រះមានព្រះភាគ កាលនឹងស្តេចចារិកទៅតាមលំដាប់ ដល់ស្រុកបាលិលេយ្យកៈ ស្តេចប្រថាប់នៅក្នុងរក្ខិតវ័ននោះ ។

## ដំរីឧបដ្ឋាកព្រះសម្ពុទ្ធ

បទថា **ភទ្ទសាលមូលេ** សេចក្តីថា អ្នកស្រុកបាលិលេយ្យកៈ ថ្វាយទានចំពោះព្រះមានព្រះភាគ ហើយបាននាំគ្នាសាងបណ្ណសាលាថ្វាយព្រះមាន-ព្រះភាគក្នុងព្រៃឈ្មោះរក្ខិតៈ ដែលនៅមិនឆ្ងាយពីព្រៃបាលិលេយ្យកៈ ទូលអារា-ធនាព្រះមានព្រះភាគឲ្យប្រថាប់នៅថា សូមព្រះអង្គព្រះមេត្តាប្រោសប្រថាប់គង់ក្នុងបណ្ណសាលានេះចុះ ។

ក៏ឯដើមសាលៈខ្វះក្នុងព្រៃនោះឯង ជាដើមឈើធំប្រសើរ ទើបហៅថា **ភទ្ទសាលៈ** ព្រះមានព្រះភាគចូលទៅអាស្រ័យក្រុងនោះ ប្រថាប់ត្រង់គល់ដើមឈើនោះ ជិតបណ្ណសាលាក្នុងព្រៃនោះ ដោយហេតុនោះ ព្រះសង្គីតិកាចារ្យទើបពោលថា **ភទ្ទសាលមូលេ** ។

ក៏កាលព្រះតថាគតប្រថាប់នៅក្នុងព្រៃនោះយ៉ាងនោះ ដំរីដ៏ប្រសើរមួយត្រូវពួកដំរីញី និងកូនដំរីជាដើម បៀតបៀនក្នុងស្ថានទីទាំងឡាយ មានស្ថានទីចេញរកស៊ី និងស្ថានទីកំពង់ទឹកជាដើម កាលនឿយណាយក្នុងហ្វូង គិតថា

យើងនឹងនៅជាមួយដំរីទាំងនេះធ្វើអ្វី ទើបលះបង់ហ្វូង (ចេញ) ទៅកាន់ដែនដីមនុស្ស ឃើញព្រះមានព្រះភាគក្នុងព្រៃបាលិលេយ្យកៈ (ឃើញភ្លាម) ចិត្តក៏ស្ងប់ត្រជាក់ ដូចភ្លើងដែលត្រូវរំលត់ដោយទឹកពាន់ថ្នាំង ។ បានឈរជិតព្រះ-សាស្តា ។ បន្ទាប់អំពីនោះមក ដំរីនោះក៏ធ្វើវត្តបដិបត្តិថ្វាយព្រះសាស្តា ថ្វាយទឹកខ្ពុរព្រះឱស្ឋ នាំទឹកស្រង់មកថ្វាយ ថ្វាយឈើស្ទន់ បោសបរិវេណ នាំផ្លែឈើមានរសឆ្ងាញ់អំពីព្រៃមកថ្វាយព្រះសាស្តា ។ ព្រះសាស្តាក៏ទ្រង់សោយ ។ ថ្ងៃមួយ ព្រះសាស្តាស្តេចចង្ក្រមហើយ ប្រថាប់អង្គុយលើផ្ទាំងថ្ម ។ ចំណែកដំរីដ៏ប្រសើរ ក៏ឈរក្នុងទីមិនឆ្ងាយ ។ ព្រះសាស្តាទ្រង់ឆ្មៀងព្រះនេត្រពីខាងក្រោយមិនឃើញអ្នកណាមួយឡើយ ទ្រង់ឆ្មៀងព្រះនេត្រមើលផ្នែកខាងមុខ និងផ្នែកខាងចំហៀងទាំងពីរ ក៏មើលមិនឃើញអ្នកណាមួយ (ដូចគ្នា) ។

ខណៈនោះព្រះអង្គកើតព្រះតម្រិះឡើងថា សុខណាស់ហ្ន៎ ដែលតថាគតនៅដោយឡែកអំពីភិក្ខុដែលឈ្លោះទាស់ទែងគ្នាទាំងនោះ ។ ឯចំណែកដំរីដ៏ប្រសើរ ក៏គិតដល់ហេតុជាដើមថា មិនមានដំរីពួកដទៃធ្លាប់ទំពារស៊ីមែកឈើដែលយើងបង្អោនចុះ ហើយកើតសេចក្តីគិតឡើងថា សុខណាស់ហ្ន៎ ដែលយើងនៅតែម្នាក់ឯង យើងបានធ្វើវត្តថ្វាយព្រះសាស្តា ។

ព្រះសាស្តាត្រួតមើលចិត្តរបស់ព្រះអង្គហើយ ទ្រង់ត្រិះរិះថា ចិត្តរបស់

តថាគត និងចិត្តរបស់ដំរី ដូចម្ដេចហ្ន៎ ទ្រង់ឃើញចិត្តរបស់ដំរីនោះ ដូច្នេះដែរ ទើបទ្រង់ត្រិះរិះថា ៖

ចិត្តរបស់យើងទាំងពីរដូចគ្នា ដូច្នេះហើយ ទ្រង់បន្លឺឧទាន នេះថា ឯតំ នាគស្ស នាគេន ឦសាទន្តស្ស ហត្ថិនោ សមេតិ ចិត្តំ ចិត្តេន យទេកោ រមតី វនេតិ ។ ហត្ថិនាគ (ដំរីដ៏ប្រសើរ) រមែងត្រេកអរក្នុងព្រៃតែម្នាក់ឯង ហេតុណា ហេតុនោះ ចិត្តរបស់ហត្ថិនាគ មានភ្លុក.ងទន្លាំ នេះ ស្មើគ្នានឹងចិត្តរបស់ព្រះពុទ្ធនាគដែរ ។

បទថា អថខោ សម្ពហុលា ភិក្ខូ (គ្រានោះ ភិក្ខុច្រើនរូប) សេចក្ដីថា គ្រានោះ កាលព្រះតថាគតប្រថាប់នៅក្នុងព្រៃបាលិលេយ្យកៈនោះ ដូចពណ៌នាមកនេះ ភិក្ខុ ៥០០ រូប ដែលចាំវស្សានៅក្នុងទិសទាំងឡាយ ។

បទថា យេនាយស្មា អានន្ទោ (ចូលទៅរកព្រះអានន្ទដល់ទីនៅ) សេចក្ដីថា (ភិក្ខុទាំងនោះ) ប្រឹក្សាគ្នាថា បានឮថា ព្រះតថាគតទ្រង់បណ្ដេញភិក្ខុសង្ឃហើយ ស្ដេចចូលទៅកាន់ព្រៃ មិនអាចនឹងចូលទៅកាន់សម្នាក់ព្រះសាស្ដាតាមធម្មតារបស់ខ្លួនបាន ទើបចូលទៅរកព្រះអានន្ទដល់ទីនៅ ។

[១៧៣] បទថា **អនន្តរា អាសវានំ ខយោ** សេចក្តីថា អរហត្តផល ដែលកើតបន្ទាប់ពីមគ្គ ។

បទថា **វិចយសោ** ប្រែថា ដោយការពិចារណា អធិប្បាយថា កំណត់ ដោយញាណ ដែលអាចពិចារណាដល់សភាវៈរបស់ធម៌ទាំងនោះៗ ។

បទថា **ធម្មោ** សំដៅដល់ សាសនធម៌ ។ ព្រះមានព្រះភាគទ្រង់សម្តែង ធម៌កំណត់ចំណែកពួកណា មានជាដើមថា សតិប្បដ្ឋាន ៤ ទុក ដើម្បីត្រូវការ ប្រកាសចំណែកទាំងនោះ ព្រះអង្គទើបត្រាស់ (ព្រះពុទ្ធវចនៈនេះទុក) ។

## បដិច្ចសមុប្បាទដោយសង្ខេប

[១៧៤] បទថា **សមនុបស្សនា** បានដល់ ការពិចារណាឃើញដោយ ទិដ្ឋិ ។

បទថា **សង្ខារោ សោ** បានដល់ សង្ខារ គឺ ទិដ្ឋិនោះ ។

បទថា **តតោជោ សោ សង្ខារោ** សេចក្តីថា សង្ខារនោះកើតពីតណ្ហា នោះ អធិប្បាយថា ក្នុងបណ្តាចិត្តដែលសម្បយុត្តដោយតណ្ហា សង្ខារនោះ រមែង កើតក្នុងចិត្ត ៤ ដួង ។

បទថា **សាបិ តណ្ហា** (សូម្បីតណ្ហានោះ) បានដល់ តណ្ហាដែលជា បច្ច័យនៃសង្ខារ គឺ ទិដ្ឋិនោះ ។

បទថា **សាបិ វេទនា** (សូម្បីវេទនានោះ) បានដល់ វេទនាដែលជាបច្ច័យនៃតណ្ហានោះ ។

បទថា **សោបិ ផស្សោ** (សូម្បីផស្សៈនោះ) បានដល់ សម្ផ័ស្សដែលកើតពីអវិជ្ជា ដែលជាបច្ច័យនៃវេទនានោះ ។

បទថា **សាបិ អវិជ្ជា** (សូម្បីអវិជ្ជានោះ) បានដល់ អវិជ្ជាដែលសម្បយុត្តដោយផស្សៈនោះ ។

**បើមានយើង បរិក្ខាររបស់យើងក៏មាន**

[១៨០] បទថា **នោ ចស្សំ នោ ច មេ សិយា** សេចក្តីថា បើយើងមិនមាន សូម្បីបរិក្ខាររបស់យើងក៏មិនមានដែរ ។

បទថា **ន ភវិស្សាមិ ន មេ ភវិស្សតិ** សេចក្តីថា បើសូម្បីក្នុងអនាគតយើងនឹងមិនមាន ដូច្នេះ សូម្បីបរិក្ខាររបស់យើងក៏នឹងមិនមាន ។

ព្រះមានព្រះភាគស្តេចមក ឲ្យភិក្ខុនោះបោះបង់ទិដ្ឋិដែលប្រកាន់ហើយតាមអធ្យាស្រ័យបុគ្គលខ្លះ តាមការផ្លាស់ប្តូរទេសនាខ្លះ ។

ក្នុងបទថា **តតោជោ សោ សង្ខារោ** គប្បីជ្រាបអធិប្បាយថា ៖

សួរថា ក្នុងចិត្តដែលសម្បយុត្តដោយតណ្ហា មិនមានវិចិកិច្ឆាឡើយ (ហើយ) សង្ខារ គឺ វិចិកិច្ឆានឹងកើតពីតណ្ហាបានយ៉ាងណា ?

ឆ្លើយថា សង្ខារ គឺ វិចិកិច្ឆាកើតពីតណ្ហា ក៏ព្រោះនៅមិនទាន់លះបង់តណ្ហាបាន ។ អធិប្បាយថា កាលតណ្ហាណានៅមិនទាន់លះបង់បាន សង្ខារ គឺ វិចិកិច្ឆានោះក៏កើតឡើង ព្រះមានព្រះភាគទ្រង់សំដៅយកតណ្ហានោះ ទើបត្រាស់ពាក្យនេះថា **តតោជោ សោ សង្ខារោ** ។ សូម្បីក្នុងទិដ្ឋិ ក៏បានន័យតែម្យ៉ាងដូចគ្នា ។ ព្រោះធម្មតាថា ទិដ្ឋិសម្បយុត្ត រមែងមិនមានក្នុងចិត្តុប្បាទ ៤ ដួង ។

ម្យ៉ាងទៀត ទិដ្ឋិសម្បយុត្តនោះកើតឡើង ព្រោះលះបង់តណ្ហាណាមិនបាន សំដៅយកតណ្ហានោះ អត្ថន័យនេះ ទើបប្រើបានសូម្បីក្នុងទិដ្ឋិនោះ រួមសេចក្ដីថា ព្រះមានព្រះភាគត្រាស់វិបស្សនាជាបជល់កំពូល គឺ អរហត្តផលទុកក្នុងឋាន: ២៣ ក្នុងសូត្រនេះ ។

ចប់អដ្ឋកថា ចាលិលេយ្យសូត្រទី៩

# អ ដ្ឋ ក ថា

## បុណ្ណមសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង បុណ្ណមសូត្រទី ១០ ដូចតទៅនេះ ៖*

*[១៨២] បទថា **តទហុបោសថេ** ជាដើម បានអធិប្បាយទុកហើយ យ៉ាងពិស្ដារក្នុងបវារណាសូត្រ ។*

### *ភិក្ខុសួរបញ្ហាក្នុងរឿងបញ្ចក្ខន្ធ*

*[១៨៣] បទថា **កិញ្ចិ ទេសំ** បានដល់ ហេតុណាមួយ ។*

*បទថា **សកេ អាសនេ និសីទិត្វា បុច្ឆ យទាកង្ខសិ** (ចូរអ្នកអង្គុយលើអាសនៈជារបស់ខ្លួន ហើយសួរប្រស្នានោះចុះ) ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបត្រាស់យ៉ាងនេះ ។*

*ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ព្រោះទ្រង់ជ្រាបថា បានឮថា ភិក្ខុនោះមានភិក្ខុជាបរិវារ ៥០០ រូប ក៏កាលភិក្ខុដែលជាអាចារ្យ ឈរទូលសួរបញ្ហាហើយ បើភិក្ខុ (៥០០ រូប) នោះអង្គុយ ក៏ជាការធ្វើសេចក្ដីគោរពក្នុងព្រះសាស្ដា (តែ) មិនជាការធ្វើសេចក្ដីគោរពក្នុងអាចារ្យ បើឈរ ក៏ជាការធ្វើសេចក្ដីគោរពក្នុងអាចារ្យ (តែ) មិនជាការធ្វើសេចក្ដីគោរពក្នុងព្រះសាស្ដា បើដូច្នេះ ចិត្ត*

របស់ភិក្ខុទាំងនោះក៏នឹងរាយមាយ ពួកភិក្ខុនឹងមិនអាចទទួលព្រះធម្មទេសនាបាន តែកាលភិក្ខុដែលជាអាចារ្យនោះអង្គុយស្ងួរ ចិត្តរបស់ភិក្ខុទាំងនោះនឹងតម្កល់មាំ (ក្នុងអារម្មណ៍តែមួយ) ពួកភិក្ខុក៏នឹងអាចទទួលព្រះធម្មទេសនាបាន ។

បទថា **ឥមេ នុ ខោ ភន្តេ** សេចក្តីថា ព្រះថេរៈនេះ ដែលអ្នកណាៗមិនគួរនិយាយ (តិះដៀល) ថា អ្នកដែលជាអាចារ្យរបស់ភិក្ខុតាំង ៥០០ រូបមិនដឹងសូម្បីត្រឹមតែបញ្ចក្ខន្ធ ។ ព្រោះកាលលោកសួរបញ្ហា នឹងសួរដូចអ្នកដែលដឹង យ៉ាងនេះថា ឧបាទានក្ខន្ធ ៥ ទាំងនេះ មិនមែនឧបាទានក្ខន្ធដទៃមិនសមគួរឡើយ ព្រោះដូច្នោះ លោកទើបសួរដូចអ្នកមិនដឹង ។

ម្យ៉ាងទៀត សូម្បីអន្តេវាសិកទាំងឡាយរបស់លោកនោះ នឹងនាំគ្នាគិតថា អាចារ្យរបស់ពួកយើង មិននិយាយថាយើងដឹង តែប្រៀបផ្ទឹមជាមួយព្រះសព្វញ្ញុតញ្ញាណមុនហើយ ទើបនិយាយ ដូច្នេះ បានសម្គាល់ពាក្យទូន្មានរបស់លោកថា គួរស្តាប់ គួរជឿកាន់យក សូម្បីព្រោះហេតុនោះ លោកទើបសួរដូចអ្នកមិនដឹង ។

## បញ្ចក្ខន្ធមានឆន្ទៈជាមូលហេតុ

[១៨៤] បទថា **ឆន្ទមូលកា** គឺ (បញ្ចក្ខន្ធ) មានឆន្ទៈ គឺ តណ្ហាជាមូល ។

បទថា **ន ខោ ភិក្ខុ តញ្ញេវ ឧបាទានំ តេ ច បញ្ចុបាទានក្ខន្ធា**

សេចក្ដីថា ព្រោះហេតុដែលបញ្ចក្ខន្ធនឹងរួចផុតពីឆន្ទរាគៈមិនមាន ដូច្នោះ ព្រះ-មានព្រះភាគទើបត្រាស់ព្រះពុទ្ធវចនៈបទនេះទុក ។ តែព្រោះហេតុដែលមិនមានឧបាទានដែលរួចផុតពីខន្ធ ទាំងដោយសហជាតប្បច្ច័យ ឬដោយអារម្មណប្ប-ច្ច័យ ដូច្នោះ ព្រះមានព្រះភាគទើបមិនត្រាស់ថា ឧបាទានមានក្រៅអំពីឧបា-ទានក្ខន្ធ ៥ ។ ព្រោះថា កាលចិត្តដែលសម្បយុត្តដោយតណ្ហាប្រព្រឹត្តទៅហើយ រូបដែលមានចិត្តនោះជាសមុដ្ឋាន ឈ្មោះថា រូបក្ខន្ធ ។ វៀរតណ្ហាចេញ អរូប-ធម៌ដ៏សេសចាត់ជាខន្ធ ៤ រួមសេចក្ដីថា សូម្បីដោយសហជាតប្បច្ច័យ មិនមានឧបាទានដែលរួចផុតពីបញ្ចក្ខន្ធ ម្យ៉ាងទៀត មិនមានឧបាទានដែលផុតពីបញ្ចក្ខន្ធ ទាំងដោយអារម្មណប្បច្ច័យ ព្រោះឧបាទានធ្វើខន្ធណាមួយ ក្នុងបណ្ដាបញ្ចក្ខន្ធ មានរូបជាដើម ឲ្យជាអារម្មណ៍កើតឡើង ។

## ឆន្ទរាគៈមានប្រការផ្សេងៗ ទៀត

[១៨៥] បទថា **ឆន្ទរាគវេមត្តតា** ប្រែថា ឆន្ទរាគៈមានផ្សេងៗទៀត ។

បទថា **ឯវំ ខោ ភិក្ខុ** សេចក្ដីថា ឆន្ទរាគៈមានផ្សេងៗ ទៀត គប្បីមានព្រោះឆន្ទរាគៈដែលមានរូបជាអារម្មណ៍យ៉ាងនេះ ក៏នឹងមិនធ្វើខន្ធណាមួយក្នុងបណ្ដាខន្ធ មានវេទនាខន្ធជាដើម ឲ្យជាអារម្មណ៍ ។

## បញ្ញត្តិ

[១៨៦] បទថា *ខន្ធាធិវចនំ* គឺ នេះជាបញ្ញត្តិរបស់ខន្ធទាំងឡាយ ។ ក៏បញ្ញត្តិនេះ មិនបន្តអនុសន្ធិគ្នាឡើយ មិនបន្តអនុសន្ធិគ្នាក៏ពិត សូម្បីយ៉ាងនោះ ពាក្យសួរក៏មានអនុសន្ធិ (បន្តសន្ធិ) សូម្បីពាក្យវិសជ្ជនាក៏មានអនុសន្ធិ (បន្តសន្ធិ) ។

សូម្បីព្រះថេរៈនេះ ទូលសួរ (បញ្ហាចំពោះព្រះមានព្រះភាគ) តាមអធ្យាស្រ័យរបស់ភិក្ខុទាំងនោះ ចំណែកព្រះសាស្តាក៏ទ្រង់ដោះស្រាយ (បញ្ហា) តាមអធ្យាស្រ័យរបស់ភិក្ខុទាំងនោះដូចគ្នា ។ បទដ៏សេសក្នុងទីគ្រប់កន្លែង មានអត្ថន័យងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា បុណ្ណមសូត្រទី ១០

ក៏ឯក្នុងសូត្រតែមួយៗ នៃវគ្គនេះ (មាន) ភិក្ខុ ៥០០ រូប បានសម្រេចជាព្រះអរហន្តនោះឯង ។

## ចប់ខជ្ជនិយវគ្គទី ៣

### រួមក្នុងវគ្គនេះមាន ០៨ អដ្ឋកថា


១-អស្សាទសូត្រ មិនមានអដ្ឋកថា
២-សមុទយសូត្រទី ១ មិនមានអដ្ឋកថា
៣-អដ្ឋកថា សមុទយសូត្រ
៤-អដ្ឋកថា អរហន្តសូត្រទី ១
៥-អដ្ឋកថា អរហន្តសូត្រទី ២
៦-អដ្ឋកថា សីហសូត្រ
៧-អដ្ឋកថា ខជ្ជនិយសូត្រ
៨-អដ្ឋកថា បិណ្ឌោលយសូត្រ
៩-អដ្ឋកថា ចាលិលេយ្យសូត្រ
១០-អដ្ឋកថា បុណ្ណមសូត្រ

# ថេរវគ្គទី ៤

## អ ដ្ឋ ក ថា

### អានន្ទសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង **អានន្ទសូត្រទី ១** ដូចតទៅនេះ ៖*

*ព្រះបុណ្ណមន្តានីបុត្រ*

[១៨៦] *ពាក្យថា **មន្តានីបុត្តោ** បានដល់ បុត្ររបស់នាងព្រាហ្មណី ឈ្មោះ មន្តានី ។*

*បទថា **ឧបាទាយ** ប្រែថា អាស្រ័យ គឺ ប្រារព្ធ បានដល់ ពឹងផ្អែក ។*

*បទថា **អស្មីតិ ហោតិ** សេចក្តីថា មានធម៌ជាគ្រឿងយឹតយូរ ៣ យ៉ាង គឺ តណ្ហា មានះ និងទិដ្ឋិ ដែលប្រព្រឹត្តទៅយ៉ាងនេះថា **អស្មិ** ។*

*បទថា **ទហរោ** ប្រែថា មនុស្សក្រម្ភោះ ។*

*បទថា **យុវា** បានដល់ ដល់ព្រមដោយភាពជាក្រមុំ ។*

*បទថា **មណ្ឌកជាតិយោ** ប្រែថា មានការតែងតាំងជាសភាវៈ គឺ មានប្រក្រតីពេញចិត្តតែងខ្លួន ។*

បទថា **មុខនិមិត្តំ** ប្រែថា ស្រមោលមុខ ។ ក៏ស្រមោលមុខនោះ អាស្រ័យកញ្ចក់ដ៏ថ្លាស្អាត ទើបប្រាកដ ។

សួរថា ក៏កាលបុគ្គលសម្លឹងមើលកញ្ចក់ដ៏ថ្លាស្អាតនោះ ស្រមោលមុខរបស់ខ្លួនទើបប្រាកដ ឬស្រមោលមុខរបស់អ្នកដទៃប្រាកដ ហ្ន៎ ?

អាចារ្យទាំងឡាយពោលថា បើស្រមោលមុខនឹងជារបស់ខ្លួន (ដូចម្តេច) នឹងត្រូវប្រាកដជាមុខដទៃ (គ្រង់កញ្ចក់មួយទៀត) , ប្រសិនបើស្រមោលមុខជារបស់អ្នកដទៃ (ដូចម្តេច) ក៏ប្រាកដមិនដូចគ្នា ដោយពណ៌ជាដើម ព្រោះដូច្នោះ ស្រមោលមុខនោះ ទើបមិនជារបស់ខ្លួន ទាំងមិនជារបស់អ្នកដទៃ តែជារូបដែលឃើញក្នុងកញ្ចក់នោះ អាស្រ័យកញ្ចក់ ទើបប្រាកដ ។

សួរថា បើនឹងមានស្រមោលមុខណាប្រាកដក្នុងទឹក ស្រមោលមុខនោះប្រាកដបានព្រោះហេតុអ្វី ?

ឆ្លើយថា ប្រាកដបាន ព្រោះមហាភូតរូប (ទឹក) ជារបស់ថ្លាស្អាត ។

បទថា **ធម្មោ ច មេ អភិសមេតោ** សេចក្តីថា ព្រះអានន្ទត្ថេរពោលថា ខ្ញុំបានសម្រេចធម៌ គឺ សច្ចៈ ៤ ដោយញាណ ខ្ញុំទើបសម្រេចជាព្រះសោតាបន្ន ។

ចប់អដ្ឋកថា អានន្ទសូត្រទី ១

# អ ដ្ឋ ក ថា

## តិស្សសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុងតិស្សសូត្រទី ២ ដូចតទៅនេះ ៖*

*ព្រះតិស្សត្ថេរ*

[១៩៤] *បទថា* **មធុរកជាតោ វិយ** *សេចក្តីថា (រាងកាយរបស់ខ្ញុំ) មិនសមគួរដល់ការងារ (មិនជំនាញ) ដូចកើតមានភារៈដ៏ធ្ងន់ ។*

*បទថា* **ទិសាបិ មេ** *សេចក្តីថា ព្រះតិស្សៈពោលថា សូម្បីទិសទាំងឡាយក៏មិនប្រាកដ គឺ មិនជាក់ច្បាស់ដល់ខ្ញុំយ៉ាងនេះថា នេះទិសខាងកើត នេះទិសត្បូង ។*

[១៩៥] *បទថា* **ធម្មាបិ មំ នប្បដិភន្តិ** *សេចក្តីថា ព្រះតិស្សៈពោលថា សូម្បីបរិយត្តិធម៌ទាំងឡាយ ក៏មិនប្រាកដដល់ខ្ញុំ វត្ថុដែលរៀនបានហើយ ស្វាធ្យាយបានហើយ ក៏មិនប្រាកដ (ភ្លេចអស់) ។*

*បទថា* **វិចិកិច្ឆា** *សេចក្តីថា មិនមែនវិចិកិច្ឆា (សេចក្តីសង្ស័យ) ដូចសម្គាល់ថា លោកមិនកើតសេចក្តីសង្ស័យថា "សាសនានាំសត្វចេញចាកទុក្ខបានឬទេហ្ន៎" តែលោកមានសេចក្តីគិតយ៉ាងនេះថា "យើងនឹងមិនអាចបំពេញ*

សមណធម៌បានឬហ្ន៎ ឬនឹងធ្វើបានត្រឹមតែគ្រងបាត្រ និងចីវរប៉ុណ្ណោះ”[១] ។

## កាមទាំងឡាយមានសេចក្ដីត្រេកអរតិច

បទថា **កាមានមេតំ អធិវចនំ** សេចក្ដីថា កាលបុគ្គលសម្លឹងមើលស្រះតូច ដែលជាល្បាប់ទំនាប បានត្រឹមតែគួរមើល គួររីករាយ តែ (ប្រសិនបើ) បុគ្គលណាចុះទៅក្នុងស្រះតូច ដែលជាល្បាប់ទំនាបនេះ ស្រះនោះក៏នឹងស្រូបទាញអ្នកនោះឲ្យដល់នូវសេចក្ដីវិនាស ព្រោះស្រះតូចនោះ មានត្រីកាចច្រើនយ៉ាងណា ក្នុងកាមគុណ ៥ ក៏ដូច្នោះដែរ (គឺ) ទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម មានត្រឹមតែសេចក្ដីគួររីករាយ ក្នុងការ (ឃើញ) អារម្មណ៍ (ជាដើម) តែ (បើ) បុគ្គលណាជាប់ចិត្តក្នុងកាមគុណ ៥ នេះ វាក៏នឹងទាញបុគ្គលនោះទម្លាក់ក្នុងទុគ្គតិភូមិ មាននរកជាដើមទុ៎ះឯង ។ ព្រោះថា កាមទាំងឡាយ មានសេចក្ដីត្រេកអរតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ក្នុងកាមទាំងនេះ មានទោសដ៏ក្រៃលែងឡើងៗ ព្រះមានព្រះភាគទ្រង់អាស្រ័យអំណាចប្រយោជន៍ដូចពោលមកនេះ ទើបត្រាស់ថា **កាមានមេតំ អធិវចនំ** ។

បទថា **អហមនុគ្គហេន** (តាមអនុគ្រោះ) សេចក្ដីថា តថាគតនឹងអនុគ្រោះ ដោយការអនុគ្រោះដោយធម៌ និងអាមិស ។

---

១ (បាឋៈថា **បត្តចីវរំ ធារយនមត្តមេវ** ជើងអត្ថជា **បត្តចីវរធារណមត្តមេវ** ប្រែតាមជើងអត្ថ) ។

*បទថា* ***អភិនន្ទិ*** *(ត្រេកអរនឹងភាសិត) គឺ ទទួលយក និងមិនមែនគ្រាន់តែទទួលយកតែម្យ៉ាង (ប៉ុណ្ណោះ) នៅលើកសរសើរផង ។*

*ក៏ព្រះតិស្សៈ បានទទួលការលួងលោមអំពីសម្នាក់ព្រះសាស្តាដូច្នេះហើយ ប្រារព្ធព្យាយាម មិនប៉ុន្មានថ្ងៃ ក៏បានសម្រេចជាព្រះអរហន្ត ។*

ចប់អដ្ឋកថា តិស្សសូត្រទី២

# អ ដ្ឋ ក ថា

## យមកសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង **យមកសូត្រទី ៣** ដូចតទៅនេះ ៖*

***ទិដ្ឋិរបស់ព្រះយមកៈ***

*[១៩៨] បទថា **ទិដ្ឋិគតំ** សេចក្តីថា ក៏ប្រសិនបើព្រះយមកៈនោះ គប្បីមានសេចក្តីគិតយ៉ាងនេះថា សង្ខារទាំងឡាយកើតឡើង និងរលត់ទៅ ការប្រព្រឹត្តទៅនៃសង្ខារទុំះឯង ដែលមិនប្រព្រឹត្តទៅ មានហើយ (ការគិតដូចពោលមកនេះ) មិនទាន់គួរជាទិដ្ឋិ (តែ) គួរជាញាណដែលត្រាច់ទៅក្នុងពាក្យទូន្មាន (សាសនា) ។*

*តែព្រោះព្រះយមកៈនោះ មានសេចក្តីគិតថា សត្វដាច់សូន្យ សត្វវិនាស ដូច្នោះ សេចក្តីគិតនោះ ទើបជាទិដ្ឋិ ។*

*បទថា **ថាមសា បរាមាសា** សេចក្តីថា ដោយកម្លាំងរបស់ទិដ្ឋិ និងដោយការស្ទាបអង្អែលដោយទិដ្ឋិ ។*

*បទថា **យេនាយស្មា សារីបុត្តោ** (ចូលទៅរកព្រះសារីបុត្ត) សេចក្តីថា កាលបច្ចន្តជនបទកើតចលាចល រាជបុរសមិនអាចបង្ក្រាបឲ្យស្ងប់ស្ងាត់បាន*

ទើបទៅរកសេនាបតី ឬក៏ទៅគាល់ព្រះរាជា យ៉ាងណា កាលព្រះថេរៈនោះ ញាប់ញ័រដោយអំណាចទិដ្ឋិ ភិក្ខុទាំងនោះ មិនអាចនឹងគ្របសង្កត់លោកបាន ទើបនាំគ្នាចូលទៅរកព្រះសារីបុត្រដែលជាព្រះធម្មសេនាបតី របស់ព្រះធម្មរាជាដរាបដល់ទីនៅ ។

## ព្រះសារីបុត្រទូន្មានព្រះយមកៈ

[១៩៩] បទថា **ឯវំ ព្យាខោ**[១] សេចក្តីថា ភិក្ខុយមកៈមិនអាចនឹងពោលបានពេញមាត់ (និយាយកុហក) ចំពោះមុខព្រះសារីបុត្រត្តេរ ដូចដែលពោលក្នុងសម្នាក់ភិក្ខុទាំងនោះបាន ទើបពោលតាមត្រង់ ដែលមានមុខសំយុងចុះថា **ឯវំ ព្យាខោ** (យ៉ាងហ្នឹងមែនហើយ) ដូច្នេះ ។

ក្នុងប្រការនេះ ព្រះសារីបុត្របានពោលឧបមាប្រៀបធៀបទុកដូច្នេះថា ម្នាលអ្នកមានអាយុ លោកសម្គាល់សេចក្តីនោះដូចម្តេច ?

ព្រះថេរៈ បានស្តាប់ពាក្យរបស់ព្រះយមកៈនោះ ដូច្នេះហើយ គិតថា ភិក្ខុនេះមិនឃើញទោសក្នុងលទ្ធិរបស់ខ្លួន យើងនឹងធ្វើទោសនោះឲ្យប្រាកដដល់ភិក្ខុនេះ ដោយការសម្តែងធម៌ ដូច្នេះ ហើយផ្តើមសម្តែងទេសនាមានបរិវដ្ត ៣ (ទេសនា ៣ ដោយជុំវិញ) ។

---

១ (បាលីជា ឯវំ ខ្វាហំ) ។

[២០០] បទថា **តំ កឹ មញ្ញសិ អាវុសោ យមក រូបំ តថាគតោ** ម្នាលអាវុសោយមកៈ លោកសម្គាល់សេចក្ដីនោះដូចម្ដេច លោកពិចារណាឃើញរូបថាជាសត្វឬ? ។ ព្រោះហេតុអ្វី ព្រះសារីបុត្រទើបផ្ដើមពាក្យនេះថា ម្នាលយមកៈដ៏មានអាយុ លោកសម្គាល់ប្រការនោះដូចម្ដេច? លោកពិចារណាឃើញរូបថាជាសត្វឬ?

ឆ្លើយថា ផ្ដើម ដើម្បីឲ្យសម្រេចធម្មទំនៀមដោយការសាកសួរ ។ ព្រោះថា ព្រះថេរៈនឹងសម្រេចជាព្រះសោតាបន្ន ក្នុងវេលាចប់ទេសនាដែលប្រកបបរិវដ្ដ ៣ ។

វេលានោះ ព្រះសារីបុត្រពោលពាក្យថា លោកសម្គាល់សេចក្ដីនោះដូចម្ដេចជាដើមទុក ក៏ដើម្បីឲ្យព្រះយមកៈនោះបានសម្រេចដល់ធម្មទំនៀមក្នុងការសាកសួរ ។

បទថា **តថាគតោ គឺ សត្តោ** (ប្រែថាសត្វ) ។

ព្រះសារីបុត្តត្រេប្រមូល (រួបរួម) ខន្ធ ៥ ទាំងនេះ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មក ហើយសួរថា លោកពិចារណាឃើញខន្ធទាំង ៥ នេះថាជាសត្វឬ?

[២០៣] បទថា **ឯត្ថ ច តេ អាវុសោ** (អាវុសោយមកៈ លោកនឹង

ស្វែងរកសត្វបុគ្គលក្នុងខន្ធ ៥) នេះ ជាសត្តមីវិភត្តិសម្តែងដល់ការសាកសួរ របស់ព្រះថេរៈ មានពាក្យអធិប្បាយដូច្នេះថា ក៏ក្នុងបច្ចុប្បន្ន លោកនៅរកសត្វមិនបាន តាមសេចក្តីពិត តាមសភាវៈដែលពិតក្នុងទីនេះ គឺ ក្នុងឋានៈមានប្រមាណប៉ុណ្ណោះ ។

[២០៤] ព្រះសារីបុត្រត្ថេរ ប្រាថ្នានឹងឲ្យភិក្ខុយមកៈព្យាករណ៍ភាពជាព្រះអរហន្ត ទើបសួរពាក្យនេះថា **សចេ តំ អាវុសោ** (អាវុសោយមកៈ ប្រសិនបើជនទាំងឡាយគប្បីសួរលោកថា) ដូច្នេះជាដើម ។

បទថា **យំ ទុក្ខំ និរុទ្ធំ** សេចក្តីថា វត្ថុណាជាទុក្ខ វត្ថុនោះឯងរលត់ទៅហើយ មិនមានសត្វដទៃណាផ្សេងដែលឈ្មោះថារលត់នោះទេ ខ្ញុំគប្បីព្យាករណ៍យ៉ាងនេះ ។

[២០៥] បទថា **ឯតស្សេវ អត្ថស្ស** សេចក្តីថា បឋមមគ្គ (សោតាបត្តិមគ្គ) នោះ យ៉ាងនេះ ។

បទថា **ភិយ្យោសោមត្តាយ ញាណាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់ញាណមានប្រមាណដ៏ក្រៃលែង អធិប្បាយថា ដើម្បីប្រយោជន៍ដល់ការធ្វើមគ្គ ៣ ខាងលើ ព្រមទាំងវិបស្សនាឲ្យជាក់ច្បាស់ ។

បទថា **អារក្ខសម្បន្នោ** គឺ ដល់ព្រមដោយការរក្សាខាងក្នុង និងការ

រក្សាខាងក្រៅ ។

បទថា **អយោគក្ខេមកាមោ** គឺ មិនប្រាថ្នាសេចក្តីក្សេម (រួចផុតភ័យ) អំពីយោគៈ ៤ ។

បទថា **បសយ្ហ** គឺ គ្របសង្កត់ បានដល់ សង្កត់សង្កិន ។

បទថា **អនុប្បវេជ្ជ** គឺ ក្លែងបន្លំចូលទៅ ។

ក្នុងបទថា **បុព្វុដ្ឋាយី** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

បុរសដែលឈ្មោះថា **បុព្វុដ្ឋាយី** ព្រោះសំដៅសេចក្តីថា ឃើញគហបតី ឬបុត្រគហបតីមកពីឆ្ងាយ ក៏ក្រោកចាកទីអង្គុយមុន ។ ដែលឈ្មោះថា **បច្ឆា-និបាតី** ព្រោះសំដៅសេចក្តីថា ឲ្យទីអង្គុយដល់គហបតី ឬបុត្រគហបតីនោះហើយ កាលលោកអង្គុយ (ខ្លួនឯង) ទើបទម្លាក់ខ្លួនចុះ គឺ អង្គុយក្រោយ ។ (ម្យ៉ាងទៀត) បុរសនោះភ្ញាក់ឡើងពីព្រឹកព្រលឹម ហើយចាត់ចែងថា ពួកអ្នកឯងចំនួនប៉ុណ្ណេះចូរទៅភ្ជួរស្រែ ចំនួនប៉ុណ្ណេះចូរទៅសាបព្រោះ ដូច្នេះ ឈ្មោះថាក្រោកឡើងមុនអ្នកណាទាំងអស់ ព្រោះហេតុនោះ ទើបឈ្មោះថា **បុព្វុដ្ឋាយី** ។ បុរសនោះឈ្មោះថា **បច្ឆានិបាតី** ព្រោះកាលអ្នកធ្វើការងារទាំងអស់ត្រឡប់ទៅកាន់ទីលំនៅរបស់រៀងៗ ខ្លួនហើយ (ខ្លួនឯង) ក៏នៅចាត់ចែងការរក្សាជុំវិញផ្ទះបិទទ្វារ ទើបដេកក្រោយគេ ។

ដែលឈ្មោះថា **កឹការប្បដិសារី** ព្រោះសំដៅសេចក្ដីថា សម្លឹងមើលមុខគហបតី ឬបុត្រគហបតី ហាក់ដូចជានឹងសួរថា ឲ្យខ្ញុំធ្វើអ្វីលោក (នឹងឲ្យ) ខ្ញុំធ្វើអ្វីលោក (តពីនោះ) ក៏ជាប់ស្ដាប់ពាក្យបង្គាប់ថា នឹងឲ្យធ្វើអ្វី[១] ។

ដែលឈ្មោះថា **មនាបចារី** សេចក្ដីថា ប្រព្រឹត្តវត្តដែលត្រូវចិត្ត ។

ដែលឈ្មោះថា **បិយវាទី** សេចក្ដីថា និយាយវាចាដែលគួរស្រឡាញ់ ។

បទថា **មិត្តតោបិ នំ ទហេយ្យ** (ជឿដោយភាពជាមិត្រ) សេចក្ដីថា (គហបតី ឬបុត្រគហបតី) គប្បីជឿថា បុរសនេះជាមិត្តរបស់យើង ។

បទថា **វិស្សាសំ អាបជ្ជេយ្យ** សេចក្ដីថា (គហបតី ឬបុត្រគហបតី) គប្បីធ្វើកិច្ចទាំងឡាយ មានផឹកស៊ីរួមគ្នាជាដើម ទើបជាអ្នកជិតដិតគ្នា ។

បទថា **សំវិស្សដ្ឋោ** ប្រែថា ស្និទស្នាលគ្នាល្អ ។

## ឧបមាប្រៀបធៀប

ក្នុងបទថា **ឯវមេវ ខោ** នេះ មានឧបមាប្រៀបធៀបដូចតទៅនេះ ៖

ពាលបុថុជ្ជនដែលមិនបានស្ដាប់ (ធម៌របស់ព្រះអរិយៈ) ក្នុងវេលាដែលអាស្រ័យវដ្ដៈ (នៅវិលវល់ស្លាប់កើត) ប្រៀបដូចបុត្រគហបតីដែលល្ងង់ខ្លៅ ។ បញ្ចក្ខន្ធមិនមានកម្លាំង និងទុព្វល (ទ្រុឌទ្រោម , កើតរលត់រហូតអស់វេលា)

១ បាឋៈថា កឹ ការណំ ច្បាប់ភូមាជា កឹការំ ប្រែតាមច្បាប់ភូមា ។

ប្រៀបដូចសត្រូវចាំស្កាត់ប្រហារ ។ បញ្ចក្ខន្ធដែលចូលដល់ក្នុងខណៈបដិសន្ធិ ប្រៀបដូចវេលាដែលសត្រូវអ្នកចាំស្កាត់ប្រហារ ចូលទៅរក ដោយសង្ឃឹមថា នឹងបានប្រើបុត្រគហបតីដែលល្ងង់ ។ វេលាដែលបុថុជ្ជនអាស្រ័យវដ្ដៈ មិនប្រកាន់បញ្ចក្ខន្ធថា ទាំងនេះជារបស់យើង (តែត្រឡប់ថែក) ប្រកាន់ថា រូបរបស់យើង វេទនារបស់យើង សញ្ញារបស់យើង សង្ខាររបស់យើង វិញ្ញាណ-របស់យើង ប្រៀបដូចវេលាដែលបុត្រគហបតីដែលល្ងង់ខ្លៅ មិនជ្រាបថា អ្នកនេះជាសម្លាញ់របស់យើង អ្នកនេះជាសត្រូវចាំស្កាត់ប្រហារយើង ។

វេលាដែលបុថុជ្ជនអ្នកអាស្រ័យវដ្ដៈ ប្រកាន់ (បញ្ចក្ខន្ធ) ថា ទាំងនេះរបស់យើង ហើយធ្វើសក្ការៈ (ប្រណិបត្តិ) បញ្ចក្ខន្ធ ដោយការងូតទឹក និងការបរិភោគជាដើម ប្រៀបដូចវេលាដែលសត្រូវអ្នកចាំស្កាត់ប្រហារ ព្រមទទួលថា អ្នកនេះជាមិត្តរបស់យើង ហើយធ្វើសក្ការៈ (ប្រណិបត្តិ) ។ ការដែលពាលបុថុជ្ជនអ្នកជិតស្និទអស់ជីវិត ព្រោះខន្ធបែកធ្លាយក្នុងខណៈចុតិ គប្បីជ្រាបថា ប្រៀបដូចការដែលសត្រូវអ្នកចាំស្កាត់ប្រហារ ជ្រាបថា គហបតី ឬបុត្រ-គហបតីនេះ នឹងយើងជិតស្និទគ្នាខ្លាំងណាស់ ធ្វើសក្ការៈបណ្ដើរ យកដាវកាត់សីសៈ (របស់គហបតី ឬបុត្ររបស់គហបតី) ។

[២០៧] បទថា **ឧបេតិ** ប្រែថា ចូលជិត ។ បទថា **ឧបាទិយតិ** ប្រែថា

ប្រកាន់មាំ ។

បទថា **អធិដ្ឋាតិ** ប្រែថា តាំងមាំ ។ បទថា **អត្តា មេ** សេចក្តីថា នេះជាខ្លួនរបស់យើង ។

បទថា **សុត្វា ច ខោ អាវុសោ អរិយសាវកោ** សេចក្តីថា បុត្រ-គហបតីដែលជាបណ្ឌិត ស្គាល់សត្រូវអ្នកចូលជិតយ៉ាងនេះថា អ្នកនេះជាសត្រូវរបស់យើង ទើបមិនប្រមាទ ប្រើសត្រូវឲ្យធ្វើការងារប្រភេទនោះៗ ចៀសវាងវត្ថុដែលមិនជាប្រយោជន៍ រមែងបានទទួលប្រយោជន៍ យ៉ាងណា សូម្បីព្រះ-អរិយសាវកដែលបានស្តាប់ (ធម៌របស់ព្រះអរិយៈ) ក៏ដូច្នោះ មិនប្រកាន់បញ្ចក្ខន្ធថាជាយើង ឬថារបស់យើង ដោយន័យជាដើមថា មិនពិចារណាឃើញរូបថាជាខ្លួន បានជ្រាបថា បញ្ចក្ខន្ធទាំងនេះជាសត្រូវរបស់យើង ហើយប្រកបចូលជិតនឹងវិបស្សនា ដោយរូបសត្តកៈ (ពួក ៧ របស់រូប) និង អរូបសត្តកៈ (ពួក ៧ របស់អរូប) ជាដើម ចៀសចេញចាកទុក្ខដែលកើតអំពីបញ្ចក្ខន្ធនោះ រមែងបានសម្រេចជាព្រះអរហន្តដែលជាផលដ៏ប្រសើរ ។ បទដ៏សេសក្នុងសូត្រនេះ ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា យមកសូត្រទី ៣

# អ ដ្ឋ ក ថា

## អនុរាធសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង **អនុរាធសូត្រទី ៤** ដូចតទៅនេះ ៖

[២០៨] បទថា **អរញ្ញកុដិកាយំ** បានដល់ បណ្ណសាលា (តាំងនៅ) ចុងវិហារនោះឯង ។

បទថា **តំ តថាគតោ** គឺ ព្រះតថាគតដែលជាសាស្តារបស់លោកទាំងឡាយ ។

បទថា **អញ្ញត្រិមេហ**[១] (ក្រៅពីស្ថានទាំង ៤ នេះ) សេចក្តីថា បានឮថា ព្រះអនុរាធៈនោះ មានសេចក្តីគិតដូច្នេះថា តិត្ថិយទាំងនេះជាបដិបក្ខ ជំទាស់ចំពោះព្រះសាសនា ព្រះសាស្តានឹងទ្រង់មិនបញ្ញត្តិដូចដែលពួកតិត្ថិយទាំងនេះពោល ដូច្នោះ លោកទើបពោលយ៉ាងនោះ ។

បទថា **ឯវំ វុត្តេ តេ អញ្ញតិត្ថិយា** (កាលខ្ញុំព្រះអង្គពោលយ៉ាងនេះ ពួកតិត្ថិយ) សេចក្តីថា កាលព្រះថេរៈពោល (បែប) មិនជ្រាបលទ្ធិរបស់ខ្លួន និងរបស់បុគ្គលដទៃយ៉ាងនេះ បរិព្វាជកដែលជាអន្យតិត្ថិយទាំងនោះ ដឹងត្រឹម

---

១ បាលីជា អញ្ញត្រ ឥមេហិ ។

តែលទ្ធិក្នុងសាសនា (របស់ខ្លួន) តែម្យ៉ាង ប្រាថ្នានឹងឲ្យទោស (ចាប់កំហុស) ក្នុងវាទៈរបស់ព្រះថេរៈ ទើបបានពោលពាក្យនេះ ចំពោះព្រះអនុរាធៈ ។

[២០៩] បទថា **កឹ តំ មញ្ញសិ អនុរាធ** (ម្នាលរាធៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច) សេចក្តីថា ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ព្រះអនុរាធៈនោះហើយ ទ្រង់ត្រិះរិះថា ភិក្ខុនេះមិនស្គាល់ទោសក្នុងលទ្ធិរបស់ខ្លួន តែភិក្ខុនេះជាអ្នកធ្វើ (ពិត) បានបំពេញព្យាយាមមកហើយ តថាគតនឹងឲ្យគេជ្រាបសេចក្តីនេះដោយការសម្តែងធម៌ ។ ព្រះសាស្តាបំណងនឹងសម្តែងទេសនា ដែលមានបរិវដ្តៈ ៣ ទើបត្រាស់ពាក្យថា **តំ កឹ មញ្ញសិ អនុរាធ** (ម្នាលអនុរាធៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច) ជាដើម ។

លំដាប់នោះ ព្រះមានព្រះភាគកាលនឹងទ្រង់លើកផ្លូវនៃសេចក្តីព្យាយាមដើម្បីជាព្រះអរហន្ត ឡើង (សម្តែង) ដល់ព្រះអនុរាធៈនោះ ដោយទេសនានោះទើបត្រាស់ព្រះតម្រាស់មានជាដើមថា **តំ កឹ មញ្ញសិ អនុរាធ រូបំ តថាគតោ** (ម្នាលអនុរាធៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អ្នកពិចារណាឃើញរូបថាជាសត្វឬ) ។

បទថា **ទុក្ខញ្ចេវ បញ្ញាបេមិ ទុក្ខស្ស ច និរោធំ** (តថាគតបញ្ញត្តិនូវទុក្ខនិងការរលត់ទុក្ខ) សេចក្តីថា តថាគតបញ្ញត្តិវដ្តទុក្ខ និងសេចក្តីរលត់ទៅនៃ

វដ្តទុក្ខ គឺ ព្រះនិព្វាន ។

ម្យ៉ាងទៀត ដោយពាក្យថា ទុក្ខំ ដែលព្រះមានព្រះភាគទ្រង់សំដៅដល់ទុក្ខសច្ចៈ កាលទ្រង់សំដៅដល់ទុក្ខសច្ចៈនោះ ក៏ជាការសំដៅដល់សមុទយសច្ចៈផង ព្រោះសមុទយសច្ចៈ ជាមូលហេតុនៃទុក្ខសច្ចៈនោះ ។

ដោយពាក្យថា និរោធំ ព្រះមានព្រះភាគទ្រង់សំដៅដល់និរោធសច្ចៈ កាលទ្រង់សំដៅដល់និរោធសច្ចៈនោះ ក៏ជាការសំដៅដល់មគ្គសច្ចៈផង ព្រោះមគ្គសច្ចៈជាឧបាយ (ឲ្យសម្រេច) និរោធសច្ចៈនោះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់ថា ម្នាលអនុរាធៈទាំងកាលមុន និងឥឡូវនេះ តថាគតបញ្ញត្តិសច្ចៈទុក ៤ ប៉ុណ្ណោះ ដោយប្រការដូចពោលមកនេះ ។

ដោយហេតុផលដូចពោលមកនេះ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ទុកទាំងវដ្តៈ និងវិវដ្តៈ ។

ចប់អដ្ឋកថា អនុរាធសូត្រទី ៤

# អ ដ្ឋ ក ថា

## វក្កលិសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុង *វក្កលិសូត្រទី ៥* ដូចតទៅនេះ ៖

[២១៥] បទថា *កុម្ភការនិវេសនេ* គឺ នៅក្នុងរោងស្មូនឆ្នាំង បានឮមកថា ព្រះថេរៈចេញវស្សាបវារណាហើយ បានធ្វើដំណើរមកដើម្បីគាល់ព្រះមានព្រះភាគ លោកកើតអាពាធជាទម្ងន់ (ខណៈដែលធ្វើដំណើរមកដល់) កណ្តាលព្រះនគរ (រាជគ្រឹះ) ជើង (ទាំងពីរខាង) ឈានមិនរួច ។ ពេលនោះ ពួកអ្នកក្រុងប្រើគ្រែស្នែង មានលក្ខណៈជាគ្រែតូច សែងលោកទៅទុកក្នុងរោងស្មូនឆ្នាំង ។ រោងនោះ ក៏ជារោងដែលធ្វើការងាររបស់ជាងស្មូនឆ្នាំងទាំងនោះ (តែ) មិនមែនជារោងដែលគេសម្រាកអាស្រ័យទេ ព្រះសង្គីតិកាចារ្យសំដៅយករោងនោះ ទើបពោលថា *កុម្ភការនិវេសនេ វិហរតិ* (ព្រះវក្កលិត្ថេរនៅក្នុងផ្ទះរបស់ស្មូនឆ្នាំង) ។

បទថា *ពាឡ្ហគិលានោ* គឺ ឈឺហួសប្រមាណ (ឈឺធ្ងន់) ។

[២១៦] បទថា *សមធោសិ* សេចក្តីថា (ព្រះវក្កលិត្ថេរ) តគេះតគះចុះមកខាងក្រោម ដើម្បីនមស្ការ (គោរព) ចំពោះព្រះមានព្រះភាគដោយអាការ

ញញីញញ័រ ។ បានពួមកថា ភិក្ខុដែលមានវស្សាតិចជាង ឃើញភិក្ខុដែលមានវស្សាច្រើនជាង សូម្បី (ខ្លួនឯង) មានជម្ងឺធ្ងន់ ក៏ត្រូវសម្ដែងការនមស្ការ ដោយអាការក្រោកឡើង នេះជាធម្មទំនៀម តែភិក្ខុដែលមានវស្សាច្រើនជាង ក៏ត្រូវប្រាប់លោកថា កុំក្រោកឡើងឡើយ ។

បទថា **សន្តិមានិ អាសនានិ** (អាសនៈទាំងនេះមានហើយ) សេចក្ដីថា ក៏ក្នុងសម័យពុទ្ធកាល ក្នុងទីនៅរបស់ភិក្ខុសូម្បីមួយរូប នឹងមានក្រាលអាសនៈទុកដូចគ្នាទាំងអស់ ដោយបំណងថា ប្រសិនបើព្រះសាស្ដាស្ដេចនឹងមកសោត នឹងបានប្រថាប់អង្គុយលើអាសនៈនេះ ។ ទីបំផុត (បើមិនមានអាសនៈ) ក៏នឹងក្រាលតែផែនក្ដា (ឬ) សូម្បីត្រឹមតែកម្រាលស្លឹកឈើ ក៏នឹងក្រាលទុក ។

បទថា **ខមនីយំ យាបនីយំ** សេចក្ដីថា ព្រះមានព្រះភាគត្រាស់សួរថា អ្នកល្មមអត់ទ្រាំបានឬ គឺ អ្នកអាចអត់ធន់ចំពោះទុក្ខបានឬទេ ឥរិយាបថអាចប្រព្រឹត្តទៅបានទេ ។

បទថា **បដិក្កមន្តិ** ប្រែថា ធូរស្រាលចុះ (ថយចុះ) ។

បទថា **អភិក្កមន្តិ** ប្រែថា ចម្រើន (ខ្លាំងឡើង) ។

បទថា **បដិក្កមោសានំ** ស្មើនឹង **បដិក្កមោ ឯតាសំ** ប្រែថា ទុក្ខវេទនាទាំងនោះថយចុះ ។

បទថា **សីលតោ ន ឧបវទតិ** សេចក្ដីថា ពោលតិះដៀល ព្រោះប្រារព្ធសីល គឺ ដោយសីលជាហេតុទេ ។

បទថា **ចិរប្បដិកាហំ** កាត់បទជា **ចិរប្បដិកោ អហំ** សេចក្ដីថា ខ្ញុំព្រះអង្គ (បំណងនឹងចូលគាល់ព្រះមានព្រះភាគ) តាំងពីយូរមកហើយ ។

បទថា **បូតិកាយេន** សេចក្ដីថា ព្រះមានព្រះភាគត្រាស់ដល់ព្រះវរកាយរបស់ព្រះអង្គ សូម្បីមានពណ៌ល្អដូចពណ៌មាសយ៉ាងនោះ ក៏សំដៅសេចក្ដីថា (មានរបស់បដិកូល) ហូរចេញជាប្រចាំ ។

ក្នុងបទថា **យោ ខោ វក្កលិ ធម្មំ** (ម្នាលវក្កលិ បុគ្គលណាមួយឃើញធម៌) នេះ គប្បីជ្រាបអធិប្បាយថា ព្រះមានព្រះភាគទ្រង់សម្ដែងព្រះធម្មកាយដែលត្រាស់ទុកថា សូមថ្វាយព្រះពរមហាបពិត្រ ធម្មកាយ គឺ ព្រះតថាគត ។ ពិតណាស់ លោកុត្តរធម៌ ៩ យ៉ាង (មគ្គ ៤ ផល ៤ និព្វាន ១) ឈ្មោះថាព្រះកាយរបស់ព្រះតថាគត ។

ឥឡូវនេះ កាលនឹងទ្រង់ផ្ដើមសម្ដែងធម៌ មានបរិវដ្ដ ៣ ដល់ព្រះថេរៈ ព្រះមានព្រះភាគទើបត្រាស់ពាក្យថា **តំ កឹ មញ្ញសិ** ជាដើម ។

[២១៧] បទថា **កាឡសិលា** បានដល់ វត្តកាឡសិលា ។

បទថា **វិមោក្ខាយ** បានដល់ ដើម្បីប្រយោជន៍ដល់មគ្គវិមោក្ខ ។

បទថា **សុវិមុត្តោ វិមុច្ចិស្សតិ** សេចក្តីថា (ព្រះវក្កលិត្ថេរនោះ) ជាអ្នករួចផុតល្អហើយ នឹងរួចផុតដោយវិមុត្តិ គឺ អរហត្តផល ។

បានឮថា ទេវតាទាំងនោះជ្រាបថា ព្រះថេរៈនេះប្រារព្ធវិបស្សនាហើយ លោកក៏នឹងសម្រេចព្រះអរហត្តផលដោយមិនមានអន្តរាយ ដោយទំនងណា ទើបបានពោលយ៉ាងនេះ ។

[២១៨] បទថា **អបាបកំ** គឺ មិនលាមក ។

បទថា **សត្ថំ អាហរេសិ** សេចក្តីថា បានឮថា ព្រះថេរៈជាអ្នកមានអធិមានៈ ។ លោកមើលមិនឃើញការផុសឡើងមក (ទៀត) នៃកិលេសទាំងឡាយ ដែលគ្របសង្កត់បានដោយសមាធិ និងវិបស្សនា ទើបមានការសម្គាល់ថា យើងជាព្រះខីណាស្រព ហើយគិត (តទៅទៀត) ថា ជីវិតនេះជាទុក្ខ យើងនឹងរស់នៅធ្វើអ្វី យើងនឹងយកកាំបិតមកសម្លាប់ខ្លួន ដូច្នេះ ហើយបានយកកាំបិតដ៏មុតមកអារ.ក ។ ក្នុងខណៈនោះ ទុក្ខវេទនាក៏កើតឡើងដល់លោក ។ ខណៈនោះ លោកទើបដឹងថា ខ្លួនឯងនៅជាបុថុជ្ជននៅឡើយ ទើបប្រញាប់កាន់យកមូលកម្មដ្ឋានមកពិចារណា បន្ទាប់ពីលោកមិនទាន់បានលះបង់ចោលកម្មដ្ឋាន (មិនយូរ) ក៏បានសម្រេចជាព្រះអរហន្ត ហើយបរិនិព្វាន ។

សួរថា ក៏បច្ចវេក្ខណញ្ញាណ កើតបានដូចម្តេច ?

ធ្វើយថា បច្ចវេក្ខណញ្ញាណ ១៩ យ៉ាង របស់ព្រះខីណាស្រព ព្រះ-ខីណាស្រពមិនគប្បីមានបច្ចវេក្ខណញ្ញាណទាំងអស់ ដោយពិត ។ ក៏កាលព្រះវក្កលិត្ថេរ យកកាំបិតដ៏មុតកាត់សីសៈ (បច្ចវេក្ខណញ្ញាណ) មួយ ឬពីរ រមែងកើតឡើងដោយពិត ។

[២២១] បទថា **វិវត្តក្ខន្ធំ** ប្រែថា ផាក.ក ។ បទថា **សេយ្យមានំ** ប្រែថា ដេកហើយ ។

បានឮថា ព្រះថេរៈដេកផ្ងារ ហើយយកកាំបិតមក (អារ.កខ្ទួនឯង) រាង-កាយរបស់លោកបានតាំងនៅដូចដើម ចំណែកសីសៈបានវិលទៅនៅខាងស្តាំពិតណាស់ ព្រះអរិយសាវកទាំងឡាយចំណែកច្រើន នឹងនិព្វានដោយដេកផ្អៀងខាងស្តាំដូចគ្នាទាំងអស់ ដោយហេតុនោះ រាងកាយរបស់ព្រះវក្កលិនោះ ទើបបានតាំងនៅដូចដើម ចំណែកសីសៈវិលទៅខាងស្តាំ ព្រះសង្គីតិកាចារ្យទាំងឡាយ សំដៅដល់ព្រះវក្កលិត្ថេរដែលដេកនោះ ទើបពោលថា ព្រះវក្កលិ (ដេក) ត្រឡប់សីសៈ ដូច្នេះខ្លះ ។

បទថា **ធូមាយិតត្តំ** ប្រែថា ភាវៈដែលកើតជាផ្សែងអ័ព្ទ ។

បទថា **តិមិរាយិតត្តំ** ប្រែថា ភាវៈដែលងងឹតឈឹង ។ អធិប្បាយថា ប្រៀបដូចជាពពកផ្សែង និងប្រៀបដូចជាអ័ព្ទ ។

ចប់អដ្ឋកថា វក្កលិសូត្រទី ៥

# អ ដ្ឋ ក ថា

## អស្សជិសូត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុង **អស្សជិសូត្រទី ៦** ដូចតទៅនេះ ៖

[២២២] បទថា **កស្សបការាមេ** បានដល់ ក្នុងអារាមដែលកស្សបសេដ្ឋីកសាង ។

[២២៣] បទថា **កាយសង្ខារេ** បានដល់ ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ ។ ក៏ព្រះអស្សជិនោះ រម្ងាប់ខ្យល់ដកដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ ដោយចតុត្ថជ្ឈានហើយ ។ បទថា **ឯវំ ហោតិ** សេចក្តីថា ឥឡូវនេះ កាលខ្ញុំព្រះអង្គមិនបានសមាធិនោះ ទើបមានការគិតយ៉ាងនេះ ។ បទថា **នោ ច ខ្វាហំ បរិហាយាមិ** សេចក្តីថា យើងមិនទាន់សាបសូន្យពីព្រះ-សាសនាទេឬ ។ បានឮថា សមាបត្តិរបស់លោកតម្កល់មាំ តម្កល់មាំហើយ[១] (ជាអប្បនា) សាបសូន្យទៅព្រោះទោស គឺ អាពាធ ព្រោះដូច្នោះ លោកទើបគិតយ៉ាងនេះ ។

---

១ (បាឋៈថា តស្ស កិរ អាពាធទោសេន អប្បិតោ សមាបត្តិតោ បរិហាយិ , ច្បាប់កូមាជា តស្ស កិរ អាពាធទោសេន អប្បិតប្បិតា សមាបត្តិ បរិហាយិ ។ ប្រែតាមច្បាប់កូមា)

បទថា **សមាធិសារកា សមាធិសាមញ្ញា** សេចក្តីថា សមាធិនុ៎ះឯង ជាសារៈ និងជាសាមញ្ញផល តែក្នុងសាសនារបស់តថាគត មិនមែនជាសារៈ វិបស្សនា មគ្គ និងផលជាដើម ជាសារៈ កាលបើអ្នកសាបសូន្យចាកសមាធិ ហេតុអ្វី ទើបគិតថា យើងសាបសូន្យចាកសាសនា ។

ព្រះមានព្រះភាគ លុះលួងលោមព្រះថេរៈយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់ផ្តើមសម្តែងធម៌ មានបរិវដ្ត ៣ ដល់ព្រះថេរៈនោះ ទើបត្រាស់ពាក្យថា **តំ កឹ មញ្ញសិ** ជាដើម ។ តមក កាលនឹងទ្រង់សម្តែងធម៌ជាគ្រឿងនៅប្រចាំដល់ព្រះថេរៈនោះ ដែលសម្រេចជាព្រះអរហន្ត ក្នុងវេលាចប់ទេសនា មានបរិវដ្ត ៣ ទើបត្រាស់ពាក្យជាដើមថា **សោ សុខញ្ចេ វេទនំ វេទយតិ** ។

បណ្តាបទទាំងនោះ ក្នុងបទថា **អនភិនន្ទិតា បជានាតិ** គប្បីជ្រាបអធិប្បាយថា ៖

សួរថា សុខវេទនា មានសេចក្តីភ្លើតភ្លើនត្រេកអរ ចូរលើកទុកសិនចុះ (ចំណែក) ទុក្ខវេទនា មានសេចក្តីភ្លើតភ្លើនត្រេកអរ ដូចម្តេច?

ឆ្លើយថា បុគ្គលប្រសព្វទុក្ខហើយ រមែងប្រាថ្នាសុខ នោះក៏គឺប្រាថ្នាទុក្ខនុ៎ះឯង ព្រោះទុក្ខមកដល់ ព្រោះសុខប្រែប្រួលទៅ អ្នកសិក្សាគប្បីជ្រាបសេចក្តីភ្លើតភ្លើនត្រេកអរក្នុងទុក្ខយ៉ាងនេះ ។ ពាក្យដ៏សេស មានន័យដូចពោល

*ហើយក្នុងខាងដើមនុ៎ះឯង ។*

ចប់អដ្ឋកថា អស្សជិសូត្រទី ៦

# អ ដ្ឋ ក ថា

## ខេមកសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ខេមកសូត្រទី ៧** ដូចតទៅនេះ ៖*

[២២៦] *បទថា **អត្តនិយំ** បានដល់ ដែលជាបរិក្ខាររបស់ខ្លួន ។*

[២២៧] *បទថា **អស្មីតិ អធិគតំ** សេចក្ដីថា យើងប្រសព្វនឹងតណ្ហា និងមានះ ដែលប្រព្រឹត្តទៅយ៉ាងនេះថា យើងមាន យើងមាន ។*

[២២៨] *បទថា **សន្ធាវនិកាយ** បានដល់ ដោយការទៅការមករឿយៗ ។*

*បទថា **ឧបសង្កមិ** សេចក្ដីថា ព្រះខេមៈធ្វើដំណើរអំពីវត្តពទរិការាម ទៅកាន់វត្តឃោសិតារាម (ដែលនៅឆ្ងាយពីគ្នា) ប្រមាណ ៣ គាវុត ចំណែកព្រះទាសកត្ថេរ ថ្ងៃនោះដើរផ្លូវឆ្ងាយដល់ទៅ ៣ យោជន៍ ដោយការទៅមកដល់ ៤ ដង ។*

*សួរថា ក៏ព្រោះហេតុអ្វី ព្រះថេរៈទាំងឡាយទើបបញ្ជូនព្រះទាសកៈនោះទៅ (កាន់សម្នាក់ព្រះខេមកៈ) ដោយសង្ឃឹមថា យើងទាំងឡាយនឹងបានស្ដាប់ធម៌អំពីសម្នាក់ព្រះធម្មកថិកដែលមានឈ្មោះបោះសំឡេង ព្រោះហេតុអ្វីលោកទើបមិននាំគ្នាទៅដោយខ្លួនឯង?*

ឆ្លើយថា ព្រៃដែលជាទីនៅរបស់ព្រះថេរៈចង្អៀត ក្នុងព្រៃនោះ ព្រះថេរៈចំនួនទាំង ៦០ រូប មិនមានកន្លែង (ល្មម) ឈរ ឬអង្គុយបាន ព្រោះដូច្នោះភិក្ខុទាំងនោះ ទើបមិនទៅដោយខ្លួនឯង (តែបញ្ជូនព្រះទាសកៈទៅដោយសង្ឃឹមថា) សូមព្រះខេមកៈ ចូរមកពោលធម៌ដល់យើងទាំងឡាយក្នុងទីនេះ ។

ម្យ៉ាងទៀត សួរថា ព្រោះហេតុអ្វី ព្រះថេរៈទាំងឡាយទើបបញ្ជូនព្រះទាសកៈនោះទៅ (កាន់សម្នាក់ព្រះខេមកៈ) ហ្ន៎ ?

ឆ្លើយថា ព្រោះព្រះ (ខេមកៈ) លោកអាពាធ ។

សួរថា បើដូច្នោះ ព្រោះហេតុអ្វីទើបបញ្ជូនទៅរឿយៗ ។

ឆ្លើយថា បញ្ជូនទៅក៏ដោយបំណងថា ព្រះខេមកៈជ្រាបហើយ នឹងមកពោលធម៌ដល់យើងទាំងឡាយដោយខ្លួនឯងនោះឯង ។

ចំណែកព្រះ (ខេមកៈ) ជ្រាបអធ្យាស្រ័យរបស់ព្រះថេរៈទាំងនោះហើយ ទើបបានដើរទៅ (ខ្លួនឯង) ។

[២២៩] បទថា **ន ខ្វាហំ អាវុសោ រូបំ** សេចក្តីថា ក៏ភិក្ខុណាពោលចំពោះរូបថាជាយើង ខន្ធ ៤ ក្រៅពីនេះ ក៏ជាការដែលភិក្ខុនោះពោលបដិសេធហើយ ។ ភិក្ខុណាពោលក្រៅអំពីរូប រូបក៏ជាការដែលភិក្ខុនោះពោលបដិសេធហើយ ។

ក្នុងវេទនាទាំងឡាយ ក៏មានន័យនេះ ។

ចំណែកព្រះខេមកត្ថេរបានប្រសព្វនឹងតណ្ហា និងមានះថា យើងមានក្នុងខន្ធទាំង ៥ ព្រោះហេតុនោះ លោកទើបពោលយ៉ាងនោះ ។

បទថា **ហោតេវ** គឺ រមែងមាននោះឯង ។

បទថា **អនុសហគតោ** ប្រែថា សុខុម (យ៉ាងល្អិត) ។

បទថា **ឩសេ** គឺ ទឹកប្រៃដែលកើតអំពីផេះ ។

បទថា **ខារេ** ទឹកក្បុងដែលកើតអំពីដីប្រៃ ។

បទថា **សម្មទ្ទិត្វា** គឺ ឲ្យសើម បានដល់ ឲ្យជប់ ។

ក្នុងបទថា **ឯវមេវ ខោ** នេះ មានឧបមាប្រៀបធៀបដូចតទៅនេះ ៖

ក៏វារៈចិត្តរបស់បុថុជ្ជន ប្រៀបដូចសំពត់ស្មោកគ្រោក ។

អនុបស្សនា ៣ ប្រៀបដូចទឹកប្រៃ ៣ ប្រភេទ ។

វារៈចិត្តរបស់ព្រះអនាគាមី ប្រៀបដូចសំពត់ ដែលបោកគក់ដោយទឹកប្រៃ ៣ ប្រភេទ ។

កិលេសដែលអរហត្តមគ្គសម្លាប់ ប្រៀបដូចក្លិនទឹកប្រៃជាដើមដ៏ល្អិត ។

អរហត្តមគ្គញ្ញាណ ប្រៀបដូចជាអប់ដោយរបស់ក្រអូប ការអស់ទៅនៃកិលេសទាំងអស់ដោយអរហត្តមគ្គ ប្រៀបដូចក្លិនទឹកប្រៃជាដើមដ៏ល្អិតអស់

ទៅ ព្រោះអាស្រ័យអប់ដោយរបស់ក្រអូប ។

ព្រះនិព្វានស្រពផ្សាយទូទៅទាំង ១០ ទិស ដោយក្លិនក្រអូបទាំងឡាយ មានក្លិនសីលជាដើម ។ ត្រាច់ (ចារិក) ទៅតាមចិត្តប្រាថ្នា ប្រៀបដូចបុគ្គល មានក្លិនខ្លួនក្រអូប ស្លៀកដណ្តប់សំពត់ដែលអប់ដោយក្លិនក្រអូប ហើយត្រាច់ ទៅតាមថ្នល់ក្នុងថ្ងៃមានមហោស្រព ។

[២៣០] បទថា **អាចិក្ខិតុំ** (ប្រាប់) ប្រែថា ដើម្បីប្រាប់ ។ បទថា **ទេសេតុំ** (សម្តែង) ប្រែថា ដើម្បីប្រកាស ។ បទថា **បញ្ញបេតុំ** (បញ្ញត្ត) ប្រែថា ដើម្បីឲ្យអ្នកដទៃជ្រាប ។ បទថា **បដ្ឋបេតុំ** (តែងតាំង) ប្រែថា ដើម្បីឲ្យ (ពាក្យទូន្មានរបស់ព្រះមានព្រះភាគ) តាំងមាំ ។ បទថា **វិវរិតុំ** (បើក) ប្រែថា ដើម្បីធ្វើ (ពាក្យទូន្មានរបស់ព្រះមានព្រះភាគ) ឲ្យបើកបង្ហាញ ។ បទថា **វិភជិតុំ** (ចែក) ប្រែថា ដើម្បីធ្វើ (ពាក្យទូន្មានរបស់ព្រះមានព្រះភាគ) ឲ្យជាការ ចែកទុកល្អហើយ ។ បទថា **ឧត្តានីកាតុំ** (ធ្វើឲ្យរាក់) ប្រែថា ដើម្បីធ្វើ (ពាក្យ ទូន្មានរបស់ព្រះមានព្រះភាគ) ឲ្យមានអត្ថងាយឡើង ។

បទថា **សដ្ឋិមត្តានំ ថេរានំ** សេចក្តីថា បានឮថា ព្រះថេរៈប្រមាណ ៦០ រូបនោះ ផ្តើមចម្រើនវិបស្សនាក្នុងទីដែលព្រះថេរៈពោល (ធម៌ដល់ពួក ខ្លួន) ហើយពិចារណាជាលំដាប់ៗ វេលាចប់ទេសនា ក៏បានសម្រេចជាព្រះ-

អរហន្ត ។ ចំណែកព្រះ (ខេមកៈ) មិនពោលដោយទំនងដទៃ តែពោលដោយចិត្តសហគតៈដោយវិបស្សនាទុំះឯង ព្រោះដូច្នោះ លោកទើបសម្រេចជាព្រះ-អរហន្តដែរ ដោយហេតុនោះ ព្រះសង្គីតិកាចារ្យទាំងឡាយទើបពោលថា ចិត្តរបស់ភិក្ខុជាថេរៈប្រមាណ ៦០ រូប និងរបស់ព្រះខេមកៈ រួចផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។

ចប់អដ្ឋកថា ខេមកសូត្រទី ៧

# អ ដ្ឋ ក ថា

## ឆន្នសូត្រទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុង ឆន្នសូត្រទី ៨ ដូចតទៅនេះ ៖

### ព្រះឆន្នត្ថេរ

[២៣១] បទថា **អាយស្មា ឆន្នោ** បានដល់ ព្រះឆន្នត្ថេរ កើតក្នុងថ្ងៃតែមួយជាមួយព្រះតថាគត ក្នុងថ្ងៃដែលព្រះតថាគតស្តេចចេញមហាភិនេស្រ្កម៍ក៏ដោយ ក៏ចេញទៅជាមួយ លុះវេលាតមកបានបព្វជ្ជាក្នុងសម្នាក់ព្រះសាស្តា ត្រឡប់ជាមានប្រក្រតីមើលងាយ វាយឫកស្មើ យ៉ាងនេះថា ព្រះពុទ្ធរបស់យើង ព្រះធម៌របស់យើង បៀតបៀនសហព្រហ្មចារីដោយ វាចាគ្រោតគ្រាត ។

បទថា **អបាបុរណំ អាទាយ** គឺ កាន់យកកូនសោរ ។

បទថា **វិហារេន វិហារំ ឧបសង្កមិត្វា** សេចក្តីថា (ព្រះឆន្នៈ) ចូលទៅកាន់វិហារមួយខ្នង ចេញចាកវិហារខ្នងនោះហើយ ក៏ចូលទៅកាន់វិហារខ្នងដទៃ ចេញចាកវិហារខ្នងដទៃនោះហើយ ក៏ចូលទៅកាន់វិហារខ្នងដទៃ (តៗទៀត) រួមសេចក្តីថា ចេញចាកវិហារខ្នងនោះៗ ចូលទៅកាន់វិហារខ្នងនោះយ៉ាងនេះ ។

បទថា **ឯតទវោច ឱវទន្តុ មំ** សេចក្តីថា សួរថា ព្រោះហេតុអ្វីលោក

ទើបទៅក្នុងវិហារនោះៗ ដោយសេចក្តីឧស្សាហ៍ច្រើនយ៉ាងនេះ ហើយបានពោលពាក្យនេះ?

ឆ្លើយថា ព្រោះលោកកើតសេចក្តីសង្វេគ ។

សេចក្តីពិត កាលព្រះសាស្តាស្តេចរលត់ខន្ធបរិនិព្វានហើយ ព្រះអានន្ទបានទទួលបង្គាប់ពីព្រះធម្មសង្គាហកត្ថេរទាំងឡាយ ទើបបានទៅកាន់ក្រុងកោសម្ពី ហើយបានដាក់ព្រហ្មទណ្ឌដល់ព្រះឆន្នៈនោះ ។

កាល (ព្រះឆន្នៈ) ត្រូវព្រហ្មទណ្ឌហើយ លោកក៏កើតសេចក្តីក្តៅក្រហាយដរាបដល់សន្លប់ លុះដឹងខ្លួនឡើងមក ទើបក្រោកឡើងទៅកាន់សម្នាក់ភិក្ខុមួយរូប ភិក្ខុរូបនោះក៏មិនព្រមនិយាយចរចាអ្វីនឹងលោក ។ លោកបានទៅកាន់សម្នាក់ភិក្ខុរូបដទៃ សូម្បីភិក្ខុរូបនោះក៏មិនបាននិយាយ (អ្វីនឹងលោក) រួមសេចក្តីថា លោកត្រាច់ទៅដរាបទូទៅទាំងវត្តយ៉ាងនេះ ហើយក៏កើតសេចក្តីនឿយណាយ ទើបកាន់បាត្រ និងចីវរទៅកាន់ក្រុងពារាណសី កើតសេចក្តីសង្វេគទើបទៅកាន់វិហារខ្ទង់នោះៗ ហើយបានពោលយ៉ាងនេះ ។

**[២៣២]** បទថា *សព្វេ សង្ខារា អនិច្ចា* សេចក្តីថា សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់មិនទៀង ។

បទថា *សព្វេ ធម្មា អនត្តា* សេចក្តីថា ធម៌ទាំងឡាយដែលប្រព្រឹត្តទៅ

ក្នុងភូមិ ៤ ទាំងអស់ ជាអនត្តា ។

ភិក្ខុទាំងអស់នោះ កាលនឹងឲ្យឱវាទព្រះថេរៈ ទើបប្រាប់លក្ខណៈ ២ គឺ អនិច្ចលក្ខណៈ អនត្តលក្ខណៈ តែមិនប្រាប់ដល់ទុក្ខលក្ខណៈ ដោយប្រការដូចពណ៌នាមកដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា បានឮថា ភិក្ខុទាំងនោះមានសេចក្តីគិតយ៉ាងនេះថា ប្រសិនបើយើងទាំងឡាយបញ្ញត្តទុក្ខលក្ខណៈ ភិក្ខុនេះ (ឆន្នភិក្ខុ) នឹងគប្បីសង្ស័យថា រូបជាទុក្ខ ។ល។ វិញ្ញាណជាទុក្ខ មគ្គជាទុក្ខ ផលជាទុក្ខ ដូច្នោះ ភិក្ខុទាំងឡាយឈ្មោះថា ជាភិក្ខុដែលខ្វាចទុក្ខផង យើងទាំងឡាយនឹងប្រាប់មិនឲ្យមានទោសដល់ឆន្នភិក្ខុ ដោយប្រការដែលភិក្ខុនេះមិនអាចកម្ចាត់ភាពសង្ស័យបាន ភិក្ខុទាំងនោះ ទើបបានប្រាប់ត្រឹមតែពីរលក្ខណៈប៉ុណ្ណោះ ។

បទថា **បរិត្តស្សនាឧបាទានំ ឧប្បជ្ជតិ** សេចក្តីថា សេចក្តីតក់ស្លុត និងឧបាទានកើតឡើង ។

បទថា **បច្ចុទាវត្តតិ មានសំ អថ កោ ចរហិ មេ អត្តា** សេចក្តីថា ចិត្តរបស់ខ្ញុំវិលត្រឡប់យ៉ាងនេះថា ប្រសិនបើក្នុងខន្ធ ៥ មានរូបជាដើម មិនមានសូម្បីខន្ធតែមួយដែលជាខ្លួនដែរ ក៏អ្វីហ្ន៎ ជាខ្លួនរបស់យើង ។

បានឮថា ព្រះថេរៈនេះ ផ្ដើមចម្រើនវិបស្សនាដោយមិនកំណត់បច្ច័យឡើយ ។ វិបស្សនាដែលទន់ខ្សោយរបស់លោកនោះ ទើបមិនអាចកម្ចាត់ការប្រកាន់ថាខ្លួនបាន កាលបើសង្ខារទាំងឡាយប្រាកដដោយភាពជារបស់សូន្យ ទើបជាបច្ច័យ (ឲ្យកើត) ឧច្ឆេទទិដ្ឋិ និងសេចក្ដីតក់ស្លុតថា យើងនឹងដាច់សូន្យ យើងនឹងវិនាស ។

ម្យ៉ាងទៀត លោកក៏ឃើញអត្តាដូចធ្លាក់ចុះទៅក្នុងជ្រោះ ទើបពោលថា សេចក្ដីតក់ស្លុត និងឧបាទានកើតឡើង ចិត្តរបស់ខ្ញុំទើបវិលត្រឡប់យ៉ាងនេះថា ក៏អ្វីហ្ន៎ ជាខ្លួនរបស់យើង ? ។

បទថា **ន ខោ បនេតំ ធម្មំ បស្សតោ ហោតិ** សេចក្ដីថា សេចក្ដីគិតយ៉ាងនេះ រមែងមិនមានដល់បុគ្គលដែលឃើញធម៌ គឺ សច្ចៈ ៤ ។

[២៣៣] បទថា **តាវតិកា វិស្សដ្ឋិ** ប្រែថា សេចក្ដីស្និទ្ធស្នាលដូច្នោះ ។

[២៣៤] បទថា **សម្មុខា មេតំ** សេចក្ដីថា ព្រះថេរៈស្ដាប់ពាក្យរបស់ឆន្នភិក្ខុនោះហើយ ទើបគិតថា ធម្មទេសនាដូចម្ដេច ទើបសមគួរដល់ភិក្ខុនេះ ជ្រើសរើសព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ក៏បានឃើញកច្ចាយនសូត្រថា ព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ជាដំបូង ក្នុងការកម្ចាត់ទិដ្ឋិផ្នែកកណ្ដាល គឺការសម្ដែងកម្លាំងរបស់ព្រះពុទ្ធ (ទសពលញាណ) , (ផ្នែកខាងចុង) ជាការ

ប្រកាសបច្ចយាការដែលល្អិតសុខុម យើងនឹងសម្តែងសូត្រនេះដល់ឆន្នភិក្ខុ ។ ព្រះអានន្ទត្ថេរ កាលនឹងសម្តែងសូត្រនោះ ទើបពោលពាក្យថា សម្មុខា មេតំ ជាដើម ។

ចប់អដ្ឋកថា ឆន្នសូត្រទី ៨

## ចប់ថេរវគ្គទី ៤

### រួមក្នុងវគ្គនេះមាន ០៨ អដ្ឋកថា

១-អដ្ឋកថា អានន្ទសូត្រ
២-អដ្ឋកថា តិស្សសូត្រ
៣-អដ្ឋកថា យមកសូត្រ
៤-អដ្ឋកថា អនុរាធសូត្រ
៥-អដ្ឋកថា វក្កលិសូត្រ
៦-អដ្ឋកថា អស្សជិសូត្រ
៧-អដ្ឋកថា ខេមកសូត្រ
៨-អដ្ឋកថា ឆន្នសូត្រ

អដ្ឋកថាសូត្រទី៩-១០ រាហុលសូត្រទី ១ និងរាហុលសូត្រទី ២ មានសេចក្តីដូចពោលហើយក្នុងរាហុលសំយុត្ត ។ក៏សូត្រទាំង ២ នេះ ដែលមកក្នុងទីនេះ ក៏ព្រោះហេតុដែលវគ្គនេះ ជាថេរវគ្គ នោះឯង ។

# បុប្ផវគ្គទី ៥

## អ ដ្ឋ ក ថា

### នទីសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង **នទីសូត្រទី ១** ដូចតទៅនេះ ៖*

[២៣៧] *បទថា **បព្វតេយ្យា** ប្រែថា ប្រព្រឹត្តទៅក្នុងភ្នំ ។ បទថា **ឱហារិណី** សេចក្តីថា នាំស្មៅ ស្លឹកឈើ និងកំណាត់ឈើជាដើម ដែលដាច់ចុះទៅក្នុងក្រសែទឹកមកខាងក្រោម ។ បទថា **ទូរង្គមា** សេចក្តីថា មានប្រក្រតីហូរទៅបាន (ឆ្ងាយ) ដល់ ៤០០ យោជន៍ ៥០០ យោជន៍ រាប់តាំងពីដែល (ផ្តើម) ហូរចេញ ។ បទថា **សីឃសោតា** ប្រែថា មានក្រសែទឹកហូរត្របាញ់ ។ បទថា **កាសា** ជាដើម សំដៅដល់តិណជាតិទាំងអស់ ។ បទថា **រុក្ខា** បានដល់ ដើមឈើដូល មានដើមល្ហុងជាដើម ។ បទថា **តេ នំ អជ្ឈោលម្ពេយ្យុំ** សេចក្តីថា ដើមឈើទាំងនោះសូម្បីដុះនៅត្រង់មាត់ច្រាំង ទេរចុះទៅ មានចុងប៉ប្រះទឹក សំយុងចុះ អធិប្បាយថា សំយុងចុះនៅខាងលើទឹក ។*

*បទថា **បលុជ្ជេយ្យុំ** សេចក្តីថា គប្បីធ្លាក់ចុះទៅលើក្បាល ព្រមជាមួយ*

កំទេចដីជាប់នឹងឫស បុរសនោះត្រូវដើមត្រែងទាំងនោះ (ដួល) សង្កត់ហើយ មានទឹកលាយខ្សាច់ លាយដី ហូរចូលមាត់ (គេ) ក៏នឹងគប្បីប្រសព្វនឹងសេចក្តីវិនាសយ៉ាងធ្ងន់ ។

ក្នុងបទថា **ឯវមេវ ខោ** នេះ មានអធិប្បាយថា ៖

ពាលបុថុជ្ជនដែលអាស្រ័យវដ្តៈ គប្បីឃើញដូចបុរសដែលធ្លាក់ចុះទៅក្នុងក្រសែទឹក ។

បញ្ចក្ខន្ធដែលទុព្វល គប្បីឃើញដូចដើមត្រែងជាដើម ដែលដុះនៅតាមមាត់ច្រាំងស្ទឹងទាំងសងខាង ។

ការដែលពាលបុថុជ្ជនមិនដឹង (តាមសេចក្តីពិត) ថា ខន្ធទាំងនេះមិនមែនសម្លាញ់របស់យើង ហើយប្រកាន់ទុកដោយការប្រកាន់ ៤ យ៉ាង គប្បីឃើញដូចបុរសនោះតោង (ដើមឈើ) ព្រោះមិនដឹងថា ដើមឈើទាំងនេះ សូម្បីចាប់តោងហើយ ក៏នឹងមិនអាចទទួលទម្ងន់ទឹកដ៏ធ្ងន់បាន ។

ការកើតឡើងនៃសេចក្តីវិនាស មានសោកៈជាដើម ដល់ពាលបុថុជ្ជន ព្រោះខន្ធដែលប្រកាន់ដោយសេចក្តីប្រកាន់ ៤ យ៉ាង ប្រែប្រួលទៅ គប្បីជ្រាបថា ដូចបុរស (នោះ) កើតសេចក្តីវិនាស ព្រោះដើមឈើដែលចាប់តោងនោះត្រូវបនា្សាត់នាំទៅ ។

ចប់អដ្ឋកថា នទីសូត្រទី ១

# អ ដ្ឋ ក ថា

## បុប្ផសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង **បុប្ផសូត្រទី ២** ដូចតទៅនេះ ៖

[២៣៩] បទថា **វិវទតិ** សេចក្ដីថា មនុស្សលោកកាលពោលថា ទៀង ជាសុខ ជាអត្តា ស្អាត ឈ្មោះថា រមែងពោលជំទាស់ជាមួយតថាគត ដែលពោលហើយតាមសភាពពិតថា មិនទៀង ជាទុក្ខ ជាអនត្តា មិនស្អាត ។

[២៤០] បទថា **លោកធម្មោ** បានដល់ ខន្ធបញ្ចកៈ (ខន្ធ ៥) ក៏ខន្ធបញ្ចកៈនោះ ហៅថា លោកធម៌ ព្រោះមានការបែកធ្លាយជាលក្ខណៈ ។

ដោយបទថា **កិន្តិ ករោមិ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់សម្ដែងថា តថាគតនឹងធ្វើយ៉ាងណា ? ព្រោះថា តថាគតមាននាទីនៅចំពោះក្នុងការប្រាប់វត្តបដិបត្តិ ចំណែកការបំពេញវត្តបដិបត្តិជានាទីរបស់កុលបុត្រទាំងឡាយ ។

ដោយហេតុផលដូចពោលមកនេះ (សរុបបានថា) ព្រះមានព្រះភាគត្រាស់លោកទុក ៣ យ៉ាង ក្នុងសូត្រនេះ គឺ ត្រាស់សត្វលោក ទុកក្នុងពាក្យនេះថា **នាហំ ភិក្ខវេ លោកេន** (ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលជំទាស់នឹងលោក) ត្រាស់សង្ខារលោក ទុកក្នុងពាក្យនេះថា **អត្ថិ ភិក្ខវេ លោកេ លោ-**

**កថេម្ម** *(ម្នាលភិក្ខុទាំងឡាយ មានលោកធម៌នៅក្នុងលោក) (និងត្រាស់)* ឱកាស-*លោកទុក ក្នុងពាក្យនេះថា* **តថាគតោ លោកេ ជាតោ លោកេ សំវឌ្ឍោ** *(ព្រះតថាគតឧប្បត្តិហើយក្នុងលោកទ្រង់ចម្រើនធំធាត់ហើយក្នុងលោក)* ។

ចប់អដ្ឋកថា បុប្ផសូត្រទី ២

# អ ដ្ឋ ក ថា

## ផេណបិណ្ឌសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង ផេណបិណ្ឌសូត្រទី ៣ ដូចតទៅនេះ ៖*

*[២៤២] បទថា **គង្គាយ នទិយា តីរេ** សេចក្តីថា ពួកអ្នកក្រុងអយោ-ជាយា ឃើញព្រះតថាគតមានភិក្ខុចំនួនច្រើនជាបរិវារ ស្តេចត្រាច់ចារិកមកដល់ក្រុងរបស់ខ្លួន ទើបបាននាំគ្នាសាងវត្តថ្វាយព្រះសាស្តាក្នុង (ភូមិ) ប្រទេសដែលជេរជាសទៅដោយព្រៃស្រោងធំ ត្រង់កន្លែងមួយ ដែលមានទន្លេគង្គាហូរគួច ។ ព្រះមានព្រះភាគប្រថាប់នៅក្នុងវិហារនោះ ព្រះសង្គីតិកាចារ្យសំដៅយកវិហារនោះ ទើបពោលថា **គង្គាយ នទិយា តីរេ** ដូច្នេះ ។*

*បទថា **តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ** សេចក្តីថា ព្រះមានព្រះភាគប្រថាប់នៅក្នុងវិហារនោះ វេលាល្ងាចស្តេចចេញអំពីព្រះគន្ធកុដិ ទៅប្រថាប់លើបវរពុទ្ធាសនៈដែលអ្នកក្រុងរៀបចំថ្វាយ ទុកត្រង់មាត់ច្រាំងទន្លេគង្គា ទតព្រះនេត្រឃើញដុំពពុះទឹកធំ អណ្តែតក្នុងទន្លេគង្គាមក ទើបទ្រង់ព្រះតម្រិះថា តថាគតនឹងពោលធម៌ដែលជាប់ទាក់ទងនឹងបញ្ចក្ខន្ធ ក្នុងសាសនារបស់តថា-គត ដូច្នេះ ហើយបានត្រាស់ហៅភិក្ខុទាំងឡាយដែលគង់ហែហម ។*

បទថា **មហន្តំ ផេណបិណ្ឌំ** សេចក្តីថា ដុំពពុះទឹក ផ្តើមតាំងពីកកើតជាគ្រាដំបូង មានទំហំប៉ុនផ្លែពុទ្រា និងប៉ុនកង់រថ កាលត្រូវក្រសែទឹកហូរនាំទៅ ក៏មានខ្លួនធំឡើងតាមលំដាប់ រហូតមានទំហំប៉ុនកំពូលភ្នំ ដែលសត្វចំនួនច្រើនមានពស់ទឹកជាដើម អាស្រ័យនៅ បានដល់ ពពុះទឹកដែលធំបែបនេះ ។

បទថា **អាវហេយ្យ** ប្រែថា គប្បីនាំមក ។

ក៏ពពុះទឹកនេះ រមែងបែកធ្លាយទៅត្រង់ទីដែលខ្លួនក.ឡើងខ្លះ អណ្តែតទៅបានបន្តិច ទើបបែកធ្លាយខ្លះ , អណ្តែតទៅបានឆ្ងាយប្រមាណមួយយោជន៍ ពីរយោជន៍ជាដើម ទើបបែកធ្លាយខ្លះ តែសូម្បីមិនបែកធ្លាយក្នុងរវាងផ្លូវ កាលដល់សមុទ្រហើយ ក៏រមែងបែកធ្លាយដោយពិត ។

បទថា **និជ្ឈាយេយ្យ** ប្រែថា គប្បីសម្លឹងមើល ។

បទថា **យោនិសោ ឧបបរិក្ខេយ្យ** ប្រែថា គប្បីពិចារណាតាមហេតុ ។

បទថា **កិញ្ហិ សិយា ភិក្ខវេ ផេណបិណ្ឌេ សារោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ក្នុងពពុះទឹក នឹងមានសារៈបានដូចម្តេច ? ពពុះទឹកនឹងគប្បីបែកធ្លាយទៅ វិនាសទៅតែម្យ៉ាង ។

## រូប

បទថា **ឯវមេវ ខោ** សេចក្តីថា ពពុះទឹកមិនមានសារៈ (ខ្លឹម) យ៉ាង

ណា សុប្បីរូបក៏មិនមានសារៈដូច្នោះដូចគ្នា ព្រោះវៀរចាកសារៈ គឺ ទៀង សារៈ គឺ ឋិតថេរ និងសារៈ គឺ អត្តា ។

ប្រៀបដូចជាពពុះទឹក នរណាៗ មិនអាចនឹងចាប់យក ដោយបំណងថា យើងនឹងយកពពុះទឹកនេះ ធ្វើកាជនៈ ឬថាស សូម្បីចាប់កាន់ហើយ ក៏មិនឲ្យសម្រេចប្រយោជន៍នោះបាន រមែងបែកធ្លាយភ្លាម យ៉ាងណា សូម្បីរូបក៏ដូច្នោះ នរណាៗ មិនអាចប្រកាន់បានថា យើង ឬរបស់យើង សូម្បីប្រកាន់ហើយ ក៏តាំងនៅយ៉ាងនោះមិនបាន រមែងដូចដុំពពុះទឹកយ៉ាងនេះឯង គឺ មិនទៀង ជាទុក្ខ ជាអនត្តា មិនស្អាតឡើយ ។

ម្យ៉ាងទៀត ប្រៀបដូចជាដុំពពុះទឹក មានប្រហោងតូចៗ ជាប់តគ្នាច្រើនតំណ ជាទីនៅអាស្រ័យរបស់សត្វដ៏ច្រើន មានពស់ទឹកជាដើម យ៉ាងណា សូម្បីរូបក៏ដូច្នោះ មានប្រហោងតូចៗ ជាប់តដោយទីតច្រើនកន្លែង ក្នុងរូបនេះ ពួកជន្តុវ ៨០ ក្រុម អាស្រ័យនៅរួមគ្នាជាត្រកូលតែមួយ រូបនោះឯង ទាំងជាផ្ទះកើត ទាំងជាស្មួន ទាំងជារោងព្យាបាល ទាំងជាព្រៃខ្មោចជាទីចោលសាកសពរបស់ពួកជន្តុវទាំងនោះ ពួកជន្តុវទាំងនោះ រមែងមិនទៅធ្វើកិច្ចទាំងឡាយ មានការកើតកូនជាដើមក្នុងទីដទៃ ។ រូប ដូចជាដុំពពុះទឹកដោយអាការយ៉ាងនេះខ្លះ ។

មួយទៀត ប្រៀបដូចដុំពពុះទឹក ពីដំបូងក៏មានទំហំប្រមាណប៉ុនផ្លែពុទ្រា និងកង់រថ (តមកបានកឲ្យធំឡើង) រហូតមានទំហំប្រមាណប៉ុនកំពូលភ្នំ តាមលំដាប់ យ៉ាងណា សូម្បីរូបក៏ដូច្នោះ ដំបូងមានទំហំប៉ុនកលលៈ (តមកក៏បានកឲ្យធំឡើង) តាមលំដាប់ រហូតមានទំហំប្រមាណមួយព្យាមខ្លះ មានទំហំប៉ុនកំពូលភ្នំជាដើម ដោយអំណាចនៃក្របី និងដំរីជាដើមខ្លះ មានទំហំប្រមាណ ១០០ យោជន៍ ដោយអំណាចនៃត្រី និងអណ្តើកជាដើមខ្លះ ។ រូប ដូចជាដុំពពុះទឹក ដោយអាការយ៉ាងនេះខ្លះ ។

មួយទៀត ប្រៀបដូចពពុះទឹក ពេលកខ្ទួនឲ្យកើតឡើងហើយ ក៏បែកធ្លាយខ្លះ អណ្តែតទៅបានបន្តិចក៏បែកធ្លាយខ្លះ អណ្តែតទៅបានឆ្ងាយក៏បែកធ្លាយខ្លះ តែពេលដល់សមុទ្រហើយ ក៏ធ្លាយពិតនោះឯង យ៉ាងណា សូម្បីរូបក៏ដូច្នោះដែរ បែកធ្លាយក្នុងគ្រាជាកលលៈខ្លះ ក្នុងគ្រាជាអព្វុទៈជាដើមខ្លះ តែសូម្បីនឹងមិនបែកធ្លាយក្នុងវ័យកណ្តាល មានអាយុរស់នៅរហូតបានដល់ ១០០ ឆ្នាំ លុះដល់ ១០០ ឆ្នាំ ក៏បែកធ្លាយដោយពិត ។ រូប នៅក្នុងវិថីនៃមរណៈរឿយៗ ។ រូប ដូចជាដុំពពុះទឹកដោយអាការយ៉ាងនេះខ្លះ ។

## វេទនា

[២៨៣] សូម្បីក្នុងបទថា កិញ្ចិ សិយា កិក្ខវេ វេទនាយ សារោ

ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

គប្បីជ្រាបថា វេទនាជាដើម ដូចគ្នានឹងក្រពេញទឹកជាដើម យ៉ាងនេះ គឺ ក្រពេញទឹកមិនមានសារៈ យ៉ាងណា សូម្បីវេទនា ក៏មិនមានសារៈ ។

ដោយន័យថា ក្រពេញទឹកនោះមិនមានកម្លាំង ចាប់មិនបាន នរណាៗ មិនអាចនឹងយកក្រពេញទឹកនោះមកធ្វើផែនក្ដា ឬទីអង្គុយបាន ក្រពេញទឹកដែលចាប់បានហើយ ក៏បែកធ្លាយក្លាម យ៉ាងណា សូម្បីវេទនាក៏ដូច្នោះ មិនមានកម្លាំង ចាប់មិនបាន នរណាៗ មិនអាចនឹងចាប់ទុកដោយសម្គាល់ថា ទៀង ឬឋិតថេរ សូម្បីចាប់បានហើយ ក៏គង់នៅយ៉ាងនោះមិនបាន វេទនា ឈ្មោះថាដូចជាក្រពេញទឹក ព្រោះចាប់ទុកមិនបាន យ៉ាងនេះខ្លះ ។

មួយទៀត ក្រពេញទឹក រមែងកើត និងបែកធ្លាយ ព្រោះក្រពេញទឹកនោះៗ តាំងនៅបានមិនយូរ យ៉ាងណា សូម្បីវេទនាក៏ដូច្នោះ រមែងកើត និងបែកធ្លាយទៅ តាំងនៅបានមិនយូរ ក្នុងខណៈមួយផ្ទាត់ម្រាមដៃ កើតហើយ រលត់ទៅរាប់បានដោយសែនកោដិជង ។

មួយទៀត ក្រពេញទឹកកើតឡើងបាន ព្រោះអាស្រ័យហេតុ ៤ យ៉ាង គឺ ទឹក តំណក់ទឹក រលកទឹក និងខ្យល់ដែលបក់មក ឲ្យរួមគ្នាជាដុំ យ៉ាងណា សូម្បីវេទនាក៏ដូច្នោះ កើតឡើងបាន ព្រោះអាស្រ័យហេតុ ៤ យ៉ាង គឺ វត្ថុ

អារម្មណ៍ កិលេស និងការប៉ះខ្ទប់គ្នាដោយអំណាចផស្សៈ **វេទនា** ដូចជាក្រពេញទឹក ដោយអាការយ៉ាងនេះខ្លះ ។

## សញ្ញា

[២៨៤] សូម្បីសញ្ញា ក៏ឈ្មោះថា ដូចជាថ្ងៃបណ្ដើរកូន ព្រោះអត្ថថា **មិនមានសារៈ** ។ មួយទៀត ឈ្មោះថា ដូចជាថ្ងៃបណ្ដើរកូន ព្រោះអត្ថថា ដែលនរណាៗ ចាប់មិនបាន ព្រោះនរណាៗ មិនអាចនឹងចាប់យកថ្ងៃបណ្ដើរកូននោះមកផឹក ងូត ឬដាក់ឲ្យពេញភាជនៈបាន ។

ម្យ៉ាងទៀត ថ្ងៃបណ្ដើរកូន រមែងកើតឡើងព្រិចៗ ប្រាកដដូចជាមានកូនរលក (ទឹក) កើត យ៉ាងណា សូម្បីសញ្ញា ចែកប្រភេទជានីលសញ្ញាជាដើមក៏ដូច្នោះ រមែងញាប់ញ័រ គឺ មានសភាពព្រិចៗ ដើម្បីប្រយោជន៍ដល់ការសោយអារម្មណ៍ មានរូបពណ៌ខៀវជាដើម ។

មួយទៀត ថ្ងៃបណ្ដើរកូន រមែងបោកបញ្ឆោតបុគ្គលចំនួនច្រើនឲ្យវង្វេង ឲ្យនិយាយថា ប្រាកដដូចទន្លេមានទឹកពេញ យ៉ាងណា សូម្បីសញ្ញាក៏ដូច្នោះ រមែងបោកបញ្ឆោតបុគ្គលចំនួនច្រើនឲ្យវង្វេង ឲ្យនិយាយថា រូបនេះពណ៌ខៀវ ស្អាត ជាសុខ ទៀង ។

សូម្បីក្នុងរូបពណ៌លឿងជាដើម ក៏មានន័យ (ន័យតែម្យ៉ាងដូចគ្នា) នេះ

ឯង ។ សញ្ញា ឈ្មោះថា ដូចគ្នានឹងថ្ងៃបណ្ដើរកូន ព្រោះធ្វើឲ្យវង្វេងយ៉ាងនេះ ខ្លះ ។

## សង្ខារ

[២៤៥] បទថា អកុក្កុជកជាតំ បានដល់ មិនមានខ្លឹមនៅខាងក្នុង ។ សូម្បីសង្ខារទាំងឡាយ ក៏ឈ្មោះថា ដូចជាដើមចេក ព្រោះអត្ថថា មិនមានសារៈ (ខ្លឹម) ។ មួយទៀត ឈ្មោះថា ដូចជាដើមចេក ព្រោះអត្ថថា ចាប់មិនបាន ។

ប្រៀបដូចជា នរណាៗ មិនអាចនឹងកាប់យកអ្វីៗ អំពីដើមចេក ហើយនាំទៅប្រើឲ្យជាប្រយោជន៍ ដូចជាសសរផ្ទះជាដើម សូម្បីនាំទៅប្រើប្រាស់ជាប្រយោជន៍ហើយ ក៏មិនសម្រេចប្រយោជន៍ (មិនសម្រេចតាមបំណង) យ៉ាងណា សូម្បីសង្ខារទាំងឡាយក៏ដូច្នោះ នរណាៗ មិនអាចនឹងប្រកាន់ថា ទៀងជាដើមបាន សូម្បីប្រកាន់ហើយក៏មិនជាយ៉ាងនោះ ។

មួយទៀត សេចក្ដីថា ដើមចេក ជាទីប្រជុំនៃស្រទបចំនួនច្រើន យ៉ាងណា សង្ខារទាំងឡាយក៏ដូច្នោះ ជាទីប្រជុំនៃធម៌ច្រើន ។

មួយទៀត សេចក្ដីថា ដើមចេក មានលក្ខណៈផ្សេងៗ គ្នា គឺ ស្រទបខាងក្រៅមានពណ៌ផ្សេង ស្រទបក្នុងៗ បន្ទាប់អំពីស្រទបនោះ ក៏មានពណ៌

ផ្សេង យ៉ាងណា សូម្បីក្នុងសង្ខារក៏ដូច្នោះដែរ ផស្សៈ មានលក្ខណៈម្យ៉ាង (ចេតនាជាដើម ក៏មានលក្ខណៈម្យ៉ាងទៀត) តែកាលបើរួមចេតនាជាដើមចូលហើយ ទើបហៅថា សង្ខារក្ខន្ធតែម្យ៉ាង ព្រោះដូច្នោះ **សង្ខារក្ខន្ធ** ដូចជាដើមចេកយ៉ាងនេះខ្លះ ។

បទថា **ចក្ខុមា បុរិសោ** សេចក្ដីថា មានចក្ខុល្អ ដោយចក្ខុទាំងពីរ គឺ មំសចក្ខុ និងបញ្ញាចក្ខុ ។ អធិប្បាយថា សូម្បីមំសចក្ខុរបស់បុរសក៏បរិសុទ្ធិប្រាសចាកបាយ (បាយភ្នែក) ក៏ប្រើបាន , សូម្បីបញ្ញាចក្ខុ ក៏អាចមើលឃើញថា មិនមានសារៈ ក៏ប្រើបាន ។

## វិញ្ញាណ

[២៨៦] សូម្បីវិញ្ញាណក៏ឈ្មោះថា ប្រៀបដូចជា **មាយា** ព្រោះមានន័យថា មិនមានសារៈ ។ មួយទៀត ឈ្មោះថា ប្រៀបដូចជាមាយា ព្រោះមានន័យថា ចាប់កាន់មិនបាន ។

សេចក្ដីថា **មាយា** ប្រាកដរហ័ស ដោយជួរខណៈតិចតួច យ៉ាងណា វិញ្ញាណក៏ដូច្នោះ ព្រោះថា វិញ្ញាណនោះ ជារបស់មានខណៈតិចជាង និងប្រាកដរហ័សជាងមាយានោះ ទើបបុគ្គលសម្គាល់ ការដើរមក ការឈរ (និង) ការអង្គុយ ដោយចិត្តមួយដួង (ជាមួយគ្នា) នោះនោះឯង ។ ប៉ុន្តែថា ក្នុងវេលាទៅ

ចិត្តមួយដួង ក្នុងវេលាមកជាដើម ចិត្តមួយដួងទៀត **វិញ្ញាណ** ដូចជាមាយា យ៉ាងនេះខ្លះ ។

មួយទៀត **មាយា** បោកបញ្ឆោតមហាជន ឲ្យមហាជនកាន់យកអ្វីៗ ផ្សេងៗ ថា នេះមាស នេះកែវមុក្តា សូម្បីវិញ្ញាណ ក៏បោកបញ្ឆោតមហាជន ឲ្យមហាជនប្រកាន់ថា ដូចជាដើរមក ដូចជាឈរ (និង) ដូចជាអង្គុយ ដោយ ចិត្ត (ដួងតែមួយ) នុ៎ះឯង ក្នុងវេលាមក ជាចិត្តមួយដួង ក្នុងវេលាទៅជាដើម ក៏ចិត្តមួយដួងទៀត វិញ្ញាណដូចជាមាយាយ៉ាងនេះខ្លះ ។

ដោះស្រាយគាថាសរុប

[២៤៧] បទថា **ភូរិប្បញ្ញេន** សេចក្តីថា មានបញ្ញាល្អិត និងមានបញ្ញា ធំទូលាយ ។ បទថា **អាយុ** បានដល់ ជីវិតិន្ទ្រិយ ។ បទថា **ឧស្មា** បានដល់ តេជោធាតុដែលកើតអំពីកម្ម ។ បទថា **បរភត្តំ** បានដល់ ជាចំណីរបស់ពួក ជន្តុវដែលមានប្រភេទផ្សេងៗ ជាដើម ។ បទថា **ឯតាទិសាយំ សន្តានោ** សេចក្តីថា ប្រពៃណីរបស់អ្នកស្លាប់នេះដូច្នេះ នឹងបន្តគ្នាទៅរហូតនឹងដល់ព្រៃ ជាទីចោលសាកសព ។ បទថា **មាយាយំ ពាលលាបិនី** សេចក្តីថា ខន្ធនេះ ឈ្មោះថា វិញ្ញាណក្ខន្ធ , វិញ្ញាណក្ខន្ធនេះ ឈ្មោះថា ជាមាយា ដែលមហា- ជនល្ងង់ខ្លៅស្និទស្នាល ។ បទថា **វធកោ** សេចក្តីថា ពេជ្ឈឃាត ពោលគឺ

ខន្ធនេះ មានដោយហេតុ ២ ប្រការ គឺ ដោយការសម្លាប់គ្នាឯង ១ ដោយព្រះបាលីថា កាលខន្ធមានហើយ អ្នកសម្លាប់ក៏ប្រាកដដូច្នេះ ១ ។

អធិប្បាយថា **បឋវីធាតុ** តែមួយ កាលបើបែកធ្លាយ ក៏នាំយកធាតុដ៏សេសបែកធ្លាយទៅជាមួយ ធាតុទាំងឡាយ មានអាបោធាតុជាដើមក៏ដូចគ្នា ។

ចំណែករូបក្ខន្ធ កាលបែកធ្លាយ ក៏នាំយកអរូបខន្ធបែកធ្លាយទៅជាមួយ ក្នុងអរូបខន្ធក៏ដូចគ្នា គឺ វេទនាជាដើម (កាលបែកធ្លាយ) ក៏នាំយកសញ្ញាជាដើម (ឲ្យបែកធ្លាយទៅជាមួយ) ។

ក៏ក្នុងទីនេះគប្បីជ្រាបថា បញ្ចក្ខន្ធជាអ្នកសម្លាប់គ្នានិងគ្នាយ៉ាងនេះ គឺ អរូបខន្ធទាំង ៤ នឹងរូបដែលជាទីអាស្រ័យរបស់អរូបខន្ធទាំង ៤ នោះ (ផ្សេងគ្នា ក៏សម្លាប់គ្នានិងគ្នា) ។

មួយទៀត កាលខន្ធទាំងឡាយមានហើយ ការសម្លាប់ ការចាប់ចងនិងការកាត់ (ដៃជើង) ជាដើម ទើបមាន ។ គប្បីជ្រាបថា បញ្ចក្ខន្ធជាអ្នកសម្លាប់ ព្រោះកាលខន្ធទាំងនេះមាន ការសម្លាប់ទើបមានយ៉ាងនេះខ្លះ ។ បទថា **សព្វ-សំយោគំ** បានដល់ សញ្ញោជនៈទាំង ១០ យ៉ាង ។ បទថា **អច្ចុតំ បទំ** សំដៅដល់ និព្វាន ។

ចប់អដ្ឋកថា ផេណបិណ្ឌសូត្រទី ៣

# អ ដ្ឋ ក ថា

## គោមយបិណ្ឌសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង **គោមយបិណ្ឌសូត្រទី ៤** ដូចតទៅនេះ ៖

[២៤៨] បទថា **សស្សតិសមំ** បានដល់ ស្មើដោយវត្ថុដែលឋិតថេរទាំងឡាយ មានភ្នំសិនេរុ ផែនដី ព្រះចន្ទ និងព្រះអាទិត្យជាដើម ។

[២៤៩] បទថា **បរិត្តំ គោមយបិណ្ឌំ** បានដល់ ដុំគោម័យ (អាចម៍គោ) មានតិចប្រមាណប៉ុនផ្កា------- ។

សួរថា ក៏ដុំអាចម៍គោនេះ ព្រះមានព្រះភាគបានមកពីណា ?

ឆ្លើយថា ព្រះអង្គទ្រង់ចាប់មកពីដុំអាចម៍គោដែលភិក្ខុរូបនោះ នាំមកដើម្បីត្រូវការប្រើបូកលាប (សេនាសនៈ) ។

អាចារ្យពួកខ្លះពោលថា ក៏គប្បីជ្រាបថា ដុំអាចម៍គោ ព្រះមានព្រះភាគទ្រង់ប្រើឫទ្ធិបណ្ដាលឲ្យមកនៅក្នុងព្រះហស្ថ ក៏ដើម្បីឲ្យភិក្ខុបានយល់អត្ថន័យ (នៃព្រះធម៌ទេសនា) បានជាក់ច្បាស់ ។

បទថា **អត្តភាវប្បដិលាភោ** បានដល់ បានអត្តភាព ។ បទថា **នយិទំ ព្រហ្មចរិយវាសោ បញ្ញាយេថ** សេចក្ដីថា ឈ្មោះថា ការនៅប្រព្រឹត្ត

មគ្គព្រហ្មចរិយៈនេះ មិនគប្បីប្រាកដ ព្រោះថា មគ្គកើតឡើង ធ្វើសង្សារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មិនឲ្យប្រព្រឹត្តតទៅទៀត ក៏ប្រសិនបើអត្តភាពត្រឹមតែប៉ុណ្ណេះ នឹងគប្បីទៀងទាត់ មគ្គសូម្បីកើតឡើង ក៏នឹងមិនអាចធ្វើសង្សារវដ្តឲ្យឈប់បាន ព្រោះហេតុនោះ ការប្រព្រឹត្តព្រហ្មចរិយៈនឹងមិនគប្បីប្រាកដ ។

[២៥០] ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងថា បើសង្ខារអ្វីៗ នឹងគប្បីទៀង សម្បត្តិដែលតថាគតធ្លាប់គ្រប់គ្រង កាលនៅជាព្រះបាទមហាសុទស្សនៈ ក៏នឹងគប្បីទៀងដែរ តែសម្បត្តិសូម្បីទាំងនោះក៏មិនទៀង ។ ព្រះមានព្រះភាគទើបត្រាស់ពាក្យថា **ភូតបុព្វាហំ ភិក្ខុ** រហូតដល់ **អហោសឹ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **កុសាវតិរាជធានិប្បមុខានិ** សេចក្តីថា កុសាវតីរាជធានី ជាធំជាងនគរទាំងនោះ អធិប្បាយថា ប្រសើរបំផុតជាងនគរ (ដទៃ) ទាំងអស់ ។

បទថា **សារមយានិ** គឺ សម្រេចដោយខ្លឹមឈើចន្ទន៍ក្រហម ។ ក៏ខ្នើយសម្រាប់បល្ល័ង្កទាំងនោះ សុទ្ធធ្វើអំពីអំបោះទាំងអស់ ។ បទថា **គោនកត្ថតានិ** សេចក្តីថា បល្ល័ង្កទាំងឡាយក្រាលដោយសំពត់រោមកែះពណ៌ខ្មៅ ដែលមានរោមវែងលើស ៤ ធ្នាប់ ដែលអ្នកទាំងឡាយហៅថា សំពត់រោមកែះមហាបដ្ដិយៈ ។ បទថា **បដិកត្ថតានិ** សេចក្តីថា បល្ល័ង្កទាំងឡាយក្រាល

ដោយសំពត់កម្ពលពណ៌ស ដែលធ្វើអំពីរោមសត្វ ដែលមានរោមទាំងសងខាង ។ បទថា **បដលិកត្ថានិ** សេចក្តីថា បល្ល័ង្កទាំងឡាយក្រាលដោយកម្រាលរោមសត្វជាផ្កាចង្កោម ។ បទថា **កទលិមិគប្បវរបច្ចត្ថរណានិ** សេចក្តីថា ទីដេកទាំងឡាយក្រាលដោយកម្រាលដ៏ប្រសើរ ធ្វើអំពីស្បែកឈ្លូស ។ បានឮមកថា កម្រាលប្រភេទនោះ មនុស្សទាំងឡាយយកស្បែកឈ្លូស ក្រាលសង្កត់លើសំពត់ស ហើយដេរភ្ជាប់ ។

បទថា **សឧត្តរច្ឆទនានិ** សេចក្តីថា បល្ល័ង្កទាំងឡាយ ព្រមទាំង (ជាប់ដោយ) ដំបូលខាងលើ អធិប្បាយថា ព្រមទាំងពិតានពណ៌ក្រហមដែលមានក្នុងខាងលើ ។

បទថា **ឧភតោ លោហិតកូបធានានិ** សេចក្តីថា ខ្នើយពណ៌ក្រហមដែលដាក់ទុកសងខាងបល្ល័ង្ក គឺ ខ្នើយកើយព្រះសិរសា និងខ្នើយកល់ព្រះបាទ ។

ក្នុងបទថា **វេជយន្តរថប្បមុខានិ** នេះ មានអធិប្បាយថា រថរបស់ព្រះរាជានោះ ឈ្មោះថា **វេជយន្តៈ** មានដុំធ្វើដោយកែវឥន្ទនិល និងកែវមណី មានកាំធ្វើដោយកែវ ៧ ប្រការ មានខ្នងកង់ធ្វើដោយកែវប្រវាឡ មានភ្លៅធ្វើដោយប្រាក់ មានជន្ទោលធ្វើដោយកែវឥន្ទនិល និងកែវមណី មានទូកធ្វើដោយប្រាក់ រថនោះ ចាត់ជារថទ្រង់គ្រឿង គឺ ប្រសើរជាងរថទាំងនោះ ។

បទថា ទុកូលសន្ថនានិ បានដល់ មានសំពត់ទុកូលពស្រ្តជាសំពត់ដណ្តប់ខ្នង ។

បទថា កំសូបធរណានិ បានដល់ ភាជនៈសម្រាប់រឹតទឹកដោះ ធ្វើដោយប្រាក់ ។

បទថា វត្ថកោដិសហស្សានិ នេះ ព្រះមានព្រះភាគត្រាស់សំដៅដល់ព្រះភូសាដែលរាជបុរសនាំទៅ ក្នុងវេលាប្រថាប់ឈរស្រង់ទឹក ដោយគិតថា ព្រះអង្គទ្រង់នឹងប្រើព្រះភូសានោះ តាមព្រះរាជបំណង ។

[២៥១] បទថា យមហំ តេន សមយេន អជ្ឈាវសាមិ សេចក្តីថា យើងនៅក្នុងនគរណា នគរនោះ ក៏ជានគរមួយកន្លែងនុ៎ះឯង (ក្នុងបណ្តានគរ ៨៤.០០០ នគរ) (ចំណែក) ព្រះញាតិដ៏សេស មានព្រះរាជឱរស និងព្រះរាជ-ធីតាជាដើម និងអ្នកបម្រើ ក៏អាស្រ័យនៅផង ។

សូម្បីក្នុងប្រាសាទ និងផ្ទះកំពូលជាដើម ក៏មានន័យ (ន័យដូចគ្នា) នេះឯង ។ សូម្បីក្នុងព្រះរាជបល្ល័ង្កជាដើម ព្រះបាទមហាសុទស្សនៈ ក៏ទ្រង់ប្រើប្រាស់ត្រឹមតែព្រះរាជបល្ល័ង្កមួយ បល្ល័ង្កដ៏សេសជារបស់ព្រះរាជឱរសជាដើមទ្រង់ប្រើប្រាស់ ។ បណ្តាព្រះស្នំទាំងឡាយ ក៏មានព្រះស្នំមួយនាក់ប៉ុណ្ណោះ ដែលប្រណិបត្តិថ្វាយ ។ ដ៏សេសត្រឹមតែជាបរិវារ ។

ស្ត្រីដែលកើតក្នុងគភ៌របស់នាងព្រាហ្មណី (ដែលជាមហេសី) របស់ក្សត្រិយ៍ក្តី ស្ត្រីកើតក្នុងគភ៌របស់ម្ចាស់ស្រី (ដែលជាភរិយា) របស់ព្រាហ្មណ៍ក្តី ឈ្មោះថា **វេឡាមិកា** ។

ដោយបទថា **បរិទហាមិ** ព្រះមានព្រះភាគទ្រង់សម្តែងថា តថាគតស្លៀកដណ្តប់សំពត់តែមួយគូប៉ុណ្ណោះ ដ៏សេសជារបស់ពួករាជបុរស ដែលត្រាច់ហែហម ចំនួន ១.៦៨០.០០០ នាក់ ។

ដោយបទថា **ភុញ្ជាមិ** ព្រះមានព្រះភាគទ្រង់សម្តែងថា តថាគតសោយបាយប្រមាណ ១ នាឡិយ៉ាងច្រើន ដ៏សេសជារបស់រាជបុរស ដែលជាអ្នកហែហម ចំនួន ៨៤០.០០០ នាក់ ។

ក៏បាយមួយថាស ល្មមមនុស្ស ១០ នាក់បរិភោគបាន ។ ព្រះមាន-ព្រះភាគ លុះទ្រង់សម្តែងសម្បត្តិ កាលនៅជាព្រះបាទមហាសុទស្សនៈនេះយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងថា សម្បត្តិទាំងនោះមិនទៀង ទើបត្រាស់ពាក្យថា **ឥតិ ខោ ភិក្ខុ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **វិបរិណតា** បានដល់ (សង្ខារទាំងឡាយ) ដល់នូវសភាពរកបញ្ញត្តិមិនបាន ព្រោះលះបង់ប្រក្រតី ប្រៀបដូចប្រទីបរលត់ដូច្នោះ ។

បទថា ឯវំ អនិច្ចា ខោ ភិក្ខុ សង្ខារា សេចក្ដីថា ដែលឈ្មោះថា មិនទៀង ព្រោះមានន័យថា **មានហើយត្រឡប់ជាមិនមាន** យ៉ាងនេះ ។

ប្រៀបដូចបុរស គប្បីចងជណ្ដើរទុកត្រង់ដើមចម្បា ដែលមានកម្ពស់ ១០០ ហត្ថ ហើយឡើងទៅបេះយកផ្កាចម្បា ចុះមកវិញលះបង់ជណ្ដើរ យ៉ាងណា ព្រះមានព្រះភាគទ្រង់ក៏ដូច្នោះ ដោយហេតុត្រឹមតែថា គឺ ស្ដេចឡើងកាន់សម្បត្តិរបស់ព្រះបាទមហាសុទស្សនៈ ប្រើប្រាស់វេលាយូរច្រើនសែនកោដិឆ្នាំ ដូចជាទ្រង់ចងជណ្ដើរ (ឡើងទៅ) ទ្រង់កាន់យកអនិច្ចលក្ខណៈត្រង់ទីបំផុតនៃសម្បត្តិហើយ ស្ដេចចុះមក ដូចទ្រង់លះបង់ជណ្ដើរ (ចុះមកវិញ) ដូច្នោះ ។

បទថា ឯវំ អទ្ធុវា សេចក្ដីថា វៀរចាកសេចក្ដីឋិតថេរយ៉ាងនោះ ដូចក្រពេញទឹកជាដើម ដូច្នោះ ។

បទថា ឯវំ អនស្សាសិកា សេចក្ដីថា វៀរចាកសភាពគួរត្រេកអរនោះ ដូចទឹកដែលផឹកក្នុងពេលយល់សប្ដិ និងដូចគ្រឿងក្រអូបខ្ចីមចន្ទន៍ ដែលខ្ទួនមិនបានលាប ដូច្នោះ ។

ព្រះមានព្រះភាគ ត្រាស់អនិច្ចលក្ខណៈទុកក្នុងសូត្រនេះ ដូចពណ៌នាមកនេះ ។

ចប់អដ្ឋកថា គោមយបិណ្ឌសូត្រទី ៤

# អ ដ្ឋ ក ថា

## នខសិខាសូត្រទី ៥

[២៥២] *ពាក្យទាំងអស់ក្នុង នខសិខាសូត្រទី ៥ មានន័យដូចបានពោលហើយនោះឯង ។*

ចប់អដ្ឋកថា នខសិខាសូត្រទី ៥

# អ ដ្ឋ ក ថា

## សាមុទ្ទកសូត្រទី ៦

[២៥៥] *សាមុទ្ទកសូត្រទី ៦ ព្រះមានព្រះភាគត្រាស់ហើយ តាមអធ្យាស្រ័យរបស់អ្នកដែលគប្បីត្រាស់ដឹង ដោយប្រការនោះ ។*

ចប់អដ្ឋកថា សាមុទ្ទកសូត្រទី ៦

# អ ដ្ឋ ក ថា

## គទ្ទូលសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង *គទ្ទូលសូត្រទី ១* ដូចតទៅនេះ ៖

[២៥៦] បទថា **យំ មហាសមុទ្ទោ** សេចក្តីថា ក្នុងសម័យណា កាលព្រះអាទិត្យដួងទី ៥ ឧទ័យឡើង មហាសមុទ្រ (ស្តេចសមុទ្រ) ក៏នឹងស្ងួតហួតហែង ។

បទថា **ទុក្ខស្ស អន្តកិរិយំ** សេចក្តីថា តថាគតមិនពោលដល់ការធ្វើទីបំផុត គឺ ការអស់នៃវដ្តទុក្ខរបស់សប្បុរសដែលមិនទាន់បានចាក់ធ្លុះអរិយ-សច្ចៈ ៤ ហើយ ត្រូវអវិជ្ជារួបរឹតទុកហើយ ។

[២៥៧] បទថា **គទ្ទូលពទ្ធោ** បានដល់ សុនខដែលត្រូវចងដោយជង-ដោយ ។

បទថា **ខីលេ** គឺ ត្រង់សសរធំដែលនៅមិនបានដោតចុះក្នុងផែនដី ។

បទថា **ថម្ភេ** គឺ ដែលសសរ (ដែក) ដែលកប់ទុក ។

ក្នុងបទថា **ឯវមេវ ខោ** នេះ គប្បីជ្រាបអធិប្បាយដូចតទៅនេះ ៖

ជនពាលដែលអាស្រ័យវដ្តៈ គប្បីជ្រាបថា ប្រៀបដូចសុនខ ។

*ទិដ្ឋិ គប្បីជ្រាបថា ប្រៀបដូចប្រវាក់ ។*

*សក្កាយៈ គប្បីជ្រាបថា ប្រៀប ដូចសសរ ។*

*ការប្រព្រឹត្តទៅតាមសក្កាយៈរបស់បុថុជ្ជន ដែលត្រូវចងទុកត្រង់កាយរបស់ខ្លួនដោយទិដ្ឋិ និងតណ្ហា គប្បីជ្រាបថា ដូចការរត់វិលជុំវិញសសររបស់សុនខ ដែលត្រូវចងដោយប្រវាក់ និងខ្សែ ជាប់នឹងសសរ ។*

ចប់អដ្ឋកថា គទ្ទុលសូត្រទី ៧

# អ ដ្ឋ ក ថា

## គទ្ទូលសុត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង គទ្ទូលសូត្រទី ២ ដូចតទៅនេះ ៖

[២៥៨] បទថា តស្មា សេចក្តីថា ព្រោះហេតុដែលពាលបុថុជ្ជនអ្នកជាប់នៅក្នុងវដ្តៈ អ្នកអាស្រ័យប្រវាក់ គឺ ទិដ្ឋិ ទើបត្រូវចងទុកត្រង់សសរ គឺ សក្កាយៈ ដោយខ្សែ គឺ តណ្ហា អាស្រ័យខន្ធបញ្ចកៈប្រព្រឹត្តទៅក្នុងឥរិយាបថទាំងពួង ។ ម្យ៉ាងទៀត ព្រោះហេតុដែលចិត្តនេះសៅហ្មង ដោយរាគៈ ទោសៈ មោហៈ មកយូរ ។

### សត្វសៅហ្មង ព្រោះចិត្តសៅហ្មង

[២៥៩] បទថា ចិត្តសង្កិលេសា សេចក្តីថា ក៏សត្វទាំងឡាយសូម្បីងូតទឹកល្អហើយ ក៏ឈ្មោះថា សៅហ្មង ព្រោះចិត្តសៅហ្មងនុ៎ះឯង ប៉ុន្តែថា សូម្បីរាងកាយមិនស្អាត ក៏ឈ្មោះថា ផូរផង់បាន ព្រោះចិត្តផូរផង់ ។

ដោយហេតុនោះ បុរាណាចារ្យទាំងឡាយទើបពោល ៖

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ស្វែងរកព្រះគុណដ៏ធំមិន
បានត្រាស់ទុកថា កាលរូបសៅហ្មង សត្វទាំងឡាយទើប

ឈ្មោះថា សៅហ្មង កាលរូបបរិសុទ្ធិ សត្វទាំងឡាយ
ទើបឈ្មោះថា បរិសុទ្ធិ ។

(តែ) ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ស្វែងរកព្រះ
គុណដ៏ធំមិនបានត្រាស់ទុកថា កាលចិត្តសៅហ្មង សត្វ
ទាំងឡាយ ទើបឈ្មោះថា សៅហ្មង កាលចិត្តបរិសុទ្ធ
សត្វទាំងឡាយ ទើបឈ្មោះថា បរិសុទ្ធិផង ។

បទថា ចរណំ នាម ចិត្តំ បានដល់ វិចរណចិត្ត (រូបគំនូរ) ។ ព្រាហ្មណ៍ជាម្ចាស់លទ្ធិ ឈ្មោះថា សង្ខា មានហើយ ពួកគេឲ្យសាងផ្ទាំងសំពត់ ហើយឲ្យជាងគំនូរសម្តែងនូវសម្បត្តិ និងវិបត្តិ នានប្បការ មានសួគ៌ មាននរក ចុះក្នុងផ្ទាំងសំពត់នោះ សម្តែង (ដល់ផលរបស់កម្ម) ថា ធ្វើកម្មនេះហើយ នឹងបានទទួលផលនេះ ធ្វើកម្មនេះហើយ នឹងបានទទួលផលនេះ កាន់យកចិត្រ-កម្មនោះ ត្រាច់ទៅ [១] ។

---

១-(បាឋ:ថា នខា នាម ព្រាហ្មណបាសណ្ឌិកា ហោន្តិ តេ បន កោដ្ឋកំកត្វា តត្ថ នានប្បការា សុគតិទុគ្គតិវសេន សម្បត្តិវិបត្តិយោ **លិខាបេត្វា** ឥទំ កម្មំ កត្វា ឥទំ បដិលភតិ ឥទំកត្វា ឥទន្តិ **ទស្សេន្តា** តំ ចិត្តំ គហេត្វា វិចរតិ ។ ច្បាប់កូមាជា សង្ខា នាម ព្រាហ្មណបាសណ្ឌិកា ហោន្តិ , តេ បដកោដ្ឋកំ កត្វា តត្ថ នានប្បការា សុគតិទុគ្គតិវសេន សម្បត្តិវិបត្តិយោ **លេខាបេត្វា** ឥទំ កម្មំ កត្វា ឥទំ បដិលភតិ ឥទំ កត្វា ឥទន្តិ **ទស្សេន្តា** តំ ចិត្តំ គហេត្វា វិចរតិ ។ ប្រែតាមច្បាប់កូមា)

បទថា **ចិត្តេនេវ ចិន្តិតំ** សេចក្តីថា ឈ្មោះថា ដែលចិត្រករ (ជាងគំនូរ) ឲ្យស្អាតល្អហើយដោយចិត្ត ព្រោះគិតហើយ ទើបគូរ[១] ។

បទថា **ចិត្តញ្ញេវ ចិត្តតរំ** សេចក្តីថា ចិត្តដែលស្វែងរកឧបាយរបស់ចិត្តនោះ វិចិត្រជាងចិត្តដែលឈ្មោះថា ចរណៈសូម្បីនោះ ។

បទថា **តិរច្ឆានគតា បាណា ចិត្តេនេវ ចិន្តិតា** សេចក្តីថា សត្វទាំងឡាយនោះវិចិត្រហើយ[២] ព្រោះចិត្តដែលជាហេតុឲ្យធ្វើកម្មនុ៎ះឯង ។ ក៏សត្វទាំងឡាយនេះ មានសត្វមាន់ទោ និងសត្វទទាជាដើម ដែលឈ្មោះថា ប្រមូលយកចិត្តដែលជាហេតុឲ្យធ្វើកម្មនោះមក ដោយគិតថា យើងទាំងឡាយនឹងវិចិត្រយ៉ាងនេះ មិនមានឡើយ ។ កម្មផ្សេងៗ ប៉ុណ្ណោះ ដឹកនាំទៅកាន់កំណើត ។ ការដែលសត្វទាំងនោះស្អាតល្អ ក៏ព្រោះមានកំណើតជាមូល ។ ពិតហើយ សត្វទាំងឡាយដែលចូលដល់កំណើតហើយ រមែងវិចិត្រ ដូចគ្នានឹងសត្វដែលកើតនៅក្នុងកំណើតនោះៗ បណ្ឌិតគប្បីជ្រាបថា ការវិចិត្រ សម្រេចមកពីកំណើត កំណើតសម្រេចមកពីកម្ម ដោយប្រការដូចពណ៌នាមកដូច្នេះ ។

---

១-(បាឋៈថា ចិត្តការេន ចិន្តេត្វា ឯកគ្គតាចិត្តេន ចិន្តិតំ ។ ច្បាប់កូមាជា ចិត្តការេន ចិន្តេត្វា កតត្តា ចិត្តេន ចិន្តិតំ នាម ។ ប្រែតាមច្បាប់កូមា )

២-(បាឋៈថា ចិន្តិតា ច្បាប់កូមាជា ចិត្តិតា ប្រែតាមច្បាប់កូមា )

ម្យ៉ាងទៀត ធម្មតាថា ចិត្តនេះ ជាសហជាតធម៌ (ធម៌ដែលកើតរួមគ្នា) ទើបគប្បីជ្រាបថា មានអារម្មណ៍ដ៏វិចិត្រជាងការវិចិត្ររបស់សត្វតិរច្ឆានទាំងឡាយ ព្រោះវិចិត្រដោយសហជាតធម៌ (ធម៌ដែលកើតរួមគ្នា) ព្រោះវិចិត្រដោយវត្ថុ (ទីអាស្រ័យ) , ព្រោះវិចិត្រដោយទ្វារ , ព្រោះវិចិត្រដោយអារម្មណ៍ទាំងព្រោះឲ្យសម្រេចការវិចិត្រជាអនេក ដូចជា ភេទផ្សេងៗ គ្នា សញ្ញាផ្សេងៗ គ្នា វោហារផ្សេងៗ គ្នា ជាដើម ដែលមានកម្មប្រភេទផ្សេងៗ គ្នា ជាមូល ។

បទថា **រជកោ** បានដល់ ជាងគូររូបដោយពណ៌ ចុះក្នុងវត្ថុទាំងឡាយក៏ជាងនោះ (បើ) មិនឆ្លាត ក៏នឹងគូររូបបានមិនគួរពេញចិត្ត (តែបើ) ឆ្លាត ក៏គូររូបបានគួរជាទីពេញចិត្ត ស្អាតគួរមើល យ៉ាងណា ។ បុថុជ្ជនក៏ដូច្នោះ គឺ រមែងញុំាងរូបដែលខុសប្រក្រតីដែលវៀរចាកគុណសម្បត្តិ មានការដល់ព្រមដោយចក្ខុជាដើម ឲ្យកើតឡើងដោយអកុសលចិត្ត ឬដោយកុសលចិត្តដែលជាញាណវិប្បយុត្ត , រមែងញុំាងរូប ដែលស្អាតល្អ ដែលដល់ព្រមដោយគុណសម្បត្តិ មានការដល់ព្រមដោយចក្ខុជាដើម ឲ្យកើតឡើងដោយកុសលចិត្តដែលជាញាណសម្បយុត្ត ។

ចប់អដ្ឋកថា គទ្ទុលសូត្រទី ៨

# អ ដ្ឋ ក ថា

## នាវាសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុង នាវាសូត្រទី ៩ ដូចតទៅនេះ ៖

[២៦១] បទថា សេយ្យថាបិ ភិក្ខវេ កុក្កុដិយា អណ្ឌានិ សេចក្ដីថា ព្រះមានព្រះភាគត្រាស់ឧបមា ២ ប្រការនេះទុក ដោយអំណាចធម៌ដែលជាចំណែកខ្មៅ និងចំណែកស ។ បណ្ដាឧបមា ២ ប្រការនោះ ឧបមាពោលដោយធម៌ដែលជាចំណែកខ្មៅ មិនទាន់ឲ្យសម្រេចប្រយោជន៍ (តែ) ឧបមាពោលដោយធម៌ដែលជាចំណែកស ក្រៅពីនេះធ្វើឲ្យសម្រេចប្រយោជន៍បាន ។ គប្បីជ្រាបសេចក្ដីរបស់ឧបមាពោលដោយធម៌ចំណែកស យ៉ាងនេះ ។

បទថា សេយ្យថា ជានិបាត ប្រើក្នុងអត្ថជាការឧបមា ។

បទថា អបិ ប្រើក្នុងអត្ថថា ជម្រុញបន្ថែម ។ ដោយបទទាំងពីរព្រះមានព្រះភាគ ទើបទ្រង់សម្ដែងថា សេយ្យថាបិ នាម ភិក្ខវេ ។

ក៏ក្នុងបទនេះថា កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា មានអធិប្បាយថា ពងរបស់មេមាន់ តិចខ្លះ ច្រើនខ្លះ អំពីចំនួនមានប្រការដូចពោលហើយក៏ពិត សូម្បីយ៉ាងនោះ ព្រះមានព្រះភាគក៏ត្រាស់ទុកយ៉ាងនោះ

ព្រោះដោយពាក្យរៀបរយល្អ និងដោយពាក្យដែលរៀបរយក្នុងលោក ក៏មានហើយយ៉ាងនេះ ។

បទថា **តានស្សុ** កាត់បទជា **តានិ អស្សុ** ។ (អស្សុ) គឺ **ភវេយ្យុំ** ប្រែថា ពងមាន់ទាំងនោះ គប្បីមាន ។

បទថា **កុក្កុដិយា សម្មាអធិសយិតានិ** សេចក្តីថា ពងមាន់ទាំងនោះដែលមាន់ញីជាមេ ត្រដាងស្លាបហើយដេកក្រាបពីលើពងទាំងនោះ ឈ្មោះថាក្រាបដោយល្អ ។

បទថា **សម្មាបរិសេទិតានិ** សេចក្តីថា ពងទាំងឡាយ ដែលមេមាន់បានអប់កំដៅតាមកាលដែលសមគួរ ឈ្មោះថា ក្រាប គឺ ធ្វើឲ្យអប់កំដៅដោយល្អ គឺ ទូទៅ ។

បទថា **សម្មាបរិភាវិតានិ** សេចក្តីថា ពងទាំងឡាយ ដែលមេមាន់ក្ដាស់ដោយល្អ គឺ ទូទៅតាមកាលដែលសមគួរ អធិប្បាយថា ឲ្យក្លិនមាន់ចាប់ ។

បទថា **កិច្ចាបិ តស្សា កុក្កុដិយា** សេចក្តីថា មេមាន់នោះធ្វើសេចក្តីមិនប្រមាទ ដោយកិរិយា ៣ យ៉ាងនេះហើយ ទោះបីមិនកើតសេចក្តីប្រាថ្នាយ៉ាងនេះក៏ពិត ។

បទថា **អថ ខោ ភព្វា តេ** សេចក្តីថា សូម្បីយ៉ាងនោះ កូនមាន់

ទាំងនោះក៏អាចនឹងចោះ (សំបកពង) ចេញមកបានដោយសួស្តី តាមន័យដែលពោលទុកហើយ ។

ក៏ព្រោះហេតុ សំបកពងទាំងនោះ ដែលមេមាន់នោះរក្សាហើយដោយអាការ ៣ យ៉ាង យ៉ាងនេះ ទើបមិនវិនាស និងជ័រស្អិតរបស់ពងទាំងនោះក៏ស្ងួតទៅ សំបកពងខ្វះ ចុងក្រចកជើង និងចុងចំពុះផ្ដើមរឹង ចាស់ក្លា ព្រោះសំបកពងខ្វះ ពន្លឺខាងក្រៅទើបប្រាកដចូលដល់ខាងក្នុង ដូច្នោះ កូនមាន់ទាំងនោះ ទើបប្រាថ្នានឹងចេញមក (ខាងក្រៅ) ដោយគិតថា យើងដេកអង្គុញខ្លួននៅក្នុងទីចង្អៀតមកយូរហើយហ្ន៎ និងពន្លឺខាងក្រៅនេះក៏ប្រាកដ ឥឡូវនេះ យើងទាំងឡាយនឹងនៅជាសុខក្នុងទីនេះឯង ដូច្នេះ ហើយយកចុងក្រចកចោះសំបកពង អើត.កចេញមក គ្រានោះសំបកពងក៏បែកចេញជា ២ ចំណែក ទីនោះកូនមាន់ទាំងនោះ ក៏ចេញមករលាស់ស្លាបបញ្ចេញសម្លេងស្រែកញ្ជីបៗ និងពេលចេញមកហើយ ក៏ដើរ (រកស៊ី) ធ្វើឲ្យគាមខេត្តស្រស់ល្អ ។

បទថា **ឯវមេវ ខោ** នេះ ជាបទយល់ព្រមតាមការឧបមា បទយល់ព្រមតាមឧបមានោះ គប្បីជ្រាបការប្រៀបធៀបជាមួយន័យនេះ ។ អធិប្បាយថា វេលាដែលភិក្ខុនេះប្រកបការបំពេញភាវនា គប្បីជ្រាបថា ប្រៀបដូចមេមាន់នោះ ធ្វើកិរិយា ៣ យ៉ាង ក្នុងពងមាន់ ។

សភាពដែលវិបស្សនាញាណរបស់ភិក្ខុ ដែលប្រកបការបំពេញការនា មិនវិនាស ព្រោះញ៉ាំងអនុបស្សនា ៣ យ៉ាងឲ្យដល់ព្រម គប្បីជ្រាបថា ប្រៀបដូចការៈដែលពងមាន់មិនស្អុយ ព្រោះមេមាន់ធ្វើកិរិយា ៣ យ៉ាងឲ្យដល់ព្រម ។

សេចក្តីស្នេហា គឺ សេចក្តីពេញចិត្តដែលជាប់នៅក្នុងភពទាំង ៣ របស់ភិក្ខុនោះអស់ទៅ ព្រោះញ៉ាំងអនុបស្សនា ៣ យ៉ាងឲ្យដល់ព្រម គប្បីជ្រាបថា ប្រៀបដូចជាជរស្អិតរបស់ពងមាន់ទាំងឡាយអស់ទៅ ព្រោះមេមាន់នោះ ធ្វើកិរិយា ៣ យ៉ាង ។

ការដែលចោះសំបកពង គឺ អវិជ្ជា របស់ភិក្ខុខ្ចះ គប្បីជ្រាបថា ប្រៀបដូចការដែលចោះសំបកពងមាន់ខ្ចះ ។

ការដែលវិបស្សនាញាណរបស់ភិក្ខុចាស់ក្លា ផូរផង់ និងក្លៀវក្លា គប្បីជ្រាបថា ប្រៀបដូចចុងក្រចកជើង និងចុងចំពុះរបស់កូនមាន់ទាំងឡាយចាស់ក្លា ។

វេលាដែលវិបស្សនាញាណរបស់ភិក្ខុចាស់ក្លា ចម្រើន គប្បីជ្រាបថា ប្រៀបដូចវេលាដែលកូនមាន់ទាំងឡាយចម្រើនឡើង ។

វេលាដែលភិក្ខុនោះ កាន់យកវិបស្សនាញាណបានហើយ ត្រាច់ (ចារិក) ទៅ បានរដូវជាទីសប្បាយ ភោជនជាទីសប្បាយ បុគ្គលជាទីសប្បាយ ឬការ

ស្តាប់ធម៌ជាទីសប្បាយ ដែលកើតពីវិបស្សនាញាណនោះ ហើយអង្គុយនៅលើ អាសនៈតែមួយនុ៎ះឯង ចម្រើនវិបស្សនា ទម្លាយសំបកពង គឺ អវិជ្ជា ដោយ អរហត្តមគ្គ ដែលសម្រេចហើយតាមលំដាប់ ទទះស្លាប គឺ អភិញ្ញា ហើយ សម្រេចជាព្រះអរហន្តដោយសួស្តី គប្បីជ្រាបថា ប្រៀបដូចវេលាកូនមាន់យក ចុងក្រចកជើង ឬចុងចំពុះ ចឹកបោះសំបកពង ទទះស្លាប អើត.កចេញមក បានដោយសួស្តី ។

មួយទៀត ប្រៀបដូចជា មេមាន់ជ្រាបថា កូនមាន់ ធំធាត់ហើយ ទើប ចឹកសំបកពង យ៉ាងណា ចំណែកព្រះសាស្តាក៏ដូច្នោះ ទ្រង់ជ្រាបថា ញាណ របស់ភិក្ខុនោះ ចាស់ក្លាហើយ ក៏ទ្រង់ផ្សាយពន្លឺទៅ ហើយទម្លាយសំបកពង គឺ អវិជ្ជា ដោយគាថាដោយន័យជាដើមថា ៖

ចូរដកសេចក្តីស្នេហារបស់ខ្លួនចេញចុះ ឲ្យដូចគ្នានឹង
ដកផ្កាកោមុទ ដែលរីកក្នុងរដូវសារទកាល ដោយដៃ
របស់ខ្លួន ដូច្នោះ សូមអ្នកចូរបំពេញផ្លូវនៃសន្តិចុះ
ព្រះនិព្វាន ព្រះសុគតទ្រង់សម្តែងទុកហើយ ។

វេលាចប់គាថា ភិក្ខុនោះទម្លាយសំបកពង គឺ អវិជ្ជាហើយ បានសម្រេច ជាព្រះអរហន្ត ។ តាំងពីនោះមក ព្រះមហាខីណាស្រពសូម្បីនេះ ក៏ចូលផល-

សមាបត្តិដែលមាននិព្វានជាអារម្មណ៍ ហើយត្រាច់ទៅ ធ្វើឲ្យសញ្ញាកាមស្រស់ល្អ ប្រៀបដូចកូនមាន់ទាំងនោះ ត្រាច់ទៅធ្វើឲ្យគាមខេត្តស្រស់ល្អ ដូច្នោះ ។

[២៦២] បទថា **ផលកណ្ឌស្ស** បានដល់ ជាងឈើ ។ ពិតហើយ ជាងឈើនោះ ហៅថា ផលកណ្ឌៈ ព្រោះវាយខ្សែបន្ទាត់ គឺ ឱសមនកៈ ហើយ បើកស្លាបឈើចេញទៅ ។

បទថា **វាសិជដេ** បានដល់ វត្ថុសម្រាប់ចាប់ដងកាំបិត (មៀនកាំបិត) ។

បទថា **ឯត្តកំ វា មេ អាសវានំ ខីណំ** មានអធិប្បាយថា ក៏អាសវៈទាំងឡាយរបស់បព្វជិត អស់ទៅជានិច្ច ព្រោះឧទ្ទេស ព្រោះបរិបុច្ឆា ព្រោះយោនិសោមនសិការ និងព្រោះវត្តបដិបត្តិ ដោយសង្ខេប គឺ ការបព្វជ្ជា ។ និងកាលអាសវៈទាំងនោះកំពុងអស់ទៅយ៉ាងនេះ លោកមិនដឹងយ៉ាងនេះថា ថ្ងៃនេះអស់ទៅប៉ុណ្ណេះ កាលម្សិលមិញអស់ទៅប៉ុណ្ណេះ កាលម្សិលម៉្ងៃអស់ទៅប៉ុណ្ណេះ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងអានិសង្សរបស់វិបស្សនា ទុកដោយឧបមានេះ ។

បទថា **ហេមន្តិកេន** បានដល់ ដោយសម័យនៃហេមន្តរដូវ ។

បទថា **បដិបស្សម្ភន្តិ** បានដល់ គ្រឿងចង គឺ ផ្តៅទាំងឡាយ រមែងវិនាសទៅ ព្រោះជរាភាព ។

ក្នុងបទថា ឯវមេវ ខោ នេះ ព្រះមានព្រះភាគទ្រង់សម្តែងសភាពនៃសញ្ញោជនៈដែលខ្សោយកម្លាំងចុះ ដោយឧបមានេះថា ៖

សាសនាគប្បីឃើញថា ប្រៀបដូចមហាសមុទ្រ

ព្រះយោគាវចរគប្បីឃើញថា ប្រៀបដូចទូក ។

ការដែលភិក្ខុនេះ ត្រាច់ទៅក្នុងសម្នាក់ឧបជ្ឈាយ៍អាចារ្យក្នុងវេលាដែលមានវស្សាមិនទាន់គ្រប់ ៥ គប្បីឃើញថា ប្រៀបដូចទូកអណ្តែតវិលវល់នៅក្នុងមហាសមុទ្រ ។

សភាពដែលសញ្ញោជនៈទាំងឡាយរបស់ភិក្ខុស្រាលស្តើង ព្រោះឧទ្ទេសនិងបរិបុច្ឆាជាដើមនុ៎ះឯង ។ ដោយសង្ខេប ក៏បានដល់បព្វជ្ជា គប្បីឃើញថា ប្រៀបដូចខ្សែចងទូកត្រូវទឹកក្នុងមហាសមុទ្រ កាត់ឲ្យស៊ីកបន្តិចម្តងៗ ខ្លះ ។

វេលាដែលភិក្ខុជានិស្ស័យមុត្តកៈរៀនកម្មដ្ឋានហើយ (ទៅ) នៅក្នុងព្រៃគប្បីឃើញថា ប្រៀបដូចវេលាដែលទូកត្រូវលើកដាក់លើគោក ។

សេចក្តីស្នេហា គឺ តណ្ហា ស្ងួតហួតហែងទៅ ព្រោះវិបស្សនាញាណគប្បីឃើញថា ប្រៀបដូចខ្សែចងទូករមាសពុកផុយ ព្រោះត្រូវខ្យល់ និងកំដៅថ្ងៃ ក្នុងពេលពេលថ្ងៃ ។

ការដែលចិត្តសើមជ្រួតជ្រាប ព្រោះបីតិ និងបាមោជ្ជៈ ព្រោះអាស្រ័យ

កម្មដ្ឋានកើតឡើង គប្បីឃើញថា ប្រៀបដូចជាទូកដែលសើម ព្រោះត្រូវទឹកសន្សើមក្នុងពេលយប់ ។

កាលភិក្ខុបានរដូវជាសប្បាយជាដើមក្នុងថ្ងៃមួយ ក្នុងវិបស្សនាញាណ-កម្មដ្ឋាន ហើយមានសញ្ញោជនៈស្រាលស្តើងចុះ ព្រោះបីតិ និងបាមោជ្ជៈ ដែលកើតពីវិបស្សនាញាណ គប្បីឃើញថា ប្រៀបដូចខ្សែចង (ទូក) ហួតហែងក្នុងពេលថ្ងៃ ព្រោះត្រូវខ្យល់ និងកំដៅថ្ងៃ និងសើមក្នុងពេលយប់ ព្រោះត្រូវទឹកសន្សើម ។

អរហត្តមគ្គញ្ញាណ គប្បីឃើញថា ប្រៀបដូចជាភ្លៀង ។

កាលភិក្ខុដែលផ្តើមរៀនវិបស្សនាកម្មដ្ឋាន ហើយចម្រើនវិបស្សនាដោយរូបសត្តកៈ (ពួក ៧ នៃរូប) ជាដើម កាលកម្មដ្ឋានជាក់ច្បាស់ឡើងៗ ក្នុងថ្ងៃមួយបានរដូវជាទីសប្បាយជាដើម អង្គុយពត់ភ្នែនតែមួយជង (មិនក្រោកឡើង) ក៏បានសម្រេចអរហត្តផល គប្បីឃើញថា ប្រៀបដូចជាទូកដែលពេញដោយទឹកភ្លៀង ។

កាលភិក្ខុនោះ អស់សញ្ញោជនៈហើយសម្រេចជាព្រះអរហន្ត មិនទាន់បានអនុគ្រោះមហាជន តាំងនៅជរាបអាយុខ័យ គប្បីឃើញថា ប្រៀបដូចជាទូកដែលមានខ្សែចងរមាសពុកផុយ គ្រាន់តែតាំងនៅបានដោយជួរខណៈមួយ

ប៉ុណ្ណោះ ។

វេលាដែលព្រះខីណាស្រពបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ដោយការអត្ថយពត់ក្អែនមួយកន្ទែង ព្រោះឧបាទិន្នកក្ខន្ធបែកធ្លាយទៅ (កិលេសអស់ហើយ ក៏បរិនិព្វានភ្លាម) ហើយចូលដល់ភាពជាបុគ្គលរកបញ្ញត្តិមិនបាន គប្បីឃើញថា ប្រៀបដូចវេលាដែលទូកមានខ្សែចងរមាសពុកផុយ រិចរិលដាច់ទៅម្តងបន្តិចៗ ដរាបចូលដល់សភាពរកបញ្ញត្តិមិនបាន (ដរាបហៅថាខ្សែមិនបាន) ។

ចប់អដ្ឋកថា ឆាវាសូត្រទី៩

# អ ដ្ឋ ក ថា

## សញ្ញាសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង **សញ្ញាសូត្រទី ១០** ដូចតទៅនេះ ៖*

*[២៦៣] បទថា **អនិច្ចសញ្ញា** បានដល់ សញ្ញាដែលកើតឡើងដល់ភិក្ខុអ្នកភាវនាថា មិនទៀង មិនទៀង ។*

*បទថា **បរិយាទិយតិ** បានដល់ នឹងធ្វើឲ្យ (កាមរាគៈ) ទាំងអស់ អស់ទៅ ។*

*បទថា **សព្វំ អស្មិមានំ** បានដល់ អស្មិមានៈទាំង ៩ យ៉ាង ។*

*បទថា **មូលសន្តានកានិ** បានដល់ ឫសឈើដែលដុះបែកចេញទៅ ។*

*ក៏ក្នុងទីនេះ មានឧបមាប្រៀបធៀបដូចតទៅនេះ ៖*

***អនិច្ចសញ្ញា** ប្រៀបដូចនង្គ័លធំ ។*

*កិលេសទាំងឡាយ ប្រៀបដូចជាឫសឈើដែលដុះបែកចេញទៅ ទាំងតូច ទាំងធំ ។*

*ព្រះយោគីអ្នកចម្រើនអនិច្ចសញ្ញា ទម្លាយកិលេសបានដោយញាណដែលកើតអំពីអនិច្ចសញ្ញា ប្រៀបដូចអ្នកស្រែ ភ្ជួរស្រែទម្លាយឫសឈើទាំង*

នោះបាន ដោយនង្គ័ល ។

[២៦៤] បទថា **ឱធុនាតិ** ប្រែថា ប្រូតកាត់ (កម្ចាត់ខាងក្រោម) ។

បទថា **និធុនាតិ** ប្រែថា បោករលាស់ ។

បទថា **និច្ឆោដេតិ** ប្រែថា បោះចោល ។

សូម្បីក្នុងទីនេះ គប្បីឧបមាប្រៀបធៀបដោយអត្ថនេះថា អាល័យ គឺ កិលេស ប្រៀបដូចស្មៅយ៉ាប្លង់ ញាណដែលកើតអំពីអនិច្ចសញ្ញា ប្រៀបដូច ការរលាស់ចោល ។

[២៦៥] បទថា **វណ្ឌច្ឆិន្នាយ** សេចក្តីថា (ចង្កោមស្វាយ) ដាច់ទង ព្រោះកូនសរដ៏មុត ។

បទថា **តន្វយានិ ភវន្តិ** សេចក្តីថា (ផ្លែស្វាយដទៃៗ) រមែងដាច់ធ្លាក់ ទៅតាមចង្កោមស្វាយនោះ ។ កាលចង្កោមស្វាយនោះដាច់ ស្វាយ (ដទៃ) ក៏ ធ្លាក់ចុះលើផែនដីដែរ ។

សូម្បីក្នុងទីនេះ មានឧបមាប្រៀបធៀបដូច្នេះថា ៖

កិលេសទាំងឡាយ ប្រៀបដូចចង្កោមស្វាយ

អនិច្ចសញ្ញា ប្រៀបដូចកូនសរដ៏មុត

កាលអវិជ្ជា ដែលជាឫសគល់របស់កិលេសទាំងឡាយ ត្រូវកម្ចាត់ដោយ

ញាណដែលកើតអំពីអនិច្ចសញ្ញា កិលេសទាំងអស់ក៏ត្រូវដក (ត្រូវកាត់) ទៅផង ប្រៀបដូចកាលចង្កោមស្វាយត្រូវដាច់ទងព្រោះមុតដោយកូនសរ ស្វាយទាំងអស់ (ក្នុងទងជាមួយគ្នា) ក៏ដាច់ជ្រុះចុះលើផែនដីដែរ ។

បទថា **កូដង្គមា** ប្រែថា (បន្ទង់ទាំងឡាយ) ឈមទៅកំពូលផ្ទះ ។

បទថា **កូដនិន្នា** ប្រែថា បាញ់ទៅរកកំពូលផ្ទះ ដោយងាកទៅរកកំពូលផ្ទះ ។

បទថា **កូដសមោសរណា** ប្រែថា ប្រជុំចុះត្រង់កំពូលផ្ទះ ។

ក្នុងទីនេះ មានឧបមាប្រៀបធៀបដូច្នេះថា ៖

អនិច្ចសញ្ញា ប្រៀបដូចកំពូលផ្ទះ ។

កុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ប្រៀបដូចជាឈើបន្ទង់ផ្ទះ ។

អនិច្ចសញ្ញា ជាកំពូលរបស់កុសលធម៌ទាំងឡាយ ប្រៀបដូចជាកំពូលរបស់កូដាគារ ដែលប្រសើរជាងបន្ទង់ទាំងនោះ ។

សួរថា ក៏អនិច្ចសញ្ញា ជាកំពូលរបស់កុសលធម៌ ដែលជាលោកិយៈ (ប៉ុណ្ណោះ) មិនមែនឬ ? (និង) មកជាកំពូលរបស់លោកុត្តរធម៌ ដូចម្ដេច ?

ឆ្លើយថា អនិច្ចសញ្ញា គប្បីជ្រាបថា ជាកំពូល (របស់លោកុត្តរធម៌ទាំងឡាយ) ព្រោះអត្ថថា ជាហេតុឲ្យបានលោកុត្តរធម៌សូម្បីទាំងនោះ ។

គប្បីជ្រាបឧបមាប្រៀបធៀបក្នុងឧបមាទាំងអស់ ដោយឧបាយនេះ ក៏ក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ដល់កិច្ចរបស់អនិច្ចសញ្ញា ដោយឧបមា ៣ ប្រការដំបូង ត្រាស់កម្លាំងរបស់អនិច្ចសញ្ញា ដោយឧបមា ៣ ប្រការក្រោយ ដូច្នេះឯង ។

ចប់អដ្ឋកថា សញ្ញាសូត្រទី ១០

## ចប់បុប្ផវគ្គទី ៥
## ចប់មជ្ឈិមបណ្ណាសកៈ

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា


១-អដ្ឋកថា នទីសូត្រ
២-អដ្ឋកថា បុប្ផសូត្រ
៣-អដ្ឋកថា ផេណបិណ្ឌសូត្រ
៤-អដ្ឋកថា គោមយបិណ្ឌសូត្រ
៥-អដ្ឋកថា នខសិខាសូត្រ
៦-អដ្ឋកថា សាមុទ្ទកសូត្រ
៧-អដ្ឋកថា គទ្ទុលសូត្រទី ១
៨-អដ្ឋកថា គទ្ទុលសូត្រទី ២
៩-អដ្ឋកថា នាវាសូត្រ
១០-អដ្ឋកថា សញ្ញាសូត្រ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 US |

តាមរយៈភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ
នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក

| | |
|---|---|
| -សមាគមពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | $ 300 US |
| -ភិក្ខុវិជ្ជាសម្បន្នោ ឈួម សំបូរ និងឧបាសិកាគង់ គី | $ 200 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 105 US |
| -ឧបាសិកា ជីវ យួម និងស្វាមី ព្រមទាំងបុត្ត | $ 101 US |
| -ឧបាសក សោម រតនៈ និងភរិយា " ខេត្តព្រៃវែង " | $ 100 US |
| -សីលវត្តី នួន សូនី និងបុត្ត នាងវ៉ង់ | $ 100 US |
| -លោក គ្រី សុភី និងភរិយា ផៃ សុណាំង ព្រមទាំងបុត្ត | $ 100 US |
| -លោក តឹក គ្រី និងភរិយា ព្រមទាំងបុត្ត | $ 100 US |
| -ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | $ 100 US |
| -ឧបាសក លន ចំរើន ឧបាសិកា ម៉ុក ថានិ | $ 100 US |
| -ឧបាសក ម៉ៅ ប៊ួយ ឧបាសិកា ម៉ៅ លន់ | |
| -ម៉ៅ ម៉ារ៉ា និងសៀង ថៃបញ្ញារិទ្ធ ព្រមទាំងបុត្ត | $ 700 US |
| -ម៉ៅ ម៉ារ៉ែង ម៉ៅ គឹមអាន ម៉ៅ គឹមសៀង | |
| -ម៉ៅ ប៊ុនសន្ធា ក្នួយស្រី ធន់ សន្ធានី | |
| -ឧបាសិកា ពិន សាមឿន និងបុត្ត | $ 50 US |
| -ឧបាសិកា ពិន សាម៉ុន និងបុត្ត | $ 50 US |
| -ឧបាសិកា ប៊ុន សារ៉ុម និងបុត្ត | $ 50 US |
| -ឧបាសិកា គង់ ជី និងបុត្ត | $ 50 US |

| | |
|---|---|
| -ឧបាសិកា ឡាច ម៉ាឡៃ និងបុត្ត | $ 50 US |
| -ឧបាសិកា ទូត ច័ន្ទវណ្ណី និងបុត្ត | $ 50 US |
| -ឧបាសិកា ម៉ែន សាវ៉ាត | $ 50 US |
| -ឧបាសិកា ពិន សាត | $ 50 US |
| -ឧបាសិកា អ៊ុំ សាត | $ 50 US |
| -លោក ណៃ សារិន និងឧបាសិកា ជា សូភី | $ 50 US |
| -លោក កែវ ណាត និងឧបាសិកា សឹម កឿន | $ 50 US |
| -ឧបាសក កុក ឆាយ និងកូនប្រុស ឧបាសក តាំង សុផល និងភរិយា ព្រមទាំងបុត្ត នៅខេត្តបាត់ដំបង | $ 50 US |
| -ឧបាសិកា សៀន សេង និងបុត្ត | $ 20 US |
| -ឧបាសក ឡាង ឆរី និងភរិយា ព្រមទាំងបុត្ត | $ 20 US |
| -ឧបាសក ម៉ឺន ប៊ុនហេង និងឧបាសិកា កូវ៉ាញ | $ 20 US |
| -ឧបាសក ប៉ោ ហេង និងឧបាសិកា លន់ ឈុនលី | $ 20 US |
| -ឧបាសិកា ពិន សាម៉ុន | $ 20 US |
| -ឧបាសក កែវ សារិន ឧបាសិកា សំងម | $ 15 US |
| -ឧបាសិកា ប៊ុន សារុំ | $ 10 US |
| -ឧបាសិកា ហាក់ សៃហេង | $ 10 US |
| -ឧបាសិកា ទេព សុផល | $ 10 US |
| -ឧបាសិកា ទេព ណាម | $ 10 US |
| -ឧបាសក គឹម កក់ និងភរិយា ពិសី | $ 10 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 10 US |
| -ឧបាសិកា តាំង ផល្លា ព្រមទាំងស្វាមី និងបុត្ត | $ 10 US |
| -ឧបាសក តាំង សុខឡាយ ភរិយា និងបុត្ត | $ 10 US |
| -អ្នកស្រី បុប្ផអ៊ីវ និងស្វាមី ព្រមទាំងបុត្ត | $ 10 US |
| -ឧបាសក យិន ឈួ និងភរិយា ព្រមទាំងបុត្ត | $ 6 US |
| -ឧបាសក តាំង សុខឡាយ ឧបាសិកា សន ស៊ីណែត និងបុត្ត នៅខេត្តបាត់ដំបង | $ 5 US |

# តាមរយៈភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ប្រទេសអូស្ត្រាលី

| | |
|---|---|
| -ភិក្ខុ ចៅ សៀប " អូស្ត្រាលី " | 100 AUS |
| -ពុទ្ធបរិស័ទច្រើននាក់ " ម៉ែលប៊ន " | 955 AUS |
| -បុណ្យនៅផ្ទះឧបាសិកា លឹម ស៊ូឆេង | 627 AUS |
| -បុណ្យនៅផ្ទះឧបាសិកា ស៊ុយ មន្ថា ព្រមទាំងកូនចៅ | 450 AUS |
| -បុណ្យនៅផ្ទះឧបាសិកា អ៊ូច សុផល្លី ព្រមទាំងបុត្ត | 400 AUS |
| -ឧបាសក ឡៅ គីមងួន ឧបាសិកា ដួង លី | 200 AUS |
| -បុណ្យនៅផ្ទះឧបាសិកា តែ យក់ហ៊ុន | 200 AUS |
| -ឧបសិកា គង់ សារឿម | 200 AUS |
| -លោកជំទាវ " ឯកអគ្គរដ្ឋទូតអាឡឺម៉ង់ " | 100 US |
| -ឧបាសិកា កូវ សារី | 100 AUS |
| -ឧបាសិកា ឈ គិមស៊ិន និងបុត្ត សំ ថានី | 100 AUS |
| -លោក ឥន ចាវ៉ាន់ ឧបាសិកា យ៉ុម យ៉ា | 100 AUS |
| -ឧបាសក ឌី មុយ ឧបាសិកា តែ ចាន់ណាវ៉ា | 100 AUS |
| -ឧបាសិកា ឯម ផាយ៉,ឆេង លន់,ម៉ា ឈួអៀ,អាបួយ | 70 AUS |
| -ឧបាសក ឈិត ទ្រី ឧបាសិកា បាន់ ណៃហ៊ាង | 50 AUS |
| -ឧបាសិកា សុឃឿន ប៊ូ | 50 AUS |
| -ឧបាសក ឡុង ហ៊ន ឧបាសិកា លិម យូអេង និងបុត្ត | 50 AUS |
| -ឧបាសិកា ហេង ប៉ោគី ព្រមទាំងកូនចៅ | 50 AUS |
| -ឧបាសិកា ស៊ុម គិមហេង | 50 AUS |
| -ឧបាសិកា ឃឹម វីឡាត់ | 50 AUS |
| -ឧបាសក តូ សវឿន ឧបាសិកា មាន សុវត្ថិ និងបុត្ត | 50 AUS |
| -ឧបាសក មង្គល ផន ឧបាសិកា គីម លាភ ( មាណ) | 50 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 50 AUS |
| -ឧបាសិកា ផ្លោក វណ្ណា | 40 AUS |
| -ឧបាសិកា សំ សុមុន្ថា ស្វាមី និងបុត្ត | 30 AUS |
| -ឧបាសិកា រ័ត្ន គីមសាន | 30 AUS |
| -ឧបាសិកា ខូវ ម៉េងលួង ព្រមទាំងស្វាមី និងបុត្ត | 30 AUS |
| -ឧបាសក ហៀក ប៉េងហួរ ឧបាសិកា ផ្លោក ម៉ុង | 30 AUS |
| -ឧបាសិកា ទូច សីណា និងស្វាមី | 20 AUS |

| | |
|---|---|
| -ឧបាសក ស៊ូ ឃីម ឧបាសិកា ស៊ូ សៀងតិច | 20 AUS |
| -ឧបាសក ប៉េង ត្រឹគួ ឧបាសិកា គីម សៀងគួ | 20 AUS |
| -ឧបាសិកា គង់ សម្បត្តិ | 20 AUS |
| -ឧបាសិកា ចំរើន វ៉ាក់ជិត | 20 AUS |
| -ឧបាសិកា តែ យក់ហ៊ុន | 20 AUS |
| -ឧបាសិកា យ៉ា យ៉ុម | 20 AUS |
| -ឧបាសិកា លឹម ស៊ូឆេង | 20 AUS |
| -ឧបាសក សន់ ប៊ុនភាវ ឧបាសិកា កាំង គីមហាន | 20 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 20 AUS |
| -ឧបាសិកា យានី | 20 AUS |
| -សេង សៀងឈុន | 20 AUS |
| -ឧបាសក វ៉ាន់ យ៉ាណូរ៉េត ឧបាសិកា វ៉ាន់យ៉ាណូរី | 20 AUS |
| -ឧបាសិកា អ៊ុច សុផល្លី | 20 AUS |
| -ឧបាសិកា ឡាច សារឹម | 15 AUS |
| -ចៃស៊ីម,ចៃខេង,អាមួយ | 15 AUS |
| -ឧបាសិកា កូវ សារី | 15 AUS |
| -ឧបាសិកា ទូច ស៊ីណា | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លីសាង | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លាង ហុងប៊ុន | 10 AUS |
| -ឧបាសិកា សៀ ចន្ថា និងគ្រួសារ | 10 AUS |
| -ឧបាសិកា កាំង អ៊ីវហ៊្គិច | 10 AUS |
| -ឧបាសក ក្រូច សាន | 10 AUS |
| -ឧបាសិកា ស៊ា ចាន់ថា | 10 AUS |
| -ឧបាសក យឹម វ៉ាន់ ឧបាសិកា អ៊ុំ ខេង | 10 AUS |
| -ឧបាសក សុខ ជួន ឧបាសិកា សុខ ធួក | 10 AUS |
| -ឧបាសិកា អេង ធីមសុខ | 10 AUS |
| -ឧបាសក ឃុត សរ ឧបាសិកា សុខ សច្ចា | 10 AUS |
| -ឧបាសិកា កេសរកូល និងគ្រួសារ | 5 AUS |
| -ឧបាសិកា វណ្ណនីសា | 5 AUS |
| -ឧបាសិកា សាន់ ឆាយ, គីម ស្រួន | 5 AUS |

| | |
|---|---|
| -ភិក្ខុ ឆុំ សាវឿន និងពុទ្ធបរិស័ទ វត្តពន្លឺពុទ្ធចក្ក | 620 USA |
| -ឧបាសក សោមរតនៈ ឧបាសិកា ស៊ុប វណ្ណា និងបុត្ត | 200 USA និង 1 លានរៀល |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេន និងបុត្ត | 30 USA |
| -ហាង ពិភពកុំព្យូទ័រ | 20 USA |
| -ឧបាសិកា តាំង ផល្លា និងស្វាមី ព្រមទាំងបុត្ត | 10 USA |
| -ឧបាសក ហេង វីរិន្ទ និងភរិយា ព្រមទាំងបុត្ត | 10 USA និង 2 ម៉ឺនរៀល |
| -ឧបាសក តាំង សុខឡាយ និងភរិយា ព្រមទាំងបុត្ត | 10 USA |
| -ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ និងកូនចៅ | 5 USA និង 1 ម៉ឺនរៀល |
| -ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ធីតា និងកូនចៅ | 5 USA និង 1 ម៉ឺនរៀល |
| -ឧបាសិកា កំសត់ នៅស្រុកសំឡូត | 30000 រៀល |
| -ឧបាសក ម៉េង ប៊ិច ព្រមទាំងកូនចៅ | 20000 រៀល |
| -ឧបាសិកា ហួន ណងសឹម | 20000 រៀល |
| -ឧបាសិកា គាត ស៊ីណា | 20000 រៀល |
| -ឧបាសិកា ទេព គឹមហ៊ា | 20000 រៀល |
| -ឧបាសិកា ហេង គួ | 20000 រៀល |
| -ឧបាសិកា គី ពេញ | 20000 រៀល |
| -ម៉ាឧបាសិកា ឆាយ អ៊ីសែង | 20000 រៀល |
| -ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្ត | 20000 រៀល |
| -ឧបាសក ហុង ជ្រិន ឧបាសិកា ឡេង ចំរើន និងកូនចៅ | 20000 រៀល |
| -ឧបាសិកា កែ ថន | 10000 រៀល |
| -ឧបាសិកា អ៊ុយ លឹង | 10000 រៀល |
| -យុវជន ស៊ូ តារា | 10000 រៀល |